# ប្រវត្តិសាស្ត្រសង្ខេបនៃរាជធានីក្នុងតំបន់អង្គរ និង សង្គមខ្មែរក្នុងរជ្ជកាលស្តេចជ័យវរ្ម័នទី៧



បកប្រែចេញពីសៀវភៅរបស់

កញ្ញា ស៊ិស តូ (Mlle CITEAU)

និងរៀបចំចងក្រង សម្រួលជាភាសាខ្មែរ

ដោយលោក អួង ចន

ប្រធាននាយកដ្ឋានបេតិកភណ្ឌ

ក្រោមការដឹកនាំរបស់ ឯកឧត្តម ឃឹម សារិទ្ធ

អនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ឆ្នាំ ២០០៦

៥១២.៣៨៩

# LOCALISATION DE DIFFERENTS SITES DE LA LISTE INDICATIVE DU PATRIMOINE CULTUREL AU CAMBODGE 12/06/2000



LEGENDE

- ■ Patrimoine Culturel dans La liste indicative
- ◉ Province
- ○ Capitale
- Groupe de ...

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE
១៣៣០/០៦


PREAH KHAN
NEAK PEAN
TA KEO
BAYON
ANGKOR THOM
BAPHUON
Preah Palilay
Preah Pithu
Khleang N
Khleang S
Ta Prohm Kel
Phnom Bakheng
Kapilapura
Banteay Kdei
Sras Srang
Pr. Kravan
ANGKOR VAT
Siemreap
Preah Enkosei
Conservation d'Angkor
SIEMREAP
Stung
R.N. 6
Trapeang Tham
Vat Chedei
Vat Athvea
Pr. Kok Ô Chrung
Pr. Daun So
Lolei
PREAH KÔ
BAKONG
ROLUOS
Pr. Preah Ko
Pr. Ô Kaek
BANTÉAY SAMRÉ
Pr. Pradak
Oriental
Tg. Pr. Bar...
Bardy Occ
Baignade
Tg. Por
Pr. Kas Hâ
Pr. Ta Kory
Pr. Trapeang Ropou
Pr. Prei
Pr. Patri
Pr. Pnek
Pr. Reach Kandal
Phnom Krom
Grand Lac
Tg. Leang Kam
Tg. Kreng Kor
LEGENDE
Route principale.
Route secondaire.
Chaussée digue khmère.
BAYON
Ta Som
Bat Chum
Ensemble monumental de 1re importance.
Monument d'importance secondaire.
Site archéologique.
Pr. = Prasat
Echelle 1/20.000

រក្សាសិទ្ធិគ្រប់យ៉ាង

# មាតិកា


សេចក្តីថ្លែងអំណរគុណ

សេចក្តីផ្តើម

ទំព័រ

## ជំពូក១

### ការស្ថាបនារាជធានីអង្គរ

១. ព្រឹត្តការណ៍របស់ព្រះបាទយសោវរ្ម័នទី១ ១

២. ការស្ថាបនារាជធានី ២

៣. រាជធានីរបស់យសោវរ្ម័ន ៤

៤. ភ្នំបាខែង ៥

៥. ការចាប់ផ្តើមកសាងរាជធានី ៧

៦. អំពីវត្ត

៧. តម្លៃនៃស្នាដៃរបស់ព្រះបាទយសោវរ្ម័នទី១ ៨

## ជំពូក២

### រាជធានីអង្គរនៅសតវត្សទី១០

១. ធានីអង្គរនៅក្រោមការគ្រប់គ្រងរបស់អ្នកបន្តវេនទី១ បន្ទាប់ពីព្រះបាទយសោវរ្ម័ន ៩

២. សំណង់របស់ស្តេចទាំងឡាយនៅធានីអង្គរក្រោយរាជស្តេចរាជេន្ទ្រវរ្ម័នទី២ ១២

៣. សំណង់ដែលសាងសង់ដោយមន្ត្រីទាំងឡាយនៅក្រោមរាជព្រះបាទរាជេន្ទ្រវរ្ម័ន ១៤

៤. ចុងបញ្ចប់នៃរាជព្រះបាទរាជេន្ទ្រវរ្ម័នទី២ ១៥

៥. ព្រឹត្តិការណ៍របស់ព្រះបាទជ័យវរ្ម័នទី៥

៦. ព្រាហ្មណ៍ យជ្ញវរាហៈ អ្នកសាងប្រាសាទបន្ទាយស្រី ១៦

៧. រាជធានីអង្គរនៅចុងសតវត្សទី១០ ១៧

## ជំពូក៣

### ធានីអង្គរនៅក្រោមការគ្រប់គ្រងរបស់សន្តតិវង្សសុរ្យវរ្ម័នទី១


១. រជ្ជកាលព្រះបាទឧទ័យាទិត្យវរ្ម័នទី១ ១៩
២. ជ័យវីរៈវរ្ម័ន និងការបះបោរដេណ្ដើមរាជ
៣. ការស្ថាបនារបស់ព្រះបាទជ័យវីរៈវរ្ម័ន ២០
៤. ព្រះបាទសូរ្យវរ្ម័នទី១ ២១
៥. ការងារដែលធ្វើឱ្យសម្រេចនៅធានីអង្គរ ក្រោមរាជ្យព្រះបាទសូរ្យវរ្ម័នទី១ ២២
៦. ការធ្វើឱមានសន្តិភាព (សន្តិភាវកម្ម)
៧. ចុងបញ្ចប់នៃរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១ ២៣
៨. របបរាជាធិបតេយ្យខ្មែរនៅក្រោមការគ្រប់គ្រងរបស់បុត្រាព្រះបាទសូរ្យវរ្ម័នទី១
៩. សំណង់ទាំងឡាយរបស់បុត្រាព្រះបាទសូរ្យវរ្ម័នទី១ នៅរាជធានីអង្គរ ២៤
១០. បារាយណ៍ខាងលិច
១១. ចុងបញ្ចប់នៃសន្តតិវង្សសូរ្យវរ្ម័នទី១ ២៥
១២. ទិដ្ឋភាពនៃរាជធានីអង្គរនៅចុងសតវត្សទី១២
១៣. អំពីរបបសង្គម ២៦
១៤. ព្រះមហាក្សត្រ ២៧
១៥. រដ្ឋបាល ២៨
១៦. ព្រះរាជនិវេសន៍ ២៩


## ជំពូក៤

### ព្រះបាទសូរ្យវរ្ម័នទី២ និងការកសាងប្រាសាទអង្គរវត្ត


១. ព្រឹត្តិការណ៍របស់ព្រះបាទសូរ្យវរ្ម័នទី២ ៣០
២. ព្រះបាទសូរ្យវរ្ម័នទី២
៣. ប្រាសាទអង្គរវត្ត ៣១
៤. បដិមាសាស្ត្រនៃប្រាសាទអង្គរវត្ត ៣២
៥. ប្រាសាទអង្គរវត្ត និងអត្ថន័យរបស់ប្រាសាទភ្នំ ៣៣
៦. ប្រាសាទទាំងឡាយស្ថិតនៅក្នុងរចនាបថអង្គរវត្ត ៣៥
៧. សង្គមខ្មែរនៅសតវត្សទី១២ តាមការពិនិត្យលើក្បាច់ក្រឡោតទាបនៅអង្គរវត្ត
៨. សារៈសំខាន់នៃសាសនានៅប្រាសាទអង្គរវត្ត ៣៧

## ជំពូក៥

### កោណាហល់ទាំងឡាយនៅសតវត្សទី១២ និងព្រឹត្តិការណ៍របស់ព្រះបាទជ័យវរ្ម័នទី៧


| | |
|---|---|
| ១. អ្នកស្នងរាជ្យបន្ទាប់ពីព្រះបាទសូរ្យវរ្ម័នទី២ | ៣៩ |
| ២. តើនរណាជាព្រះបាទធរណីន្ទ្រវរ្ម័នទី២? | |
| ៣. ព្រះបាទយសោវរ្ម័នទី២ | ៤០ |
| ៤. ការដណ្តើមរាជ្យរបស់ព្រះបាទត្រីភូវនាទិត្យវរ្ម័ន | ៤១ |
| ៥. ការចូលកាន់កាប់ធានីអង្គរដោយពួកចាម ឆ្នាំ១១៧៧ | |
| ៦. ផលវិបាក និងជ័យជំនះរបស់ពួកចាម | ៤២ |
| ៧. សេរីភាពនៅក្នុងប្រទេសកម្ពុជាដោយព្រះបាទជ័យវរ្ម័នទី៧ | ៤៣ |


## ជំពូក៦

### ព្រះបាទជ័យវរ្ម័នទី៧ និងការកសាងធានីអង្គរធំ


| | |
|---|---|
| ១. ព្រះបាទជ័យវរ្ម័នទី៧ | ៤៥ |
| ២. គំនិតសាសនាទាំងឡាយរបស់ព្រះបាទជ័យវរ្ម័នទី៧ | ៤៦ |
| ៣. សំណង់ធំៗទាំងឡាយ | ៤៧ |
| ៤. ប្រាសាទតាព្រហ្ម | ៤៨ |
| ៥. ប្រាសាទព្រះខ័ន | |
| ៦. ប្រាសាទនាគព័ន្ធ | ៤៩ |
| ៧. ការចាប់ផ្តើមនៃធានីអង្គរធំ វិហារតូចៗរបស់មន្ទីរពេទ្យ និងផ្ទះសំណាក់ | ៥១ |
| ៨. កំពែងធានីអង្គរធំ | |
| ៩. ប្រាសាទបាយ័ន | ៥២ |
| ១០. ព្រះបរមរាជវាំង និងមុខងារសំខាន់ៗនៃធានីអង្គរធំ | ៥៣ |
| ១១. ចុងបញ្ចប់នៃរាជ្យព្រះបាទជ័យវរ្ម័នទី៧ | ៥៤ |


## ជំពូក ៧

### រាជធានីអង្គរ និងសង្គមមនុស្សសម័យអង្គរនាសតវត្សទី១៣


| | |
|---|---|
| ១. អ្នកស្នងរាជ្យទាំងឡាយបន្តពីព្រះបាទជ័យវរ្ម័នទី៧ | ៥៥ |

២. ការធ្វើដំណើររបស់ជីវតាក្វាន់ ឆ្នាំ១២៩៦ ៥៦
៣. ទិដ្ឋភាពប្រាសាទនៃរាជធានី ៥៧
៤. ព្រះរាជវាំង ៥៨
៥. សង្គម ៥៩
៦. សកម្មភាពរបស់ប្រជាជន ៦០
៧. ជីវភាពផ្ទាល់ខ្លួន ៦១
៨. អំពីពិធីបុណ្យទាំងឡាយ ៦២

## ជំពូក ៨

### អង្គររាជធានីដែលត្រូវគេបោះបង់ចោល

១. ស្តេចចុងក្រោយទាំងឡាយដែលសោយរាជ្យនៅធានីអង្គរ ៦៣
២. ការរស់ឡើងវិញនៃសតវត្សទី១៦ ៦៦
៣. ធានីអង្គរនៅសតវត្សទី១៧ និងទី១៨ ៦៨
*សន្និដ្ឋាន* ៧០
៧៦

### ព្រះជីវប្រវត្តិសង្ខេប

ស្នាព្រះហស្តព្រះបាទជ័យវរ្ម័នទី៧ ៧៧
សមិទ្ធិផលជាស្នាព្រះហស្ត ៧៨
នយោបាយទឹក ៧៩
សន្និដ្ឋាន ៨០

## ជំពូក ៩

### ឯកសារបន្ថែម

ស្ដីអំពី រមណីយដ្ឋានប្រាសាទ វត្តអារាម ពុទ្ធបដិមា និង រឿងព្រេងនិទាន

# ផ្នែករូបថត


រូបថតទី១ : ប្រាសាទភ្នំដា មើលពីចម្ងាយ ស្រុកអង្គរបុរី ខេត្តតាកែវ

រូបថតទី២ : រូងភ្នំមួយក្នុងចំណោមរូងភ្នំនៅចង្កេះភ្នំដា ដែលនៅពីខាងមុខរូងមានទម្រយោនិ

រូបថតទី៣ : ប្រាសាទព្រះគោ ខេត្តសៀមរាប

រូបថតទី៤ : រូបទ្វារបាល នៅប្រាសាព្រះគោ

រូបថតទី៥ : ប្រាសាទបាគង ខេត្តសៀមរាប

រូបថតទី៦ : ទិដ្ឋភាពមើលពីលើប្រាសាទបាគង ពីលិចទៅកើត

រូបថតទី៧ : រូបចម្លាក់យក្សនៅប្រាសាទបាគង

រូបថតទី៨ : ចម្លាក់តាមជញ្ជាំងខឿននៃប្រាសាទបាគង ត្រូវសឹករិចរឹលដោយសារអាកាសធាតុ។

រូបថតទី៩ : ប្រាសាទក្រវ៉ាន់ ខេត្តសៀមរាប

រូបថតទី១០ : ចម្លាក់ព្រះវិស្ណុដៃ៨ ជិះលើសត្វគ្រុឌ

រូបថតទី១១ : ទេវរូបភេទស្រី និងនាងលក្ស្មី

រូបថតទី១២ : ប្រាសាទបក្សីចាំក្រុង ខេត្តសៀមរាប

រូបថតទី១៣ : ប្រាសាទបន្ទាយស្រី ខេត្តសៀមរាប

រូបថតទី១៤ : តួប៉មប្រាសាទបន្ទាយស្រី

រូបថតទី១៥ : ប្រាសាទអង្គរវត្ត ខេត្តសៀមរាប

រូបថទី១៦ : ទិដ្ឋភាពប្រាសាទអង្គរវត្ត មើលផ្ទាត់ជ្រុងពីត្បូងទៅជើង

រូបថតទី១៧ : ចម្លាក់រឿងរាមកេរ្តិ៍ នៅលើជញ្ជាំងប្រាសាទអង្គរវត្ត

រូបថតទី១៨ : ចម្លាក់ក្សត្រិយ៍អង្គុយលើទេន និងស្រីស្នំអង្គុយបាំងក្លស់ និងបក់ផ្លិត

រូបថតទី១៩ : ប្រាសាទបន្ទាយសំរ៉ែ ខេត្តសៀមរាប

រូបថតទី២០ : តួប៉មកណ្ដាលនៃប្រាសាទបន្ទាយសំរ៉ែ

រូបថតទី២១ : ប្រាសាទធម្មានន្ទ ខេត្តសៀមរាប

រូបថតទី២២ : ប្រាសាទចៅសាយទេវតា ខេត្តសៀមរាប

រូបថតទី២៣ : ប្រាសាទប៉ាលីល័យ ខេត្តសៀមរាប

រូបថតទី២៤ : ព្រះពុទ្ធបដិមា នៅព្រះវិហារវត្តទេពប្រណម ខេត្តសៀមរាប

រូបថតទី២៥ : ប្រាសាទបាយ័ន ខេត្តសៀមរាប

រូបថតទី២៦ : ទិដ្ឋភាពប្រាសាទបាយ័ន មើលផ្ទាត់ជ្រុង

រូបថតទី២៧ : បារក្សបុរោហិតចូលគាល់ស្តេច នៅជញ្ជាំងថែវខាងក្រៅនៃប្រាសាទបាយ័ន
រូបថតទី២៨ : ល្បែងសៀកខាងល្អនិង ប្រាសាទបាយ័ន
រូបថតទី២៩ : គោបុរៈខាងត្បូង កំពែងខាងក្រៅនៃប្រាសាទព្រះខ័ន ខេត្តសៀមរាប
រូបថតទី៣០ : ផ្តែរទ្វារនៃរោងរាំ ផ្នែកខាងកើត ប្រាសាទព្រះខ័ន
រូបថតទី៣១ : ព្រះលានជល់ដំរី មើលផ្ទាក់ជ្រុង ផ្នែកខាងត្បូងបង្អស់ ខេត្តសៀមរាប
រូបថតទី៣២ : ប្រាសាទសួរព្រ័ត្រ ខេត្តសៀមរាប
រូបថតទី៣៣ : ព្រះលានជល់ដំរី មើលពីខាងមុខ ខេត្តសៀមរាប
រូបថតទី៣៤ : ចម្លាក់រូបលោកេស្វរៈ ក្បែរលានស្តេចគំលង់ ខេត្តសៀមរាប
រូបថតទី៣៥ : ប្រាសាទតាព្រហ្ម គោបុរៈខាងលិច ខេត្តសៀមរាប
រូបថតទី៣៦ : ប្រាសាទភ្នំក្រោម ខេត្តសៀមរាប
រូបថតទី៣៧ : ទិដ្ឋភាពមើលពីលើភ្នំក្រោម ខេត្តសៀមរាប
រូបថតទី៣៨ : ប្រាសាទបាពួន ខេត្តសៀមរាប
រូបថតទី៣៩ : ចម្លាក់នៅតាមជញ្ជាំងប្រាសាទបាពួន ខេត្តសៀមរាប
រូបថតទី៤០ : ប្រាសាទតាកែវ ខេត្តសៀមរាប
រូបថតទី៤១ : ទ្វូលអាកាមរោងចិន នៃប្រាសាទនៅតំបន់ភ្នំគូលែន ខេត្តសៀមរាប
រូបថតទី៤២ :ប្រាសាទរោងចិន ភ្នំគូលែន ខេត្តសៀមរាប
រូបថតទី៤៣, ៤៤, ៤៥ : ប្រាសាទតាសោម ខេត្តសៀមរាប
រូបថតទី៤៦ : តួប៉មកណ្តាលនៃប្រាសាទតាសោម ខេត្តសៀមរាប
រូបថតទី៤៧ : ទិដ្ឋភាពមើលពីលិចទៅកើត នៃប្រាសាទតាសោម ខេត្តសៀមរាប
រូបថតទី៤៨ : រូបមើលពីមុខ នៃព្រះអង្គខ្មៅ
រូបថតទី៤៩ : រូបមើលពីចំហៀងនៃព្រះអង្គតង់ជុំ
រូបថតទី៥០ : ព្រះសេអាមេត្រី មើលពីមុខ
រូបថតទី៥១ : ព្រះសេអាមេត្រី មើលពីចំហៀង
រូបថតទី៥២ : ក្លោងទ្វារវត្តព្រះព្រហ្មរតន៍
រូបថតទី៥៣ : រូបព្រះចូលនិព្វាន
រូបថតទី៥៤ : រូបព្រះចូលនិព្វាន
រូបថតទី៥៥ : រូបព្រះវិស្ណុឈរដៃ៨
រូបថតទី៥៦ : ប្រាសាទអង្គរវត្ត មើលផ្ទាក់ជ្រុង
រូបថតទី៥៧ : ព្រះអង្គគោកធ្លក

រូបថតទី៥៨ : ព្រះអង្គគោកធ្លក

រូបថតទី៥៩ : ព្រះអង្គចេក និងព្រះអង្គចម

រូបថតទី៦០ : រូបព្រះអង្គជុំ

រូបថតទី៦១ : ព្រះវិហារក្រោយអង្គគោកធ្លក

រូបថតទី៦២ : ព្រះវិហារក្រោយអង្គគោកធ្លក

រូបថតទី៦៣ : ព្រះអង្គប្រក់នាគ

រូបថតទី៦៤ : ព្រះអង្គប្រក់នាគ

រូបថតទី៦៥ : រូបព្រះប្រក់នាគ

រូបថតទី៦៦. ៦៧: រូបទ្វារបាលនៅប្រាសាទព្រះខ័ន សៀមរាប

រូបថតទី៦៨ : រូបលោកេស្វរៈ មើលពីចំហៀង

រូបថតទី៦៩ : រូបលោកេស្វរៈ

រូបថតទី៧០ : ព្រះឥន្ទទេព

រូបថតទី៧១ : ព្រះឥន្ទទេព

រូបថតទី៧២ : ព្រះវិហារអង្គងោក

រូបថតទី៧៣ : ព្រះវិហារអង្គងោក

រូបថតទី៧៤ : ព្រះពុទ្ធបដិមាទ្រង់ឈរ

រូបថតទី៧៥ : ព្រះវិហារទេពប្រណម្យ

រូបថតទី៧៦ : ព្រះវិហារព្រះបាលិល័យ

រូបថតទី៧៧ : ព្រះវិហារព្រះបាលិល័យ

រូបថតទី៧៨ : តួអង្គព្រះធំ

រូបថតទី៧៩ : តួអង្គព្រះធំ

រូបថតទី៨០. ៨១. ៨២ : រូបពុទ្ធបដិមា

រូបថតទី៨៣ : ព្រះវិហារសាងទុក

រូបថតទី៨៤ : ព្រះអង្គសាងទុក

# អារម្ភកថា

* * *

កន្លងមកមានអ្នកនិពន្ធជាច្រើន ជាជនជាតិខ្មែរ និងបរទេសបានធ្វើការសិក្សាស្រាវជ្រាវ និងសរសេរពីប្រវត្តិប្រទេសកម្ពុជា ហើយបានចងក្រងបោះពុម្ពជាសៀវភៅ គឺច្រើនសរសេរតែជាភាសាបរទេសសម្រាប់បរទេសស្វែងយល់អំពីការវិវត្តន៍ពីសម័យកាលមួយទៅសម័យកាលមួយទៀតឥតឈប់ឈរ។

អំឡុងទសវត្សទី៧០ គឺមានអ្នកប្រាជ្ញខ្មែរ បានសិក្សាស្រាវជ្រាវដែរ តែច្រើនជាភាសាបរទេស ឯភាសាខ្មែរវិញ គឺមានភាគតិច មូលហេតុមកពីចារឹកខ្មែរគឺសំអាងតែចងចាំរៀងៗខ្លួនតែប៉ុណ្ណោះ មិនចង់សរសេរទេ។ ម្យ៉ាងទៀត បើសរសេរជាភាសាបរទេស គឺលក់បានថ្លៃខ្ពស់ បើសរសេរជាភាសាខ្មែរ ការបោះពុម្ពលក់បានតម្លៃថោក អ្នកខ្លះសរសេរហាក់បីដូចជាលក់ចំណេះឱ្យគេ តាមទារឹកខ្មែរ បើមានអ្នកសរសេរ គឺតែងតែរិះគន់គេវិញ។ វិទ្យាស្ថានបារាំងនៅចុងបូព៌ាប្រទេស (EFEO) បានបញ្ជូនអ្នកប្រាជ្ញបុរាណវិទ្យាចំណាន់ៗមកសិក្សាស្រាវជ្រាវពីសិល្បៈ វប្បធម៌ខ្មែរ និងទំនៀមទម្លាប់ប្រពៃណីរបស់ខ្មែរ និងស្រាវជ្រាវអំពីប្រវត្តិប្រាសាទ សិលាចារឹក ស្ថាបត្យសិល្បៈធ្វើពីសិរិទ្ធ ធ្វើកំណាយ និងធ្វើអង្កេតពិនិត្យពីលើយន្តហោះ។ សិក្សាអំពីការរីកចំរើន និងការវិវត្តន៍របស់សិល្បៈខ្មែរជំនាន់មុន។ល។ ហើយបានចងក្រងឯកសារជាស្នាដៃដ៏ធំធេងនេះជាភាសាបារាំងទុកសម្រាប់ការស្វែងយល់របស់កូនខ្មែរជំនាន់ក្រោយៗមកទៀត។

ជាធម្មតាទេ ការចងក្រង គឺគេមិនដែលបង្ហាញឱ្យអស់ទេ គេបង្កប់នូវការងឿងឆ្ងល់ខ្លះៗ ដើម្បីឱ្យកូនខ្មែរស្វែងរកគ្រឿងដើម បើកុំតែបានបារាំងចងក្រងទុកឱ្យខ្លះៗនោះ ម៉្លោះក្មេងៗជំនាន់ក្រោយត្រូវជួបការលំបាក និងធ្វើការសិក្សាស្រាវជ្រាវបន្តទៀត។ ឯកសារជាភាសាបារាំង ឬអង់គ្លេស ជាសៀវភៅទាំងឯកសារគ្រាន់យកមកប្រែកែសម្រួលខ្លះៗ តាមការយល់ដឹងរបស់យើង ទើបឱ្យយើងមានការពិចារណា ដូចជា សៀវភៅរបស់ ម៉ាដឺម៉្វាស្សែល ហ្ស៊ីតូ (Mlle Citeau) ដែលបានសរសេរនេះ ខ្ញុំបានបកប្រែពីច្បាប់ដើមខ្លះៗ សម្រាប់ការយល់ដឹងពីប្រវត្តិសាស្ត្រសង្ខេបនៃធានីក្នុងតំបន់អង្គរ។ គោលបំណងនៃការបកប្រែសៀវភៅនេះ គឺបង្កលក្ខណៈងាយស្រួលដល់កូនខ្មែរឱ្យកាន់តែមានការយល់ដឹងកាន់តែប្រសើរឡើង។

ដោយសិល្បៈចម្លាក់បុរាណខ្មែរ ជារតនៈសម្បត្តិដ៏មានតម្លៃ មានន័យទូលំទូលាយ ហើយមានច្រើនប្រភេទបែបនេះ យើងពុំបានលើកយកមកអធិប្បាយបានសព្វគ្រប់ទាំងអស់ទេ យើងលើកយកតែលក្ខណៈសំខាន់ៗនៃសិល្បៈចម្លាក់បុរាណខ្លះៗមកបង្ហាញតាមរជ្ជកាលនៃស្តេចនិមួយៗ។

ស្វែងយល់ឱ្យកាន់តែច្បាស់ សូមអញ្ជើញអានសៀវភៅដែលរក្សាទុកនៅសារៈមន្ទីរជាតិ ឬនៅបណ្ណាល័យជាតិភ្នំពេញ។

គួរតែខ្មែរយើងយល់ថា ប្រទេសកម្ពុជាយើង ជាប្រទេសមួយដែលសំបូរទៅដោយបេតិកភណ្ឌជាតិ។ កាន់តែចាស់រឹតតែមានតម្លៃកាន់តែខ្ពស់មិនអាចកាត់ថ្លៃបាន។

យើងទាំងអស់គ្នា ជាពលរដ្ឋត្រូវតែមានភារកិច្ច និងកាតព្វកិច្ចសិក្សាស្រាវជ្រាវស្វែងយល់ឱ្យកាន់តែស៊ីជំរៅ ព្រោះយើងជាម្ចាស់រតនៈសម្បត្តិទាំងនេះ ដើម្បីឱ្យដឹងពីរាជ្យស្តេចនិមួយៗ ត្រូវយល់ថា: មានបេតិកភណ្ឌ ទើបប្រទេសមានភាពថ្កុំថ្កើងរុងរឿង។

ប្រធាននាយកដ្ឋានបេតិកភណ្ឌ

អួង វន

# សេចក្ដីផ្ដើម

នៅលើពិភពលោកយើងនេះ មនុស្សជាតិទូទៅមិនថារស់នៅក្នុងប្រទេសតូច ឬធំនោះទេ តែងតែត្រូវការនូវសិទ្ធិសេរីភាព និងអធិបតេយ្យភាព ដែលប្រកបដោយសុភមង្គល និងសុខសន្តិភាពយ៉ាងពេញលេញ ។ វត្ថុបំណងដ៏ពិសិដ្ឋនេះ ក៏ជាឆន្ទៈដ៏មោះមុតរបស់ស្ដេចខ្មែរដ៏ឆ្នើមមួយព្រះអង្គ គឺព្រះបាទជ័យវរ្ម័នទី៧ដែលជាព្រះមហាក្សត្រដ៏កំពូលនាសម័យមហានគរ ដែលបានសោយរាជពីឆ្នាំ ១១៦២ ដល់ ១២០១ នៃ គ.ស ។

ប៉ុន្តែសេចក្ដីប្រាថ្នាដ៏ត្រឹមត្រូវនេះ អាចនឹងសម្រេចទៅបានលុះត្រាតែជាតិខ្មែរស្ថិតក្នុងរដ្ឋមួយដែលមានសិទ្ធិសេរីភាព សន្តិភាព និងមានការអភិវឌ្ឍគ្រប់វិស័យ ហើយមនុស្សខ្មែរត្រូវកំណត់ជោគវាសនា និងអនាគតប្រទេសជាតិរបស់ខ្លួនដោយខ្លួនឯង ។ ទាំងនេះជាក្រឹត្យក្រមដែលមនុស្សជាតិត្រូវអនុវត្តតាមគន្លងច្បាប់ ។

ស្ថិតក្នុងការណ៍នេះហើយ ដែលព្រះរាជាខ្មែរ ព្រះបាទជ័យវរ្ម័នទី៧ ក៏ដូចព្រះរាជានាសម័យមុនៗដែរ បានយកព្រះទ័យទុកដាក់ណាស់ ស្វែងរកសិទ្ធិសេរីភាព យុត្តិធម៌ បូរណភាពទឹកដី និងអត្តសញ្ញាណជាតិជូន ប្រជានុរាស្ត្រគ្រប់មជ្ឈដ្ឋាន គ្រប់ស្រទាប់វណ្ណៈ ប្រឆាំងនឹងអាណានិគមចម្ប៉ា ពីព្រោះនាសម័យនោះប្រទេស កម្ពុជាបានស្ថិតនៅក្រោមការត្រួតត្រារបស់ប្រទេសចម្ប៉ាដែលជាអ្នកឈ្លានពាន ។ ក្នុងនាមជាអ្នកតស៊ូរំដោះជាតិ ដើម្បីសម្រេចនូវព្រះរាជបំណងនេះ ព្រះអង្គបានធ្វើពលិកម្មគ្រប់បែបយ៉ាងទាំងអស់ ដូចជា ត្រូវបែកបាក់ ព្រាត់ប្រាស់ប្រពន្ធកូន គឺព្រះនាងជ័យរាជទេវី និងព្រះរាជបុត្រស្រីឥន្ទ្រកុមារ និរាស្ដឆ្ងាយពីមាតុភូមិជាដើម ដោយក្ដីឈឺចុកចាប់ក្រៃលែង និងក្ដីវិយោគអួលណែនដ៏ក្រៃ ជារៀងរាល់ថ្ងៃអស់រយៈពេលជិត ៤ឆ្នាំ ។ តាមប្រភពសិលាចារឹក យើងដឹងថានៅឆ្នាំ ១១៨១ នៃគ្រិស្តសករាជ ការតស៊ូរំដោះជាតិមាតុភូមិរបស់ព្រះបាទ ជ័យវរ្ម័នទី៧ បានទទួលជោគជ័យជាស្ថាពរលើកងទ័ពចាម ដែលបានចូលមកលុកលុយកាន់កាប់ព្រះរាជាណាចក្រកម្ពុជា ហើយក្នុងឆ្នាំដដែលនេះព្រះអង្គក៏បានឡើងសោយរាជ្យសម្បត្តិ ជាព្រះមហាក្សត្រនៃព្រះនគរខ្មែរយ៉ាងពេញលេញ ។

យើងសូមលំអោនកាយឧទ្ទិស ការសាកល្បងនេះ ដើម្បីរំលឹកដល់គុណបំណាច់ដ៏ថ្លៃថ្លា និងដ៏មហាធំធេងរបស់មហាបុរសខ្មែរមួយរូបដែលត្រូវជាចៅរបស់ព្រះបាទជ័យវរ្ម័នទី៦ និងជាក្មួយរបស់ព្រះឧបាទសុរិយាវរ្ម័នទី២ ដែលបានស្រោចស្រង់ព្រះរាជាណាចក្រកម្ពុជាពីការវិនាសហិនហោច គឺព្រះបាទជ័យវរ្ម័នទី៧ ។ ប៉ុន្តែបំណងមួយទៀតរបស់យើងគឺការរំលឹកឡើងវិញនូវប្រវត្តិស្នេហាដ៏ល្អប្រពៃបរិសុទ្ធជ្រះថ្លា រវាងមេទ័ពខ្មែរ មានអាយុត្រឹមតែ១៥ ព្រះវស្សាតែប៉ុណ្ណោះរូបនេះ និងព្រះនាងជ័យទេវី ដែលមានទុក្ខសោក រីងរៃ ស្រងេង ខ្លោចផ្សាក្រៃលែង ក្នុងពេលដែលព្រះស្វាមីបាននាំទ័ពទៅតស៊ូនៅឯសមរភូមិសែនឆ្ងាយពីព្រះនាង ។ ការតស៊ូបូជាថ្ពាច់របស់ព្រះអង្គមានរយៈពេល ១៧ ឆ្នាំ ពោលគឺនៅឆ្នាំ ១១៨១ នៃ គ.ស ទើបព្រះអង្គបានរំដោះមាតុភូមិ ជាទីស្នេហារបស់ព្រះអង្គពីកណ្ដាប់ដៃចាម ក្នុងខណៈនោះព្រះនាងទេពីជ័យរាជាទេវីបានធ្វើបុណ្យយ៉ាងគគ្រឹក គគ្រេងដើម្បីអរគុណដល់ព្រះរតនត្រ័យ ដែលបានជួយព្រះស្វាមីរបស់ព្រះនាងទទួលបាននូវជ័យជំនះ តាមការបួងសួងរបស់ព្រះនាង ដែលរង់ចាំផ្លូវព្រះស្វាមីរាល់ថ្ងៃ ដោយព្រះនាងបាន

ចែកអំណោយគ្រប់ប្រភេទថ្វាយ ប្រគេនដល់ព្រះភិក្ខុសង្ឃ និងជូនដល់ប្រជានុរាស្ត្រក្រីក្រក្នុងព្រះរាជនគរ ។ ក៏ប៉ុន្តែ ជាអនិច្ចំ ក្រោយមកព្រះនាងរាជាទេវី ក៏សោយទិវង្គតទៅដោយរោគា ដែលបានញាំញីព្រះកាយព្រះនាងឱ្យស្គមស្គាំង ។ ដើម្បីភ្ជាប់និស្ស័យ ជាមួយព្រះនាង ព្រះបាទជ័យវរ្ម័នទី ៧ ក៏បានរៀបព្រះអភិសេកជាមួយព្រះនាងឥន្ទ្រទេវីដែលត្រូវជាបង តាមគន្លងធម៌នៃព្រះពុទ្ធសាសនា ។ ព្រះនាងឥន្ទ្រទេវីជាស្ត្រីកំពូលក្នុងប្រវត្តិសាស្ត្រកម្ពុជា ពីព្រោះព្រះនាងប្រកបដោយចំណេះវិជ្ជាខ្ពង់ខ្ពស់ ប្រាជ្ញាវាងវៃ និងព្រះហឫទ័យហារពមិនីជុំនិងគ្របសម្បុរ ក្នុងប្រវត្តិសាស្ត្រខ្មែរ ។

វត្ថុបំណងចុងក្រោយនៃការស្រាវជ្រាវរបស់យើងនេះ គឺការលាតត្រដាងចំពោះចិត្តអ្នកអាន នូវលក្ខណៈវប្បធម៌ខ្មែរនាសម័យបាយ័ន ដែលប្រកបដោយវឌ្ឍនៈភាពដ៏ខ្ពង់ខ្ពស់អស្ចារ្យ ជាងសម័យណាៗទាំងអស់ នៃចក្រភពអង្គរ ពោលគឺមុនការបាត់បង់ទឹកដីខ្មែរមួយចំនួនធំ ដែលក្រោយមកទឹកដីខ្មែរទាំងនោះក៏បានក្លាយទៅជារបស់ប្រទេស ថៃ. លាវ. និងប្រទេសវៀតណាមខាងត្បូងបច្ចុប្បន្ន។ ដែលបណ្តាលមកពីមូលហេតុសង្គ្រាមភាទិនិយមរបស់បរទេស មិនឈប់ឈរ លើមាតុភូមិដ៏អភ័ពកម្ពុជា ជាតិខ្មែររបស់យើង។

សូមរំលឹកឡើងវិញថា ឯកសារមូលដ្ឋាន ស្តីពីប្រវត្តិរបស់ព្រះបាទជ័យវរ្ម័នទី៧ ព្រះមហាក្សត្រដ៏ធ្លើមរបស់ខ្មែរ សម័យមហានគរមានជាអាទិ: សិលាចារឹកប្រាសាទមន្ទាយឆ្មារ. សិលាចារឹកប្រាសាទបាយ័ន. សិលាចារឹកប្រាសាទតាព្រហ្ម ព្រះខ័ន. សិលាចារឹកប្រាសាទវិមានអាកាស. សិលាចារឹកប្រាសាទជ្រុងនៅក្នុងរង្វង់ទីក្រុងនគរធំ និងសិលាចារឹកមួយចំនួនទៀត ដែលទាក់ទីងអំពីការសាងសង់ និងការគ្រប់គ្រងរោងឆ្នាសាលា និងមន្ទីរពេទ្យ ដែលគេបានរកឃើញនៅប្រទេសសៀម និងលាវ ដែលពីដើមជាអាណាខេត្តរបស់ចក្រភពអង្គរ ។

# លិខិតថ្លែងអំណរគុណ

******

ខ្ញុំសូមថ្លែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅ និង ឧទ្ទិសស្នាដៃនេះដល់រូបអ្នកមានគុណទាំងពីរគឺលោកឪពុក អ៊ុង វង់ (ហៅទុំ) និងអ្នកម្ដាយ កេះ អន់ ដែលលោកបានចែកឋានទៅហើយ លោកទាំងពីរបានផ្ដល់កំណើត និង ចិញ្ចឹមបីបាច់ថែរក្សា ព្រមទាំងផ្ដល់នូវការទំនុកបម្រុងដល់រូបកូននូវសីលធម៌ ចិត្តស្មោះត្រង់ គិតគូរប្រយោជន៍ជាតិជាធំ។ គុណនេះមានតម្លៃថ្លៃថ្លាប្រសើរបំផុតដែលគ្មានអ្វីអាចកាត់ថ្លៃបានឡើយ។

ព្រមជាមួយនេះ ខ្ញុំសូមថ្លែងអំណរព្រះគុណដ៏ឧត្ដុង្គឧត្ដមយ៉ាងជ្រាលជ្រៅ និងប្រគេនចំពោះសម្ដេចឧត្ដមបញ្ញ ជុង ជង់ ដែលបានផ្ដល់នូវពុទ្ធិចំពោះខ្ញុំព្រះករុណា។

ខ្ញុំសូមថ្លែងអំណរគុណដ៏ឧត្ដុង្គឧត្ដមយ៉ាងជ្រាលជ្រៅ និង ជូនចំពោះ សម្ដេច ហុន សែន និង លោក ជំទាវ ដែលបានលើកអនុសាសន៍ បង្កលក្ខណៈងាយស្រួលដល់រូបខ្ញុំបាទបានបកប្រែពីភាសាបារាំងមកភាសាខ្មែរ ដើម្បីកូនខ្មែរយល់ដឹងពីប្រវត្តិសាស្ត្រសង្ខេបនៃរាជធានីតំបន់អង្គរ សម្ដេចបានលើកអនុសាសន៍ អភិរក្ស ដើម្បីធ្វើការ អភិវឌ្ឍន៍ ក្នុងបំណងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

ជាថ្មីម្ដងទៀត ខ្ញុំសូមដឹងគុណដ៏ឧត្ដុង្គឧត្ដមបំផុតចំពោះ ឯកឧត្ដម ឃឹម សារិទ្ធ និង ឯកឧត្ដម អ៊ឹក សុជាតិ ថ្នាក់ដឹកនាំក្រសួងបានលើកទិសដៅ និងបង្កលក្ខណៈងាយស្រួលអោយខ្ញុំបានបកប្រែនិងចងក្រងឯកសារជាស្នាដៃ សំរាប់ការយល់ដឹងបន្ថែមរបស់កូនខ្មែរ។

ខ្ញុំសង្ឃឹមទុកជាមុនថា អស់លោកជាម្ចាស់ស្នាដៃទាំងនោះពិតជាអនុគ្រោះដល់ខ្ញុំជាមិនខានឡើយ។

សូមអ្នកអាន ជួយរិះគន់និងជួយបន្ថែមចំណុចខ្វះខាតដែលនៅសេសសល់ក្នុងន័យការពារកេរដំណែលជាតិ។

សូមថ្លែងអំណរគុណ ចំពោះមន្ត្រីបុគ្គលិក នាយកដ្ឋានបេតិកភណ្ឌមាន :

លោក វ៉ា វណ្ណថេត អនុប្រធាននាយកដ្ឋានបេតិកភណ្ឌ ទទួលបន្ទុករដ្ឋបាលទូទៅ

លោក ទួន ភោក អនុប្រធាននាយកដ្ឋានបេតិកភណ្ឌ ទទួលបន្ទុកអភិរក្សអង្គរសៀមរាប

លោក ថោង ប៊ុនធឿន អនុប្រធានការិយាល័យបច្ចេកទេសអភិរក្សអង្គរសៀមរាប

លោក ប្រាក់ សុណ្ណារ៉ា ប្រធានការិយាល័យអង្គរុករក

លោក សេង សោត ប្រធានការិយាល័យបញ្ជីសារពើភណ្ឌ

លោកស្រី អួង ចាន់ធី អនុប្រធានការិយាល័យរដ្ឋបាលអភិរក្សអង្គរសៀមរាប

លោក អួង សាវេត អនុប្រធានការិយាល័យបច្ចេកទេសអភិរក្សអង្គរសៀមរាប

ដែលបានជួយជ្រោមជ្រែងគ្រប់បែបយ៉ាង ធ្វើអោយការស្រាវជ្រាវចងក្រងឯកសារនេះបានសំរេចជាស្នាដៃ

# លិខិតថ្លែងអំណរគុណ

******

ខ្ញុំសូមថ្លែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅ និង ឧទ្ទិសស្នាដៃនេះដល់រូបអ្នកមានគុណទាំងពីរគឺលោកឪពុក អ៊ួង វង់ (ហៅទុំ) និងអ្នកម្តាយ កែះ គន់ ដែលលោកបានចែកឋានទៅហើយ លោកទាំងពីរបានផ្តល់កំណើត និង ចិញ្ចឹមបីបាច់ថែរក្សា ព្រមទាំងផ្តល់នូវការទំនុកបំរុងដល់រូបកូននូវសីលធម៌ ចិត្តស្មោះត្រង់ គិតគូរប្រយោជន៍ជាតិជាធំ។ គុណនេះមានតម្លៃថ្លៃថ្លា ប្រសើរបំផុតដែលគ្មានអ្វីអាចកាត់ថ្លៃបានឡើយ។

ព្រមជាមួយនេះ ខ្ញុំសូមថ្លែងអំណរព្រះគុណដ៏ឧត្តុង្គឧត្តមយ៉ាងជ្រាលជ្រៅ និងប្រគេនចំពោះសម្តេចឧត្តមបញ្ញ ជួង ជង់ ដែលបានផ្តល់នូវពុទ្ធិចំពោះខ្ញុំព្រះករុណា។

ខ្ញុំសូមថ្លែងអំណរគុណដ៏ឧត្តុង្គឧត្តមយ៉ាងជ្រាលជ្រៅ និង ជូនចំពោះ សម្តេច ហុន សែន និង លោក ជំទាវ ដែលបានលើកអនុសាសន៍ បង្កលក្ខណៈងាយស្រួលដល់រូបខ្ញុំបាទបានបកប្រែពីភាសាបារាំងមកភាសាខ្មែរ ដើម្បីកូនខ្មែរយល់ដឹងពីប្រវត្តិសាស្ត្រសង្ខេបនៃរាជធានីតំបន់អង្គរ សម្តេចបានលើកអនុសាសន៍អភិរក្ស ដើម្បីធ្វើការ អភិវឌ្ឍន៍ ក្នុងបំណងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

ជាថ្មីម្តងទៀត ខ្ញុំសូមដឹងគុណដ៏ឧត្តុង្គឧត្តមបំផុតចំពោះ ឯកឧត្តម ឃឹម សារិទ្ធ និង ឯកឧត្តម អ៊ុក សុផាតិ ថ្នាក់ដឹកនាំក្រសួងបានលើកទិសដៅ និងបង្កលក្ខណៈងាយស្រួលអោយខ្ញុំបានបកប្រែនិងចងក្រងឯកសារជាស្នាដៃ សំរាប់ការយល់ដឹងបន្ថែមរបស់កូនខ្មែរ។

ខ្ញុំសង្ឃឹមទុកជាមុនថា អស់លោកជាម្ចាស់ស្នាដៃទាំងនោះពិតជាអនុគ្រោះដល់ខ្ញុំជាមិនខានឡើយ។

សូមអ្នកអាន ជួយរិះគន់និងជួយបន្ថែមចំណុចខ្វះខាតដែលនៅសេសសល់ក្នុងន័យការពារកេរដំណែលជាតិ។

សូមថ្លែងអំណរគុណ ចំពោះមន្ត្រីបុគ្គលិក នាយកដ្ឋានបេតិកភណ្ឌមាន :

លោក វ៉ាំ វណ្ណថេត អនុប្រធាននាយកដ្ឋានបេតិកភណ្ឌ ទទួលបន្ទុករដ្ឋបាលទូទៅ

លោក ទូន ភោគ អនុប្រធាននាយកដ្ឋានបេតិកភណ្ឌ ទទួលបន្ទុកអភិរក្សអង្គរសៀមរាប

លោក ថោង ប៊ុនធឿន អនុប្រធានការិយាល័យបច្ចេកទេសអភិរក្សអង្គរសៀមរាប

លោក ព្រាក់ សុវណ្ណារ៉ា ប្រធានការិយាល័យអង្កេតរុករក

លោក សេង សោភ ប្រធានការិយាល័យបញ្ជីសារពើភណ្ឌ

លោកស្រី អ៊ួង ចាន់ធី អនុប្រធានការិយាល័យរដ្ឋបាលអភិរក្សអង្គរសៀមរាប

លោក អ៊ួង សាវេត អនុប្រធានការិយាល័យបច្ចេកទេសអភិរក្សអង្គរសៀមរាប

ដែលបានជួយជ្រោមជ្រែងគ្រប់បែបយ៉ាង ធ្វើអោយការស្រាវជ្រាវចងក្រងឯកសារនេះបានសំរេចជាស្នាដៃ។

# លិខិតថ្លែងអំណរគុណ

******

ខ្ញុំសូមថ្លែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅ និង ឧទ្ទិសស្នាដៃនេះដល់រូបអ្នកមានគុណទាំងពីរគឺលោកឪពុក អ៊ួង វង់ (ហៅទុំ) និងអ្នកម្ដាយ កេះ អន់. ដែលលោកបានចែកឋានទៅហើយ លោកទាំងពីរបានផ្ដល់កំណើត និង ចិញ្ចឹមបីបាច់ថែរក្សា ព្រមទាំងផ្ដល់នូវការទំនុកបំរុងដល់រូបកូននូវសីលធម៌ ចិត្តស្មោះត្រង់ គិតគូរប្រយោជន៍ជាតិជាធំ។ គុណនេះមានតម្លៃថ្លៃថ្លាប្រសើរបំផុតដែលគ្មានអ្វីអាចកាត់ថ្លៃបានឡើយ។

ព្រមជាមួយនេះ ខ្ញុំសូមថ្លែងអំណរព្រះគុណដ៏ឧត្តុង្គឧត្តមយ៉ាងជ្រាលជ្រៅ និងប្រគេនចំពោះសម្ដេច ឧត្តមបញ្ញា ជុង ជង់ ដែលបានផ្ដល់នូវពុទ្ធិចំពោះខ្ញុំព្រះករុណា។

ខ្ញុំសូមថ្លែងអំណរគុណដ៏ឧត្តុង្គឧត្តមយ៉ាងជ្រាលជ្រៅ និង ជូនចំពោះ សម្ដេច ហ៊ុន សែន និង លោក ជំទាវ ដែលបានលើកអនុសាសន៍ បង្កលក្ខណៈងាយស្រួលដល់រូបខ្ញុំបាទបានបកប្រែពីភាសាបារាំងមកភាសាខ្មែរ ដើម្បីកូនខ្មែរយល់ដឹងពីប្រវត្តិសាស្ត្រសង្ខេបនៃរាជធានីតំបន់អង្គរ សម្ដេចបានលើកអនុសាសន៍អភិរក្ស ដើម្បីធ្វើការ អភិវឌ្ឍន៍ ក្នុងបំណងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

ជាថ្មីម្ដងទៀត ខ្ញុំសូមដឹងគុណដ៏ឧត្តុង្គឧត្តមបំផុតចំពោះ ឯកឧត្តម ឃឹម សារិទ្ធ និង ឯកឧត្តម អ៊ុក សុផាតិ ថ្នាក់ដឹកនាំក្រសួងបានលើកទិសដៅ និងបង្កលក្ខណៈងាយស្រួលអោយខ្ញុំបានបកប្រែនិងចងក្រងឯកសារជាស្នាដៃ សំរាប់ការយល់ដឹងបន្ថែមរបស់កូនខ្មែរ។

ខ្ញុំសង្ឃឹមទុកជាមុនថា អស់លោកជាម្ចាស់ស្នាដៃទាំងនោះពិតជាអនុគ្រោះដល់ខ្ញុំជាមិនខានឡើយ។

សូមអ្នកអាន ជួយរិះគន់និងជួយបន្ថែមចំណុចខ្វះខាតដែលនៅសេសសល់ក្នុងន័យការពារកេរដំណែលជាតិ។

សូមថ្លែងអំណរគុណ ចំពោះមន្ត្រីបុគ្គលិក នាយកដ្ឋានបេតិកភណ្ឌមាន :

លោក វ៉ា វណ្ណថេត អនុប្រធាននាយកដ្ឋានបេតិកភណ្ឌ ទទួលបន្ទុករដ្ឋបាលទូទៅ

លោក ទួន ភោគ អនុប្រធាននាយកដ្ឋានបេតិកភណ្ឌ ទទួលបន្ទុកអភិរក្សអង្គរសៀមរាប

លោក ថោង ប៊ុនធឿន អនុប្រធានការិយាល័យបច្ចេកទេសអភិរក្សអង្គរសៀមរាប

លោក ប្រាក់ សុណ្ណារ៉ា ប្រធានការិយាល័យអង្គរក្សករក

លោក សេង សោត ប្រធានការិយាល័យបញ្ជីសារពើភណ្ឌ

លោកស្រី អ៊ួង ចាន់ធី អនុប្រធានការិយាល័យរដ្ឋបាលអភិរក្សអង្គរសៀមរាប

លោក អ៊ួង សាវេត អនុប្រធានការិយាល័យបច្ចេកទេសអភិរក្សអង្គរសៀមរាប

ដែលបានជួយជ្រោមជ្រែងគ្រប់បែបយ៉ាង ធ្វើអោយការស្រាវជ្រាវចងក្រងឯកសារនេះបានសំរេចជាស្នាដៃ។

# ជំពូក I

# ការស្ថាបនាធានីអង្គរ

## ១- ព្រឹត្តិការណ៍របស់ព្រះបាទ យសោវរ្ម័នទី ១ ( ៨៨៩ )

ក្រោយពីបានឡើងគ្រងរាជ្យសម្បត្តិជាព្រះរាជា នៃប្រទេសកម្ពុជាក្នុងឆ្នាំ ៨៨៩ គ.ស មកព្រះបាទយសោវរ្ម័នបានក្តាប់ និង ពង្រីកអំណាចរបស់ព្រះអង្គ ក្នុងរយៈពេល ២ ឬ ៣ ឆ្នាំ ក្រោយ ដោយបានបង្កើតនូវរាជធានីមួយនៅទីនោះ ហើយពេញចិត្តដាក់ឈ្មោះអោយរាជធានីថាជា យសោធរៈបុរៈ ( Yaçodharapura ) អោយដូចឈ្មោះរបស់ព្រះអង្គ ។ ដូចគ្នានិងពួកឡាតាំងដែរ ដែលបានអោយឈ្មោះទីក្រុងរ៉ូម ពីមុនថាជា Urbs ឯរាជធានីយសោធរបុរៈ ក៏ក្លាយជាធានីរបស់ប្រជាជនកម្ពុជា ហើយអង្គរក៏ដូច្នេះដែរ ។ រាជធានីរបស់យសោវរ្ម័នបានចាប់ផ្តើមឡើងដោយប្រថ្នូលល្អ រួមនិងសមិទ្ធិជាច្រើនទៀត ។ ព្រះអង្គបានឡើងគ្រងរាជ្យសម្បត្តិបន្តពីបិតារបស់ព្រះអង្គ គឺព្រះបាទឥន្ទ្រវរ្ម័ន និង ព្រះមាតា ឥន្ទ្រទេវី ព្រះអង្គបានបន្តការដឹកនាំសន្តតិវង្សដ៏ចំណាស់ ២ ដែលតាំងនៅក្នុងប្រទេសកម្ពុជា គឺអាណាចក្រហ្វូណន់ និង ចេនឡា ជាឈ្មោះដែលពួកចិនបានដាក់អោយនៅក្នុងសៀវភៅកំណត់ត្រាប្រវត្តិសាស្ត្ររបស់ពួកគេ ។ ហ្វូណន់បានតាំងនៅភាគខាងត្បូងនៃប្រទេស ហើយព័ទ្ធវង់រហូតដល់សមុទ្រ ។ នៅសតវត្សទី ៧ អាណាចក្រនេះត្រូវបានឈ្លានពានដោយពួកចេនឡា ដែលស្ថិតនៅភាគខាងជើងប្រទេសកម្ពុជា ដែលស្ថិតនៅក្នុងប្រទេសឡាវផ្នែកខាងក្រោម គឺនៅជុំវិញមជ្ឈមណ្ឌលសាសនាវត្តភូ ។

ក្នុងព្រឹត្តិការណ៍របស់ព្រះអង្គ ព្រះបាទយសោវរ្ម័ន ដោយបង្រួបបង្រួមទឹកដីទាំងអស់ មកគ្រប់គ្រង និង ចាត់ចែងអោយនៅក្រោមរាជអំណាចដ៏ខ្លាំងពូកែរបស់ព្រះអង្គ ។ នៅចុងបញ្ចប់សតវត្សទី ៨ ព្រះបាទជ័យវរ្ម័នទី ២ ( 802-850 ) បានចាប់ផ្តើមធ្វើការបង្រួបបង្រួមប្រទេសកម្ពុជា និង ធ្វើអោយមានឯករាជ្យ ។ ព្រះអង្គបានរៀបចំនៅផ្នែកខាងជើងទន្លេសាប ដែលជាតំបន់ពោរពេញទៅដោយដីល្បប់មានជីជាតិ ហើយអាណាចក្ររបស់ព្រះអង្គបានលាតសន្ធឹងរហូតដល់ជ្រលងទន្លេមេគង្គ ។ តាមរយៈការធ្វើពិធីអភិសេកឡើងសោយរាជរបស់ព្រះអង្គ នៅលើភ្នំមហេន្ទ្រ ( Mahendra ) ជាភ្នំគូលែន បច្ចុប្បន្នបានធ្វើអោយឈ្មោះរបស់ព្រះអង្គបានល្បីនៅក្នុងឆ្នាំ ៨០២ គ.ស ដូច ( ជាម្ចាស់លើផែនដីតែមួយគត់លើលោកគឺធ្វើជាស្តេចចក្រពត្តិ ) ។ ជាការល្អណាស់ ដែលព្រះអង្គសំរេចចិត្តធ្វើអោយដូចស្តេចចក្រពត្តិគឺបានន័យថា ព្រះអង្គគ្រប់គ្រងពិភពលោកទាំងមូល អោយនៅក្នុងអំណាចរបស់ព្រះអង្គ ។ ព្រះបាទជ័យវរ្ម័នទី ២ បានធ្វើការរៀបរាប់ប្រៀបធៀប និង ស្តេចដទៃទៀតដែលនៅជុំវិញ និង សតវត្សជំណាលគ្នា នឹងអ្នកដែលធ្វើអោយប្រទេសរងនូវការខ្ទេចខ្ទាំ គឺមានតែព្រះអង្គទេ ដែលធ្វើអោយប្រទេសកម្ពុជាបានទទួលភ្លក់នូវរស់ជាតិឯករាជ្យជាតិ ។ គេបានដឹងថា ព្រះអង្គបានធ្វើការផ្លាស់ប្តូរទីកន្លែងម្តងទៀត នៅក្នុងប្រទេសកម្ពុជារហូតដល់ចូលទីវង្គត់ នៅរាជធានីថ្មីរបស់ព្រះអង្គ គឺហរិហរាល័យ ( Hâriharalâya ) ដែលស្ថិតនៅចំងាយ ១៥គម ពីក្រុងសៀមរាបបច្ចុប្បន្ននេះ ។ មានស្នងរាជ្យបន្តពីព្រះអង្គ ពីរអង្គ គឺមួយអង្គជាបុត្របង្កើតរបស់ព្រះអង្គ គឺស្តេចជ័យវរ្ម័នទី ៣ ហើយមួយអង្គទៀត ត្រូវជាបងប្អូនសាច់ឆ្លាយខាងឪពុកម្តាយគឺឥន្ទ្រវរ្ម័ន ក៏អាចធ្វើការបន្តស្នាដៃនេះបានដែរ ។

ក្រោមអំណាចរបស់ព្រះបាទ ឥន្ទ្រវរ្ម័ន បានសំរេចផលក្នុងការប្រមូលផ្តុំប្រជាជនមួយភាគធំនៅក្នុងប្រទេសកម្ពុជា ក្រោយមកទៀតនៅភាគខាងជើងនៃប្រទេស ជាដីព្រះកេរ្តិ៍របស់ភវៈបុរៈ ( Bhava pura ) ដែលស្ថិតនៅខាងក្រៅការគ្រប់គ្រងរបស់ព្រះអង្គនៅឡើយ ។ ក្រោយពីការឡើងគ្រងរាជ្យបន្តពីជ័យវរ្ម័នទី ៣ ព្រះបាទឥន្ទ្រវរ្ម័នបានសំរេចចាកចេញពីធានី ហរិហរាល័យ ។ ក្នុងអំឡុងពេល ១២ ឆ្នាំនៃការគ្រងរាជ្យរបស់ព្រះអង្គ ព្រះអង្គបានប្រែក្លាយធានីនេះ អោយទៅជាធានីមួយគួរអោយគោរព ដោយបានស្ថាបនាប្រាសាទជាច្រើន ហើយបានធ្វើការជីកបារាយណ៍មួយឈ្មោះថា ឥន្ទ្រតាតាក (Indratataka)។ ក្រោយមកព្រះបាទ យសោវរ្ម័ន បានទទួលសិក្សាអប់រំ និង ជំបូន្មានល្អៗយ៉ាងយកចិត្តទុកដាក់ពីសំណាក់គ្រូបាធ្យាយរបស់ព្រះអង្គ ។

ក្នុងពេលដែលដកខ្លួនចេញនៃ ( បុត្ររបស់ព្រះអង្គ វាពុំមែនជាការបង្ខិតបង្ខំចិត្តអ្វីទេ ) ហើយក៏គ្មានការយកចិត្តទុកដាក់ ដើម្បីធានាដល់ការសិក្សារបស់ព្រះបាទ យសោវរ្ម័នដែរ ។ វ៉ាមៈស៊ីវៈ ( VAMA ÇIVA ) ជាគ្រូបាធ្យាយរបស់ព្រះអង្គ ដែលមានចំណេះដឹងខ្ពស់ ក្រោយលោកជាសាវ័ក ផ្នែកទស្សនៈវិជ្ជាហិណ្ឌូ ចាន់ករាចារយា ( Çankaracharya ) ។ យសោវរ្ម័ននៅតែមានភក្តីភាពចំពោះព្រះសិវៈ ។ ការអប់រំរបស់ព្រះអង្គ មិនបានធ្វើអោយទប់នូវសេចក្តីប្រាថ្នាពីការសិក្សាទស្សនៈវិជ្ជាទេ មានសិលាចារឹកមួយបាននិយាយថា ( ព្រះអង្គបានចាប់ស្រឡាញ់ដោយភក្តីភាព ចំពោះការអនុវត្តន៍នូវគ្រប់ផ្នែកទាំងអស់នៃសិល្បៈងាយពត់ប្រដៅដូចដែលព្រះអង្គបានចាញ់ស្នាដៃគេ ហើយទទួលមកវិញនូវការថ្នាក់ថ្នម និង សីលបារមីរបស់ព្រះអង្គ ) ។ ប្រសិនបើគេជឿតាមសិលាចារឹក លទ្ធផលគឺវាមិនប្រាសចាកពីសេចក្តីសង្ឃឹម ដែលគេបានប្រគល់អោយដល់ស្តេចក្មេងនេះទេ ។ គេបានបង្ហាញអោយឃើញ នូវតេជានុភាពដ៏ស្ញៀមស្ងាត់ ។ សមត្ថភាពនៃការបោះបង់ចោល នូវសេចក្តីច្រណែនចំពោះអទិទេព ដែលមានសេចក្តីស្រឡាញ់ចំពោះតែខ្លួនឯង ដែលល្មោភតែសង្គ្រាមមិនចេះនឿយហត់ ( សកម្មភាពរបស់អទិទេព គឺបង្ហាញអោយអស់នូវសកម្មភាពដ៏គ្រោះថ្នាក់របស់សត្រូវ ) ។ តាមចរិយាសាស្ត្ររបស់ព្រះអង្គ ( លំអដោយសមត្ថភាព ៤យ៉ាង គឺថាមពលចំណេះវិជ្ជា សេចក្តីក្លាហាន និង វិធីសាស្ត្រ ) គេបាននិយាយដូចគ្នានេះដែរ ចំពោះសមត្ថភាពទាំង ៤ នេះ គឺស្ថិតនៅក្នុងបេះដូងព្រះអង្គជានិច្ច ទទួលយកមកវិញ ដោយសីលបារមីរបស់ព្រះអង្គ ហើយព្រះអង្គក៏បានបញ្ឈប់នូវអ្វីដែលនឹងកើតមាន នូវសេចក្តីវិនាសចំពោះមុខដែរ ។ នៅចំពោះមុខ ដូចដែលព្រះភក្ត្ររបស់ព្រះអង្គមិនបានធ្វើអោយយើងញញឹមដោយក្តីរំភើបសាទរ ដែលផ្តល់កំណើតដល់ការឡើងទៅកាន់អំណាចដោយសោយរាជ្យសម្បត្តិ " តាមព្រឹត្តិការណ៍របស់ព្រះអង្គ ( ដោយលើកតំកើងព្រះអាទិត្យ ) ផ្កាឈូកទាំងឡាយត្រូវបានលើកបញ្ឈរដោយព្រះអង្គ..... បំណែកនៃអង្គទាំងឡាយនៅលើមេឃដែលមានពន្លឺ បានធ្វើអោយរាយមាយ មេឃឡើងពណ៌ក្រហមនៅឯជើងមេឃ " ។

កត្តាដឹកនាំដ៏ល្អដែលនៅក្រោមអំណាចរបស់ព្រះអង្គ បានធានាអោយព្រះរាជាណាចក្រកម្ពុជាមានច្បាប់ទំលាប់ល្អ សិលាចារឹកក៏បាននិយាយពីការខិតខំប្រឹងប្រែងស្ថាបនាទីក្រុងដ៏ល្អឯកមួយ ទៅតាមគំនិតរបស់ព្រះអង្គ អោយដូចជាទីឋានរបស់អទិទេពមកប្រតិស្ថាននៅលើផែនដី ។

២- ការស្ថាបនារាជធានី :

ក្រោយពីព្រះបិតារបស់ព្រះអង្គចូលទិវង្គត់ទៅព្រះបាទ យសោវរ្ម័ន ក៏បានឡើងគ្រងរាជ្យសម្បត្តិបន្តនៅរាជធានីហរិហរាល័យ ។ នៅឆ្នាំ ៨៩៣ នៃគ.ស ព្រះបាទយសោវរ្ម័នក៏បានសាងប្រាសាទលលៃរួមមាន ៤ តួ ( ប្រាង្គ ) ធ្វើពីឥដ្ឋ នៅចំកណ្តាលបារាយណ៍ឥន្ទ្រតាតាក ដើម្បីឧទ្ទិសដល់ព្រះមាតា ព្រះបិតា និងព្រះអ័យកោ ព្រះអ័យការរបស់ព្រះអង្គ វាដូចគ្នាទៅនឹងព្រះបាទឥន្ទ្រវរ្ម័ន ដែលបានកសាង

ប្រាសាទព្រះគោ ដើម្បីឧទ្ទិសដល់បុព្វបុរសរបស់ព្រះអង្គដែរ ។ ដើម្បីបំពេញនូវកាតព្វកិច្ចរបស់ខ្លួនត្រូវជាកូនព្រះអង្គ ក៏បានសំរេចចិត្តចាកចេញពីរាជធានីហរិហរាល័យ ដើម្បីទៅកសាងរាជធានីថ្មីមួយទៀត ។ ក្រោយ . រមណីយ៍ដ្ឋានអង្គរ ត្រូវបានកកើតឡើងនៅចំងាយ ២០គម ពីធានីហរិហរាល័យ គឺនៅលើដីទំនាបផ្នែកខាងជើងទន្លេសាប ក្បែរនឹងជើងភ្នំគូលែន ដែលជាភ្នំមួយសំបូរទៅដោយថ្មភក់ ។ គឺជាតំបន់មួយដែលរួមមានភ្នំបីនៅតំរៀបគ្នា គឺភ្នំបូក ភ្នំបាខែង និង ភ្នំក្រោម ។ ធានីបុរាណទាំងពីរនេះ បានតាំងនៅក្បែរស្ទឹងដូចគ្នាគឺ : ធានីហរិហរាល័យបញ្ចូលទឹកដោយស្ទឹងរលួស ឯក្បែរប្រាសាទអង្គរក៏មានស្ទឹងសៀមរាបហូរកាត់ដែរ ។ នៅតំបន់ក្បែរៗច្រាំងទន្លេសាប ត្រូវទទួលរងនូវការលិចលង់រាល់រដូវវស្សាដោយសារតែទឹកទន្លេមេគង្គហូរបញ្ច្រាសមកវិញនារដូវនេះ ។ ស្ទឹងសៀមរាបដែលមានប្រភពទឹកហូរពីភ្នំគូលែន ហើយក៏ហូរចាក់ទៅទន្លេសាបនៅក្បែរជើងភ្នំក្រោម ។

តំបន់ក្បែរៗច្រាំងស្ទឹងសៀមរាប គឺជាតំបន់ដែលដីពោរពេញទៅដោយជីវជាតិណាស់ ។ វាទំនង ជាការពិតនៅតំបន់អង្គរដែលដូចគ្នាទៅនឹងតំបន់រលួស គឺប្រជាជនធ្វើស្រូវនៅតាមតំបន់ក្បែរជើងភ្នំរួច ទើបបន្តមកធ្វើស្រូវឡើងទឹកវិញម្តង / ព្រោះស្ទឹងបាននាំទឹកអោយជន់ឡើងខ្ពស់ មានស្លាកស្នាមនៃការប្រកបរបរកសិកម្មរបស់បុព្វបុរសខ្មែរជាច្រើនកន្លែងនៅផ្នែកខាងលិច និង ខាងត្បូងក្រុងអង្គរ ។ ក្នុងចន្លោះនៃស្លាកស្នាមទាំងនេះ គេអាចកត់សំគាល់បានថាប្រាសាទអកយំ គឺជាប្រាសាទមួយដែលស្ថិតនៅចំកណ្តាលទីក្រុងដែលត្រូវគេបោះបង់ចោលក្នុងអំឡុងឆ្នាំ នៃសតវត្សទី ១១ ហើយទីក្រុងត្រូវបានគេជីកធ្វើជាបារាយណ៍ទឹកទុកវិញ គឺបារាយណ៍ខាងលិច ។ ទីក្រុងនេះប្រហែលត្រូវបានគេបោះបង់ចោលនៅពេលដែលព្រះបាទជ័យវរ្ម័នទី ២ ឡើងគ្រងរាជ្យ ។ នៅខាងកើតក្រុងអង្គរមានប្រាសាទតូចមួយឈ្មោះកុដិស្វរ: ( Kutiçvara ) ប្រហែលជាត្រូវសាងឡើង ដើម្បីរំឭកទៅដល់អនុស្សាវរីយ៍ នៃវិសាលភាពដ៏ធំធេងរបស់ស្តេចតែមួយអង្គដដែលនេះ ចំពោះព្រាហ្មបរោហិតរបស់ព្រះអង្គ ។ នៅក្នុងប្រទេសត្រូវបានប្រជាជនប្រកបមុខរបរកសិកម្ម ហើយនឹងមានប្រជាជនរស់នៅកុះករមុនពេលដែលព្រះបាទ យសោវរ្ម័នជ្រើសរើស ដើម្បីជាទីក្រុងតទៅទៀត ។

នៅក្រោមការគ្រប់គ្រងរបស់ស្តេច និង មន្ត្រីជាច្រើនទៀតនោះ បានធ្វើអោយតំបន់អង្គរបានបង្ហាញអោយឃើញថា វាមានលក្ខណៈពិសេស ដែលធ្វើអោយក្លាយទៅជារមណីយ៍ដ្ឋានតែមួយគត់ ដែលមានសុខដុមរម្យនា និង ភ្នំបាខែង ដោយក្រុងបានព័ទ្ធបញ្ចូលនូវភ្នំដ៏ពិសិដ្ឋមួយនេះ ។ នៅក្នុងជំនឿនៃប្រពៃណីរបស់ប្រជាជនឥណ្ឌា អ័ក្ស ( Axe ) នៃពិភពលោក គឺជាភ្នំព្រះសុមេរុ ( Méru ) ហើយនៅទីនោះមានអទិទេពជាច្រើនគង់នៅ ។ មួយផ្នែកទៀតនៅលើភ្នំកៃឡាស គឺជាអសនៈរបស់ព្រះសិវៈ ។ ទីបញ្ចប់គឺភ្នំគូលែននេះហើយ ដែលព្រះបាទជ័យវរ្ម័នទី ២ បានធ្វើអោយទៅជាភ្នំមួយដ៏ពិសិដ្ឋដែរ ។

យសោវរ្ម័នបានជ្រើសយកភ្នំបាខែង តែព្រះអង្គមិនបានពេញចិត្តនឹងភ្នំបូក និងភ្នំក្រោមទេពីព្រោះភ្នំទាំងនេះទាបជាង និង មួយទៀតខ្ពស់ជាង ឯកន្លែងដែលមានវិសាលភាពនោះក៏តូចដែរ ប៉ុន្តែវាអាចជាច្រកចូលដ៏ល្អទៅកាន់ទីក្រុង |ម្យ៉ាងទៀតភ្នំបូកនៅឆ្ងាយពីទន្លេសាបពេក ឯចំណែកភ្នំក្រោមវិញ នៅជិតទន្លេសាបពេកដែរ អញ្ចឹងហើយគឺវាងាយស្រួលធ្វើអោយមានការលិចលង់ដល់លំនៅដ្ឋានរបស់ប្រជាជនទៀតផង ។ ភ្នំបាខែងជាកន្លែងដែលស្ថិតនៅជិតស្ទឹងសៀមរាបបំផុត ហើយក្រុងនេះស្ថិតនៅខាងក្រៅតំបន់ដែលរងនូវការលិចលង់ ហើយនៅស្ទឹងសៀមរាបមានទឹកហូរមិនដាច់ ជាហេតុធ្វើជាខ្សែក្រវ៉ាត់ទីក្រុងបាន។ វាពុំបានទទួលរងនូវការលិចលង់ចំពោះការឡើងជន់ខ្លាំង នៃទឹកបឹងទន្លេសាបដែរ គឺទីក្រុងមានស្តុកទឹក

មួយដែលមានលទ្ធភាពសំរាប់បង្ហូរទឹកបញ្ចូល និង ស្តុកទឹកទុកបានស្រួល ហើយសំបូរទៅដោយត្រីស្ទើរតែមិនចេះរីងស្ងួត ។

វាជាការចំលែកចិត្តខ្លះដែរ ដែលព្រះបាទយសោវរ្ម័ន បានសំរេចចិត្តចាកចេញពីទីក្រុង ហរិហរាល័យដោយមកតាំងទីក្រុងថ្មីមួយ ដែលមានចំងាយ ២០គម ប៉ុណ្ណោះពីទីក្រុងចាស់ ។ នៅក្នុងធានីហរិហរាល័យ គ្រប់សំណង់ទាំងអស់ ត្រូវបានរាប់បញ្ចូលទៅក្នុងផែនទីដែលបានរៀបចំរួចហើយ ។ ស្តេចក្មេងដែលបានសំរេចចិត្តស្ថាបនាធានីថ្មីមួយនោះ ព្រោះតែព្រះអង្គចង់ធ្វើធានីនេះ អោយក្លាយទៅជាមជ្ឈមណ្ឌលសាសនានៃប្រទេសជាតិ ។ នៅក្នុងព្រះរាជាណាចក្ររាជធានី គឺជាកន្លែងមួយដែលប្រមូលផ្តុំទៅដោយអទិទេពទាំងឡាយ នៃពិភពលោក ។ ភាពពិតជាបេះដូងនៃប្រទេសជាតិ ពិភពរបស់អទិទេព គឺបានជួយអោយមានវិបុលសុខដល់អាណាចក្រទាំងមូល ។ រមណីយដ្ឋានអង្គរបានបង្ហាញអោយឃើញពីលក្ខណៈសម្បត្តិដ៏ពិសេស ពីការការពារប្រទេស និង ការធ្វើពាណិជ្ជកម្មរបស់ពួកគេ ។ វាក៏បានបញ្ជាក់អោយឃើញនូវមហិច្ឆិតានៃជំនឿរបស់ព្រះបាទ យសោវរ្ម័ន ដែលបានជ្រើសរើសយកតំបន់អង្គរ ពីព្រោះការលេចចេញនូវភ្នំបាខែង ប្រៀបបីដូចជាប៉ូលមួយ ដែលមានស្ទឹងសៀមរាបប្រកបដោយទឹកហូរឥតឈប់ និង បឹងទន្លេសាបជាអាងស្តុកត្រីទុកបំរុងសំរាប់ប្រជាជន ។ គឺជាការផ្តល់អោយមានការចាប់បដិសន្ធិនូវយុគ្គសម័យថ្មីមួយដែលភាគច្រើនគេមិនសូវស្គាល់ ។ វាមានសំភារៈសំខាន់ៗជាច្រើន សំរាប់រៀបចំធ្វើជាតំណាងអោយរូបធាតុ ដូចជានៅលើភ្នំគូលែនទឹកស្ទឹងហូរកាត់លិង្គបរិសុទ្ធទាំងឡាយ ដែលគេឆ្លាក់នៅបាតស្ទឹងជានិមិត្តរូបនៃព្រះសិវៈ ។ ទឹកទាំងនេះជាទឹកបរិសុទ្ធ ដោយផុសចេញរបស់អទិទេព ដែលនាំមកអោយនូវដីមានជីជាតិធ្វើអោយមានភាពបរិបូណ៌ទៅដោយផល ហើយក៏ធានាអោយមានបរមសុខនៅរាជធានីនៃព្រះរាជាណាចក្រទាំងមូលផង ។ ឯចំណែកនៅលើភ្នំបាខែងឯណោះវិញ មានប្រាសាទដ៏សំខាន់មួយដែលបានសង់ឡើងមានសណ្ឋានដូចជាបន្ទាយ ឬ បាយសី ។

សិលាចារឹកនៅស្តុកកក់ធំ បាននិយាយបញ្ជាក់ពីការកសាងក្រុងអង្គរបានថា " ស្តេចបានតាំងខ្លួនអោយដូចជាអទិទេព នៃពិភពកណ្តាល " ហើយព្រះគ្រូរបស់ព្រះអង្គ គឺជាមនុស្សឈ្លៀសវៃគឺវាមៈសិវៈ ( Vamaçiva ) " បានកសាងលិង្គបរិសុទ្ធនៅកណ្តាល " ។ គោលបំណងរបស់យសោវរ្ម័នក្នុងការផ្លាស់ប្តូរធានីនោះ ពុំមែនអោយមានបរមសុខធម្មតា ដោយបានយកឈ្មោះរបស់ខ្លួនទៅដាក់ឈ្មោះធានីប៉ុណ្ណោះទេ គឺជាការសំរេចចិត្តដើម្បីធ្វើនិវេសនដ្ឋានដ៏ពិសិដ្ឋ ដែលជានិមិត្តរូប នៃការរៀបចំទឹកដីអោយទៅជាទឹកដីរបស់អទិទេព ដែលបញ្ចេញកាំរស្មីបានដល់គ្រប់កន្លែងទាំងអស់នៃព្រះរាជាណាចក្រ ។ ភាពក្រអឺតក្រទម គឺជាឫកពាររបស់ស្តេច ប៉ុន្តែការបន្ទាបខ្លួននេះ គឺជាអំពើត្រូវតាមច្បាប់របស់សាសនាឯការធ្វើអោយមានការបង្រួបបង្រួម នូវបដិហារ្យ៍សាមញ្ញនៃបរមសុខ របស់មហាចក្រពត្តិធិរាជមួយ ។

៣- <u>រាជធានីរបស់យសោធរ្ម័ន</u> :

រាជធានីដែលកសាងដោយព្រះបាទយសោវរ្ម័ននោះ ពុំមែនជាក្រុងអង្គរធំទេ ប៉ុន្តែគួរអោយឆ្ងល់ណាស់សព្វថ្ងៃជញ្ជាំងកំពែងបានទំលុះទ្វាររបស់ប្រាសាទ ។ ចំណុចកណ្តាលរបស់រាជធានីគឺបានប្រាប់យើងថាជាភ្នំបាខែង ដែលស្ថិតនៅផ្នែកខាងត្បូងកំពែងអង្គរធំ ដូច្នេះទីក្រុងគឺតាំងទីនៅលើរមណីយដ្ឋាននេះនៅចន្លោះនៃដើមសតវត្សទី ៩ និង ចុងបញ្ចប់នៃសតវត្សទី ១២ ។ ប្រាសាទអង្គរត្រូវបានកសាងឡើងនៅក្នុងរយៈពេល ៣០ ឆ្នាំក្រោយ ពីការកសាងរាជធានីអង្គរ អ្នកស្រាវជ្រាវទី ១ បានគិតថា អង្គរធំគឺជាឈ្មោះរបស់ធានីយសោធរបុរៈ ព្រោះមានសណ្ឋានដូចគ្នាទៅ នឹងធានីរបស់យសោវរ្ម័ន ហើយកំហុសនេះវានាំអោយមានកំហុសឆ្គងជាច្រើនទៀត ទៅនឹងកាលបរិច្ឆេទនៃកាលប្រវត្តិរបស់ប្រាសាទ ។

រាជធានីរបស់យសោវរ្ម័ន ពុំមែនមានខ្សែក្រវ៉ាត់ការពារជាជញ្ជាំងទេ គឺខ្សែក្រវ៉ាត់ជារាងភ្លឺពីរ ( Doulde : ស្នាមភ្លោះ ) ។ ជ្រុងមួយក្នុងចំណោមជ្រុងទាំង ៤ របស់រាជធានីគឺនៅល្អនៅឡើយ ។ ត្រូវទឹកនេះត្រូវព័ទ្ធពីក្រៅដោយទំនប់ខ្ពស់ ប៉ុន្តែនៅទិសខាងកើត គឺជំនួសដោយស្ទឹងសៀមរាប ដែលតាមបង្វៀងគឺអោយទឹកហូរតាមប្រឡាយ នៃទំនប់ដីដែលលើកជាខ្សែក្រវ៉ាត់ទីក្រុងបច្ចុប្បន្ន គេឃើញយ៉ាងច្បាស់នូវស្នាមភ្លឺដី ដែលលើកធ្វើជាខ្សែការពារនេះ ពិសេសនៅត្រង់ជ្រុងខាងត្បូងឈៀងខាងលិច ។ ត្រូវទឹកបុរាណបានរក្សាទឹកទុកយ៉ាងគ្រប់គ្រាន់សំរាប់កសិករ ដើម្បីញ៉ាំងអោយប្រព្រឹត្ត នូវរបរកសិកម្មបានល្អ ។

៤- <u>ភ្នំបាខែង</u> :

យើងពុំបានដឹងថា តើទីក្រុងនេះគេគ្រប់គ្រងដោយរបៀបណាទេ ។ មានតែសំណង់របស់សាសនាធ្វើពីសំភារៈស្រាលៗ ដែលត្រូវបាត់បង់ខូចខាតអស់តាំងពីយូរយារមកហើយម្លេះ ឯសំណង់ដែលនៅផ្នែកខាងជើង នៃទីក្រុងទីមួយនេះ ក៏ត្រូវជំនួសដោយក្រុងអង្គរធំដែរ ។ បើវាជារាជធានីមួយនៅអង្គរអញ្ជើងប្រហែលជាមានតែប្រាសាទភ្នំបាខែងតែមួយគត់ ដែលគេសន្មត់ថាជាប្រាសាទនៅក្នុងរាជ្យស្តេចយសោវរ្ម័ន ។ នៅក្នុងសិលាចារឹកស្តុកកក់ធំបានថា បានប្រដូចភ្នំបាខែង នៅនឹងកណ្តាល ។ ជាកូនភ្នំមួយដែលមានកំពស់ ៦០ម ហើយគ្របសង្កត់លើរមណីយដ្ឋានអង្គរទាំងមូល ។ ឯប្រាសាទក៏ត្រូវបានគេសង់នៅពីលើកំពូលរបស់វា ។

នៅជុំវិញកំពូលភ្នំ គេបានសាងតួប្រាសាទសំខាន់ប្រាំតួ តំរៀបជារៀងចំណិតត្រសក់ ( Quinconce ) នៅលើគ្រឹះរាងជាពីរ៉ាមីឌប្រាំថ្នាក់ រួមមានកំពស់ ១៣ម ។ តួប្រាសាទកណ្តាលដែលជាប្រាសាទសំខាន់ជាងគេ ត្រូវគេធ្វើអោយខ្ពស់ជាងតួ ៤ ផ្សេងទៀតដែលនៅតាមជ្រុង ។ គេអាចឡើងទៅកាន់ទីលានកំពូលបានតាមជណ្តើរ ដែលគេបានធ្វើសំរាប់អោយឡើងនៅគ្រប់ជ្រុងទាំង ៤ ។ ទីលាន និង តួប្រាសាទខាងលើ ត្រូវបានកសាងអំពីថ្មភក់ ។ នៅផ្នែកខាងក្រោមរបស់ពីរ៉ាមីឌ គឺគេបានកសាងប្រាសាទឥដ្ឋចំនួន ៤៤ ព័ទ្ធជុំវិញ ។ ចំពោះប្រាសាទរបស់ឥន្ទ្រវរ្ម័នវិញ ក៏បានសាងប្រាសាទរាងជាពីរ៉ាមីឌមួយខ្ពស់ដែរនៅធានីហរិហរាល័យ គឺប្រាសាទបាគង ។ ប៉ុន្តែការកសាងតួប្រាសាទប្រាំនៅកណ្តាលនៃកំពូលពីរ៉ាមីឌ គឺជារូបមន្តមួយថ្មី ប្រសិនបើមាននិម្មិតរូបដ៏សំបូរបែបវិញ នោះគេអាចរាប់បញ្ចូលទៅក្នុងស្នាដៃនៃសិល្បៈជំនាន់ក្រោយៗហើយ ។ មានតួប្រាសាទចំនួន ៦០ ទៀត ដែលគេសង់នៅតាមជ្រុងជាប់នឹងជណ្តើរ និង តាមថ្នាររបស់ពីរ៉ាមីឌ ។

លោក J. Filliozals បានធ្វើការកត់សំគាល់ពីចំនួននៃតួប៉មប្រាសាទភ្នំមួយនេះថា ការកសាងនូវចំនួនបែបនេះ គឺវាពុំមែនគ្មានអត្ថន័យអ្វីនោះទេ ។ តួប្រាសាទទាំងអស់មានចំនួន ១០៨ គឺជាចំនួនឯកសិទ្ធិមួយ ដែលរួមមានលេខ ១ និងលេខ ៨ ។ ដូច្នេះលេខនេះគឺវាចេញមកពីក្នុងលេខ ១០៨០០ របស់គាថា នៅក្នុងគម្ពីរវេទ ( Veda ) ហើយមួយទៀត នៅក្នុងប្រតិទិនឥណ្ឌា ក្នុងមួយថ្ងៃៗ គេចែកចេញជា ៣០ ដំណាក់កាលចំនួនក្នុង មុហូត ( Muhuta ) មួយឆ្នាំរួមមាន ៣៦០ថ្ងៃ ត្រូវជា ១០៨០០ មុហូត ។ ទីបញ្ចប់នេះ ប្រសិនបើគេគុណនៃចំនួនលេខ ២៧ នៃខែក្នុងច័ន្ទគតិ ជាមួយនឹងលេខ ៤ ដែលជាលេខនៃចំនួនសម័យ ( Phases ) របស់ព្រះច័ន្ទ គេនឹងបាននូវចំនួន ១០៨ ដូចលេខនៃចំនួនតួប្រាសាទដែលគេបានសង់នោះ ។

ការកសាងប្រាសាទតាមចំនួនរបស់វានោះ វាពុំមែនអត់ប្រយោជន៍នោះទេ ។ គេបានកត់សំគាល់ជាយូរយារមកហើយដែលតួប៉មប្រាសាទប្រាំ សង់តំរៀបគ្នារាងចំណិតត្រសក់ ( En quinconce ) គឺជានិម្មិតរូបនៃកំពូលប្រាំរបស់ភ្នំព្រះសុមេរុ ដែលជាលំនៅដ្ឋានរបស់អទិទេព ។ នៅលើភ្នំសុមេរុមានអទិទេព

តង់នៅចំនួន ៣៣អង្គ ។ តាមការពិចារណា និង ការកត់សំគាល់របស់លោក J. Filliozale បានថាគ្រប់ជ្រុងទាំងអស់របស់ប្រាសាទភ្នំបាខែងមានតួប្រាសាទទាំងអស់ចំនួន ៣៣តួ ហើយតួខ្លះទៀត ត្រូវរលំបាក់អស់ ។ គ្រប់ៗតួរបស់ប្រាសាទសុទ្ធតែតំកល់លិង្គនៅខាងក្នុង ឬ ក៏គ្រប់ប្រាសាទដែលឧទ្ទិសទៅព្រះសិវៈត្រូវជំនួសដោយលិង្គ ។ នៅលើកំពូលភ្នំគេអាចមើលពីគ្រប់ជ្រុងឃើញតួប្រាសាទមានតែបីជានិច្ច ប៉ុន្តែតួមួយនៅកណ្តាលខ្ពស់ជាងតួដទៃទៀត គឺជានិម្មិតរូបនៃអទិទេពបី ( Trimiti ) គ្រប់គ្រងដោយព្រះសិវៈ ។ ភ្នំបាខែងគឺជាភ្នំមួយដែលត្រូវលក្ខណៈដូចគ្នា និងភ្នំព្រះសុមេរុ ដែលជាលំនៅដ្ឋានរបស់អទិទេពផង និងជាអ័ក្សនៃពិភពលោកផង ។

គេបានធ្វើការពិចារណាទៅឃើញថា កន្លែងដែលជាទិសក្ការៈរបស់អទិទេពគឺជាភ្នំបាខែង ជាភ្នំធម្មជាតិមួយរបស់ព្រះរាជាណាចក្រកម្ពុជា ។ អត្ថបទសិលាចារឹកស្តុកកក់ធំ បានសរសេររៀបរាប់ឡើងវិញពីព្រះរាជគ្រូរបស់ស្តេច គឺព្រាហ្មណ៍វាមសិវៈ ( Vamaçiva ) " បានអភិសេកលិង្គមួយនៅលើភ្នំ ស្រីយសោធរបុរៈ ( Çriyaçogharapura ) គឺជាការលើកស្ទួយស្តេចអោយទៅជាស្តេចភ្នំ ហិមាឡៃ " អត្ថបទជាភាសាខ្មែរដែលមាននៅក្នុងសិលាចារឹកជាមួយគ្នានេះ ក៏បាននិយាយរៀបរាប់ពីព្រះបាទយសោវរ្ម័ន ដោយបង្ហាញជាមរណៈនាមរបស់ព្រះអង្គគឺបរមសិវៈលោក ( Paramaçivarloka )។

" ការតាំងរាជធានី ស្រីយសោធរបុរៈ ក៏បាននាំអទិទេពជាម្ចាស់ ( Kamrateng jagat taraja ) ពីធានីហរិហរាល័យទៅរាជធានីយសោធរបុរៈដែរ ។ នៅពេលនោះបរមសិវៈលោកបានតាំងខ្លួនជាម្ចាស់ភ្នំកណ្តាល ។ ព្រះគ្រូនៃសិវៈក្រៀម ( Çivacrama ) គឺវាមសិវៈ បានសាងលិង្គដ៏ពិសិដ្ឋមួយនៅចំកណ្តាល " ។

សរសេរនៅក្នុងសិលាចារឹកនេះ ពុំបានបង្ហាញបញ្ជាក់អោយច្បាស់ពីនាទីរបស់ពាក្យថា ព្រះអទិទេពជាម្ចាស់ ( Kamra teng jagat la raja ) ទេ ។

គេបានគិតថា ពាក្យខ្មែរមួយនេះ មានតំលៃស្មើនឹងពាក្យថា ទេវរាជ ដែលគេប្រែថា" អទិទេពស្តេច ( Dieu-roi ) ហើយបានជ្រើសរើសយកអ្នកត្រូវជា Dieu-roi គឺជាតួអង្គនៃគោរូបដ៏សំខាន់របស់រាជាណាចក្រ ឯពាក្យទេវរាជ ( Devaraja ) បានកើតឡើងនៅក្នុងអត្ថបទដែលចែងដោយព្រះបាទជ័យវរ្ម័នទី ២ ។ លោក J. Filliozat បានធ្វើការកត់សំគាល់ថា Kamrateng jagat ក្លាយមកពីពាក្យថា Jagadievara " ម្ចាស់នៃពិភពលោក " គឺសំដៅទៅលើព្រះសិវៈ ដែលធ្វើជាស្តេចទៅតាមប្រពៃណីអាចបញ្ជាក់ជាកស្តិណសាក្សីបាននៅប្រទេសឥណ្ឌាប៉ែកខាងត្បូង ។ វាពុំមែនជាសារៈប្រយោជន៍អ្វីទេនៅក្នុងរាជាណាចក្រ ប៉ុន្តែព្រះសិវៈបានមកតាក់តែងក្នុងពិធីសាសនានៅធានី យសោធរបុរៈ ជាស្រេចហើយ ។ លិង្គដែលសាងដោយវាមសិវៈ ហើយដាក់នៅក្នុងតួប្រាសាទកណ្តាល មានឈ្មោះថា Yaçodharaçuna ម្ចាស់របស់យសោធរបុរៈ ការដែលសំដែងបដិហារបស់ព្រះសិវៈ គឺជា " ម្ចាស់របស់ព្រះបាទយសោវរ្ម័ន " ។

នៅជុំវិញលិង្គ គេត្រូវធ្វើបរិយាកាសមានភាពបរិសុទ្ធល្អ ដែលហៅថា សិវៈក្សេត្រ ( Çivakshe tra ) ត្រូវដាំដើមឈើដែលអាចអោយតាបសបានកន្លែងល្អ សំរាប់ធ្វើតមធម៌ ។ សិវៈក្សេត្រនិមួយៗមានទំហំរហូតដល់ ១០០០ហត្ថ នៅជុំវិញលិង្គ ។ របងព័ទ្ធជុំវិញភ្នំបាខែងផ្នែកខាងក្រៅមានទំហំ ៦៥០ម * ៤៤០ម ដោយទំហំនេះមានតែប៉ុណ្ណោះ ធ្វើអោយសិវៈក្សេត្រមានតែមួយទេ ។

រាជធានីជាកន្លែងបរិសុទ្ធដោយឡែកមួយ ដោយមានរៀបជាកន្លែងរបស់លោកធាតុនៅចំពាក់កណ្តាលទីក្រុង ដែលជាទីដ្ឋានរបស់អទិទេព និង ការស្រលាញ់ចូលចិត្តរបស់ស្តេច ។ តើវាទៅជាកន្លែង

បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

សំរាប់ឧទ្ទិសយ៉ាងម៉េច ? តើពិធីបុណ្យដែលគោប្រារព្ធនៅទីនេះ ? គ្មានទេដែលយើងត្រូវនិយាយពីពិធីទាំងនេះនោះ ។ សិលាចារឹកស្តុកកក់ធំមួយទៀត មិនបាននិយាយអំពីចំណុចនេះទេ តែបាននិយាយរៀបរាប់អំពីពិធីបុណ្យរបស់គ្រួសារសង្ឃសមណោមួយវិញ ហើយក៏មិនសរសេរអ្វីពីប្រវត្តិ នៃរាជាណាចក្រនេះទេ ។ តែវាពុំមែនជាព្រឹត្តិការណ៍យកមកជំនួសក្នុងបន្ទាត់ សំរាប់ដាក់ជាសំអាង ដើម្បីបញ្ជាក់ពីសកម្មភាពខ្លះៗ ដែលមាននៅទីនេះទេ ។

នៅក្នុងរង្វង់ខ្សែក្រវ៉ាត់របស់ធានីទី ១ នៅអង្គរនេះ ប្រាសាទភ្នំបាខែងគឺជាប្រាសាទតែមួយគត់បើតាមគំនិតរបស់យើង គឺត្រូវបានសាងឡើងដោយព្រះបាទយសោវរ្ម័ន ។ គ្មានស្លាកស្នាមអ្វីមួយអំពីរាជវាំង ឬ ក៏លំនៅដ្ឋានដែលមានកាលបរិច្ឆេទដំណាលគ្នាជាមួយ និង ប្រាសាទដែលត្រូវបានរកឃើញឡើយរហូតមកដល់ពេលនេះ ។ រូបចំលាក់ទាំងឡាយ ការតុបតែងលំអនៃប្រាសាទមិនបង្ហាញអោយឃើញពីការចូលចិត្តស្ថាបត្យកម្មដែលជាអត្តប្បដិរូបឡើយ ។

៥- ការចាប់ផ្តើមកសាងរាជធានី :

រាជធានីយសោធរបុរៈ ពុំមែននៅឯកោក្នុងតំបន់ដែលគេបោះចោលនោះទេ ។ គេបានធ្វើផ្លូវមួយភ្ជាប់មកពីធានីហរិហរាល័យ ដោយចេញពីភាគខាងត្បូងនៃធានីថ្មី ហើយទៅតភ្ជាប់ជាមួយ និងមុំខាងជើងឈៀងខាងកើត និង បារាយណ៍ឥន្ទ្រតាតាក ។ ភូមិស្រុកទាំងអស់ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់មនុស្សដែលត្រូវជាខ្សែស្រឡាយរបស់ស្តេច ដែលរស់នៅក្នុងតំបន់នេះ ។ នៅផ្នែកខាងត្បូងនៃអតីតខ្សែក្រវ៉ាត់ទីក្រុងមានប្រាសាទតូចមួយឈ្មោះប្រាសាទបត្រី ( Patri ) មានលំនាំជារចនាបថបាខែង ប្រហែលជាកន្លែងសំរាប់ការបន់ស្រន់របស់អ្នកស្រែ ។

គេបានគិតថា ភូមិទាំងឡាយរបស់ប្រជាជនបានតាំងទីស្ថិតនៅក្នុងតំបន់ចន្លោះពីបឹងទន្លេសាប និង ខ្ពង់រាបនៃភ្នំគូលែន ។ បើពិនិត្យអោយឃើញទៅថា មានតែតំបន់នេះទេ ដែលបែងចែកតំបន់គ្នារវាងប្រជាជនចំពោះទីកន្លែង ដែលគេត្រូវធ្វើការគោរពបូជាក្នុងសាសនា ។ អាស្រមឥសីប្រហែលជានៅឯកោតែឯងក្នុងគុម្ពោតព្រៃ ប៉ុន្តែនៅក្នុងប្រាសាទមួយៗ ត្រូវតែមានប្រជាជនក្នុងភូមិរស់នៅ និង ថែរក្សាតិច ឬច្រើនទៅតាមនោះ ។ នៅខាងលើភ្នំក្រោម និង ភ្នំបូកមានតួប្រាសាទបីសង់ទន្ទឹមគ្នា គឺឧទ្ទិសទៅអទិទេពបីគឺ ៖ សិវៈ វិស្ណុ និង ព្រះព្រហ្ម ។ នៅផ្នែកខាងកើតទីក្រុង គេច្រើនតែប្រកបរបរធ្វើស្រូវឡើងទឹក ។ ស្តេចបានរៀបចំជីកបារាយណ៍មួយ សំរាប់ស្តុកទឹកទុកអោយប្រជាជនធ្វើស្រែចំការ ឈ្មោះថាបារាយណ៍យសោធរៈតតាក ( Yaçodharatataka ) ដែលសព្វថ្ងៃគេអោយឈ្មោះថា បារាយណ៍ខាងកើត ។ បារាយណ៍នេះមានបណ្តោយ ៧គម និងទទឹង ១៨០០ម ដែលស្តុកទឹកទុកបានជាច្រើនសំរាប់ប្រើប្រាស់ ។ មានសិលាចារឹក ៤ ដែលគេដាក់នៅតាមជ្រុងទាំង ៤ របស់បារាយណ៍ដោយអង្វរករអទិទេពអោយជួយថែរក្សានូវស្រះទឹកដ៏ធំនេះផង ។ ដើម្បីបំពេញដល់បារាយណ៍នេះ ស្ទឹងសៀមរាបបានហូរនាំទឹកពាំងមកភ្ជាប់ជាមួយនឹងតួទឹករបស់រាជធានី ។

៦- អំពីវត្ត :

យើងពុំបានដឹងទេថា តើព្រះបាទយសោវរ្ម័នគ្រប់គ្រងរាជធានី យសោធរបុរៈយ៉ាងម៉េចនោះទេ ហើយប្រជាជនដែលរស់នៅក្នុងរាជធានី ឬ ក្នុងភូមិស្រុកនោះក៏មិនដឹងយ៉ាងម៉េចដែរ ។ តែផ្ទុយទៅវិញយើងបានដឹងអំពីពត៌មានខ្លះៗ ដែលជារឿងពិតអំពីមនុស្សរស់នៅក្នុងវត្តមួយ ដែលសាងដោយយសោវរ្ម័ននៅជិតបារាយណ៍ យសោធរៈតតាក ។ សិលាចារឹកជាច្រើនបានបញ្ជាក់អំពីការស្ថាបនាសំណង់នេះ ។ ទីមួយគឺប្រាម្មអាស្រម ( Prâhmanâçrama ) ដែលទទួលយកតែអទិទេព ដែលជានិកាយសិវៈ ( Çi

vaites ) ទីពីរគឺជាវៃស្នះអាស្រម ( Vaishnavâçrama ) គឺជាកន្លែងតាំងនៅរបស់អទិទេពវិស្ណុ ( Vishnc ites ) ។ សិលាចារឹកបី ដែលគេរកឃើញនៅអង្គរធំជិតប្រាសាទទេពប្រណម បានសរសេររៀបរាប់ឡើងវិ អំពីការសាងសង់អាស្រមព្រះពុទ្ធសាសនាមួយ ។ សិលាចារឹកនេះបាននិយាយថា វត្តទីបី ត្រូវបានសា នៅលើទំនប់ខាងត្បូងរបស់បារាយណ៍ ។ នៅលើមុខទាំងសងខាង នៃសិលាចារឹកមានសរសេរជាអក្សរ ពីរប្រភេទខុសគ្នាស្រលះមុខម្ខាង គឺជាលំនាំនៃអក្សរឥណ្ឌាខាងត្បូង ។ សិលាចារឹកនេះបានបញ្ជាក់ប្រាប់ យើងអោយដឹងយ៉ាងច្បាស់អំពីការគ្រប់គ្រង និង អំពីជីវភាពរបស់អ្នករស់នៅក្នុងវត្តនេះ ។ គេបានធ្វើ បន្ទប់តូចៗសំរាប់ធ្វើជាលំនៅដ្ឋានរបស់មនុស្ស មានបន្ទប់សំរាប់សិក្សា និង បណ្ណាល័យ ។

គ្រប់វត្តទាំងអស់ គឺត្រូវដឹកនាំដោយចៅអធិការមួយអង្គ ដែលត្រូវតែនៅតាមមើលថែរក្សារហូត " អាស្រមនេះ បានចំរើនឡើងយ៉ាងសំបូរបែប " ។ មួយក្នុងចំណោមមុខងារមានសារៈសំខាន់គឺជាការ សិក្សា គេបានស្មានថាការស្នាក់នៅរបស់គ្រូ និង និស្សិតទាំងអស់ ត្រូវទទួលស្បៀងអាហារជាមធ្យមតែ ៨៤ ទេ គឺស្លា ៨ផ្លែ មួយចំណែកជាអង្ករ ម្ហូ ៦០សន្លឹក ក្រៅពីនេះគឺជាឱសថុត ហើយរបស់ទាំងអស់នេះ ត្រូវប្រគល់ទៅអោយដល់គ្រូ និង និស្សិតដែលនៅលីវ ។ កាលនោះពិធីបុណ្យប្រចាំឆ្នាំ គេត្រូវបន្ថែមនូវ ម្ហូបអាហារជាច្រើនទៀតអោយដល់វត្តនេះ ។ សំភារៈខ្លះៗត្រូវបានគេចែកអោយស្មើគ្នាដល់ពួកនិស្សិត ។ វត្ថុធាតុពាប់រយមុខនៃសំភារៈទាំងអស់ ត្រូវបានគេប្រមូលទុកនៅក្នុងបន្ទប់តូចៗមាន " កូនត្រៃ កាំបិតកោ ហើយនិងកន្ទ្រៃប់ពីរអោយការបំផ្លាស់ប្តូរថ្មីជារៀងរាល់ឆ្នាំ នៅក្នុងបន្ទប់និមួយៗ " ។ សំភារៈដទៃទៀតគឺតំរូវ លើកម្មសិទ្ធិផ្ទាល់ខ្លួន " និស្សិតដែលផ្ចែកលើគុណធម៌ ត្រូវបានទទួលយកនូវក្រដាសថ្មីៗសុទ្ធល្អ ។ ស្បែក សត្វខ្មៅ ដីស " ។ ក្រដាសថ្មីសុទ្ធ ប្រហែលជាក្រដាសធ្វើពិធីដើមភ្លស់ ? សំរាប់បំរើអោយការសរសេរ ។

និស្សិត និង គ្រូទាំងឡាយគឺជាមនុស្សដែលរស់នៅក្នុងវត្ត ហើយទទួលបាននូវលក្ខន្តិកៈ ឯកសិទ្ធិ ។ ក្នុងពេលនេះវត្តបានបើកទទួលមនុស្សគ្រប់ប្រភេទអោយចូលសិក្សា សូម្បីមនុស្សអភ័ព្វអនាថា ក៏ត្រូវបានគេទទួលបដិសណ្ឋារកិច្ចអោយចូលសិក្សាដែរ ។ ម្យ៉ាងទៀតគេបានស្មានទុកថាអ្នកគ្រប់គ្រងវត្ត ទាំងឡាយអាចទទួលយកបាននូវមនុស្សជាច្រើន ហើយក៏ទទួលនូវសេចក្តីពប់អានយ៉ាងខ្លាំងពីសំណាក់ ផងទាំងពួងដែរ ។ គេបានបន្ថែម ៖

" ប្រសិនបើស្តេចយាងមកកាន់ទីនេះជាមួយ នឹងអគ្គមហេសី ព្រះគ្រូចៅអធិការ និងត្រូវតំឡើង ឋានៈអោយស្មើនឹងអទិទេព បន្ទាប់មកទៀតមនុស្សដែលមានប្រាជ្ញទាំងឡាយនៃអាស្រមនេះ នឹងឡើងទៅ ជាអ្នកត្រួតត្រាលើអទិទេព លើដី ចៅអធិការនឹងទៅជាព្រះគ្រូរបស់ពិភពលោកទាំងមូល " ។

ម្យ៉ាងវិញទៀតបុត្រីស្តេច បុត្រីតូច ឬ ក៏អគ្គមហេសីដែលមានវ័យចំណាស់យ៉ាងណាក៏ដោយ ដែលបានយាងមកកាន់ទីនេះ គឺត្រូវបានគេគោរពដូចព្រះគ្រូចៅអធិការអញ្ជើងដែរ ប៉ុន្តែលោកគ្រូចៅអធិការ បានបញ្ជាក់ថា អគ្គមហេសី និង បុត្រី " មិនត្រូវយាងចូលទៅកាន់បន្ទប់តូចៗ ដែលជាកន្លែងស្នាក់នៅ របស់គ្រូ និង សិស្សឡើយ " ។ ទីបញ្ចប់ពេលណាព្រះអគ្គមហេសី " ប្រទាននូវសេចក្តីស្រលាញ់ចូលចិត្ត ដែលមនុស្សទូទៅគេដឹងឮគ្រប់គ្នានោះ ព្រះនាងពុំចាំបាច់យាងមកកាន់ទីនេះទេ " ។ សំរាប់យើងដែលជា ប្រជាពស្ត្រវិញ គឺឈរនៅខាងក្រៅរបងវត្តនេះ គឺជាឋានានុក្រមនៃសង្គមខ្មែរសម័យអង្គរ ដែលយើងបាន ស្រាវជ្រាវរកឃើញ ។

៧- <u>តំលៃនៃស្ពានដៃរបស់ព្រះបាទយសោវរ្ម័ន</u> :

ការស្ថាបនាធានីអង្គរ គឺពិតជាចេញមកពីស្នាដៃដ៏ធំបងរបស់ព្រះបាទ យសោវរ្ម័ន ដែលការ គ្រងរាជ្យរបស់ព្រះអង្គនេះ ប្រហែលជាមានរយៈពេល ២០ឆ្នាំ ។ ប៉ុន្តែការគ្រប់គ្រងរបស់ព្រះអង្គប្រៀបបើ

ដូចជាការគ្រប់គ្រងតាមបែបយោធាដ៏មានអំណាច ដូចដែលសិលាចារឹកដែលគេបានរកឃើញនៅផ្នែកខាងក្រោមប្រទេសឡាវ ជិតព្រំប្រទល់ឈូងសមុទ្រសៀមបានបញ្ជាក់ស្រាប់ ។ ព្រះអង្គបានអនុវត្តនូវគំរោងស្ថាបនាធានីអង្គរ វាដូចគ្នាទៅនឹងការស្ថាបនាក្រុងក្រោយៗទៀតដែរ ។ គេគិតថាព្រះបាទយសោវរ្ម័នមាននិន្នាការគួរអោយចំឡែក នៃការស្ថាបនាធានីយសោធរបុរៈ ហើយបានប្រដូចធានីនេះទៅនឹងពិភពលោកទាំងមូល ដោយបានធ្វើអោយមានការគោរពបូជាចំពោះសិវៈ នៅចំចំណុចកណ្តាលនៃព្រះរាជាណាចក្រ ។ គំរូនៃនិមិត្តរូបរបស់រាជធានីនេះ ពុំមែនជាការប្រឌិតទេ គឺជាទេពកោសល្យរបស់ព្រះបាទយសោវរ្ម័នដែលយកតាមគំនិតរបស់ប្រជាជនឥណ្ឌា ។ រាជធានីនេះ បានរំលេចចេញនូវភ្នំមួយនៅចំកណ្តាល គឺជាភ្នំបាខែងដែលជារូបរបស់ភ្នំព្រះសុមេរុ ឯកំពែងការពាររាជធានី គឺជាទំនប់ដីលើកខ្ពស់ ប្រៀបបីដូចជាជួរភ្នំដែលមាននៅក្នុងលោកធាតុទៀត ហើយមានបារាយណ៍ដែលជីកដោយមនុស្សនោះ គឺជាបារាយណ៍ពិសិដ្ឋដែលជានិមិត្តរូបនៃសមុទ្រ ។ អ្នកបន្តវេនបន្តពីព្រះបាទយសោវរ្ម័នទាំងឡាយ មិនបានធ្វើអោយបាត់បង់នូវអត្ថន័យរបស់រាជធានីអង្គរទេ ហើយមានការធានាអោយមានវិបុលភាព និង គុណសម្បត្តិរបស់រាជធានីជូនដល់ព្រះរាជាណាចក្រទាំងមូលផង ។ រាជធានីនេះ បានស្ថិតនៅលើរមណីយដ្ឋានចាស់របស់ខ្លួនដដែល និមិត្តរូបថ្មីនឹងវិលមកជំនួស ប៉ុន្តែអទិទេពចាស់ស្ថិតនៅដដែល ដូច្នេះសន្តតិវង្សនេះ មិនត្រូវបានគេបោះបង់ចោលឡើយ ។

---

## ជំពូក II

## ធានីអង្គរនៅសតវត្សរ៍ទី ១០

---

### ១- ធានីអង្គរនៅក្រោមការគ្រប់គ្រងរបស់អ្នកបន្តវេនពីមួយបន្ទាប់ពីព្រះបាទយសោវរ្ម័ន :

ក្រោយពីបានឡើងគ្រងរាជ្យសម្បត្តិនៅឆ្នាំ ៨៨៩ មកព្រះបាទយសោវរ្ម័នក៏បានសោយទិវង្គត់ទៅក្រោយពីបានគ្រងរាជ្យអស់រយៈពេលបានត្រឹមតែ ២០ឆ្នាំប៉ុណ្ណោះ ។ ក្រោយពីចូលទិវង្គត់ ព្រះអង្គបានទទួលនូវមរណៈនាមមួយថ្មី គឺបរមសិវៈលោក ( Paramaçivaloka ) នាមនេះគឺជានាមតាមទំនៀមទំលាប់ប្រពៃណីស្តេច ព្រះអង្គក៏បានធ្វើការចុះហត្ថលេខាលើសិលាចារឹកមួយ ដែលជាសិលាចារឹកចារក្រោយរាជរបស់ព្រះអង្គ ។ សំរាប់អ្នកដែលត្រូវបន្តវេនពីព្រះអង្គ ព្រះអង្គបានបន្សល់ទុកនូវបុត្រាពីរអង្គសំរាប់អោយស្នងរាជ្យបន្តដែរ បុត្រាទីមួយមានព្រះនាមថា ហរសវរ្ម័នទី ១ ( Harchavar man I ) បុត្រាទី ២ ព្រះនាមថា ឥសានវរ្ម័ន ២ ( Icanavarman II ) ។ អ្នកស្នងរាជទីមួយបានចាប់ផ្តើមនៅឆ្នាំ ៩១២ ការស្នងរាជ្យទី ២ ក៏បានបញ្ចប់នៅឆ្នាំ ៩២៨ ។

យើងពុំបានដឹងពីអ្វីទេ នៅក្នុងការឡើងគ្រងរាជ្យសម្បត្តិរបស់បុត្រទាំងពីរអង្គនេះ ។ សិលាចារឹកនៅប្រាសាទបក្សីចាំក្រុង បានធ្វើការលើកសរសើរដល់ព្រះបាទ ហរសវរ្ម័ន ពណ៌នាថា " ភាពទន់ភ្លន់នៃក្បាច់គុណងារ ពន្លឺដែលភ្លឺជាឆព្វណ្ណរង្សី ភាពប្រិតប្រៀននៃការធ្វើតបធម៌ ភាពរវាសរវៃ នៃការបំរើដល់បុគ្គលដទៃ បានបញ្ចេញអោយឃើញច្បាស់ថា ព្រះអង្គគឺជាវីរៈបុរសមួយរូប " ។ អត្ថបទដដែលគ្នា ហើយល្បីល្បាញបំផុតនោះបាននិយាយថា " ប្អូនប្រុសរបស់ព្រះអង្គ ដែលប្រសូត្រចេញមកពីម្តាយតែមួយដូចគ្នាឈ្មោះ ស្រីឥសាន Varman ( Çri Içanavarman ) គឺមានជ័យជំនះជានិច្ច ជាមនុស្សសំបូរស្នេហ៍ដោយសារតែសំរស់របស់គេ ហើយចេះយ៉ាងច្បាស់នូវគ្រប់សិល្បៈទាំងអស់ផង " ។

នៅឆ្នាំ ៩២១ ឪពុកមាម្នាក់របស់ស្តេចទាំងពីរអង្គនេះ ដែលនៅពេលអនាគតជា ជ័យវរ្ម័ន ទី ៤ បានចាកចេញពីធានី យសោធរបុរៈ ឆ្ពោះទៅ ជក់ហ្គារក្យារ ( Chor Gargyar ) ដែលស្ថិតនៅរមណីយដ្ឋានកោះកេរ្តិ៍ចំងាយប្រហែល ១០០គម ពីធានីអង្គរ ។ គេបានគិតថាស្តេចអង្គនេះ មានគោលបំណងមួយដោយប្រុងធ្វើការដណ្តើមរាជ្យ ហើយចាប់ពីឆ្នាំ ៩២១ មក មានការបាក់បែកគ្នាមួយ នៅរាជាណាចក្រ ហើយព្រះបាទជ័យវរ្ម័នក៏បានឡើងគ្រងរាជ្យនៅកោះកេរ្តិ៍ ក្នុងខណៈពេលដែលព្រះបាទ Harshavarman រួចព្រះបាទ Icanavarman កំពុងតែសោយរាជ្យបន្តគ្នានៅរាជធានី យសោធរបុរៈ ។ ក្នុងពេលនេះមានអត្ថបទសិលាចារឹកជាច្រើន បាននិយាយថាព្រះបាទជ័យវរ្ម័ន បានធ្វើជាអ្នកជ្រែករាជ្យសម្បត្តិ ។ សិលាចារឹកនៅប្រាសាទបក្សីចាំក្រុង ក៏បាននិយាយពាក្យពីរបីម៉ាត់យ៉ាងសាំៗថា ៖

" ភាពឆ្លាតវៃរបស់ព្រះបាទ ស្រីជ័យវរ្ម័ន មានការច្រឡោតដោយពាក្យថាស្រី ( Çri ) ហើយក៏បានសាងរាជធានីតាមភាពខ្លាំងរបស់គេ រួចក៏បានឡើងរាជដោយច្រានចោលពាក្យ ស្រី នៃ ពិភពចិ " ។

សិលាចារឹកនៅស្តុកកក់ធំ បាននិយាយយ៉ាងច្បាស់ថា ការតាំងទីលំនៅ នៅកោះកេរ្តិ៍ ហើយនិងការផ្លាស់ប្តូរទីតាំងនៃតំបន់នេះរបស់ Kamrateng jagat taraja ប៉ុន្តែគេមិនបានបញ្ជាក់អំពីកាលបរិច្ឆេទអោយបានច្បាស់លាស់ទេ ។ មានសិលាចារឹកមួយផ្សេងទៀត ដែលបានសរសេរអំពីព្រឹត្តិការណ៍របស់ព្រះបាទជ័យវរ្ម័នទី ៤ ក្នុងឆ្នាំ ៩២៨ ។ មានរឿងអ្វី តើអ្នកណាជាអ្នកបញ្ចប់រាជរបស់ព្រះបាទ Icanavarman ហើយប្រអូសប្រទាញអោយចាកចោលប្រាសាទទាំងឡាយនៅធានីអង្គរ។

ក្នុងអំឡុងពេល ១៨ឆ្នាំ ក្រោយពីការសោយទិវង្គត់របស់ព្រះបាទយសោវរ្ម័ន នៅធានីអង្គរមានសំណង់យ៉ាងសំខាន់ ២ បានត្រូវសាងឡើង គឺប្រាសាទបក្សីចាំក្រុង និង ប្រាសាទក្រវ៉ាន់ ។ សំណង់នេះស្ថិតនៅខាងជើងបន្តិច ជាប់នឹងជើងភ្នំបាខែង ។

តួប្រាសាទបក្សីចាំក្រុង គេមិនយកទៅប្រៀបធៀបនឹងប្រាសាទធំៗរបស់ព្រះបាទ យសោវរ្ម័នបានទេ ។ ប្រាសាទនេះបានត្រូវសាងឡើងដោយព្រះបាទ Harshavarman ទី ១ ដើម្បីឧទ្ទិសទៅដល់ព្រះមាតា ព្រះបិតារបស់ព្រះអង្គ ។ ប្រាសាទបានសាងឡើងមានតួប្រាសាទតែមួយ នៅលើគ្រឹះមួយខ្ពស់រាងជាថ្នាក់ៗ ។ វាគឺជាសំណង់មួយ ដែលរួមតូចនៅផ្នែកខាងលើមានសមាមាត្រល្អ ប្រកបដោយសុខដុមហើយជានិច្ចកាលឥដ្ឋ និង ថ្មបាយក្រៀមមានពណ៌ឆ្អិនឆ្អៅ ( ដូចនេះ ) បានលេចចេញមកបង្ហាញខ្លួននៅចន្លោះដើមឈើទាំងឡាយ ដែលមានពណ៌ខ្ចី ។ សិលាចារឹកដែលដាក់នៅពីក្រោមមេទ្វារខាងស្តាំនៃប្រាសាទនេះបានបញ្ជាក់ថា ព្រះបាទ Harshavarman បានសាងរូបចំលាក់របស់ព្រះអង្គផ្ទាល់ អំពីមាសក្រោមរូបភាពជាព្រះសិវៈ ដាក់នៅក្នុងប្រាសាទ គឺមានន័យថាជារូបព្រះសិវៈ និង ភរិយា គឺនាងឧមា ។

សិលាចារឹកទាំងឡាយរបស់ប្រាសាទក្រវ៉ាន់ បានចុះកាលបរិច្ឆេទនៅឆ្នាំ ៩២១ ។ គឺជាប្រាសាទមួយដែលមាន ៥តួ ឬ ប្រាំប្រាសាទធ្វើអំពីដីឥដ្ឋដុតឆ្អិន ។ តួប្រាសាទកណ្តាល និង ប្រាសាទខាងជើងដែលនៅលើជញ្ជាំងផ្នែកខាងក្នុងមានលំអដោយក្បាច់ក្រឡោតទាប ឆ្លាក់ពីលើដុំឥដ្ឋតែម្តង ។ បើប្រៀបធៀបប្រាសាទក្រវ៉ាន់ទៅនឹងប្រាសាទនាងខ្មៅ ដែលជាប្រាសាទមួយស្ថិតនៅផ្នែកខាងត្បូងឈៀងខាងកើតប្រទេសកម្ពុជា ហើយមានកាលបរិច្ឆេទស្រករគ្នាដែរនោះ យើងឃើញថាប្រាសាទនេះ ក៏មានស្នាមគំនូរនៅលើជញ្ជាំងផ្នែកខាងក្នុង ហើយជាខ្សែរឿងរបស់ទេវកថាដូចគ្នា នឹងប្រាសាទក្រវ៉ាន់ដែរ ។

ប្រាសាទក្រវ៉ាន់ពុំមែនសាងឡើងដោយស្តេចគ្រប់គ្រងផែនដីទេ ប៉ុន្តែត្រូវបានសាងឡើងដោយមន្ត្រីអ្នកមានបណ្តាសក្តិជាច្រើនអ្នក ។ ដង្វាយដ៏សំខាន់ៗទាំងឡាយ ត្រូវថ្វាយដល់ប្រាសាទនោះដោយមន្ត្រីថ្នាក់ខ្ពស់មួយរូបឈ្មោះ មហីធរវរ្ម័ន ( Mahidharavarman ) ពិធីនេះត្រូវបានប្រារព្ធធ្វើឡើងនៅឆ្នាំ

នៅឆ្នាំ ៩២១ ឪពុកមាម្នាក់របស់ស្តេចទាំងពីរអង្គនេះ ដែលនៅពេលអនាគតជា ជ័យវរ្ម័ន ទី ៤ បានចាកចេញពីធានី យសោធរបុរៈ ឆ្ពោះទៅ ជក់ហ្គារក្យារ ( Chor Gargyar ) ដែលស្ថិតនៅរមណីយ៍ដ្ឋានកោះកេរ្តិ៍ចំងាយប្រហែល ១០០គម ពីធានីអង្គរ ។ គេបានគិតថាស្តេចអង្គនេះ មានគោលបំណងមួយដោយប្រុងធ្វើការដណ្តើមរាជ្យ ហើយចាប់ពីឆ្នាំ ៩២១ មក មានការបាក់បែកគ្នាមួយ នៅរាជាណាចក្រ ហើយព្រះបាទជ័យវរ្ម័នក៏បានឡើងគ្រងរាជ្យនៅកោះកេរ្តិ៍ ក្នុងខណៈពេលដែលព្រះបាទ Harshavarman រួចព្រះបាទ Icanavarman កំពុងតែសោយរាជ្យបន្តគ្នានៅរាជធានី យសោធរបុរៈ ។ ក្នុងពេលនេះមានអត្ថបទសិលាចារឹកជាច្រើន បាននិយាយថាព្រះបាទជ័យវរ្ម័ន បានធ្វើជាអ្នកជ្រែករាជ្យសម្បត្តិ ។ សិលាចារឹកនៅប្រាសាទបក្សីចាំក្រុង ក៏បាននិយាយពាក្យពិរបិម៉ាត់យ៉ាងសាំៗថា ៖

" ភាពឆ្លាតវៃរបស់ព្រះបាទ ស្រីជ័យវរ្ម័ន មានការច្រឡោតដោយពាក្យថាស្រី ( Çri ) ហើយក៏បានសាងរាជធានីតាមភាពខ្លាំងរបស់គេ រួចក៏បានឡើងរាជដោយព្រានចោលពាក្យ ស្រី នៃ ពិភពបី " ។

សិលាចារឹកនៅស្តុកកក់ធំ បាននិយាយយ៉ាងច្បាស់ថា ការតាំងទីលំនៅ នៅកោះកេរ្តិ៍ ហើយនិងការផ្លាស់ប្តូរទីតាំងនៃតំបន់នេះរបស់ Kamrateng jagat taraja ប៉ុន្តែគេមិនបានបញ្ជាក់អំពីកាលបរិច្ឆេទអោយបានច្បាស់លាស់ទេ ។ មានសិលាចារឹកមួយផ្សេងទៀត ដែលបានសរសេរអំពីព្រឹត្តិការណ៍របស់ព្រះបាទជ័យវរ្ម័នទី ៤ ក្នុងឆ្នាំ ៩២៨ ។ មានរឿងអ្វី គេអ្នកណាជាអ្នកបញ្ចប់រាជរបស់ព្រះបាទ Icanavar man ហើយប្រមូលប្រទាញអោយចាកចោលប្រាសាទទាំងឡាយនៅធានីអង្គរ។

ក្នុងអំឡុងពេល ១៨ឆ្នាំ ក្រោយពីការសោយទីវង្គត់របស់ព្រះបាទយសោវរ្ម័ន នៅធានីអង្គរមានសំណង់យ៉ាងសំខាន់ ២ បានត្រូវសាងឡើង គឺប្រាសាទបក្សីចាំក្រុង និង ប្រាសាទក្រវ៉ាន់ ។ សំណង់នេះស្ថិតនៅខាងជើងបន្តិច ជាប់នឹងជើងភ្នំបាខែង ។

តួប្រាសាទបក្សីចាំក្រុង គេមិនយកទៅប្រៀបធៀបនឹងប្រាសាទធំៗរបស់ព្រះបាទ យសោវរ្ម័នបានទេ ។ ប្រាសាទនេះបានត្រូវសាងឡើងដោយព្រះបាទ Harshavarman ទី ១ ដើម្បីឧទ្ទិសទៅដល់ព្រះមាតា ព្រះបិតារបស់ព្រះអង្គ ។ ប្រាសាទបានសាងឡើងមានតួប្រាសាទតែមួយ នៅលើគ្រឹះមួយខ្ពស់រាងជាថ្នាក់ៗ ។ វាគឺជាសំណង់មួយ ដែលរួមតូចនៅផ្នែកខាងលើមានសមាមាត្រល្អ ប្រកបដោយសុខដុម ហើយជានិច្ចកាលឥដ្ឋ និង ថ្មបាយក្រៀមមានពណ៌ឆ្អិនឆ្អៅ ( ដូចនេះ ) បានលេចចេញមកបង្ហាញខ្លួននៅចន្លោះដើមឈើទាំងឡាយ ដែលមានពណ៌ខ្ចី ។ សិលាចារឹកដែលដាក់នៅពីក្រោមមេទ្វារខាងស្តាំនៃប្រាសាទនេះបានបញ្ជាក់ថា ព្រះបាទ Harshavarman បានសាងរូបចំលាក់របស់ព្រះអង្គផ្ទាល់ អំពីមាសក្រោមរូបភាពជាព្រះសិវៈ ដាក់នៅក្នុងប្រាសាទ គឺមានន័យថាជារូបព្រះសិវៈ និង ភរិយា គឺនាងឧមា ។

សិលាចារឹកទាំងឡាយរបស់ប្រាសាទក្រវ៉ាន់ បានចុះកាលបរិច្ឆេទនៅឆ្នាំ ៩២១ ។ គឺជាប្រាសាទមួយដែលមាន ៥តួ ឬ ប្រាំប្រាសាទធ្វើអំពីដីឥដ្ឋដុតឆ្អិន ។ តួប្រាសាទកណ្តាល និង ប្រាសាទខាងជើងដែលនៅលើជញ្ជាំងផ្នែកខាងក្នុងមានលំអដោយក្បាច់ក្រឡោតទាប ឆ្លាក់ពីលើដុំឥដ្ឋតែម្តង ។ បើប្រៀបធៀបប្រាសាទក្រវ៉ាន់ទៅនឹងប្រាសាទនាងខ្មៅ ដែលជាប្រាសាទមួយស្ថិតនៅផ្នែកខាងត្បូងឈៀងខាងកើតប្រទេសកម្ពុជា ហើយមានកាលបរិច្ឆេទស្រករគ្នាដែរនោះ យើងឃើញថាប្រាសាទនេះ ក៏មានស្នាមគំនូរនៅលើជញ្ជាំងផ្នែកខាងក្នុង ហើយជាខ្សែរឿងរបស់ទេវកថាដូចគ្នា នឹងប្រាសាទក្រវ៉ាន់ដែរ ។

ប្រាសាទក្រវ៉ាន់ពុំមែនសាងឡើងដោយស្តេចគ្រប់គ្រងផែនដីទេ ប៉ុន្តែត្រូវបានសាងឡើងដោយមន្ត្រីអ្នកមានបណ្តាសក្តិជាច្រើននាក់ ។ ដង្វាយដ៏សំខាន់ៗទាំងឡាយ ត្រូវថ្វាយដល់ប្រាសាទនោះដោយមន្ត្រីថ្នាក់ខ្ពស់មួយរូបឈ្មោះ មហីធរវរ្ម័ន ( Mahidharavarman ) ពិធីនេះត្រូវបានប្រារព្ធធ្វើឡើងនៅឆ្នាំ

កេរ្តិ៍មរតករបស់ភវបុរៈ បានកើតចេញមកពីបិតារួមជាមួយមាតារបស់ព្រះអង្គ បានបង្កើតព្រះបាទ Rajen dravarman ឡើង ដែលជាអំណោយនៃការរួបរួម នៃអាណាចក្រទាំងពីរ ហើយវាគឺជាសុបិន្តរបស់ពុញ្ញធិការី តាំងពីរជ្ជកាលព្រះបាទជ័យវរ្ម័នទី ២ មកម្លេះ ។

មានសិលាចារឹកជាច្រើននៅក្នុងរជ្ជកាលព្រះបាទ Rajendravarman ដែលសរសេរប្រជែងសរសើរសំរាប់ជាអំនួត ។ សិលាចារឹកនៅប្រាសាទបក្សីចាំក្រុង មានអំនួតថា " សំរាប់គួរអោយស្នេហា " របស់ស្តេចអង្គនេះ " ពិតពលោកបានច្រៀងថា គុណធម៌កើតឡើងហើយ " ។

ចាប់តាំងពីពេលនេះមក ព្រឹត្តិការណ៍របស់Rajendravarman បាននាំត្រលប់ទៅកាន់ធានីអង្គរវិញ ដើម្បីជំនួសនូវការគ្រប់គ្រងរបស់ឪពុកមាព្រះអង្គ គឺព្រះបាទយសោវរ្ម័ន ។ សិលាចារឹកមួយបានធ្វើរបាយការណ៍ពី " ការរៀបចំធានីយសោធរបុរៈ " អោយមានសុក្រិតភាពឡើងវិញ ក្រោយពីធ្លាក់ទៅក្នុងភាពរីកររអស់រយៈកាលជាច្រើនឆ្នាំ " ។

ព្រះអង្គរួមជាមួយនិងបណ្តាមន្ត្រីថ្នាក់ខ្ពស់ជាច្រើននាក់ទៀត បានមកតាំងទីលំនៅថ្មីនៅធានីអង្គរវិញ ។ ជំបូន្មានមួយ ក្នុងចំណោមជំបូន្មានជាច្រើនរបស់ស្តេច ព្រាហ្មសិវាចារិយា ( Çivacharya ) បានចាប់ផ្តើមពីសេរីភាពយ៉ាងពេញលេញរបស់លោកក្រោមនាមជា Içanavarman II ។ មនុស្សម្នាក់ទៀត ដែលយើងពុំបានស្គាល់ពីប្រវត្តិនោះឈ្មោះថា រាជកុល មហាមន្ទ្រិន ( Rajakula Mahamantrin ) គឺជាអ្នកធ្វើនយោបាយនៅក្នុងប្រទេស ។ គាត់បានតាមបំរើព្រះបាទ Rajendravarman រហូតហើយក៏បានរក្សាទុកនូវមុខតំណែងនេះ រហូតដល់មានស្តេចថ្មីសោយរាជ្យបន្តទៀត ។ មនុស្សទី ៣ ឈ្មោះ កវីន្ទ្រារីមថនៈ ( Kavindrarimathana ) ជាអ្នកកាន់ព្រះពុទ្ធសាសនា គឺគាត់នេះហើយ ដែលស្តេចបានទុកចិត្តប្រគល់អោយទទួលការសាងសង់ នូវសំណង់ជាច្រើននៅក្នុងរាជវាំង ហើយ និង ប្រាសាទមេបុណ្យខាងកើត ។ នៅចុងបញ្ចប់នៃរាជស្តេចអង្គនេះ មានលេចចេញនូវមន្ត្រីថ្នាក់ខ្ពស់ម្នាក់ទៀត គឺព្រាហ្ម យជ្ញាវរាហ ( Yajnavaraha ) បានរៀបការជាមួយនិងរាជវង្សានុវង្សស្តេច ហើយក្រោយមកក៏បានដើរតួជាមនុស្សដ៏សំខាន់ម្នាក់ ។ ពពួកមនុស្សទាំងអស់នេះ ជាមនុស្សដែលគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន និង ជាអ្នកផ្តើមគំនិតរុះរើក្នុងគ្រួសាររាជវង្ស ។ នៅតាមប្រាសាទជាច្រើន ដែលគេបានស្ថាបនាសិលាចារឹកក៏បានបញ្ចេញអោយឃើញអំពីភាពសំបូរបែបរបស់ពួកគេ ។ មានសំណង់មួយដែលជាសំណង់របស់មន្ត្រីថ្នាក់ខ្ពស់ម្នាក់ឈ្មោះ Yajnavaraha បានសាងប្រាសាទមួយដ៏ល្អឯកនៅឆ្នាំ ៩៦៧ នៅលើរមណីយដ្ឋានបន្ទាយស្រី ។

៣- <u>សំណង់របស់ស្តេចជាំខ្សោយនៅធានីអង្គរក្រោយរាជស្តេចរ៉ាជេន្ទ្រវរ្ម័នទី ២</u> (944-968 ) :

ក្នុងការកសាងទីលំនៅ នៅទីនេះព្រះបាទរ៉ាជេន្ទ្រវរ្ម័ន បានខំប្រឹងប្រែងទៅតាមគោលបំណងពីររបស់ព្រះអង្គ ៖ ទី ១ ព្រះអង្គបានដើរតួនាទីជាបុត្រដ៏ល្អរបស់ខ្សែរាជវង្ស ។

ទី ២ ព្រះអង្គបានរួមរិតឡើងវិញ នូវចំណងរវាងរាជវង្សយសោវរ្ម័ន ហើយ និង សន្តតិវង្សអង្គរ ។

នៅអំឡុងឆ្នាំ ៩៤២ ព្រះបាទ Harshavarman បានសាងប្រាសាទបក្សីចាំក្រុង " ដើម្បីបង្កើតធម៌ ( Dhama ) អោយដល់ព្រះមាតាព្រះបិតារបស់ព្រះអង្គ " ។ សិលាចារឹកដែលចុះនិទ្ទេសអោយ រ៉ាជេន្ទ្រវរ្ម័នថា " ស្តេចអង្គនេះជាស្តេចមួយអង្គដ៏ចំណាន ដែលមាននិស្ស័យពីធម្មជាតិ ហើយជាមនុស្សដែលជិតស្និតនឹងអទិទេព បានសាងរូបចំលាក់បរមេស្វរៈ ( Paramecvara ) មួយអង្គ អំពីមាស ដែលគ្មានអ្នកណារកប្រដូចបាននោះ បានយកទៅធ្វើពិធីអភិសេកនៅក្នុងប្រាសាទមួយ ដែលលំអដោយកំបោរបាយអ"។ គេបានចោទសួរថា ប្រសិនបើព្រះបាទរ៉ាជេន្ទ្រវរ្ម័នបានសាងប្រាសាទ ដែលបច្ចុប្បន្នត្រូវអភិសេកនៅលើ

ត្រិះរបស់ប្រាសាទបក្សីចាំក្រុង ឬ មួយក៏ព្រះអង្គបានយកកំបោរបាយអទៅលំអលើប្រាសាទនេះតែបន្តិចបន្តួចប៉ុណ្ណោះ ។ លោក G-Coedès ក៏បានបញ្ចេញនូវសមត្ថកម្មទីមួយរបស់គាត់ ។ តាំងពីពេលនោះ លោក Boisselier បានពិនិត្យអំពីតួប្រាសាទនោះ បាននិយាយថាការតុបតែងនៃក្បាច់លំអលើប្រាសាទនេះ គឺធ្វើឡើងដំណាលគ្នា នឹងការកសាងត្រិះ ហើយនិងតួប្រាសាទទាំងមូល ឯការលំអដោយវត្ថុបន្សំកំបោរបាយអ ដោយពាសប៉ាតកំបោរបាយអនៅលើតួប្រាសាទបក្សីចាំក្រុង ដែលបន្តពីលើត្រិះរាងពីរ៉ាមីឌរាងជាថ្នាក់ៗ ឯព្រះបាទរ៉ាជេន្ទ្រវរ្ម័ន បានប្រៀបប្រដូចតួប្រាសាទនេះទៅនឹងភ្នំកៃលាស ( Kailasa ) ពន្លឺនៃភ្នំកៃលាសបានស្ថិតនៅវែងឆ្ងាយ ហើយពន្លឺចាំងចែងនៃព្រះសិវៈ និង ឧមា ហើយរូបទាំងនេះ ត្រូវបានអភិសេកដោយព្រះបាទ Harshavarman ។ ដើម្បីស្រោច ស្រង់ប្រទេសឡើងវិញ ព្រះបាទរ៉ាជេន្ទ្រវរ្ម័នបានចាប់ផ្តើមកសាងមួយតាំងពីដើមរាជរបស់ព្រះអង្គ ហើយ ក៏បានចាប់ផ្តើមពីសម្ព័ន្ធភាពទំនៀមទំលាប់ខ្លះដែលបានធ្វើឡើងដោយព្រះបាទ យសោវរ្ម័ន ហើយត្រូវ អាក់ខានអស់មួយរយៈពេលកន្លងមក ។

សំណង់ទីមួយរបស់យសោវរ្ម័ន គឺប្រាសាទលលៃជាសំណង់មួយ ដើម្បីឧទ្ទិសទៅដល់បុព្វបុរសរបស់ព្រះអង្គ ហើយប្រាសាទនេះត្រូវសង់នៅចំកណ្តាលបារាយណ៍ ឥន្ទ្រតដាក ( Indratataka ) ជាបារាយណ៍ដែលបានជីកដោយ ឥន្ទ្រវរ្ម័ន ( Indravarman ) ឯសំណង់ទី ១ ដែលរៀបចំកសាងឡើងដោយព្រះបាទរ៉ាជេន្ទ្រវរ្ម័ន ( Rājendravarman ) នោះ គឺជាប្រាសាទមេបុណ្យខាងកើត ដែលជាសំណង់សំរាប់ឧទ្ទិសទៅបុព្វបុរសរបស់ព្រះអង្គ ដោយសាងនៅចំកណ្តាលបារាយណ៍យសោធរៈតដាក ឬ ឈ្មោះបារាយណ៍ខាងកើត ។ ប្រសិនបើប្រាសាទមេបុណ្យដូចប្រាសាទលលៃវិញ រូបរាងនៃកោះមួយនៅចំកណ្តាលបារាយណ៍ដែលគេបានជីកនេះ គឺជានិន្នាការនៃប្រាសាទ ២ ដែលដូចគ្នា ។ ប្រាសាទលលៃគឺជាក្រុមនៃតួប្រាសាទ ៤ សង់នៅលើត្រិះតែមួយ ឯប្រាសាទមេបុណ្យខាងកើតមាន ៥ តួតំរៀបគ្នាជាចំណិតត្រសក់ នៅលើទីទួលរាបស្មើមួយ ។ ការធ្វើបៀបនេះ គឺជាការបួងសួងដល់ប្រាសាទភ្នំបាខែង ។ ក៏ប៉ុន្តែប្រាសាទភ្នំបាខែង គឺជាប្រាសាទអំពីថ្មភក់ ឯប្រាសាទមេបុណ្យ គឺជាសំណង់អំពីឥដ្ឋដុតឆ្អិនហើយសង់នៅលើត្រិះអំពីថ្មបាយក្រៀម ។ រជ្ជកាលព្រះបាទរ៉ាជេន្ទ្រវរ្ម័ន បានត្រូវគេកត់សំគាល់ដោយការយកដីឥដ្ឋដុតឆ្អិនសង់ប្រាសាទ ដោយបូកពាសដោកកំបោរបាយអវិញ ។ ការតុបតែងលំអរ គឺអំពីកំបោរបាយអ ប៉ុន្តែមានតែមេទ្វារ ឬ ស៊ុមបង្អួចទេ ដែលត្រូវឆ្លាក់អំពីថ្មភក់ ។

តួប្រាសាទ ២ ក្នុងចំណោមតួទាំង ៥ របស់ប្រាសាទមេបុណ្យ ត្រូវបានឧទ្ទិសដល់ព្រះមាតាព្រះបិតារបស់ស្តេច ក្រោមរូបភាពជាព្រះសិវៈ និង នាងឧមា ។ តួប្រាសាទកណ្តាល ហើយនិងតួប្រាសាទពីរទៀត នៅតាមមុំ ( ជ្រុង ) ជាតួដែលឧទ្ទិសដល់អទិទេព ៣ ( Trimuti ) នៅកណ្តាលគឺជាលិង្គឈ្មោះ RAJENDREÇVARA ហើយបានតំកល់នៅពីលើរូប ៤ ផ្សេងទៀត ។ នៅចំកណ្តាលទឹកនៃបារាយណ៍ខាងកើត ប្រាសាទមេបុណ្យគឺជាប្រាសាទ ១ ដែលមានសំរស់យ៉ាងល្អ ដោយនៅតាមជ្រុងមានលំអដោយសត្វដំរីអំពីថ្មភក់ ដើម្បីបញ្ចប់នូវការតុបតែងលំអអំពីកំបោរបាយអនេះ ។ លិង្គទាំងឡាយស្ថិតនៅក្នុងកន្លែងមួយ ដែលមានវិសាលភាពបំផុត គឺនៅលើឌីខ្ពស់មានបន្ទប់វែងលាតសន្ធឹងលើខ្សែផ្តេកដែលដូចគ្នាស្រលះពីជណ្តើរត្រង់ឆ្ពោះទៅលើ ហើយនិងប្រាសាទដែលមានកំពូលស្រួច ។ វាជាការល្អណាស់ ដោយប្រៀបស្ថានទំហំរបស់ប្រាសាទប្រែរូបសាងក្នុងឆ្នាំ ៩៦១ ជាប្រាសាទគួរអោយសរសើរដូចគ្នា និង ប្រាសាទមេបុណ្យដែរ ។ ត្រិះរាងជាពីរ៉ាមីឌដែលទ្រនោះមានកំពស់ ១២ម ហើយកំពូលរបស់វាគឺជាប្រាសាទប្រាំសង់តំរៀបគ្នា ជារាងចំណិតត្រសក់ ( enquinconce ) តាមប្លង់លើនៃតួប្រាសាទធំកណ្តាល ។ សំរាប់ការសាងសង់ប្រាសាទប្រែរូប គឺគេក៏យកថ្មបាយក្រៀម ដីឥដ្ឋដុតឆ្អិន ហើយនិងគ្រឿង

ប្ចូកពាសដោយកំបោរបាយអយកមកលំអដូចប្រាសាទមេបុណ្យដែរ ។ សារធាតុនៃរចនាបថចន្លោះនៃសំណង់ទាំងពីរនេះ គឺជារយៈពេលមួយខ្លីណាស់ ប៉ុន្តែបែរជាមានសមាសភាព និង និន្នាការផ្ទុយគ្នាទៅវិញ ។

ប្រាសាទប្រែរូបពុំមែនជាសំណង់មួយ ដែលជំនួសអោយភ្នំបាខែង ប្រាសាទធំនៅកោះកេរ្តិ៍ទេ គឺជាប្រាសាទមួយសំរាប់ឧទ្ទិសទៅដល់យសោធរេស្វរៈ ( Yaçodhareçvara ) " ជាម្ចាស់របស់យសោធរៈ" ហើយនិងទ្រីភុវនេស្វរៈ ( Tribhuvaheçvara ) " ជាម្ចាស់នៃពិភពបី" ។ នៅប្រាសាទប្រែរូបគេបានរៀបចំអោយមានលទ្ធិថ្មី មានអនុភាពដល់លិង្គ Rajendrabhadreçvara ឬ ជា Bhadreçvara " ជាម្ចាស់នៃមានជោគជ័យ " គឺជាអទិទេពនៃវត្តភូ ដែលជាកន្លែងមួយខ្ពស់របស់សន្តតិវង្ស ។

គេបានទទួលស្គាល់ថា ប្រាសាទប្រែរូប បានត្រូវសាងសង់ឡើងនៅលើគ្រឹះដីហាប់មាំល្អ ហើយមានផ្លូវតូចព័ទ្ធជារបងផង ។ នៅលើទីលានបន្ទប់វែងទាំងអស់ សុទ្ធតែមានអត្ថប្រយោជន៍ជាងប្រាសាទមេបុណ្យ នៅមុខខាងកើតមានតួប្រាសាទប្រាំ សង់នៅពីក្រោមពីរ៉ាមីឌ ។ ប្រាសាទនេះរួមជាមួយពណ៌សម្បុរឆ្អិនឆ្អៅនៃគ្រឹះរបស់វា អំពីថ្មបាយក្រៀម ហើយនិងពណ៌ក្រហមរលីងនៃដីឥដ្ឋដុតឆ្អិនកាន់តែធ្វើអោយប្រាសាទនេះមានសំរស់ល្អ ហើយជាស្នាដៃស្ថាបត្យកម្មមួយឈ្នះគេនៅធានីអង្គរ ។ ស៊ុំទ្វារតូចៗ និងទ្វារបញ្ឆោតធ្វើអំពីថ្មភក់ពណ៌បៃតងភ្លាវ ហើយគេបានឆ្លាក់វាដោយការប្រុងប្រយ័ត្នជាទីបំផុត ។ នៅលើជញ្ជាំងរបស់តួប្រាសាទពីរ បី នោះមាននៅជាប់ដុំកំបោរបាយអ ដែលប្រគោងជាប់ទៅនឹងដីឥដ្ឋ គឺជារូបអទិទេពស្រីរាងស្គម ហើយសង្ហាជាងរូបចំលាក់នៅប្រាសាទភ្នំបាខែង តែមិនបានបោះបង់ចោលនូវតួនាទីជាអ្នកថែរក្សាតួប្រាសាទដែរ ។

នៅចន្លោះឆ្នាំ ៩៥៧ និង ៩៦១ នៅក្នុងពេលជាមួយនោះ ព្រះបាទរ៉ាជេន្ទ្រវរ្ម័ន បានសាងសំណង់ដ៏ធំមួយនៅខាងកើតក្រុងយសោធរបុរៈ រួចបានធ្វើជាព្រះមហរាជវាំងតែម្តង ។ គឺជាសម័យកាលនោះហើយ ដែលជាកាលបរិច្ឆេទទី ១ នៃស្ថានភាពប្រាសាទវិមានអាកាស ជាឈ្មោះនៃវាំងនៅឋានសួគ៌ ដែលបានកើតឡើងជាស្រេចហើយ នៅផ្នែកខាងក្នុងនៃកំពែងខ្លាំង ។ ដូច្នេះប្រាសាទវិមានអាកាសពុំមានថែវទេ គឺសង់នៅលើទីលានរាងជាពីរ៉ាមីឌធ្វើអំពីថ្មបាយក្រៀម ដោយសារមានការផ្គុំឡើងនៃពីរ៉ាមីឌធ្វើអោយប្រាសាទនេះមានលក្ខណៈដូចគ្នាទៅនឹងប្រាសាទប្រែរូប ប៉ុន្តែនៅតាមជ្រុងវិញ មានយាមដោយសត្វដំរីដូចប្រាសាទមេបុណ្យទៅវិញ ។ ក្នុងអំឡុងពេលនៃសម័យកាលនោះ ព្រះបរមរាជវាំង គឺជាដំណែលទីក្រុងចាស់ ដែលស្តេចជាច្រើនអង្គបានរក្សាទុកអស់រយៈពេលដ៏យូរ ដែលស្តេចទាំងអស់បានគង់ប្រថាប់នៅធានីអង្គរ ។

## ៤- <u>សំណង់ដែលសង់ដោយមន្ត្រីធំខាងឡាយនៅក្រោមរាជ្យព្រះបាទរ៉ាជេន្ទ្រវរ្ម័ន</u> :

នៅក្នុងពេលពាក់កណ្តាលសតវត្សទី ១០ នេះ ស្តេចពុំមែនជាអ្នកបានកសាងសំណង់ទាំងអស់នោះតែមួយព្រះអង្គឯងទេ ។ មានសំណង់សំខាន់ៗជាច្រើន ដែលត្រូវបានកសាងឡើងដោយស្នាដៃនៃឥស្សរៈជនជាន់ខ្ពស់ជាច្រើននាក់ ។ មានប្រាសាទបីនៃប្រាសាទទាំងនោះជាសំណង់នៅក្នុងធានីអង្គរ ។ សំណង់ទី ១ ដែលបានសាងឡើងនៅក្នុងរាជស្តេចអង្គនេះ នៅធានីអង្គរនោះ គឺជាប្រាសាទរបស់ព្រះពុទ្ធសាសនាឈ្មោះបាតជុំ ។ ប្រាសាទនេះសាងឡើងនៅឆ្នាំ ៩៥៣ ដោយមន្ត្រីឈ្មោះ កវីនទ្រារិនថន ( Kavindrarinathana ) ជាជនមួយរូប ដែលព្រះបាទរ៉ាជេន្ទ្រវរ្ម័នអោយទទួលបន្ទុកជាអ្នកសាងសង់រាជវាំង និង ប្រាសាទមេបុណ្យ ។ ទោះបីយ៉ាងណាក៏ដោយក៏ការកសាងវត្តព្រះពុទ្ធសាសនាត្រូវគេបានស្គាល់នៅធានីអង្គរ ការពិតនៃឱនភាពមួយ កើតមានក្នុងអំឡុងសតវត្សទី ៩ រហូតដល់សតវត្សទី ១០ ។

មានសិលាចារឹកមួយ នៅចុងសតវត្សទិ ១០ បានបញ្ជាក់ប្រាប់ថា ឥឡូវនេះព្រះពុទ្ធសាសនាបានកើតមានវិញហើយ ហើយសិលាចារឹកនេះក៏បាននិយាយបន្ថែមទៀតថា គេបានធ្វើការជួសជុលរូបដែលបាក់ទៅ ហើយនិងការបង្កើតវត្តឡើងវិញ ។ ប្រាសាទតូចបាតជុំ បានត្រូវជ្រែកដោយតួប្រាសាទ ៣ មានរូបព្រះពុទ្ធ ហើយក៏មានរូបនៃអទិទេពដែលជាព្រះពុទ្ធពីរទៀត នៃពុទ្ធសាសនាមហាយាន ( Mahayanique )។

មានប្រាសាទពីរទៀត ដែលសាងសង់ដោយឥស្សរៈជនជាន់ខ្ពស់ ហើយបានចុះកាលបរិច្ឆេទ នៅចុងបញ្ចប់នៃរាជស្តេចអង្គនេះ ប្រាសាទទាំងពីរនេះ ជាប្រាសាទសំរាប់ព្រហ្មញ្ញសាសនា ។ ទី ១ គឺ ប្រាសាទបន្ទាយស្រី ដែលជាប្រាសាទតែមួយគត់ ដែលមានឈ្មោះល្បីនៅក្នុងក្រុមប្រាសាទអង្គរ ត្រូវបានសាងឡើងនៅក្នុងឆ្នាំ ៩៦៧ ដោយព្រាហ្មណ៍ យជ្ញាវ៉ារ៉ាហ ( Yajnavaraha ) ហើយគាត់ក៏បានសាងប្រាសាទព្រះឥន្ទ្រកោសីយ៍មួយទៀត ស្ថិតនៅខាងឆ្វេងស្ទឹងសៀមរាប ដែលស្ថិតនៅក្រោមរាជស្តេចក្រោយមកទៀត ។ ប្រាសាទនេះកសាងឡើងមានតួប្រាសាទពីរ អំពីឥដ្ឋ ក្នុងឆ្នាំ ៩៦៨ គឺជាឆ្នាំមួយជាមួយគ្នានិងការចូលទិវង្គត់របស់ព្រះបាទរ៉ាជេន្ទ្រវរ្ម័ន ហើយនិងការរៀបអភិសេកនៃបុត្រីរបស់ព្រះអង្គជាមួយនឹងព្រាហ្មណ៍ ឌិវ៉ាករភត្ត ( Divakarabhatta ) មកពីប្រទេសឥណ្ឌា ។

សំណង់ទាំងឡាយរបស់ឥស្សរៈជនជាន់ខ្ពស់ គឺជាការបញ្ជាក់សំរាប់ជាការចង់ដឹងអំពីធានីអង្គរ ប៉ុន្តែវាបានបង្ហាញនៅក្បែរៗរាជស្ថាបត្យកម្មប្រាសាទមានការខុសប្លែកគ្នា ហើយសិលាចារឹកក៏បានបញ្ជាក់ប្រាប់យើងយ៉ាងពិតប្រាកដផងដែរ អំពីការគ្រប់គ្រងសង្គម និង តុលាការនៃប្រទេសកម្ពុជា នាសម័យកាលនោះ ។ សិលាចារឹកនេះ ក៏បានដំណាលប្រាប់ផងដែរ អំពីសេចក្តីនៃការបញ្ជូនទំរោះការបរិចាក ឬ ការមូលទទួលយកមតិក ហើយនិងសេចក្តីសំរេចចិត្តតែងតាំងនៃត្រកូលរបស់សន្តតិវង្ស ។

៥- ចុងបញ្ចប់នៃរាជព្រះបាទរ៉ាជេន្ទ្រវរ្ម័នទី ២ :

ព្រះបាទរ៉ាជេន្ទ្រវរ្ម័នទិ ២ បានសោយទិវង្គត់នៅឆ្នាំ ៩៦៨ ក្រោយពីរាជបល្ល័ង្កបានត្រូវធ្លាក់ទៅក្នុងកណ្តាប់ដៃនៃពួកចាម ។ នៅពេលមានការពតត្បាតពីពួកចាម ហើយបានប្រមូលយកនូវបដិមាករមាសរបស់ប្រជាជនខ្មែរពីពោធិនគរទៅញ៉ាក្រុង ។ ការចូលទិវង្គត់របស់រ៉ាជេន្ទ្រវរ្ម័នទិ ២ នោះ ព្រះអង្គផ្ទេរអំណាចទៅអោយបុត្រារបស់ព្រះអង្គ គឺជ័យវរ្ម័នទិ ៥ ( Jayvarman V ) គឺជាស្តេចក្មេងជាងគេ ហើយប្រហែលជាមានបុត្រាមួយអង្គផង ។

៦- ព្រឹត្តិការណ៍របស់ជ័យវរ្ម័នទី ៥ :

" នៅពេលនោះ មានបុត្រាមួយអង្គរបស់ព្រះបាទស្រីរ៉ាជេន្ទ្រវរ្ម័ន ជាផ្កាឈូកដែលអណ្តែតនៅលើទឹកនៃឋានសួគ៌ អម្បូរស្តេចនេះ គឺជាស្តេចនៃជ័យជំនះ Çri Jayavarmadeva " ។ ស្តេចអង្គនេះបានឡើងគ្រងរាជ្យសម្បត្តិនៅធានីអង្គរ ក្នុងឆ្នាំ ៩៦៨ គឺបានកត់ត្រាទុកនៅក្នុងសិលាចារឹករបស់ប្រាសាទ ( Komphus ) ( កំផុស ) " សម្បុរស្គាំតក្មេង ព្រះនេត្រទាំងគូដូចផ្កាឈូក និង ជើងទាំងពីរសំគាល់ជាផ្កាឈូក មានដៃសំគាល់ជាកងចក្រ ពោរពេញទៅដោយទេពកោសល្យ ដែលពេលរៀលដោយកំហឹងស្រី " ។

បើតាមសិលធម៌ផ្ទៃមុខពុំមែនជាមនុស្សបញ្ចេញយកផលប្រយោជន៍ទេ ភាពពិតនៃគុណសម្បត្តិនៃព្រេងសំណាង ដែលជានិស្ស័យពីធម្មជាតិ នៃប្រាជ្ញាបារមីយ៉ាងល្អថ្លៃថ្លា ព្រះអង្គពន្លឺដូចព្រះវិស្ណុឯទៀតៗដែរ... ខ្លាំងក្លាហានគួរអោយចូលចិត្តនៅក្នុងវោហារ កោសល្យរបស់ព្រះអង្គទាំងឡាយ ។ គោលចារឹកនៅវត្តស៊ីធរ ដែលតំកល់នៅកន្លែងសិលបារមី " ប្រៀបបីដូចជាឪពុកដែលជាទីស្នេហា នៃកូនទាំង

ឡាយ ព្រះអង្គបានពង្រឹងនូវជាវរបស់ព្រះអង្គទាំងឡាយ ក្រោមប្រធានបទទុក្ខព្រួយ ដោយជាអ្នកបំរើអោយដៃទាំងទ្វេរបស់ព្រះអង្គ កាន់តែមានវិសាលភាពឡើង" ។

ថ្ងៃមុខដែលប្រកបដោយសីលធម៌ គឺស្ថិតនៅជាប់ជាមួយនិងគុណធម៌ នៃការគ្រប់គ្រងរបស់ព្រះអង្គ គឺធានាអោយមានសេរីភាព និង មានច្បាប់ទំលាប់ល្អប្រពៃនៅក្នុងរាជាណាចក្រ ។

ព្រះបាទជ័យវរ្ម័នទី ៥ ជាស្តេចមួយអង្គដែលក្មេងបំផុត ក្នុងអំឡុងពេលនៃព្រឹត្តិការណ៍របស់ព្រះអង្គ ។ មានមន្ត្រីជាន់ខ្ពស់ជាច្រើន ដែលដើរតួនាទីសំខាន់នៅក្រោមការដឹកនាំរបស់ព្រះបិតារបស់ព្រះអង្គនោះ នៅតែបន្តការងារដដែល ។ មានម្នាក់នៅក្នុងចំណោមមន្ត្រីទាំងនោះ ដែលយើងបានរកឃើញ គឺជាបងថ្លៃរបស់ស្តេចឈ្មោះ ព្រាហ្ម ដិវ៉ាករភត្ត ( Divakarabhatta ) ប៉ុន្តែគាត់ទទួលបានអំណាចច្រើនជាងព្រាហ្ម Yajnvaraha ( យជ្ញាវ៉ារ៉ាហៈ) ។ បុរសនេះជាកម្មសិទ្ធិនៃអភិជនាធិបតេយ្យជាន់ខ្ពស់នៃប្រទេសកម្ពុជា ដោយហេតុថា ម្តាយរបស់គាត់ជាបុត្រីរបស់ស្តេច ហរសវរ្ម័នទី ១ ( Harshavarman I ) ដែលបានរៀបការជាមួយនឹងព្រាហ្មម្នាក់ ។

៧- <u>ព្រាហ្មយជ្ញាវ៉ារ៉ាហៈ ( Yajnavaraha )</u> <u>អ្នកកសាងប្រាសាទបន្ទាយស្រី</u> :

បុរសរូបនេះ បានដាក់ឈ្មោះរបស់គាត់នៅក្នុងសំណង់ប្រាសាទបន្ទាយស្រី គឺជាព្រាហ្មដ៏ឆ្លាតវៃម្នាក់ ។ សិលាចារឹកនៅសេកតាទុយ បានអះអាងថា ក្រោមប្រធានបទ" ព្រាហ្មក្សត្រីយ៍ ( Kshatriya ) នេះឈ្មោះ យជ្ញាវ៉ារ៉ាហៈ ដែលបានដេញនូវជ្រុងមួយទៀត នៃវិទ្យាសាស្ត្រដែលគាត់ដាក់ចំណាងជើងអោយថា ជាគ្រូរបស់លិទ្ធិព្រះសិវៈ ហើយនិងជាព្រះរាជគ្រូទី ១ របស់ស្តេចខ្មែរ " ។ គឺជាពិតណាស់ដែលគាត់ឡើងគ្រប់គ្រងប្រទេសនៅក្នុងអំឡុងពេលដែលព្រះបាទជ័យវរ្ម័នទី ២ នៅក្មេងខ្ចីនៅឡើយ ។ " ដែលគាត់បានចុះហត្ថលេខាគ្រប់សារលិខិតទាំងអស់ " ។ ពេលនោះស្តេចបានក្លាយខ្លួនទៅជាមនុស្សម្នានឹងគេហើយ ដោយសារតែឥទ្ធិពលរបស់យជ្ញាវ៉ារ៉ាហៈ ដែលស្ថិតនៅជួយជាកំលាំង ជូទ្រនុះស្តេច " បានត្រូវជំរុញដោយព្រះរាជគ្រូ ដោយនៅក្នុងចិត្តទទួលទុកតែអ្វីដែលប្រព្រឹត្តិទៅដោយជោគជ័យ " បានប្រទានមកវិញនូវរាជបញ្ញាត្តិដែលគាត់បានអោយយោបល់ច្រើន ឬ តិច ។ គាត់មិនបានផ្តល់នូវអ្វីអោយភ្ញាក់ផ្អើលជាងគេ ដោយបានដើរតួនាទីជាមនុស្សសំខាន់នៅក្នុងរាជាណាចក្រ ដោយបានកសាងប្រាសាទបន្ទាយស្រីមួយដ៏ល្អឯក ។

ប្រាសាទបន្ទាយស្រី គឺជាប្រាសាទមួយល្អស្អាតជាងគេ នៅក្នុងក្រុមប្រាសាទអង្គរ ប្រាសាទនេះសាងនៅចំងាយ ៣០គម នាភាគខាងជើងឈៀងខាងកើតក្រុង ស្ថិតនៅក្បែរស្ទឹងសៀមរាប នៅក្នុងមជ្ឈមណ្ឌលមួយឈ្មោះឥស្វាបុរៈ ( Içvapura ) ឬជាធានី " នៃម្ចាស់ព្រះសិវៈ " ។ កសាងនៅក្នុងឆ្នាំ ៩៦៧ គឺនៅក្រោយពេលដែលព្រះបាទរ៉ាជេន្ទ្រវរ្ម័នសោយទីវង្គត់បានបន្តិច គឺបានន័យថាសង់រួចនៅក្នុងរាជរបស់ព្រះរាជបុត្រព្រះអង្គ ។ ប្រាសាទនេះឧទ្ទិសទៅដល់ព្រះសិវៈ ហើយគោរពចំពោះ ទ្រិភូវណាមហេស្វរៈ ( Tribhuvanamaheçvara ) " ជាម្ចាស់ធំជាងគេនៃភពទាំងបី " ។ នេះគឺប្រាសាទធ្វើអំពីថ្មភក់ពណ៌ក្រូឡាបដែលបង្ហាញពីភាពដោយឡែក និង មានសមាមាត្រនៃរាងប្រាសាទតូចៗ ដែលសង់នៅជិតនឹងតួប្រាសាទកណ្តាល ។ គេអាចចូលទៅកាន់តួប្រាសាទខាងក្នុងបានតាមទ្វារពីទិសខាងកើត ដែលទំហំនៃបន្ទប់អសនៈ នៃប្រាសាទក្នុងសម័យនោះ ត្រូវតែដើរឆ្លងកាត់កំពែងជាបន្តបន្ទាប់គ្នា គេឆ្លងកាត់បង្គោលព្រាំតូចៗដ៏ច្រើនម្តងមួយៗ ប្រសិនបើល្អគេទៅមុខតួកណ្តាល ហាក់បីដូចជាមិនដឹងខ្លួន ដែលនៅទីនោះគេត្រូវតែដើរឱនទើបបាន ។ ក្បាច់លំអតូចៗនេះ ជាការភ្ជាប់អោយឃើញពីភាពសំបូរបែប នៃគ្រឿងគុបតែងលំអ ដែលគេអាចនិយាយបានថា ប្រាសាទបន្ទាយស្រី គឺជាគ្រឿងអលង្ការមួយដ៏ល្អឯក ។

ប្រាសាទបន្ទាយស្រីជាសំណង់ដែលសង់តាមប្លង់មានខ្សែអ័ក្សនៅចំកណ្ដាល ដែលវែងចែកគ្រឿងសំណង់អោយស្មើគ្នាទាំងសងខាង ដោយនៅតាមជ្រុងនិមួយៗមានខ្សែអ័ក្សមួយទៅពុះក្លោងទ្វារ ( Gopura ) ខាងក្រៅនៃទិសខាងកើត ហើយកាត់តាមចន្លោះកណ្ដាលនៃក្លោងទ្វារខាងលិចចំពាក់កណ្ដាលដែរ ដោយឆ្លងកាត់បីចំណុចកណ្ដាល នៃតួប្រាសាទកណ្ដាល ។ ការធ្វើរបៀបនេះជាការខុសប្លែកពីប្លង់ប្រាសាទភ្នំ គឺប្រាសាទភ្នំបាខែង និង ប្រាសាទប្រែរូប ។

តួប្រាសាទកណ្ដាល មានសង់តួប្រាសាទពីរអមសងខាងទៀត ដែលធ្វើអំពីថ្មបាយក្រៀមរួមមានបន្ទប់មួយសំរាប់ធ្វើពិធីគោរពបូជា គឺជាប្លង់មួយ ដែលយកលំនាំតាមបែបភណ្ឌា តួទាំងនេះត្រូវសង់បន្ទើកពីលើទីលានមួយរួមមានកំពស់ ០.៩០ម ។ នៅខាងកើតទីលានមានសង់វិហារ ២ " បណ្ណាល័យ " មានសមាមាត្រគ្នាដោយអ័ក្សកណ្ដាលប្រាសាទ ហើយប្រហែលជានៅក្នុងបណ្ណាល័យនេះ គេរក្សាទុកនូវសៀវភៅ ឬ ក៏សំភារៈសំរាប់បំរើអោយដល់កិច្ចគោរពបូជា ។ គ្រប់សំណង់នៅកំពែងទីមួយ បានត្រូវដួលរលំអស់ ។ ប្រាសាទបន្ទាយស្រីព័ទ្ធជុំវិញដោយកំពែង ៤ជាន់ ហើយមានទ្វារចេញចូលនៅទិសខាងកើត និង ខាងលិច ។ វាដូចគ្នាទៅនឹងប្រាសាទខ្មែរទាំងអស់ ដែលទ្វារចេញចូលរបស់ប្រាសាទ តែងតាំងមានមណ្ឌបដែលគេអាចដាក់រូបធ្វើជាឆ្មាំ ។

ក្បាច់តុបតែងនៃប្រាសាទបន្ទាយស្រី មានទឹកដៃល្អប្លែកពីគេ ។ ថ្មភក់ពណ៌ក្លូឡាបអាចធ្វើអោយអ្នកឆ្លាក់មានភាពងាយស្រួល ដោយពន្លាកតូចៗសំរាប់ដាប់ឆ្លាក់ ។ សិល្បករទាំងឡាយបានលាយបញ្ចូលនៃក្បាច់តុបតែងលំអនេះ ដោយបានប្រមូលយកគ្រប់រូបទាំងអស់ ប៉ុន្តែវាបានបញ្ចូលនូវភាពទទួលបន្ទុកហួសប្រមាណ នៃផ្នែកសិល្បៈនៃក្បាច់ទាំងឡាយ ដែលរូបមនុស្សប្រុសទ្វារបាល ( Dvara pala ) ឬទេវរូបស្រី ជាទេវតា ( devata ) ក្រោមរូបភាពជាឆ្មាំ ត្រូវបានឆ្លាក់នៅលើជញ្ជាំងមានភាពជាមនុស្សក្មេងហើយសង្ហាណាស់ ។

នៅលើហោជាង នៃបណ្ណាល័យ និង ក្លោងទ្វារចូលមានលំអផ្ទាំងរូបភាពដែលដាក់ជំនួសដោយក្បាច់លំអនៃធម្មជាតិ ហើយនៅក្នុងនៃប្រាសាទមានពីមុន គេលំអដោយអទិទេពមានជីវិតពិត ។ នៅប្រាសាទបន្ទាយស្រី សំរាប់ដើមដំបូងនៃសតវត្សទី ១០ ក្រោមក្រសែភ្នែកនៃមនុស្សទាំងឡាយបានបង្ហាញអោយឃើញពីភាពប្លែកៗគ្នា នៃប្រាសាទនេះនូវការកំរើក ការសញ្ជឹងគិត ការប្រយុទ្ធតតាំង ឬ ក៏ការជ្រុលហួសទៅមុខនៅក្នុងព្រៃ ។ នៅលើផ្ទៃទាំងពីររបស់បណ្ណាល័យខាងត្បូង មានរូបអទិទេព ព្រះសិវៈបានគង់នៅលើភ្នំកៃលាស ដោយអង្គុយលើពីរ៉ាមីឧរាងជាថ្នាក់ៗ ជានិម្មិតរូបនៃអសនៈនៃប្រាសាទនិងនិម្មិតរូបនៃភ្នំ ។ នៅបណ្ណាល័យខាងជើង មានខ្សែរឿងមួយបង្ហាញអំពីព្រះឥន្ទ្រកំពុងសំដែងបដិហារអោយមានភ្លៀងផ្គរនៅលើព្រៃ ដែលធ្វើអោយពពួកមនុស្ស និង សត្វមានភាពសប្បាយរីករាយ ។ នៅលើបណ្ណាល័យដដែលនេះ នៅហោជាងខាងលិចបានបង្ហាញពីក្រឹសនៈកំពុងសំលាប់ស្ដេចកុំសៈ ( Kamsa ) នៅក្នុងវាំងរបស់ព្រះអង្គ ។ រូបដែលឆ្លាក់នៅលើប្រាសាទបន្ទាយស្រី បានបន្ថែមអោយមានសំរស់ទៅតាមបែបបទរបស់វា ហើយមានភាពសុខដុមរស់ នៃសិល្បៈខាងការតុបតែងមានតំលៃយ៉ាងជ្រៅ សំរាប់មនុស្សដោយភាពរស់ ដែលបានសាយចេញពីរូប ហើយនិងតាមរយៈភស្តុតាងដំបូង ដែលយើងបានរកឃើញពីជីវិតប្រជារាស្ត្រខ្មែរ នៅក្នុងសម័យពាក់កណ្ដាលទី ២ នៃសតវត្សទី ១០ ។

៤- រាជធានីអង្គរនៅចុងសតវត្សទី ១០ :

ព្រះបាទជ័យវរ្ម័ន បានគ្រងរាជ្យនៅធានីអង្គរ ដោយបានកសាងប្រាសាទនៅក្រៅធានីដែលបានបោះបង្គោលខណ្ឌសីមាដោយឪពុកមារបស់ព្រះអង្គ គឺយសោវរ្ម័ន ។ ការកសាងប្រាសាទ

វិមានអាកាស ដោយតាំងជាពជវាំងនៅក្នុងផ្នែកខាងជើងធានីយសោធរបុរៈ ។ ប្រាសាទវិមានអាកាសតាំងនៅលើអ័ក្សខាងជើងទៅត្បូងនៃធានីយសោធរបុរៈ ។ ទ្វារចេញចូលនៃរាជវាំង គឺជាសំណង់នៅក្នុងពាក់កណ្ដាលទី ២ នៃសតវត្សទី ១០ ដូច្នេះវាកើតក្រោយនៃស្នាដៃកសាងរបស់ព្រះអង្គ ។ នៅទល់មុខនឹងរាជវាំង គេបានសាងប្រាសាទពីរដូចគ្នា ស្ថិតនៅសងខាងផ្លូវ ដែលចេញពីវាំង គឺសំណង់ពីរល្វែងឈ្មោះថា ឃ្លាំងជើង និង ឃ្លាំងត្បូង ហើយនៅពីក្រោយប្រាសាទឃ្លាំងខាងជើង គេបានសាងប្រាសាទតូចមួយនៅក្នុងរចនាបថបន្ទាយស្រីរួចជាស្រេចហើយ ។

នៅសម័យកាលនោះ មានសំណង់ ៣ក្រុម កើតឡើងគឺ ៖ នៅចំកណ្ដាលនៃធានីយសោធរបុរៈទី ១ មានភ្នំបាខែង បក្សីចាំក្រុង និង ប្រាសាទបី នៅក្នុងប៉ែកខាងជើងរាជធានី រាជវាំង ហើយនិងប្រាសាទពីរ បីទៀត នៅជុំវិញទីវាលធំ ជាទីបញ្ចប់នៅខាងកើតប៉ែកខាងក្រៅក្រុងមានប្រាសាទមេបុណ្យខាងកើត ប្រាសាទប្រែរូប ប្រាសាទក្រវ៉ាន់ និង ប្រាសាទបាតជុំ ។ នៅក្នុងចំណោមប្រាសាទទាំងអស់នេះ គេត្រូវបន្ថែមប្រាសាទតូចមួយទៀត គឺប្រាសាទព្រះឥន្ទ្រកោសី ។ នៅពេលដែលប្រាសាទបន្ទាយស្រីកើតឡើង នៅក្នុងចំណែកដែលយើងហៅថា " ក្រុមអង្គរ" វាស្ថិតនៅក្នុងក្រុងឥស្វរៈបុរៈ (Içvarapura ) ជាភូមិមួយដែលស្ថិតនៅខាងក្រៅធានី យសោធរៈបុរៈ ។

យើងពុំបានដឹងអំពីផ្ទះសម្បែងសាមញ្ញរបស់ប្រជាជននៅធានីអង្គរ ទាំងនៅក្នុងធានី យសោធរបុរៈក៏ពុំបានដឹងដែរ ។ នៅអំឡុងពេលនោះ ហោជាងរបស់ប្រាសាទបន្ទាយស្រី ក៏បានបង្ហាញពីវាំងរបស់ស្ដេចកាំសៈ ( Kamsa ) នៅមធុរៈ ( Mathura ) ។ លំនៅដ្ឋានក៏ទំនើប និង សម្បូរបែបនេះ គឺជាផ្ទះដែលសង់បន្ទើតពីលើសសរឈើ ដែលទ្រក្តារក្រាលជាសំណង់ដែលអាចរស់នៅបាន ។ គ្រឹសនៈបានទុកសាកសពកាំសៈនៅក្នុងបន្ទប់ធំ ចែកចេញជាពីរបន្ទប់ ដែលមានទំហំតូចៗ ហើយពិដានទៀប ។ នៅទីនេះគឺជាស្រ្តីតាសខ្លួនចេញពីវាំង ដែលកំពុងតែតូចចិត្តខ្លាំង ។ ថ្វីត្បិតតែសំណង់ទាំងនេះសង់នៅលើទីខ្ពស់ពីទឹកចិត្តក៏ដោយ ក៏វាំងនេះក៏ពុំមែនមានតែមួយជាន់ដែរ ។ ជានិច្ចកាលនៅពីលើបន្ទប់ធ្វើពីថ្មបាយក្រៀមទាំងឡាយ គឺជាគុកងងឹតនៅបន្ទើតពីលើហោជាង ដែលអាចអោយមនុស្សដែលជាប់នៅក្នុងនោះ អាចអើតក្បាលចេញបានតាមបង្អួចតូចៗ ។ សំណង់ស្ថាបត្យកម្មជាសំណង់ចំលងចេញពីសំណង់ឈើដ៏សំបូរបែបដូចដែលគេឆ្លាក់នេះ ។ មាននាំងធំមួយប្រៀបបីដូចជាប្រក់ពីលើពិដាននៃបន្ទប់សំខាន់ ។ នៅតាមថ្នោងថ្នាន រូតរបស់បន្ទប់ទាំងឡាយ ដែលធ្វើពីថ្មបាយក្រៀម ហើយនៅចន្លោះសសរនិមួយៗមានព្យួរដោយកំរងផ្កា ។

វាជាការធ្វើអោយមានពិត ដែលលំនៅដ្ឋាននៅក្នុងវាំងស្ដេច ហើយនិងនៅក្នុងគេហដ្ឋាននៃសមាជិករាជវង្សាភិបាល គឺត្រូវបានបង្ហាញអោយដេញពីលំនៅដ្ឋានទាំងនោះ តាមរយៈសំណង់ស្ថាបត្យកម្មដែលជាប្រពៃណីយ៍ក្នុងសម័យទំនើប ។ កាលៈទេសៈនោះ ប្រជាជនរស់នៅក្នុងសម័យអង្គរ មានឬក្រយើងមិនសូវបានដឹងទេ ។ ចំលាក់រឿងទី ១ ដែលឆ្លាក់ពីសកម្មភាពប្រចាំថ្ងៃ មិនសូវមានបង្ហាញទេ នៅលើក្បាច់ក្រឡោតទាប ដែលមាននៅចុងសតវត្សទី ១១ ។

## ជំពូក III
## ធានីអង្គរនៅក្រោមការគ្រប់គ្រងរបស់សន្តតិវង្ស
## សុរិយាវរ្ម័នទី ១ ( SURYAVARMAN I )
## ( 1002 - 1080 )

១- រជ្ជកាលព្រះបាទ ឧទ័យអាទិត្យវរ្ម័នទី ១ ( Udaya dityvarman I ) ( 1001 - 1002 )

ព្រះបាទជ័យវរ្ម័នទី ៥ បានចូលទិវង្គត់នៅក្នុងឆ្នាំ ១០០១ ។ ព្រះអង្គមិនបានបោះបង់ និងមិនសូវជាធ្វើអោយប្រទេសធ្លាក់ចុះប៉ុន្មានទេ ។ ការស្នងរាជសម្បត្តិ ត្រូវបានប្រគល់អោយស្តេចមួយអង្គ ដែលត្រូវជាប្អូនរួមនឹងម្តាយជាមួយព្រះអង្គ គឺព្រះបាទឧទ័យអាទិត្យវរ្ម័នទី ១ (Uday à ditya varman I[er] ) " គឺព្រះអង្គនេះហើយដែលជាអនុណោទ័យ ហើយត្រូវការពារដោយព្រះអាទិត្យ " ស្តេចថ្មីគឺត្រូវជាប្រពន្ធថ្មី នៃទឹកដីដែលគ្រប់គ្រងទៅដោយស្តេចច្រើនអង្គ ដែលចូលទិវង្គត់ទៅ ។ ព្រះអង្គបានទទួលនូវមត៌កនៃច្បាប់ទំលាប់នៅទីនេះ ដែលគេពុំអាចនឹងពណ៌នាបាន ។ សិលាចារឹកស្តុកកក់ធំបាននិយាយថា ព្រះអង្គសោយរាជ្យសម្បត្តិនេះមិនបានយូរទេ គឺបានតែមួយឆ្នាំក៏សោយទិវង្គត់ទៅវិញ នៅឆ្នាំ ១០០២ ។ ទាំងនៅក្នុងរាជធានីអង្គរ ទាំងនៅក្រៅធានី ព្រះអង្គពុំបានសាងសង់អ្វីទេ សំរាប់រាជរបស់ព្រះអង្គនោះ ។

នីតិទាំងឡាយដែលត្រូវអោយព្រះបាទ ឧទ័យអាទិត្យវរ្ម័ន បានឡើងសោយរាជ្យសម្បត្តិនោះ គឺមានអ្នកប្រឆាំងជាច្រើន រហូតដល់ការទាស់ទែងគ្នាធ្វើអោយផ្ទុះជាសង្គ្រាមឡើង ។ ការចូលទិវង្គត់របស់ព្រះអង្គ ត្រូវបានគេកត់សំគាល់ឃើញ គឺនៅពេលដែលមានការចាប់ផ្តើម នៃការបះបោរដណ្តើមរាជម្លេះ ។ រហូតមកដល់ ១០ឆ្នាំក្រោយ ក៏ត្រូវបញ្ចប់ដោយមានការបង្កើតនូវសន្តតិវង្សថ្មីអោយមកជំនួស ។

២- ជ័យវិរៈវរ្ម័ន ( Jayaviravarman ) និង ការបះបោរដណ្តើមរាជ :

មានស្តេចពីរអង្គ ដែលជាអ្នកទាមទារសោយរាជ្យសម្បត្តិ ហើយដែលបានធ្វើអបគមន៍ ( បំបែកខ្លួន ) នៅក្នុងពេលដែលព្រះបាទឧទ័យអាទិត្យវរ្ម័នទី ១ នៅគង់ព្រះជន្មនៅឡើយនោះ ៖ ទី ១ គឺជាទ្រង់ជ័យវិរៈវរ្ម័ន ( Jayaviravarman ) ដែលទំនងជាត្រូវបានឡើងសោយរាជ្យភ្លាមៗនៅធានីអង្គរ ។ ទី ២ គឺសូរិយាវរ្ម័ន ( Suryavarman ) ដែលត្រូវតែរងចាំអស់ជាច្រើនឆ្នាំ ដើម្បីច្បាំងដណ្តើមយករាជធានី ប៉ុន្តែគឺព្រះបាទសូរិយាវរ្ម័ន ហើយនិងបុត្រារបស់ព្រះអង្គ ដែលត្រូវបានសោយរាជ្យបន្តពីក្រោយជ័យវិរៈវរ្ម័ន ។

តាមការពិចារណា អ្នកដណ្តើមរាជ្យ ដែលបានកត់ត្រាទុកនៅសិលាចារឹកស្តុកកក់ធំ ប្រហែលជារឹបអូសធានីអង្គរបាននៅឆ្នាំ ១០០៦ ហើយព្រះបាទជ័យវិរៈវរ្ម័ន ពេលនោះលែងមានចារឹកអ្វីនៅលើសិលាចារឹកខ្មែរហើយ ។ គ្មានទេ ដែលយើងត្រូវនិយាយថា ស្តេចអង្គនេះឡើងគ្រងរាជ្យទៅតាមច្បាប់បវេណីយ៍នោះ ហើយទ្រង់ក៏បានរិះរកនូវវិធី ដើម្បីអោយគេទទួលស្គាល់ក្នុងការយកអំណាចមកក្តាប់តែឯង ។ សិលាចារឹកនៃប្រាសាទត្រពាំងរន្ធ បាននិយាយយ៉ាងខ្លីថា ៖ ដោយបានគង់នៅលើកៅអីបត់ធ្វើអំពីមាស នៅដៃមានកាន់លំអងនៃកំរងផ្កា ហើយព្រះកេសទំរេតលើកៅអី ព្រះបាទស្រីជ័យវិរៈវរ្ម័ន (Çri Jayaviravarman ) បានគ្រប់គ្រងអំណាចនៅឆ្នាំ ៩២៤ ។

កាលបរិច្ឆេទដែលពន្យល់ដោយស័កៈ ( Çaka ) របស់ប្រជាជនឥណ្ឌា ត្រូវជាឆ្នាំ ១០០២ គស ( 924 Çaka + 78 = 1002 គស ) សិលាចារឹកដូចគ្នានេះដែរ ក្រោយពីសរសេរពាក្យបញ្ជោរពីសំរស់

អ្នកអំពីចំណេះវិជ្ជា ហើយនិងរបាយការណ៍ដែល "បានយកទន្លេគង្គា ( Ganga ) មកធ្វើជាឧទាហរណ៍ប្រដូចទៅនឹងមហាសមុទ្រ ទៅតាមលក្ខណៈវិទ្យាសាស្ត្រ មានផ្លូវទឹកជាច្រើនហូរកាត់ចូលទៅក្នុងសមុទ្រនេះ" ។ ព្រះអង្គបានតាំងទីនៅតំបន់អង្គរ ក្នុងចន្លោះឆ្នាំ ១០០៣ និង ១០០៦ ប៉ុន្តែយើងមិនដឹងពីឆ្នាំដែលព្រះអង្គបោះបង់ចោលតំបន់អង្គរម្តងទៀត ដោយសារតែការប្រកួតប្រជែងអំណាចគ្នានោះទេ ។

ដើម្បីពង្រឹងអំណាចរបស់ព្រះអង្គ ព្រះបាទជ័យវីរៈវរ្ម័ន បានរកអ្នកដែលចេះដឹងនៅក្នុងចំណោមមន្ត្រីជាន់ខ្ពស់ទាំងឡាយ ដែលអាចទុកចិត្ត ដើម្បីធ្វើជាជនួលក្នុងការសំរុះសំរួលការងារអោយប្រសើរ ឬដើម្បីគាំទ្រនូវការប្រតិបត្តិការណ៍ផ្ទៃក្នុង ។ ក្នុងខណៈនោះ ពេលព្រះអង្គទទួលបន្ទុកដឹកនាំ និង គ្រប់គ្រងដោយលទ្ធិវិជ្ជា នៅក្រោមរាជរបស់ព្រះអង្គនេះ មានមន្ត្រីថ្នាក់ខ្ពស់ជាច្រើននាក់ បានមកចុះចូលជាមួយនឹងព្រះអង្គ ។ លទ្ធផលដែលទទួលបាននេះ គឺមានការប្រកែកជំទាស់ជាច្រើនពីសំណាក់អ្នកប្រឆាំង ហើយក៏មានអ្នកជាប់ទោសជាច្រើននាក់ដែរ ។ សិលាចារឹកជាច្រើនដែលប្រមូលបាននោះ ក៏បានបញ្ជាក់ពីហេតុការណ៍នេះដែរ ។

ធ- <u>ការស្ថាបនារបស់ព្រះបាទជ័យវីរៈវរ្ម័ន</u> :

បានស្ថាបនាប្រាសាទមួយ និង មានការដឹកនាំ ហើយនិងជាស្ថាបត្យកម្មដ៏ល្អ នៅក្នុងសំណង់សំរាប់រាជ្យ ។ គេបានសន្មត់ថា ប្រាសាទវិមានអាកាស ត្រូវបានសាងសង់ឡើងដោយព្រះបាទជ័យវីរៈវរ្ម័ន ប៉ុន្តែចំពោះពីរាមីឌនៃប្រាសាទនេះ ទំនងជាបានត្រូវចុះកាលបរិច្ឆេទមុនរាជស្តេចអង្គនេះ ។ លោក J.Boisselier បានសុំធ្វើសេចក្តីសន្និដ្ឋានប្រាសាទតាកែវ ដែលស្ថិតនៅខាងកើតធានីអង្គរធំថាជាសំណង់របស់ព្រះបាទជ័យវីរៈវរ្ម័ន ។ គេមានគិនភាគរបស់ប្រាសាទតាកែវ ដូចគ្នានឹងគិនភាគរបស់ភ្នំ ហេមស្រីន្គគិរី ( Hemaçringagiri ) "ភ្នំលែងមាស" ហើយប្រាសាទនេះ គេប្រដូចទៅនឹងភ្នំព្រះសុមេរុ ។ សិលាចារឹកមួយដែលរកឃើញនៅប្រាសាទតាកែវ ហើយត្រូវបានចារដោយមន្ត្រីម្នាក់ឈ្មោះ បណ្ឌិតយោគីស្វរៈបណ្ឌិត ( Yogiçvarapandita ) ដែលជាអ្នករាជការរបស់ព្រះបាទ សូរិយាវរ្ម័នទី ១ ( Suryavarman I[er] ) បាននិយាយថា ៖ ម្យ៉ាងទៀតបុរសនោះដែលចូលកាន់តំណែងជាស្តេច "បានកសាងហេមស្រីន្គគិរីរួចជាស្រេចហើយ" ។ ប្រសិនបើប្រាសាទតាកែវចេញមកពីហេមស្រីន្គគិរិ អញ្ចឹងប្រាសាទនេះត្រូវបានសាងសង់រួចតាំងពីរជ្ជកាលព្រះបាទសូរិយាវរ្ម័នទី ១ម្លេះ ។ ឬ ក៏ការពិតប្រាសាទតាកែវ គឺជាប្រាសាទមួយដែលសំខាន់បំផុត ដែលមិនត្រូវបានបញ្ចប់ទាំងស្រុងនៅឡើយទេ ការតុបតែងក្បាច់លំអត្រូវជួបនឹងឧបសគ្គ ។

លោក G-Coedès បានគិតថា គេអាចរកឃើញពីការពន្យល់ណាមួយនៅក្នុងសិលាចារឹកតែមួយអំពីភាពមិនទាន់រួច នូវប្រាសាទតាកែវនេះ ។ អត្ថបទនេះបានសរសេរពីហេតុការណ៍ នៃរន្ទះបាញ់ចំពីលើហេមស្រីន្គគិរិ ហើយនឹងព្រឹត្តិការណ៍របស់បណ្ឌិត Yogiçvarapandita បានធ្វើពិធីបុណ្យមួយ ដើម្បីលាងទោសកំហុស គាត់ក៏បានបញ្ជាក់ពីមន្ត្រីដែលចាប់ផ្តើមធ្វើបង្ហើយប្រាសាទនេះ " ដោយទិញថ្ម" ។ ដោយមានរន្ទះបាញ់ចំពីលើប្រាសាទ អញ្ចឹងហើយមិនអាចអោយគេបញ្ចប់នូវសំណង់នេះបានទេ ។ សិលាចារឹកមួយទៀតក៏បានបញ្ជាក់យ៉ាងច្បាស់ដែរ អំពីការបន្តសង់បង្ហើយហេមស្រីន្គគិរិ ក្រោយពីមានគ្រោះថ្នាក់មក ។ លោក J. Boisselier បានទាញនូវសេចក្តីសន្និដ្ឋានថា ជាកំហុសឆ្គងនៃការប្រកាសអោយដូចគ្នានៃហេមស្រីន្គគិរិ និង ប្រាសាទតាកែវ ហើយនិងភាពមិនទាន់ហើយ ចុងក្រោយនេះ គឺជាបញ្ហាមួយផ្សេងទៀត ។ គាត់បានគិតថា ការដណ្តើមអំណាចរបស់ជ័យវីរៈវរ្ម័ននេះ បានបង្ហាញអោយឃើញពីការបោះបង់ចោលនូវប្រាសាទមួយដែលស្តេចអង្គនេះ បានទទួលយកការសាងសង់ ។ សំរាប់ព្រះអង្គឈ្មោះ ហេមស្រីន្គគិរិនោះ ពុំមែនជាប្រាសាទតាកែវទេ គឺជាប្រាសាទវិមានអាកាស ។

តាមរយៈស្ថាបត្យកម្ម តាមសមាមាត្រ ហើយតាមសម្ភារៈដែលយកមកប្រើប្រាស់នេះ បានធ្វើអោយប្រាសាទតាកែវបានលេចចេញជារូបរាងឡើង ដូចជាសំណង់រាជស្តេច ។ ពីរ៉ាមីឌរបស់វាមានកំពស់ប្រាំថ្នាក់ ដែលរួមមានតួប្រាសាទប្រាំរាងជាចំណិតត្រសក់ ហើយជាសំណង់មួយ ដែលសង់ពេញលេញដោយថ្មភក់ទាំងអស់ ។ ការណ៍សំខាន់នោះ គេពុំបានរកឃើញសិលាចារឹករបស់ស្តេចទេ ។ សិលាចារឹកទាំងឡាយបាននិយាយពីសកម្មភាពយ៉ាងសាមញ្ញរបស់មន្ត្រីថ្នាក់ខ្ពស់ៗ ដែលនៅក្រោមការគ្រប់គ្រងរបស់ព្រះបាទសូរិយាវរ្ម័នទី ១ ។ ក្នុងខណៈពេលចុងក្រោយ ព្រះអង្គពុំអាចបោះបង់ចោល ទទួលយកសំរាប់រាប់បញ្ចូលទៅក្នុងរាជ្យ ឯសំណង់សំខាន់របស់ភាគីដែលប្រឆាំងរបស់ព្រះអង្គត្រូវផ្អាក ។ ព្រះអង្គបានទុកចិត្តអោយមន្ត្រីរបស់ព្រះអង្គនៅមើលថែរក្សាប្រាសាទ នៅក្នុងអំឡុងពេល ២ ឬ ៣ ឆ្នាំ ក្រោយមក ។

តាមមូលហេតុ នៃភាពមិនទាន់បញ្ចប់របស់ប្រាសាទតាកែវ បានលេចចេញក្នុងពេលបច្ចុប្បន្ននូវប្រាសាទមួយរឹងមាំ ដែលមានសមាមាត្រយ៉ាងត្រឹមត្រូវបំផុត ។ តួប្រាសាទទីមួយនៃប្រាសាទខ្មែរបានបង្ហាញអោយឃើញនូវបញ្ចប់លយទៅមុខ ( Avant Corps ) ជាផ្លូវចូល ៤ នៃតួប្រាសាទសំខាន់ ហើយនៅជាន់ទី ២ នៃពីរ៉ាមីឌ មានថែវព័ទ្ធជុំវិញ ដោយមកបញ្ចប់នៅត្រង់អ័ក្ស នៃបន្ទប់ផ្លូវចូលរបស់ជណ្តើរ ។ ជូនកាលនីន្នាការនៃស្ថាបត្យកម្មខ្មែរ អោយតំលៃលើភាពឆើតឆាយ ដោយសារការតុបតែងលំអដែរ ។ ប្រាសាទតាកែវប្រហែលជាត្រូវដកយកចេញ នូវគ្រប់ចំលាក់ដែលមានជាប់មកជាមួយស្ថាបត្យកម្មនេះ សមាមាត្រហើយ និងភាពត្រឹមត្រូវ នៃខ្សែបន្ទាត់ដែលត្រូវតាមសុក្រិត្រភាពល្អ ។

៤- <u>ព្រះបាទសូរិយាវរ្ម័នទី ១ ( Survavarman Ier ) ( 1002 - 1050 )</u> :

ជាកាលបរិច្ឆេទមួយ ដែលប្រហែលជាពិត ប៉ុន្តែនៅចន្លោះឆ្នាំ ១០០៦ និង ១០១០ ព្រះបាទជ័យវីរៈវរ្ម័ន បានបាត់បង់ពីសាច់រឿងនយោបាយ នៃប្រទេសខ្មែរជាស្ថាពរហើយ ។ ឯព្រះបាទ សូរិយាវរ្ម័នទី ១ បានគង់នៅតែមួយព្រះអង្គឯង ។

តើអ្នកណាជាអ្នកត្រូវទទួលតំណែងបន្តពីអ្នកជ្រែករាជ្យ ព្រះបាទជ័យវីរៈវរ្ម័ននេះ ? សិលាចារឹកនៅតុកព្រីងជ្រុម បានធ្វើការអួតសរសើរពីស្តេចមួយអង្គ ។

" កាលនោះមានស្តេចមួយអង្គ ព្រះនាម ស្រីសូរិយាវរ្ម័ន ( Çri suryavarman ) ដែលបន្តវង្សពីអម្បូរអ្នកដែលត្រូវការពារដោយព្រះអាទិត្យ ជាការលំអឋានៈស្តេច ដែលមាននិស្ស័យទៅនឹងពន្លឺភ្លឺថ្លាជាច្រើនរបស់ព្រះអាទិត្យ" ។

" គឺជាគុបុរៈ ( Kubora ) ដែលជាអ្នកមានសណ្តានចិត្តសម្បុរស បានធ្វើអោយមហាសមុទ្រមានស្ថេរភាព ប្រៀបដូចព្រះអាទិត្យមានពន្លឺចិញ្ចាចចិញ្ចែង ប្រៀបដូចសត្វគោ ជានិម្មិតរូបនៃវីរៈបុរស ប្រៀបដូចព្រះច័ន្ទ ជានិម្មិតរូបនៃភាពស្រស់ថ្លា ប្រៀបដូចសាស្ត្រាចារ្យ ជាអ្នកបំភ្លឺនៃវិទ្យាសាស្ត្រ" ។

យើងពុំបានដឹង តើព្រះរាជក្រឹត្យអ្វី ដែលចេញជាសារតាំងអោយព្រះអង្គទៅជាបេក្ខជនដែលត្រូវបានឡើងសោយរាជ្យ ។ សិលាចារឹកមួយបាននិយាយយ៉ាងសាមញ្ញថា " អ្នកត្រូវសោយរាជ្យសម្បត្តិបន្ត គឺត្រូវជាមនុស្សនៅក្នុងគ្រួសារ នៃខ្សែស្រឡាយខាងម្តាយ ដូចព្រះបាទ ស្រីឥន្ទ្រវរ្ម័ន ដែលព្រះអង្គធ្លាប់បានបន្តនូវខ្សែស្រឡាយអោយស្តេចជាច្រើនអង្គ អោយសោយរាជ្យបន្តរហូតមក ។ វាដូចគ្នាទៅ នឹងសន្តតិវង្សវិទ្យា ទៅតាមទំរង់ច្បាប់របស់ព្រះបាទសូរិយាវរ្ម័ន ក៏មិនមែនអ្នកណាឆ្ងាយពីខ្សែស្រឡាយស្តេចឡើយ ។ ព្រះអង្គបានភ្ជាប់ចំណងរបស់ព្រះអង្គ និង ព្រះបាទ ហរសវរ្ម័នទី ១ ដោយព្រះអគ្គមហេសីរបស់ព្រះអង្គគឺ វីរលក្ស្មី ( Viralakshmi ) ដែលត្រូវជាក្មួយស្រីរបស់ព្រះបាទជ័យវីរៈវរ្ម័ន ។ ព្រះបាទសូរិយាវរ្ម័នបានរៀបការជាមួយនាង ដើម្បីបំពេញច្បាប់ក្នុងការសោយរាជ្យសម្បត្តិ ។

គេបានអោយយោបល់ទាំងបំពានថា ព្រះបាទសូរិយាវរ្ម័ន មកពីប្រទេសម៉ាឡេស៊ី ការសន្និដ្ឋាននេះគឺពឹងផ្អែកទៅលើកាលប្បវត្តិនៅឈៀងម៉ៃ ដែលបានរៀបរាប់ពីអន្តរាគមន៍ដោយកូនស្តេចគ្រងអំណាចរបស់អាណាចក្រម៉ាឡេស៊ី នៅទន្លេមេណាម ឡុបប៊ុយរី ( Lopburi ) ដែលជាអតីតទឹកដីរបស់កម្ពុជរាជ ( Kambojaraja ) ។ គេបានគិតថា ព្រះបាទសូរិយាវរ្ម័នទី ១ បានតាំងទីលំនៅលើដីព្រះគេ្ហ ស្ថិតនៅក្នុងតំបន់កណ្តាលប្រទេសថៃ ។ វាជាការពិតណាស់ ដែលព្រះអង្គស្រឡាញ់ចូលចិត្តតំបន់នេះ ហើយមានសិលាចារឹកជាច្រើន ដែលព្រះអង្គបានរកកន្លែង ដែលសង្កត់ធ្ងន់ទៅលើដែនដីអតីតអាណាចក្រ ទ្វារវតី (Dvaravati) ដែលជាទឹកដីមួយធំល្វឹងល្វើយ នៅក្នុងជ្រលងទន្លេមេណាម ។

ព្រះបាទសូរិយាវរ្ម័នបានឡើងគ្រងរាជ្យសម្បត្តិជាស្តេចខ្មែរ នៅក្នុងឆ្នាំ ១០០២ ក្រោយពីការសោយទិវង្គតរបស់ ឧទ័យអាទិត្យវរ្ម័ន និង រាជស្តេចជ័យវីរៈវរ្ម័ន ហើយព្រះអង្គពុំបានទទួលគ្រោះថ្នាក់អ្វីទេ ពីព្រោះព្រះអង្គបានតាំងទីនៅឆ្ងាយពីធានីអង្គរ នៅក្នុងអំឡុងពេលផ្នែកទីមួយ នៃរាជរបស់ព្រះអង្គ ។ ទំបាំងដណ្តើមរាជដែលដឹកនាំដោយព្រះអង្គ នៅខាងក្រៅធានីនោះ ប្រហែលជាមានរយៈពេល ១០ឆ្នាំ ។ សំណង់ទាំងឡាយរបស់ព្រះអង្គ ពុំមែនមាននៅធានីអង្គរទេ ។ ប្រហែលជាប្រាសាទធំមួយ នៃសន្តតិវង្សរបស់ព្រះអង្គនៅលើភ្នំដងរែក គឺជាប្រាសាទព្រះវិហារ ។ ប្រាសាទនេះ ត្រូវបានគេសង់នៅលើគែមនៃខ្ពង់រាប ដែលគ្របពីលើទីវាលដ៏ល្វឹងល្វើយនៃប្រទេសកម្ពុជា ហើយព្រះបាទសូរិយាវរ្ម័នទី ១ បាននាំយកអទិទេព ភទ្រេស្វរៈ ( Bhadreçvara ) ដែលជាអទិទេពនៅវត្តភូ មកអោយស្ថិតនៅក្នុងប្រាសាទ ។

៥- ការងារដែលធ្វើបានសំរេចនៅធានីអង្គរ ក្រោមរាជ្យព្រះបាទសូរិយាវរ្ម័នទី ១ :

នៅក្រោមរបស់ព្រះបាទសូរិយាវរ្ម័នទី ១ ពុំមានសំណង់ថ្មីៗសំខាន់ៗនៅធានីអង្គរទេ ប៉ុន្តែជីវិតនៃសាសនានៅក្នុងប្រាសាទទាំងឡាយ មិនត្រូវបានគេកាត់ផ្តាច់ទេ ។ ស្តេចបានសំរេចបំពេញបំណងដ៏មានវិបុលភាពនៃសំណង់ទាំងឡាយ របស់អ្នកសោយរាជ្យមុនៗ ។ ហើយម្យ៉ាងវិញទៀត ហេតុអ្វីបានជាធ្វើប្រាសាទតាកែវអោយហើយ តែព្រះអង្គមិនបានប្រគល់អោយមន្ត្រីថ្នាក់ខ្ពស់ជាច្រើនអ្នកទទួលមើលថែរក្សាជាស្រេចហើយ ។ ព្រះបាទសូរិយាវរ្ម័នទី ១ បានរៀបចំសាងសង់ប្រាសាទសំខាន់នៅក្រៅធានីអង្គរ ហើយសំណង់ដែលធ្វើបានសំរេចនោះ ច្រើនតែការងារនៅក្នុងបរមរាជវាំង ។ នៅលើពីរ៉ាមីឌប្រាសាទវិមានអាកាស ព្រះអង្គទំនងជាបានសង់ថែវដែលដំបូលកោងជាវូត ( Voutes ) ព័ទ្ធជុំវិញ ។ ប្រសិនបើ Hemaçringagiri ជាវិមានអាកាសនោះ ការងារនេះត្រូវធ្វើឡើងក្រោយពីមានរន្ទះបាញ់នៅលើប្រាសាទ ។

៦- ការធ្វើអោយមានសន្តិភាព ( សន្តិភាវកម្ម ) :

ក្នុងអំឡុងពេលដ៏វែង នៃរាជស្តេចសូរិយាវរ្ម័ន ជាដំបូងព្រះអង្គបានធ្វើអោយមានសន្តិភាព ដែលត្រូវហែកកំទេច ក្រោយពីមានសង្គ្រាមស៊ីវិលអស់រយៈកាលប្រាំបួនឆ្នាំហើយ ហើយក៏ត្រូវបានជួសជុលឡើងវិញនូវអ្វីដែលរុះរើ ឬក៏បោះបង់ចោល ។ សន្តិភាវកម្មបានលេចឡើងយ៉ាងពេញលក្ខណៈ ព្រោះថា៖

" នៅក្រោមរាជ្យស្តេចនោះ មានមនុស្សជាច្រើនបានយល់ជ្រួតជ្រាប ក្រោយពីត្រូវលង់លក់តែម្នាក់ឯងនៅក្នុងព្រៃ ហើយគេគ្មានខ្លាចអាទាល់តែសោះ ដែលពួកគេបានចាប់ច្បាមដោយដៃ ( ចោរទាំងឡាយ ) " ។

ព្រះអង្គពុំមានអំណាចល្មម ដើម្បីរៀបចំច្បាប់នៅក្នុងប្រទេសឡើងវិញទេ ដូច្នេះព្រះអង្គត្រូវតែធានាកុំអោយមានកោលាហលកើតមានឡើងវិញ ។ គំរោងការនេះ គឺគ្រោងដើម្បីរៀបចំបណ្តាខេត្តទាំងឡាយដែលត្រូវរៀបចំអំណាចអោយស្តេចនៅភាគខាងកើត ។ បញ្ហាមួយសំខាន់ផ្សេងទៀត គឺការវិលត្រឡប់ចូលមកបំរើការងារក្នុងប្រទេសវិញ នៃអ្នកដែលមានស្វាមីភក្តិ ហើយគ្មានកំហុសឆ្គង ។

ដើម្បីសុវត្ថិភាពក្នុងស្រុក ពួកមន្ត្រីថ្នាក់ខ្ពស់ទាំងអស់ បានខិតខំរកគ្រប់វិធី ដើម្បីប្រមូលពួកខ្មាំងយកមកដាក់គុក ហើយខ្លះទៀតបានត្រូវប្រគល់អំណាចអោយទៅតាមឋានៈ ។ ភស្តុតាងនៃទង្វើទាំងនេះ គឺព្រះបាទសូរិយាវរ្ម័ន បានផ្ដាក់ពាក្យសម្បថសច្ចាប្រណិធាន ចំពោះមុខស្ដេចនៅលើជញ្ជាំងនៃទ្វាររាជវាំង ។ នៅក្នុងរបបរាជាធិបតេយ្យខ្មែរ គេបានស្គាល់ទំនៀមទំលាប់នៃការសច្ចាប្រណិធានជារៀងរាល់ឆ្នាំ ពាក្យសម្បថសន្យាទាំងចាស់ទាំងថ្មី ត្រូវបានគេបញ្ចេញអោយឃើញនៅសតវត្សទី ១១ នៅក្នុងព្រះបរមរាជវាំងអង្គរ ។ គេបានឃើញរួចមកហើយពីសម័យបុរាណ ដែលបានលាតត្រដាងអោយឃើញពីពិធីបុណ្យទាំងឡាយនៅក្នុងសម័យនោះ ហើយបានត្រូវថែរក្សារហូតមកដល់សម័យថ្មីនេះ ។ អត្ថបទនៃពាក្យសម្បថដែលធ្វើសច្ចាប្រណិធាន ចំពោះព្រះបាទសូរិយាវរ្ម័នទី ១ បានបញ្ជាក់អោយឃើញថា ជាពិធីតាមបែបព្រាហ្មណ៍សាសនា ហើយបច្ចុប្បន្ននេះ ពាក្យសម្បថធ្វើឡើងតំរូវតាមបែបព្រះពុទ្ធសាសនា ។

៧- ចុងបញ្ចប់នៃរជ្ជកាលព្រះសូរិយាវរ្ម័នទី ១ :

គេបានគិតថា ព្រះបាទសូរិយាវរ្ម័នទី ១ គឺជាអ្នកកាន់ព្រះពុទ្ធសាសនា ក្រោយពីគេបានដឹងពីមរណៈនាមរបស់ព្រះអង្គមានឈ្មោះថា និព្វានបទៈ ( Nirvanapada ) ។ តែគ្រប់សំណង់ទាំងអស់របស់ព្រះបាទសូរិយាវរ្ម័នទី ១ ច្រើនតែជាសំណង់ព្រាហ្មណ៍សាសនា ។ វាជាការពិតដែលថា បរមសុខរបស់ព្រះពុទ្ធសាសនាក៏ដូចជាសំណង់របស់ព្រាហ្មណ៍សាសនា ដូចដែលលោក J.Filliozat បានធ្វើការកំណត់សំគាល់ទៅលើមរណៈនាម Nirvanapada នេះគឺបានស្រុះស្រួលនឹងព្រះសិវៈដែរ ។

ព្រះបាទសូរិយាវរ្ម័នទី ១ បានសោយទិវង្គត់នៅឆ្នាំ ១០៥០ ក្រោយពីបានគ្រងរាជ្យសម្បត្តិអស់រយៈកាល ៥០ឆ្នាំ ។ គឺជារយៈពេលមួយយ៉ាងវែង ដែលព្រះអង្គបានអំណាចក្នុងការកសាងនូវសត្តតិវង្សរបស់ព្រះអង្គ ។ នៅពេលព្រះអង្គចូលទិវង្គត់ទៅ ទ្រង់បានបន្សល់ទុកនូវបុត្រា ២ អង្គ សំរាប់គ្រងរាជ្យបន្តគឺ ឧទ័យាទិត្យវរ្ម័នទី ២ ហើយនិងទ្រង់ Harshavarman III ( ហ្សវរ្ម័នទី ៣ ) ។

៨- របបរាជាធិបតេយ្យខ្មែរនៅក្រោមការដឹកនាំរបស់បុត្រាព្រះបាទសូរិយាវរ្ម័នទី ១ ( 1050 - 1080 ) :

ទ្រង់ឧទ័យាទិត្យវរ្ម័នទី ២ ( Uday à dityavarman II ) គឺត្រូវជាគ្រូរបស់ព្រះបាទសូរិយាវរ្ម័នទី ១ និង ម្ចាស់ក្សត្រីវីរលក្ស្មី ( Viralaksmi ) ប្រហែលជាអគ្គមហេសី ដែលបានរៀបអភិសេកលើកទី ១ នៅពេលដែលព្រះបាទជ័យវីរៈវរ្ម័ន នៅគ្រងរាជ្យនៅឡើយ ។ ស្ដេចថ្មីបានទទួលនូវមត៌ក នៃការសិក្សាអប់រំតាមរបៀបស្ដេច ៖

" គេជានុភាពរបស់ព្រះអង្គ ដែលបានសិក្សាគ្រប់ចំណេះវិជ្ជា គឺចាប់ផ្ដើមឡើងពីវិទ្យាសាស្ត្រទាំងឡាយ ពីវេយ្យាករណ៍ ច្បាប់ និង គ្រប់សាស្ត្រាទាំងអស់ " ។ អត្ថបទសិលាចារឹកស្ដុកកក់ធំក៏បានបន្ថែមថា ៖ បំណងប្រាថ្នារបស់ព្រះអង្គ គឺចង់បង្វឹកនូវគ្រប់កោសល្យទាំងអស់មានសិល្បៈ ដែលដុះចេញពីគំនិត និង ផ្សេងៗទៀត ។

មានមន្ត្រីថ្នាក់ខ្ពស់ម្នាក់ ក្នុងចំណោមមន្ត្រីជាច្រើននាក់របស់បិតារបស់ព្រះអង្គឈ្មោះ បណ្ឌិត Jayendrapadita ( ជយេន្ទ្របណ្ឌិត ) បានធ្វើជាគ្រូព្រះអង្គដ៏មានប្រាជ្ញឈ្លៀសវៃ ។ នៅក្នុងមុខងារនេះគាត់បានរៀបចំពិធីអភិសេកអោយស្ដេចថ្មីបានឡើងសោយរាជ្យសម្បត្តិ ហើយក៏បានបង្រៀនវិជ្ជាសាសនាផ្សេងៗអោយចេះចាំស្ទាត់ទៀតផង ។ នៅពេលនោះ សិលាចារឹកស្ដុកកក់ធំ បានបញ្ជាក់យ៉ាងច្បាស់ថា " ព្រះអង្គមានសេចក្ដីសប្បាយរីករាយ នឹងព្រះរាជាណាចក្រ ដែលដឹកនាំដោយក្សត្រប្រកប ដោយទេពកោសល្យ " ហើយ " ដែលព្រះអង្គបានលាតត្រដាងពីបេះដូង " នៅក្នុងរាជរបស់ទ្រង់មានពួកបះបោរ

ជាច្រើននាក់ បានធ្វើអោយមានកោលាហលនៅពេញផ្ទៃប្រទេស ហើយក៏ត្រូវបានបង្ក្រាបទៅវិញ ដោយឧត្តមសេនីយ៍សង្គ្រាម ( Sangrâma ) ។ វាជាការពិបាកណាស់ ក្នុងការរកមុខរកឃើញ នូវអ្នកដែលបានបង្កហេតុអោយមានអសន្តិសុខដល់សង្គម ហើយបានលាតសន្ធឹងរហូតដល់ភាគខាងដើមនៃការស្ថាបនាប្រាសាទអង្គរ ។

ពួកបះបោរទាំងនោះ បានបង្កអោយមានវិនាសកម្មជាច្រើន នៅក្នុងព្រឹត្តិការណ៍របស់ទ្រង់ហ្រស់វរ្ម័ន នាឆ្នាំ ១០៦៦ ហើយព្រះអង្គក៏បានលើកស្ទួយប្រទេស ដែលរងការខូចខាតឡើងវិញ ។ ព្រះអង្គបានចាប់ផ្តើមកសាងប្រទេសជាថ្មី ហើយក៏បានរៀបចំទ័ព ដើម្បីធ្វើសង្គ្រាមជាមួយប្រទេសដែលនៅជាប់ផ្នែកខាងកើត គឺប្រទេសចាម ។ នៅក្នុងរាជរបស់ព្រះអង្គមានព្រាហ្មណ៍ម្នាក់ឈ្មោះ បណ្ឌិតជីវាករបណ្ឌិត ( Divâkarapandita ) បានចាប់ផ្តើមជាអាជីពក្នុងការងាររាជការ ដោយបានធ្វើសមយុទ្ធយោធាប្រកបដោយមហិច្ឆិតា ដើម្បីដឹកនាំនយោបាយប្រទេសកម្ពុជា ក្នុងអំឡុងពេល ៣០ឆ្នាំ ។

៩- សំណង់ធំៗល្បីរបស់បុត្រាព្រះបាទសូរិយាវរ្ម័ន នៅធានីអង្គរ :

ថ្វីបើមានការពិបាកក្នុងការងារ ទើបប្រទះនូវស្នាដៃទាំងឡាយនៅក្នុងវេលាកាលនេះ អំឡុងពេល ១៦ឆ្នាំ ។ បើទ្រង់ឧទ័យអាទិត្យវរ្ម័ន ក៏បានទទួលសាងនូវសំណង់ធំៗច្រើននៅធានីអង្គរ ហើយនាមរបស់ព្រះអង្គក៏នៅតែភ្ជាប់ជាមួយ នឹងប្រាសាទបាពួន ហើយនិងបារាយណ៍ដ៏ធំមួយ គឺបារាយណ៍ខាងលិច ។

សិលាចារឹកមួយ បានសរសេរពីការកសាងប្រាសាទបាពួន ៖ " គេបានឃើញនៅចំកណ្តាលជម្ពូទ្វីប ( Jambudvip ) មានលំនៅដ្ឋានអទិទេពមួយបានលេចឡើង គឺភ្នំមាស ( ភ្នំព្រះសុមេរុ ) ព្រះអង្គបានធ្វើភ្នំមាសនៅចំកណ្តាលរាជធានី ។ នៅលើភ្នំមាសមានសាងប្រាសាទមាសមួយ ហើយនៅក្នុងប្រាសាទនេះ ព្រះអង្គបានអភិសេកសិវៈលិង្គមួយ អំពីមាស ដែលមានពន្លឺចិញ្ចាចដូចឋានសួគ៌ " ។

ប្រាសាទបាពួនពុំមែននៅចំកណ្តាលធានីយសោធរបុរៈទេ ប៉ុន្តែប្រហែលជានៅចំព្រំប្រទល់ខាងជើងរបស់ធានីយសោធរបុរៈ ដែលសព្វថ្ងៃនេះ គេពុំសូវដឹងច្បាស់ ។ តាំងពីមួយសតវត្សមុនមជ្ឈមណ្ឌលនយោបាយរបស់រាជធានី គឺជាក្រុមដែលបង្កើតឡើងដោយព្រះរាជវាំង ។ ដូចព្រះបរមរាជវាំងដែរ ប្រាសាទបាពួនត្រូវបានកសាងឡើងនៅលើទីធ្លាធំមួយ នៃធានីអង្គរ ហើយនៅផ្នែកខាងកើតមានទីលានដ៏ធំមួយលាតសន្ធឹងរហូតដល់ប្រាសាទឃ្លាំងទាំងពីរ ។ ប្រាសាទបាពួនសង់នៅទន្ទឹមនឹងរាជវាំង ។

តួកណ្តាលរបស់ប្រាសាទបាពួន ត្រូវដួលរលំអស់ហើយ ពុំមានសល់កំទេចកំទីអ្វីទេ ។ គឺជាតួប្រាសាទទោល ដែលសង់នៅលើកំពូលពីរ៉ាមីឌ ហើយនៅតាមថ្នាក់ៗរបស់ពីរ៉ាមីឌ មានសាងថែវព័ទ្ធជុំវិញ និង មានផ្លូវចូលពីគ្រប់ជ្រុងទាំង ៤ ដែលប្រកបទៅដោយមណ្ឌប ឯនៅជញ្ជាំងនៃខ្លោងទ្វារទាំងនោះ ( gopura ) មានលំអទៅដោយក្បាច់ក្រឡោតទាបកង ៤ជ្រុងតូចៗ រៀបរាប់ពីទេវកថាផ្សេងៗ និង ពណ៌នាពីសាច់រឿងដោយពាក្យកាព្យ ។ នៅទីនោះគេបានស្គាល់រូបក្រិស្នៈនៅពីក្មេង ហើយនិងឈ្មោះជាច្រើននៅក្នុងរឿងរាមកេរ្តិ៍ ។ នៅផ្នែកខាងចុងផ្ទាំងក្បាច់ផ្សេងពីគ្នាទាំងនេះ មានលំអទៅដោយរូបមនុស្ស សត្វ ចំបាំង និង រឿងរ៉ាវនៅក្នុងព្រះបរមរាជវាំង ។ វាជាលើកទីមួយ ដែលនៅលើជញ្ជាំងបាពួនមានក្បាច់ខ្លះ ដែលនិយាយអំពីជីវភាពប្រជាជនខ្មែរ ។

ប្រាសាទបាពួន គឺជាប្រាសាទសំខាន់របស់ព្រះបាទ ឧទ័យអាទិត្យវរ្ម័នទី ២ គឺនៅទីនេះហើយ ដែលឧត្តមសេនីយ៍សង្គ្រាម ( Sangrâma ) បានបំពេញនូវករណីកិច្ចមួយរំលែកអ្នកសបានពីពួកខ្មាំង ដែលទទួលបរាជ័យនៅទីនោះ ។

១០- បារាយណ៍ខាងលិច :

នៅខាងលិចរាជធានីអង្គរ ព្រះបាទឧទ័យអាទិត្យវរ្ម័ន បានជីកអាងស្តុកទឹកមួយ មានបណ្តោយ ៨គម និងទទឹង ២,២០០គម ។ គេបានគិតថា បារាយណ៍ខាងកើតប្រហែលជាសញ្ញាមួយ បញ្ជាក់អោយដឹងថា ប្រទេសមានភាពរាំងស្ងួត ហើយម្យ៉ាងទៀត គឺចង់សង្កត់ធ្ងន់លើការសាងសង់នូវបារាយណ៍ថ្មី ។ នៅសម័យនោះ ទឹកបារាយណ៍នៅខាងកើតស្រកអស់ ហើយទឹកស្តុកទុកនោះក៏ពុំអាចគ្រប់គ្រាន់ ដើម្បីប្រើប្រាស់ដែរ ដែលជាហេតុតែមួយគត់ ។ អញ្ចឹងហើយទើបព្រះបាទឧទ័យអាទិត្យវរ្ម័នចង់បង្កើតអាងស្តុកទឹកដ៏ពិសិដ្ឋមួយ នៅផ្នែកខាងលិចអោយដូចព្រះបាទយសោវរ្ម័ន ដែលបានជីកបារាយណ៍នៅខាងកើតរាជធានី ។

នៅចំកណ្តាលបារាយណ៍ខាងលិច ព្រះអង្គបានសង់ប្រាសាទមួយឈ្មោះថា ប្រាសាទមេបុណ្យខាងលិច ហើយមានលំអរដោយក្បាច់ក្រឡោតទាបជារាង ៤ជ្រុងតូចៗ តាមលក្ខណៈក្បាច់លំអរបស់ប្រាសាទបាពួន ។ នៅជិតប្រាសាទមេបុណ្យ គេបានរកឃើញ នូវដងខ្លួនរូបព្រះវិស្ណុផ្ទុំអំពីស្ពាន់ដ៏ធំមួយ ។ រូបនេះត្រូវបានគេយកទៅថែរក្សាទុកនៅសារៈមន្ទីរជាតិភ្នំពេញ ហើយក៏ជាវត្ថុមួយ ដែលគួរអោយចាប់អារម្មណ៍ណាស់ ថ្វីបើរូបនេះត្រូវបានបាត់បង់អវៈយវៈអស់ គឺជាភស្តុតាងមួយបញ្ជាក់អោយដឹងថា សិល្បៈចំលាក់ស្ពាន់ នៃប្រទេសបានឡើងដល់កំពូល ក្នុងអំឡុងសតវត្សទី ១១ ។

១១- ចុងបញ្ចប់នៃសន្តតិវង្សសូរិយាវរ្ម័នទី ១ :

ព្រះបាទហ្សវរ្ម័នទី ៣ ( Harshavarman III ) បានសោយទិវង្គត់នៅឆ្នាំ ១០៨០ ព្រះអង្គបានសោយរាជ្យនៅធានីអង្គរ រហូតដល់ចុងបញ្ចប់នៃជីវិតរបស់ព្រះអង្គ ។ អ្នកស្នងរាជ្យបន្តពីព្រះអង្គ ដែលមាននៅក្នុងបញ្ជីឈ្មោះស្តេចនោះ គឺជ័យវរ្ម័នទី ៦ ( Jayavarman VI ) ដែលពុំមែនជាអ្នកជាប់សាច់សារលោហិតអ្វីនឹងព្រះអង្គទេ ។ ជ័យវរ្ម័នទី ៦ មានដើមកំណើតមកពីត្រកូលមហិធរៈបុរៈ (Mahidharapura) គឺជាសន្តតិវង្សមួយនៅផ្នែកខាងជើងប្រទេសកម្ពុជា ។

១២- ទិដ្ឋភាពនៃរាជធានីអង្គរនៅចុងបញ្ចប់សតវត្សទី ១២ :

នៅក្នុងរាជធានី នៃយុគ្គសម័យនោះមានសំណង់ និង ប្រាសាទដែលបន្សល់ទុកពីសតវត្សទី ១០ ដូចជាប្រាសាទបាពួន និង ប្រាសាទដែលមានមុខងារនៅក្នុងព្រះបរមរាជវាំង ។ ដំណាក់របស់ស្តេចគឺធ្វើពីសំភារៈដែលងាយនឹងវិនាស ។ ក្បាច់ក្រឡោតទាបតូចៗនៅប្រាសាទបាពួនមានបង្ហាញពីរូបភាពខ្លះៗអំពីលំនៅដ្ឋានរបស់ប្រជាជន ។ ក៏ប៉ុន្តែដូចនៅលើផ្ទៃខាងក្នុង នៃហោជាងប្រាសាទបន្ទាយស្រី ក្បាច់ ៤ជ្រុងតូចៗបានបង្ហាញពីរឿងទេវកថា ឬ ក៏ដំណាលជាពាក្យកាព្យលាតត្រដាងពីលំនៅដ្ឋានរបស់អ្នកមាន ។ ត្រូវរង់ចាំដល់ពាក់កណ្តាលសតវត្សទី ១២ ដើម្បីអោយសិល្បៈករបង្ហាញឡើងវិញពីជីវភាពអ្នកស្រែ ។ ស្ថាបត្យកម្មដែលយើងបានឃើញនៅលើជញ្ជាំងប្រាសាទបាពួន និង មណ្ឌបបានចំលងចេញមកពីជីវភាពពិតៗ នៅក្នុងព្រះរាជវាំង ។

នៅជាប់នឹងផ្លូវចូលទី ២ ពីខាងជើងមានលេចចេញនូវវាំងឋានសួគ៌មួយទាំងស្រុង ។ វាមានតួគេហដ្ឋានជាច្រើនរាងទ្រវែង ហើយនៅផ្នែកខាងចុងប្រកបទៅដោយយ៉ ។ ដំបូលរបស់យ៉វាទាបជាងដំបូលរបស់តួផ្ទះកណ្តាល ។ វាដូចគ្នាទៅនឹងវាំងរបស់កាំសៈ ( Kamsa ) ដែលគេបានឆ្លាក់នៅប្រាសាទបន្ទាយស្រី គ្រឿងដំបូលទាំងអស់នៅបន្ទើតពីលើសសរជាច្រើន ហើយមណ្ឌបមិនត្រូវបានគេបិទបាំងដោយជញ្ជាំងទេ ប៉ុន្តែវាំងននធំៗត្រូវបានគេចងលាតនៅចន្លោះសសរទាំងឡាយ ។ នៅផ្នែកខាងលើតាមជ្រុងនៃតួគេហដ្ឋាន ប្រក់ទៅដោយក្បឿងស្រទបចេក ហើយព្រុំដំបូលរៀបចំលំអដោយក្បឿងព្រុំ ( រាងទ្រនុងស្រួចដូចត្រយូងចេក ) ។ គេបានជួបប្រទះនូវសំណង់បែបនេះ នៅក្នុងសង្គមខ្មែរទំនើបដែរ ។

ដល់សព្វថ្ងៃនេះ តើផ្ទះដែលស្ថិតនៅទាំងនោះបិតបាំងដោយជញ្ជាំងជាច្រើន ឬ ក៏ជញ្ជាំងឈើស្តើងៗ ? ទាំងនោះយើងគិតថា វាទំនងជាបែបនេះ ប៉ុន្តែគេមិនបានបង្ហាញពីសណ្ឋាប់ធ្នាប់ទាំងឡាយ នៅក្នុងព្រះរាជវាំងទេ ។

អចលនៈវត្ថុ ដែលគេបានឃើញនោះ គឺជារបស់របរប្រើប្រាស់ធម្មតាទេ ហើយកៅអីទាបៗមានជើង ៤ គេអាចយកមកអង្គុយបែបបញ្ឈរជង្គង់ ឬ អង្គុយពែនភ្នែន និង បត់ជើងបាន ។ កៅអីទាំងនោះ គឺគេបំរុងទុកសំរាប់តែមនុស្សឋានៈខ្ពស់ ឬ ក៏សំរាប់តាបសធ្វើតបធម៌ ។

វាំងគឺជាលំនៅដ្ឋានរបស់ស្តេច ត្រូវតែលំអដោយរបស់របរយ៉ាងទំនើបៗ ហើយស្រស់សង្ហា ។ សិលាចារឹកស្តុកកក់ធំបានសរសេរពីវាំងរបស់ព្រាហ្មបណ្ឌិត Jayendrapanhdita ( ជយេន្ទ្របណ្ឌិត ) :

" វាំងនេះបានលំអដោយរូបចំលាក់អំពីថ្ម ប្រកបទៅដោយការលួងលោម គាត់តែងលំអដោយកំរងមាលាចំពោះមនុស្សស្រី តាមការត្រិះរិះ តើត្រូវនិយាយដូចម្តេច ចំពោះសោភ័ណ្ឌភាពនេះ ?"

នៅទីនេះ ឬ ទីនោះ ក្បាច់ក្រឡោតទាបបានបង្ហាញផ្លូវខ្លះអោយយើងឃើញ ។ នៅក្បែរពពួកក្រុមមនុស្ស ដែលដើរនៅខាងមុខរទេះ អូសដោយសេះមួយ ហើយបរដោយមនុស្សម្នាក់ និង មនុស្សពីរនាក់ទៀតជិះក្នុងរទេះ ។ ក្រៅពីនេះ មានដីមួយដើរយឺតៗនៅឆ្ងាយពីមនុស្សពីរនាក់ នៃ ប្រជាជនដែលដើរជុំវិញរទេះគោមួយផ្ទុកទៅដោយពួកឈ្នួញ និង ផ្លែឈើ ។ អ្នកបររទេះទាំងពីរនាក់នោះស្លៀកសំពត់ដូចគ្នាទៅនឹងវីរៈបុរស និង អទិទេពទាំងឡាយ ដែលរុំដោយក្រណាត់ផ្លត់ៗជុំវិញ ចង្កេះល្វតល្វន់ ហើយសំពត់នេះគឺមានលំនាំនឹងសំពត់សម័យទំនើប ដោយជាយរបស់វាបត់ជាបន្ទះតូចនៅចំពីមុខ បត់ចូលតាមប្រឡោះភ្លៅមកញាត់ពីក្រោយខ្នងក្រោមខ្សែក្រវាត់ ( ស្លៀកចងក្បិន ) ។ ល្អម៉្យាងដែរ ដែលចំលាក់នៅប្រាសាទបាពួន ស្រាវជ្រាវរក និង បង្ហាញពីជីវភាពប្រចាំថ្ងៃ តែវាបានបង្ហាញជាពន្លឺខ្លះៗនៅក្នុងសិលាចារឹក ។

១៣- អំពីរបបសង្គម : ⁄

វាដូចជាអនុលោមទៅតាមការបែងចែកវណ្ណៈអភិជន ក្នុងចំណោមប្រជាជន ។ នៅក្នុងសិលាចារឹកជាច្រើន ដែលយើងបានឃើញជារឿយៗមកហើយ ពីការធ្វើឧទ្ទិសនៃពួកវណ្ណៈព្រាហ្ម ។ តែផ្ទុយទៅវិញ លក្ខណ៍ណ្ឌនៃក្សត្រិយ៍ ( Kshatriya ) ត្រូវបានលេចឡើងយ៉ាងកំរ ហើយដូចជាគេបំរុងទុកអោយតែសមាជិកនៃគ្រួសារស្តេច នៅក្នុងចន្លោះអ្នកទាំងនោះ ដែលជាកម្មសិទ្ធិរបស់វណ្ណៈថ្នាក់ខ្ពស់ៗពីរ ហើយការជួបជុំដែលជាបច្ច័យដល់អាពាហ៍ពិពាហ៍ គឺមានជាញយៗ ។ លោក យជ្ញាវរាហ ( Yajna varaha ) បានកើតមកពីអាពាហ៍ពិពាហ៍រវាងបុត្រីរបស់ព្រះបាទ Harshavarman I[er] ( ហស្រវរ្ម័នទី ១ ) ជាមួយនឹងព្រាហ្មម្នាក់ ឬ ព្រាហ្មម្នាក់ទៀតឈ្មោះ វាករភត្ត ( Divakarabhatta ) ដែលព្រាហ្មម្នាក់មកប្រទេសឥណ្ឌា ត្រូវជាស្វាមីរបស់ប្អូនស្រីព្រះបាទជ័យវរ្ម័នទី ៥ ទាំងនេះគឺជាឧទាហរណ៍ខ្លះៗ បង្ហាញអំពីច្បាប់ដែលកើតនៅចន្លោះវណ្ណៈ នៃអភិជនរាធិបតេយ្យ ។

យើងបានឃើញពីតួនាទីនៃអ្នកជំនិតរបស់ឥស្សរៈជន ដែលដើរតួជាមនុស្សសំខាន់ ។ នៅជុំវិញស្តេចព្រាហ្មណ៍ទាំងឡាយ បានបំពេញមុខងារក្នុងសាសនា ដែលជាឥទ្ធិពលមួយយ៉ាងធំ ដែលពុំមែនជាអ្នកក្តោបក្តាប់មើលតែខាងសាសនាប៉ុណ្ណោះទេ គឺត្រូវដើរតួជាអ្នកនយោបាយផង នេះជាសង្គមខ្មែរក្នុងសម័យអង្គរ ។

វាមានការពិបាកណាស់ ប្រសិនបើមនុស្សទាំងឡាយបានទទួលយកនូវឧត្តមភាព នៃស្តេចមកធ្វើជាកម្មសិទ្ធនៃវណ្ណៈជាន់ខ្ពស់ ។ គ្រប់វណ្ណៈនៃសង្គមទាំងអស់ ដែលស្ថិតនៅក្រោមអំណាចនៃអ្នកដឹកនាំ

គឺជាមន្ត្រីរាជការ នៃរាជាណាចក្រ ដែលពុំមែនជាព្រាហ្មណ៍ ឬ ក៏ក្សត្រិយ៍ ( Kshatriya ) ទេ ។ យើងបានឃើញពីមុខងារទាំងនោះ ដែលគេប្រកាន់យកតំណាងមួយខ្ពស់ គឺដោយសារតែអំពើទាំងនោះបានមកដោយកុសល ។ ឯសិទ្ធិរបស់ស្តេចវាពុំមែនតែការគ្រប់គ្រងតែមួយមុខ ហើយនិងយុទ្ធជនសង្គ្រាមទេ ។ សិលាចារឹកមួយរបស់វត្តបាសេត ( Baset ) មានទាក់ទងទៅនឹងគុណធម៌ ហើយនិងកិត្តិយសដែលព្រះបាទ ឧទ័យអាទិត្យវរ្ម័នទី ២ ( Udayadityavarman II ) បានបំពេញនូវពត៌មានបន្ថែម ៖

" តាមវិរៈរបស់ស្តេចត្រូវបាន ( ឡើងសក្តិអោយមន្ត្រី ) វិសក្ម័ន ( Viçarman ) ដែលជានាយកខាងសិល្បៈ ។ នៅក្នុងពេលដែលធ្វើបញ្ចប់នូវការងារទាំងឡាយ ស្តេចបានប្រទានអោយនូវដីដែលជារបស់កម្មសិទ្ធិផ្ទាល់របស់ព្រះអង្គ ដោយមានការធានាអះអាង សំរាប់ការមកដល់នូវគ្រប់វិវាទកម្មទាំងអស់ ។ មានការប្រមូលផ្តុំពួកវណ្ណៈព្រាហ្ម និង វណ្ណៈស្តេច ដើម្បីធ្វើជាសាក្សីនៅពេលដែលស្តេចប្រគល់អោយអ្នកម្ចាស់ដីដាំបង្គោលព្រំប្រទៅលើដីនោះ ។ ដោយមានការពិនិត្យសង្កេតសំរាប់គុណធម៌ទាំងឡាយរបស់ព្រាហ្ម វិស្វាកម្ម័ន ( Viçvakarman ) ស្តេចបានសរសេរពីកម្មសិទ្ធិជាមួយនឹងគ្រួសារនៃពួកវណ្ណៈថ្នាក់ខ្ពស់ ដោយប្រគល់អោយនូវពានរង្វាន់មាស " ។

យើងបានរកឃើញនៅទីនេះ នូវការបង្ហាញពីព្រឹត្តិការណ៍នៃការលើកតំកើងជាអភិជន នៃគ្រួសារមួយ ។

ប្រជាជនបានមកប្រមូលផ្តុំគ្នា នៅផ្នែកខាងក្នុងរាជធានី ដែលយើងបានដឹងថា វាជារឿងអាក្រក់មួយរបស់សង្គម ។ វណ្ណៈដ៏សែនអាក្រក់ជាងគេ ដែលគេបានស្គាល់ គឺជាសិល្បៈហត្ថករទាំងឡាយ និងជាទូទៅគឺគ្រប់មនុស្សតូចៗទាំងអស់ ។ នៅក្នុងអត្ថបទចំណារ ដែលបានចារនៅលើសិលាចារឹក ឬ នៅលើមេទ្វារមានចុះបញ្ជីយ៉ាងវែង នូវឈ្មោះទាសាទាសី ដោយបានប្រគល់អោយនូវការងារផ្សេងៗ ។ ការបន្ទាបបន្ទន់យ៉ាងខ្លាំងនៃគ្រប់ " ទាសករដើម្បីប្រកបរបរធ្វើស្រែ" ។ លំដាប់ថ្នាក់មួយដែលខ្ពង់ខ្ពស់ល្មម វាគឺជាទាសករដែលមានជំនាញ ជាអ្នកធ្វើការដោយដៃ ក្រៅពីការងារផ្ទះបាយ អ្នករែងអំបោះ អ្នកតំបាញទាំងឡាយ ។ ចុងបញ្ចប់គេត្រូវអោយអ្នកទាំងនោះមានការងារមួយប្រភេទ សំរាប់ជនដែលព្រមដោយឯកសិទ្ធិរមមាន អ្នកបាំងឆត្រ តន្ត្រីករ តន្ត្រីការិនី អ្នករបាំ និង អ្នកច្រៀង ។ ការសាងសង់ប្រាសាទទាំងឡាយ គឺត្រូវតែធ្វើដោយអ្នកហត្ថពល ដែលមានស្នាដៃដើម្បីឆ្លាក់ថ្ម ដឹកជញ្ជូន រៀបចំ ដុតឥដ្ឋ កាត់ និង សំរួតដុំថ្មបាយក្រៀម ។ ហត្ថពលទាំងនេះ ត្រូវតែជ្រើសរើសសំរាប់អោយធ្វើការងារជីកបារាយណ៍ដើម្បីស្តុកទឹក ។

លោក G. Coedès បានស្រង់ឈ្មោះទាសាទាសីនៅក្នុងសិលាចារឹក ដែលគេប្រមាថ ដោយអោយឈ្មោះថាជា "ឆ្កែ" "មនុស្សថោកទាប" ឬ ក៏ជាមនុស្សគួរអោយស្អប់ខ្ពើម" ឈ្មោះទាំងនេះមិនបានយកមកជាប់ខ្លួនទាសករបានទេ វាគឺគួរអោយស្អប់ខ្ពើមខ្លាំងណាស់ ។ មានឈ្មោះមួយដែលគេបន្ថែមដើម្បីហៅបង្អាប់ឈ្មោះគឺ " ភាពទឹងក្លាញ់ដោយគ្មានយុត្តិធម៌ " ។ មួយផ្សេងទៀត " គ្មានអ្នកណាម្នាក់រៀបរាប់អ្វីទាំងអស់ " ។ ស្ត្រីម្នាក់ដូចដែលគេបានហៅ " កើតមកគឺដើម្បីស្នេហា " ។

១៤- <u>ព្រះចេហាក្សត្រ</u> :

ប្រសិនបើអត្ថបទទាំងឡាយរបស់សិលាចារឹកមានការកើនឡើង នូវពាក្យសរសើរ ដែលថ្លែងទៅកាន់ស្តេចនោះ វាមិនមែនស្ថិតនៅក្រោមបញ្ហាទេ ពីព្រោះស្តេច គឺជាអ្នកត្រូវតែបញ្ចេញនូវគ្រប់សកម្មភាពសំរាប់អោយគេអួតសរសើរ ។ តាមគំនិតនៃសន្តតិវង្សឥណ្ឌា ស្តេចគឺជារាជការទី ១ នៃរាជាណាចក្រ

ដែលជាអ្នកអភិរក្សលើចទបញ្ញានៃច្បាប់ លើអ្នកដឹកនាំប្រទេសជាតិទាំងឡាយ ហើយនិងប្រជាជនតូចតាច ។ អំណាចរបស់ស្តេច ត្រូវតែកំណត់ដោយព្រំដែន នៃការគោរពច្បាប់ ។

ព្រះមហាក្សត្រមានមុខនាទីដឹកនាំប្រទេស ដែលជាកេរ្តិ៍ដំណែលពីព្រះបិតារបស់ព្រះអង្គ ឬ ក៏ពីសមាជិកណាម្នាក់នៃគ្រួសាររបស់ព្រះអង្គ សិលាចារឹកទាំងឡាយ ដែលជានិច្ចកាលត្រូវបានគេចារនៅលើច្បាប់នៃស្តេចសោយរាជ្យសម្បត្តិ ដែលបានបន្តមកពីបុព្វបុរសរបស់ព្រះអង្គ ហើយជានិច្ចកាលតែងតែមានវិវាទកម្មនៅក្នុងខណៈពេល នៃព្រឹត្តិការណ៍ទាំងឡាយរបស់ព្រះអង្គទៀតផង ។ ព្រះនាមរបស់ព្រះមហាក្សត្រ ស្តេចនិងឈ្មោះរបស់មន្ត្រីថ្នាក់ខ្ពស់ទាំងឡាយ ត្រូវចាប់ផ្តើមដោយពាក្យថា "ស្រី ( Çri )" ( មានសំណាង ដែលនាំមកនូវសុភមង្គល ) ។ នៅក្នុងភាសាខ្មែរបុរាណ គេបានរកឃើញថា នៅពីមុខព្រះនាមរបស់ព្រះមហាក្សត្រ តែងតែដាក់ពាក្យថា " Vrah Pada " ( បាតជើងពិសិដ្ឋ ) ដែលជាទូទៅគេបកស្រាយថា " ព្រះករុណាជាម្ចាស់ " ។

ក្រោយពេលសោយទិវង្គត់ ស្តេចតែងតែមានគ្រឿងសំគាល់ ដោយមរណៈនាមរបស់ព្រះអង្គ ។ ទាំងនេះប្រសិនបើអ្នកស្នងរាជបន្តទាំងឡាយ ដែលគេបានដឹងច្បាស់ថា ជាអ្នកផ្ទេរករាជ្យសម្បត្តិមិនអាចទទួលយកបាននូវមរណៈនាមទេ ។ នៅក្នុងខណៈនោះ សំណង់ទាំងឡាយរបស់ព្រះមហាក្សត្រ ក៏ដូចជាស្នាដៃរបស់ព្រះមហាក្សត្រដែលឥតលក្ខខ័ណ្ឌ តាមច្បាប់គំរូវក៏ត្រូវបានគោរពបូជាដោយស្តេចស្នងរាជក្រោយៗដែរ ហើយលទ្ធផលនេះ គឺយើងទាំងអស់គ្នាបានឃើញរួចមកហើយ ស្តេចអាចបញ្ជាអោយមន្ត្រីថ្នាក់ខ្ពស់ណាម្នាក់ ជាអ្នកទទួលមើលការខុសត្រូវ ។

ការកើនឡើងនៃការប្រទាន និង ការអះអាងបន្ថែមនៃម្ចាស់កម្មសិទ្ធិដី ត្រូវបានគេរចនាឡើងជាស្តុតាងនៅលើសិលាចារឹកទាំងឡាយ ដែលស្តេចជាអ្នកសំរេចអោយ ។ បើស្ថិតិច្បាប់ក្នុងប្រទេសវិញគ្រប់ការសំរេចព្រះទ័យ ត្រូវចេញមកពីស្តេច ប៉ុន្តែគ្រប់រាជបញ្ញត្តិរបស់ព្រះអង្គ ត្រូវតែគោរពតាមច្បាប់ដែលបានរៀបចំហើយ ។ សិលាចារឹកនៅប្រាសាទប្រែរូប បានកំណត់យ៉ាងច្បាស់ពីការគំរូវអោយធ្វើអ្វីមួយដោយអំណាចច្បាប់របស់ស្តេច ៖

គាថា CCXCV " អូ អ្នកឯងគឺជាអ្នកដែលធ្វើបានសំរេច ដោយព្រះរាជាណាចក្រជានិច្ចកាល អ្នកឯងត្រូវតែចងភ្ជាប់ដោយ Dharma ( ច្បាប់ ) ឧត្តមប្រសើរដោយគុណធម៌ នៃអំណាចដែលធ្វើដោយចិត្តសម្បុរសខ្ពស់ថ្កុំថ្កើងដោយគេជានុគាព សំបូរបែបដោយរតនសម្បត្តិ និង ដោយកងទ័ពដូចជាព្រះមហាក្សត្រចាស់ៗជំនាន់មុនៗទាំងឡាយ " ។

សិលាចារឹកដូចគ្នានេះ ដែលនិយាយពីស្តេចទទួលយកមករក្សាទុកនូវសំណង់ទាំងឡាយ ដែលបានសាងសង់ដោយបុព្វបិតរីទាំងឡាយរបស់ព្រះអង្គ ៖

គាថា CCXCI " អូ អ្នកឯងគឺជាអ្នកដែលជក់ចិត្ត និង ភ័ព្វសំណាងនៃការរុំលង់លក់នៅក្នុងការត្រេកត្រអាលដោយរាជអំណាច ប្រសិនបើស្នាដៃនេះ ត្រូវធ្លាក់ទ្រុឌទ្រោម អ្នកឯងត្រូវកើនឡើង ( ភ្ញាក់ ) ដើម្បីការពារនូវស្នាដៃនេះអោយដូច Nārāyana ( ព្រះវិស្ណុ ) ផ្ទុំនៅលើសមុទ្រទឹកដោះ។

១៥- រដ្ឋបាល :

នៅជុំវិញព្រះមហាក្សត្រ ព្រះអង្គបានជ្រើសរើសយកមន្ត្រីថ្នាក់ខ្ពស់ពីរបីនាក់ ចេញមកពីវណ្ណៈទាំងពីរនៃអភិជនាធិបតេយ្យ ។ ជាការពិតណាស់ មន្ត្រីទាំងអស់នោះ ត្រូវតែទទួលធ្វើគ្រប់ការងារទាំងអស់ដែលបំពើអោយព្រះមហាក្សត្រ ។ រួមមានប្រធានពួកផ្កាំនៃបន្ទប់ផ្ទុំ ចៅហ្វាយនៃលេខានុការជាទីទុកចិត្តនៃចៅហ្វាយនាយ ភ្នាក់ងារនៃគ្រែផ្ទុំរបស់ស្តេច ប្រធាននៃមន្ត្រីរាជការទទួលបន្ទុកគ្រប់គ្រងគ្រឿងឥស្សរិយស

របស់រាជាទាំងឡាយដូចជា ៖ ម្កុដ ក្រវិល កងដៃ ខ្សែឈៀងខ្វេងលើខ្លួន ( ខ្សែបន្ទោង ) ។ល។ ការធ្វើតទៅទៀតជាច្រើន នៃសិលាចារឹកទាំងឡាយបានចុះនិទ្ទេសពីចៅហ្វាយនាយឃ្លាំងនៃរាជវាំង ។ ជាការពិតណាស់ មន្ត្រីរាជការទាំងឡាយតែងតែធ្វើបូកជាអ្នកបំពីរខ្មោច ។ ខ្លះក្នុងចំណោមអ្នកទាំងនោះ មានជាដំបូងគឺត្រូវតែបង្គាប់បញ្ជា ឬ ក៏បំពេញករណីកិច្ចចំពោះពិធីទាំងឡាយ នៃបុណ្យសព ប៉ុន្តែការងារទាំងនោះ គឺត្រឡប់ផ្ទាប់ផ្ទា ខ្មោចទាំងឡាយដោយគ្មានទីបញ្ចប់ទៅតាមសារព័ន្ធ នៃពិធីនៅក្នុងបុណ្យសពក៏រមមានយ៉ាងពិសេសទៅដល់ការទំនាក់ទំនង នៃសំណង់ទាំងឡាយ ដែលបានសាងឡើងដោយបុគ្គលដែលស្លាប់ ឬ ក៏ការចំណេញរបស់ពួកគេ ឯក្ដាក់ងារហើយ និង ជនឧបត្ថម្ភទាំងឡាយ គឺនៅមានជីវិតរស់នៅដដែល ដើម្បីធ្វើជាអ្នកជួយដល់ខ្មោច ដោយបានសាងជាប្រាសាទមួយ ឬ ក៏វត្តមួយ ។

អត្ថបទសច្ចាប្រណិធាន ដែលសរសេរឡើងដោយមន្ត្រីជាច្រើននាក់ ថ្វាយដល់ព្រះបាទសូរ្យវរ្ម័នទី ១ ( Suryavarman I$^{er}$ ) បានចុះនិទ្ទេសពីអត្ថបទទាំងឡាយ ដែលមិនទំនងជាមានបច្ច័យខាងអនុលោម ដោយបានទុកដាក់អោយមានមុខងារដោយឡែក ហើយដែលមុខងារទាំងនេះ ត្រូវតែជារបស់មន្ត្រីរាជការដែលជាវីរៈជន ។ ក្នុងចំណោមមន្ត្រីទាំងនោះ គេបានលើកយកអត្ថបទរបស់លោក Sanjak ហើយនិងរបស់លោក តម្វាក ( Tamrvac ) ។ លោក G.Coedès បានលើកយកអត្ថបទរបស់លោក សញ្ជាក់ ( Sanjak ) ៖

ការបង្ហាញប្រាប់ដោយសញ្ញារបស់មន្ត្រីទាំងឡាយ ទំនងជាសប្បាយចិត្តដោយបានទទួលយកនូវចំណែកមួយ នៃការធ្វើអោយទុកចិត្តពីព្រះមហាក្សត្រ និង បានបញ្ជាក់ពិសក្ដិភាព នៃភាពពាក់ទាក់នៃកក្ដីភាពរបស់ពួកមន្ត្រីទាំងនោះ រហូតដល់ពលិកម្មនៃជីវិត ។ អត្ថបទរបស់ tamrvac បានធ្វើអោយបាននូវផលប្រយោជន៍ជាចាំបាច់ដល់មនុស្សទាំងឡាយ ដែលមិនសូវសំខាន់ ។ លោក G Coedes បានស្មានថាគឺគេត្រូវបង្កើតនូវលក្ខណ៍ល្អអំពីការសំដែង នៃភាពពាក់ទាក់នៅផ្ទៃខាងក្នុង ដែលទាំងនេះ ព្រះមហាក្សត្របានជ្រើសរើសមនុស្សជាច្រើន ដែលមានការទុកចិត្ត ។

អត្ថបទផ្សេងទៀតរបស់មន្ត្រីទាំងឡាយបានថា ការធ្វើបានសំរេចរបស់ព្រះមហាក្សត្រ ដែលជាទូទៅបានកត់សំគាល់សំរាប់តែមនុស្សថ្នាក់ខ្ពស់ៗ គឺសំគាល់ដោយត្រែស្នែង ហើយនិងក្លស់ជាច្រើន ។ ត្រែស្នែងគេទុកបំរុងតែស្ដេច ឬ ក៏មន្ត្រីថ្នាក់ខ្ពស់បំផុត ។ បន្តមកទៀតភាពសំខាន់របស់អង្រឹង ហើយនិងត្រែស្នែង គឺមានស្រោបមាស ឬ ក៏ប្រាក់ ។ កាលនោះភាពថ្លៃថ្នូរយ៉ាងឧឡារិក នៃមន្ត្រីរាជការក្នុងការចូលរួមក្នុងពិធីបូជនីយកិច្ច មានចំពាក់ទៅដោយក្លស់ជាច្រើន ។ ក្លស់ទាំងនេះ អាចធ្វើឡើងពីក្រណាត់ព័ទ្ធជុំវិញ ហើយមានច្រើនជាន់ ។

១៦- ព្រះរាជនិវេសន៍ :

នៅជុំវិញព្រះមហាក្សត្រគឺមានក្រុមគ្រួសារ ញាតិវង្សស្ដេច ហើយនិងក្រុមបរិពារទាំងអស់ (មន្ត្រីសេនាអាមាត្រ ) ។ នៅក្នុងសិលាចារឹកបានថា : ជារឿយៗម្ចាស់ក្សត្រីក៏បានចូលរួមក្នុងគារវកិច្ចចំពោះព្រះមហាក្សត្រដែរ ។ វាជាការពិតណាស់ តាមច្បាប់ម្ចាស់ក្សត្រីអាចបញ្ជូនបុត្រអោយឡើងគ្រងរាជ្យសម្បត្តិ ឬ ផ្ដល់មុខងារអោយដល់មហេសីរបស់បុត្រព្រះនាង ។ វាដូចគ្នាទៅនឹងចំលាក់ដ៏ល្អឯក នៃស្វាមីភរិយាស្ដេចមួយគូរ ដែលឆ្លាក់ក្រោមរូបភាពជារូប Umàmaheçvara ( ឧមាមហេស្វរៈ ) គឺជាចំលាក់ ឬក៏សំខាន់មួយមកពីប្រាសាទបន្ទាយស្រីជារូបអទិទេពស្រី គឺនាងឧមាអង្គុយនៅលើភ្លៅរបស់ព្រះសិវៈកំពុងចូលរួមក្នុងពិធីប្រាស្រ័យដោយស្មើមុខគ្នា ហើយនិងបង្ហាញពីគេជានុភាពរបស់នាង ។ ម្ចាស់ក្សត្រីទីមួយគឺជាប្រពន្ធការពេញច្បាប់ ឯប្រពន្ធនៅឋានៈបន្ទាប់ គឺជាសាហាយ ។

ភាពហ៊ុកហ៊ាក់នៃព្រះរាជនិវេសន៍ បានសំដែងអោយឃើញនៅក្នុងខណៈពេល នៃពិធីបុណ្យ នៃព្រះរាជពិធី ។ ពិធីបុណ្យពុទ្ធាភិសេក គឺព្រះមហាក្សត្រជាអ្នកបួសក្នុងសាសនា ព្រះអង្គបានប្រទាន ឱកាសដើម្បីបង្ហាញពីអធិកភាព ។

សិលាចារឹកមិនបានចុះពិធីបុណ្យទេ ប៉ុន្តែវាបានបង្ហាញប្រាប់ពីសកម្មភាពដ៏ពិសេសពីរ ការរៀន ប្រដៅដោយវិជ្ជាផ្សេងៗអោយចាំស្ទាត់ ( dikshā ) និង ពិធីមហាសិទ្ធិបណ្ណាភិសេក ( abhi seka ) ។ ជារៀងរាល់ឆ្នាំ គេបានធ្វើបុណ្យរំឭកដល់ពិធីអភិសេកស្តេច ដែលត្រូវតែរាំងកុំអោយរាជាណាចក្រជួប គ្រោះថ្នាក់ និង មានភោគភាគក្សាក ។ ក្នុងពេលនោះ គេបានរៀបចំអភិសេកស្តេចជាថ្មីម្តងទៀត ។ សិលាចារឹកនៅប្រាសាទប្រែរូបបានសរសេរថា " ជារៀងរាល់ខែ ពិសាខ ស្តេចអង្គនេះ បានបង្អក់ឆ្អប ដោយ នៅគ្រប់ពេលមានបណ្តែតទៅតាមរលកទឹក នូវអាហារឆ្ងាញ់ចាក់ក្នុងផើងធំៗរាប់រយផើងយ៉ាងស្អាតទៀត ផង " ។

បុណ្យដទៃទៀតមានជាហូរហែរៀងរាល់ឆ្នាំ ។ ចុងបញ្ចប់មានបុណ្យដ៏ចំលែកពីរបីទៀត ដែល ជាពិធីបុណ្យសាធារណៈ ដែលជាការចូលរួមនៃការវិលត្រលប់របស់ព្រះមហាក្សត្រ ប្រកបដោយជ័យជំនះ វិលត្រលប់មកធ្វើនៅធានីដែលកំសាន្តដោយមនុស្សច្រើននាក់ ។

## ជំពូក IV
## ព្រះបាទសូរិយាវរ្ម័នទី ២ ( 1113 - ap 1144 ) ហើយនិង ការសាងសង់ប្រាសាទអង្គរវត្ត

១- ព្រឹត្តិការណ៍របស់ព្រះបាទសូរិយាវរ្ម័នទី ២ :

យើងពុំបានទទួលនូវពត៌មានអោយបានច្បាស់ល្អ នៃធានីអង្គរនៅចន្លោះរាជស្តេចព្រះបាទ Harshavarman III ដែលសុគតនៅក្នុងឆ្នាំ ១០៨០ និង ព្រឹត្តិការណ៍របស់ព្រះបាទសូរិយាវរ្ម័នទី ២ នៅ ឆ្នាំ ១១១៣ ទេ ។ គេបានគិតថា ព្រះបាទជ័យវរ្ម័នទី ៦ បានឡើងសោយរាជ្យសម្បត្តិនៅភាគខាងជើង ប្រទេសកម្ពុជា ដែលជាអ្នកស្នងរាជបន្តពីព្រះបាទ Harshavarman VI ដែលគ្រងរាជ្យនៅធានីអង្គរ ។ ក្នុងខណៈនោះ អត្ថបទក្នុងសិលាចារឹកនៅព្រះខ័នបានសរសេរថា ៖

គាថាទី ១៣ " ការទទួលយកបានសំរេចដូចប្រាថ្នា នៃរបបរាជាធិបតេយ្យដ៏ប្រសើរបំផុត នៅ ក្នុងរាជធានីដ៏បរិសុទ្ធ គឺធានីយសោធរបុរៈ ក្រោយពីបានធ្វើអោយពួកសត្រូវទទួលរងនូវការបរាជ័យ ព្រះបាទជ័យវរ្មទេវៈ ( Jayavarmadeva ) ដែលចេញមកពីគ្រួសារមួយ រស់នៅធានីមហីធរបុរៈ (mahidharapura ) ព្រះអង្គបានទទួលការដឹកនាំគ្រប់ផ្នែកទាំងអស់ ដោយកត្តិគុណរហូតដល់សមុទ្រ" ។

ក៏ប៉ុន្តែ ជាការពិតណាស់រហូតមកដល់សតវត្សទី ១២ ប្រទេសកម្ពុជា គឺស្ថិតនៅក្នុងការបែង ចែកនៅឡើយ ។ គេយល់ថា ព្រះបាទសូរិយាវរ្ម័នទី ២ បានទទួលយកអំណាចពីស្តេចពីរអង្គ គឺម្នាក់ជា ឪពុកមារបស់ព្រះអង្គឈ្មោះ ធរណិន្ទ្រវរ្ម័នទី ១ ( dharanindhavarman I<sup>er</sup> ) ដែលសោយរាជ្យបន្តប្អូន របស់ព្រះបាទជ័យវរ្ម័នទី ៦ " ពុំមែនជាចំណងប្រាថ្នារបស់របបរាជាធិបតេយ្យទេ " ។ នៅក្នុងការប្រយុទ្ធ គគូដ៏សែនតឹងចិត្តមួយ ដើម្បីប្រឆាំង និង ក្មួយប្រុសរបស់ព្រះអង្គ ស្តេចអង្គនេះបាន " បកអាក្រាត អោយឃើញពីរបបរាជាធិបតេយ្យ " ។

២- ព្រះបាទសូរិយាវរ្ម័នទី ២ :

ក្នុងព្រឹត្តិការណ៍របស់ព្រះអង្គ ព្រះបាទសូរិយាវរ្ម័នទី ២ បានកើតចេញមកដូចស្តេចមួយអង្គដ៏មានមហិច្ឆិតាដែរ " ជានិច្ចកាលនៅក្មេង នៅចុងបញ្ចប់នៃការសិក្សារបស់ព្រះអង្គបានសាកល្បងសំរេចចិត្តដឹកនាំព្រះរាជាណាចក្រតាមតំណរនៃត្រកូល " ។ អ្នកដណ្តើមរាជដែលមិនចេះនឿយហត់ ក្នុងរយៈពេលសោយរាជ្យអស់រយៈពេលប្រមាណ ៤០ឆ្នាំ ព្រះអង្គបានបញ្ចប់នូវការកាន់អាវុធ ដើម្បីប្រយុទ្ធប្រឆាំងនឹងពួកបរទេសឈ្លានពានជិតខាង ដូចជាពួកនៅទន្លេមេណាមផ្នែកខាងកើត ប្រយុទ្ធជាមួយពួកចាមក៏ដូចជា ជាមួយពួក Daiviète ដែលក្រោយមកក្លាយជាវៀតណាមបច្ចុប្បន្ននេះ ។ នៅក្រោមរាជរបស់ព្រះអង្គមានរបាយការណ៍ជាច្រើន ដែលនិយាយពីការចងភ្ជាប់ឡើងវិញ ជាមួយប្រទេសចិន ហើយនិងឯកអគ្គរាជទូតជាច្រើន ដែលអធិរាជបានបញ្ជូនមកអោយព្រះបាទសូរិយាវរ្ម័ននូវ "មន្ត្រីថ្នាក់ខ្ពស់ៗជាច្រើននាក់ " ។

ក្បាច់ក្រឡោតទាបនៅប្រាសាទអង្គរវត្ត ត្រូវបានគេនិយាយថាជា " ក្បាច់ក្រឡោតទាបប្រវត្តិសាស្ត្រ " រូបភាពពីការយកបានឡើងវិញពីវេងរបស់ព្រះបាទសូរិយាវរ្ម័នទី ២ ជាមួយនឹងនិទ្ទេសនៃមរណៈនាមរបស់ព្រះអង្គ " បរមវិស្ណុលោក ( Paràmavishnuloka ) " ។ ការបង្ហាញទាំងនេះ វាពុំមែនជារូបភាពដែលចំលងចេញមកពីគំនីតគួរអោយស្ញើច ដែលរៀបចំឡើងដោយព្រះបាទសូរិយាវរ្ម័នទី២ ទេ។ នៅផ្នែកខាងលិច នៃក្បាច់ក្រឡោតទាបជាចំណែកមួយ ដែលគួរអោយកត់សំគាល់ គឺមានគេមកចូលគាល់ដើម្បីសំដែងនូវគារវកិច្ច ស្តេចគង់ដោយលាតសន្ទឹងដៃឆ្វេងនៅក្នុងកាយវិការដ៏មានអំណាច ។ មកឆ្ងាយជាងនេះបន្តិច ក្បាច់ក្រឡោតទាបនេះ ក៏បានបង្ហាញម្តងទៀត គឺស្តេចឈរនៅលើខ្នងដំរីសង្គ្រាមនៅចំលាក់កណ្តាលសេនាប្រមុខទាំងឡាយរបស់ព្រះអង្គ ដែលនៅព័ទ្ធដោយក្លស់ជាច្រើន អ្នកបក់រុយទង់សញ្ញា និង អ្នកជិះសេះហែរហមជាច្រើនទៀត ។

សំរាប់ទិវាករបណ្ឌិត ( Divakarapandita ) លើកទី ៣ បានក្លាយមកជាព្រះគ្រូរបស់ព្រះបាទសូរិយាវរ្ម័នទី ២ ដោយធ្វើប្រតិបត្តិការដំបូងនៃការឡើងគ្រងរាជ្យរបស់ស្តេច ។ នៅក្នុងឱកាសនោះវាមានលក្ខណៈគ្រប់គ្រាន់ក្នុងការបង្ហាញអោយឃើញពីស្តេចថ្មី ដោយបំពេញនូវករណីកិច្ចរបស់ព្រះអង្គធ្វើបូជនីយ៍ចរទៅគ្រប់ប្រាសាទសំខាន់ៗទាំងឡាយ នៃព្រះរាជាណាចក្រ ដើម្បីប្រទាននូវអំណោយ ដែលប្រព្រឹត្តិដោយគ្មានអ្នកណាប្រឆាំងឡើយ ។ សិលាចារឹកទាំងឡាយដែលចុះពីសំណង់ទាំងឡាយ ដែលព្រះអង្គចារនៅគ្រប់ប្រាសាទធំៗផ្សេងៗពីគ្នានៅវត្តភូ ព្រះវិហារ និង បន្ទាយស្រី ។ ព្រះរាជគ្រូរបស់ស្តេចគឺជាមនុស្សខ្លាំងមុនអាយុ គាត់បានស្លាប់នៅក្នុងអំឡុងពេលព្រះបាទសូរិយាវរ្ម័ននៅសោយរាជ្យនៅឡើយ ។ ការសំដែងនូវសុជនភាពរបស់ស្តេច ដែលព្រះអង្គពេញចិត្ត និង ចារនៅលើសិលាចារឹកនៅប្រាសាទព្រះវិហារ ដោយបានបង្ហាញនូវពាក្យថា " ព្រះគ្រូ ស្រីទិវាករបណ្ឌិត ( Çridivakara pandita ) ដែលមានជើងឈរលើម្កុដ ដែលលំអរនៅលើព្រះកេសរបស់ព្រះបាទស្រីសូរិយាវរ្ម័នជាគ្រូនៃពិភពលោក"។

៣- ប្រាសាទអង្គរវត្ត :

ប្រាសាទអង្គរវត្ត គឺជាប្រាសាទតែមួយគត់ ដែលសាងដោយព្រះបាទសូរិយាវរ្ម័នទី ២ ប្រាសាទអង្គរវត្តគឺជាប្រាសាទមួយដ៏អស្ចារ្យនៃសិល្បៈខ្មែរ ។ គឺប្រាសាទអង្គរវត្តនេះហើយដែលជា " ប្រាសាទភ្នំ " មួយដែលវិវត្តន៍មកដល់ចំណុចខ្ពស់បំផុត ។

ទំហំសរុបដោយគិតទាំងគូទឹកព័ទ្ធជុំវិញផង គឺមានទំហំ ២០០ហិចតា ។ ប្រាសាទអង្គរវត្តតាំងលើមុំជ្រុងខាងត្បូងឈៀងខាងកើតនៃធានីយសោធរបុរៈ ដែលខ្សែក្រវ៉ាត់របស់ធានីធ្វើអំពីដីលើកជាទំនប់ ហើយត្រូវបានគេលើកតាំងពីដើមសតវត្សទី ១២ ។ ប្រាសាទអង្គរវត្តសង់បែរទៅទិសខាងលិច។

គេបានសង់ផ្លូវចូលពីទិសខាងលិច ដោយខាងចុងផ្លូវនេះបានឆ្លងកាត់គូទឹក ។ នៅប្រាសាទផ្សេងៗទៀត គោបុរៈ ( Gopura ) ( ទ្វារចូល ) របស់វាពុំមានផ្លូវចូលមកពីខាងលិចដូចប្រាសាទអង្គរវត្តទេ ។ ជ្រុងនិមួយៗត្រូវកាត់ជាបីដំណាក់ទៅដល់កណ្តាល ហើយការលាតសន្ធឹងរបស់ថែវវែង ត្រូវបញ្ចប់ដោយទ្វារធំដែលអាចបររទេះចូលបាន គេហៅថា " ទ្វារដំរី " ។ ផ្លូវចូលទិសខាងលិច មានប្រវែង ៣៥០ម ជាផ្លូវធំដែលភ្ជាប់ពីទីលានរាងកាកបាទ រួចភ្ជាប់ទៅដល់ប្រាសាទដោយខ្លួនឯង ដោយសង់នៅលើពីរ៉ាមីឌមួយខ្ពស់ដែលរួមមានថែវ ៣ ។

នៅជុំវិញតួប្រាសាទកណ្តាល មានតួប្រាសាទបួនទៀត សង់នៅតាមជ្រុងដែលភ្ជាប់គ្នាដោយថែវធ្វើជារាងកំពែងទី ១ ហើយសង់នៅតាមអ័ក្សនិមួយៗមានវិហារង្ហាន ៤ ដែលមានដំបូលរួមជាមួយនឹងថែវហើយនិងតួប្រាសាទកណ្តាល ។ នៅជ្រុងខាងលិចគេបានសង់បន្ថែម នូវវិហារង្ហានមួយទៀតរាងជាកាកបាទ នៅចន្លោះកំពែងទី ២ និងទី ៣ ។

នៅខាងក្រោមថែវនៃកំពែងទី ៣ ដែលមានបរិមាត្រមិនហួសពី ៨០០ម នោះ ជញ្ជាំងរបស់វាមានឆ្លាក់ទៅដោយក្បាច់ក្រឡោតទាប ដែលល្អជាងគេនៅក្នុងស្នាដៃនៃចំលាក់ខ្មែរ ។ ក្បាច់ក្រឡោតទាបដែលឆ្លាក់បន្តគ្នានេះ មិនត្រូវបានកាត់ផ្តាច់ដោយមណ្ឌបទាំងឡាយនៅតាមជ្រុង ហើយនិងគោបុរៈ ( ទ្វារ ) នៅតាមអ័ក្សទេ ។ មានតែក្បាច់ក្រឡោតទាបនៅជ្រុងខាងជើងឈៀងខាងកើតតែមួយគត់ ដែលមិនត្រូវបានបញ្ចប់នៅក្នុងរជ្ជកាលព្រះបាទសូរិយាវរ្ម័នទី ២ ទេ ប្រហែលជាគេបានគូរដោយដែកគួត ។ យើងបានដឹងពីស្នាដៃនេះ ត្រូវបានគេបញ្ចប់នៅក្នុងកាលៈទេសៈមួយ នៃសតវត្សទី ១៦ ។

៤- <u>បដិមាសាស្ត្រ នៃប្រាសាទអង្គរវត្ត</u> :

បដិមាសាស្ត្រនៃប្រាសាទអង្គរវត្ត បានឧទ្ទិសទាំងស្រុងទៅដល់កត្តិគុណរបស់អទិទេពព្រះវិស្ណុ ដែលជាអទិទេពមួយអង្គ នៃការចូលចិត្តរបស់ព្រះបាទសូរិយាវរ្ម័នទី ២ ( Suryavarman II ) ដែលក្រោយពេលព្រះអង្គចូលទីវង្គត់ ព្រះអង្គបានទទួលយកមរណៈនាមថា បរមវិស្ណុលោក ( Param vishnuloka ) ។ នៅគ្រប់ហោជាង ផ្តែទ្វារទាំងអស់ក៏ដូចជានៅផ្នែកខាងក្រោម នៃសសរផ្តោប គេបានបង្ហាញនូវរូបភាពជាអទិទេព ជាអវតាទាំងឡាយ ដោយចុះមកឋានកណ្តាលនៅក្រោមរូបភាពជាមនុស្ស ឬ សត្វ ។ ប៉ុន្តែនៅថែវទី ៣ គេបានឆ្លាក់ពីរឿងរ៉ាវយ៉ាងវែងរបស់ព្រះវិស្ណុនេះ ។

នៅលើជញ្ជាំងទាំងឡាយនៃថែវខាងលិច នៅគ្រប់ជ្រុងនៃផ្លូវឆ្លងកាត់ ដែលនាំទៅដល់វិហារង្ហានរាងកាកបាទ ចំលាក់ទាំងឡាយបានត្រូវគេឆ្លាក់រៀបរាប់ពីចំបាំង នៅចុងបញ្ចប់នៃខ្សែរឿង ជាពាក្យកាព្យកំណាព្យខ្មែរ គឺរឿងរាមកេរ្តិ៍ និង មហាភារត ( Mahābharata ) ។ នៅផ្នែកខាងជើងបានឆ្លាក់ពីជ័យជំនះរបស់ Lanka កត់សំគាល់ពីជ័យជំនះរបស់ព្រះរាម ដែលអវតាររបស់ព្រះវិស្ណុ ។ នៅផ្នែកខាងត្បូងគេបានឆ្លាក់ពីចំបាំងរបស់ Kurukshetra នៅឈុតចុងក្រោយនៃរឿងមហាភារត ដែលនាំយកទៅដោយ Pandava ចាកចេញពីគ្រឹស្នៈ ដែលជាអវតាមួយរបស់ព្រះវិស្ណុ ។ នៅថែវជ្រុងខាងត្បូងឈៀងខាងកើត គេបានឆ្លាក់នូវសមាសភាពចំលាក់មួយផ្ទាំង ដែលនិយាយពីទេវកថា នៃការកូរសមុទ្រទឹកដោះ ដោយអទិទេពព្រួតគ្នាបែបជាមិនធម្មតា នៃកំលាំងពួកគេជាមួយនឹងពួកសត្រូវ ដែលជាអសូរៈ ( Asura ) ។ ការកូរនេះ គឺដើម្បីរកអោយបានទឹកអម្រឹត ។

នៅក្នុងផ្នែកខាងលិច លើជញ្ជាំងថែវជ្រុងខាងត្បូង ត្រូវបានបើកចំហរដោយ " ក្បាច់ក្រឡោតទាបបែបប្រវត្តិសាស្ត្រ" ដែលយើងបានចុះនិទ្ទេសរួចហើយ ។ នៅជ្រុងខាងកើតនៃថែវដដែលបានបង្ហាញពីការកាត់ទោសនៃខ្មោចទាំងឡាយ ការស្នាក់នៅឋានសួគ៌ និង នៅឋាននរក ។ សមាសភាពនៃការ

ប្រតិបត្តិដ៏ល្អនូវគ្រប់ក្បាច់ក្រឡេកទាប គឺគួរអោយគេកោតសរសើរខ្លាំងណាស់ ។ ការលាតត្រដាងនៃខ្សែរឿងនៅលើផ្ទៃជញ្ជាំងយ៉ាងវែងនេះ វាមិនបានប្រទាញទៅរកភាពដដែលៗទេ ។

ផ្ទាំងក្បាច់ជាច្រើនបានឆ្លាក់ពីលើជញ្ជាំងទាំងពីរ នៅតាមជ្រុងរបស់មណ្ឌបនៃមុខខាងលិច ។ វាពុំមានភាពធំទូលាយដូចសមាសភាពរបស់ថែវទាំងឡាយទេ ។ វាបានចងភ្ជាប់ភាគច្រើនទៅនឹងឈុតឆាកទាំងឡាយនៃទេវកថារបស់ព្រះរាម ( Ràma ) ហើយនិងក្រឹស្នៈ ( Krishna ) ជានិច្ចកាលក៏មានឆាកពីរ បីនិយាយពីព្រះសិវៈ ដែលគេបានជួបប្រទះនៅទីនោះ ។ ការបាត់បង់នូវឈុតឆាកទាំងឡាយ បានបន្សល់ទុកនូវភាពសង្ខេបខ្លះ ប៉ុន្តែនៅលើរូបភាពទាំងឡាយ មិនសូវអចីកអចមទេ សិល្បៈករទាំងឡាយបានបោះបង់ចោល នូវការចំលងមនោរម្មណ៍ ក៏ដូចជាការនឹករឃើញពីអ្វីមួយ ។

នៅគ្រប់ជ្រុងនៃផ្លូវចូលទាំងឡាយ នៅលើជញ្ជាំងទាំងឡាយនៃគោបុរៈ ( Copura ) ( ទ្វារចូល ) តួប្រាសាទទាំងឡាយ ក៏ដូចជាចន្លោះបង្អួចនៃថែវខាងលើ គេបានឆ្លាក់ពីទេវតាជាច្រើន ។ ទេវតាភេទស្រីទាំងនោះ ជាអ្នកថែរក្សាប្រាសាទទាំងឡាយ បានលេចឡើងនៅក្នុងប្រាសាទផ្សេងៗទៀត ដូចជាភាពសមសួនជាឆ្មាំទោលឈរនៅក្នុងក្បាច់អង្កែលុង ( Niches ) ។ នៅប្រាសាទអង្គរវត្ត ឆ្មាំស្រីទាំងនោះបានឈរជាក្រុមៗពីរនាក់ ៣នាក់ ឬ ច្រើនពីនេះទៅទៀត ។ ជួនកាលញញឹម ជានិច្ចកាលនឹងនឹងនាងៗហាក់ដូចជានៅមើលថែទាំនៅចន្លោះពួកគេដែលឈរនោះ ។ សំលៀកបំពាក់ និង គ្រឿងអលង្ការរបស់ពួកគេមានការខុសប្លែកៗគ្នាដែរ បាញ់ចេញជាការស្នើ ប្រហែលជាទំនៀមទំលាប់ ដែលមានបច្ច័យដល់សំលៀកបំពាក់ទាំងឡាយទៅតាមតំបន់ខុសៗគ្នា នៃប្រទេសកម្ពុជា ហើយនិងម៉ូត ដែលជ្រើសរើសដោយយុវតីទាំងឡាយនាសម័យអង្គរ ។ ប្រពន្ធទាំង ១៦ ពាន់ របស់ក្រឹស្នៈ ជាអវតាទាំងឡាយដែលជាអ្នកបំរើរបស់អទិទេព ដែលជាម្ចាស់របស់ប្រាសាទ ។

៥- <u>ប្រាសាទអង្គរវត្ត ហើយនិងអត្ថន័យរបស់ប្រាសាទភ្នំ</u> :

ប្រាសាទអង្គរវត្ត គឺជាប្រាសាទភ្នំដ៏ល្អឯក ស្របទៅតាមលក្ខណៈភ្នំព្រះសុមេរុ ដែលសង់ឡើងរួមមានតួប្រាសាទប្រាំ រួមមានកំពស់ខ្ពស់ជាង ៦០ម ។ នៅក្រោមតួប្រាសាទកណ្តាល តាមការធ្វើកំណាយទាំងឡាយ គេបានរកឃើញនូវអណ្តូងមួយ ដែលចុះរហូតដល់កំពស់ដី ( ផ្នែកលើរបស់ដី ) នៅបាតអណ្តូងគេបានរកឃើញនូវគំនរកាក់មាស ដែលគេបញ្ចុះនៅពេលសាងសង់ ។

គេបានគិតថា ការស្ថិតនៅនៃអណ្តូងចំកណ្តាលប្រាសាទនេះ អាចអោយគេភ្ជាប់ទៅនឹងពិធីនៃពិភពជាច្រើនទៀត ឬ ក៏ប្រាសាទអង្គរវត្តបានបង្ហាញពីការបាត់បង់ ដែលគេអាចដាក់ចូលទៅក្នុងរបាយការណ៍ជាមួយនឹងមុខងារ ដែលជាប់ទាក់ទិនទៅនឹងពិធីបុណ្យសព ។ ផ្លូវចូលសំខាន់របស់ប្រាសាទគឺនៅទិសខាងលិច ដែលជាទិសរបស់ខ្មោច ។ មួយផ្នែកទៀត ដើម្បីលាតត្រដាងពីក្បាច់ក្រឡេកទាបនៅកំពែងទី ៣ គេត្រូវធ្វើតួប្រាសាទ ដោយដើរប្រកាន់យកខាងឆ្វេង គឺជាការដើរប្រទក្សិណាសំរាប់ពិធីបុណ្យខ្មោច ។ លោក G. Coedès បានចោទសួរជាបញ្ហា ប្រាសាទខ្មែរត្រូវបានសង់នៅលើគ្រឹះមួយខ្ពស់ ដែលមានមុខងារប្រាសាទ ឬ ផ្នូរខ្មោច ។

នៅក្នុងប្រាសាទខ្មែរជាច្រើន គេបានរកឃើញក្តារមឈូសអំពីថ្មជាច្រើន វែងហើយចង្អៀតជានិច្ចកាលប្រដាប់ដោយតំរបមួយ ហើយមានចោះប្រហោងនៅបាតរន្ធ សំរាប់បង្ហូរចេញ ។ ទំរង់នៃមឈូសទាំងនេះ បានអនុវត្តយ៉ាងជ្រាកដដល់រុយក្បាលខៀវ ។ នៅប្រាសាទបន្ទាយសំរែ គេបានរកឃើញនូវមឈូសមួយ ដែលទំនងមានការថែទាំ តំរបបិទជិត ហើយនៅផ្នែកខាងលើមានលំអដោយប្រហោងរាងការេធំល្មម ព័ទ្ធជុំវិញដោយក្បាច់លំអ ហើយផ្នែកបាតនៃមឈូស បានត្រូវលំអដោយក្បាលយក្ស ។ ទំហំ

របស់មឈូសនេះ អាចផ្ទុកបានខ្មោចមនុស្សម្នាក់ ។ លោក G. Coedès បានគិតថា គេបានដាក់ខ្មោចនៅក្នុងមឈូស ដោយមានលក្ខណៈដូចទារកនៅក្នុងគភ៌ ។ អំពើទាំងនេះត្រូវបានគេយកមកអនុវត្តន៍នៅក្នុងប្រទេសខ្មែរសម័យទំនើប ដោយគេបានដាក់សពស្តេចធម្មតា ឬ ក៏ព្រះមហាក្សត្រនៅក្នុងកោដិមួយ ដើម្បីធ្វើឈាបនកិច្ចនៅពេលក្រោយ ។ ប្រហោងដែលគេចោះនៅបាតមឈូស ប្រហែលជាចង្អូរសំរាប់បង្ហូរខ្ទុះចេញ ឯរន្ធនៅលើគំរបវិញ ប្រហែលជាសំរាប់ហូតក្រណាត់សំពត់ធ្វើពីសំឡីចេញ ដើម្បីចែកអោយអ្នកដែលនៅរស់ ដែលបានចូលរួមក្នុងពិធីបុណ្យសពនេះ ។ ដូច្នេះមឈូសទាំងនេះ គេគ្រាន់តែផ្ទុកខ្មោចតែមួយភ្លែត នៅពេលដែលមានមនុស្សជាច្រើនមកចូលរួមពិធីបុណ្យប៉ុណ្ណោះ ឯបុគ្គលដែលស្លាប់ទៅនោះត្រូវបានគេយកមកបូជានៅក្នុងឡ ដោយគ្មានក្តារមឈូសទេ ។ លោក G. Coedès បានគិតថា ប្រាសាទភ្នំដំបូង គឺម៉ុងខ្មោច ហើយនិងតួប្រាសាទទាំងឡាយនៃផ្នូរ ដែលគេតំកល់ព្រះសព ត្រូវបានគេធ្វើអោយពិសិដ្ឋ ដោយលើកឋានៈអោយទៅជាអទិទេពក្រោយពីការគោរពបូជា ក្រោយពេលសោយទិវង្គត់ទៅ ។

លោក J.Filliozat បានប្រៀបផ្ទឹមពីទំរង់ប្រាសាទភ្នំរបស់ខ្មែរថា គឺជាប្រាសាទមួយតូចសង់នៅពីលើផ្នូរទាំងឡាយ ដែលមានស្វាមីភ័ក្ត ដែលទទួលនូវទិក្ស ( diksha ) មានន័យថាជាការបញ្ចូលនូវសមាជិកថ្មី ដែលអត្តសញ្ញាណនៃស្តេចទាំងនោះ មាននិស្ស័យនឹងព្រះសិវៈ ហើយក្រោយពីសោយទិវង្គត់ទៅមិនត្រូវបានគេធ្វើឈាបនកិច្ចទេ ប៉ុន្តែត្រូវបានបញ្ចុះសពក្នុងដី ។ អត្ថបទទាំងឡាយជាភាសាសំស្ក្រឹត ៖ សពដែលគេបញ្ចុះក្នុងដីរូចនោះ ត្រូវបានគេសរសេរពីអាគមៈ ( Agama ) បញ្ជាក់ពីស្វាមីភ័ក្តនៅលើផ្នូរដែលមានភាពងាយស្រួលក្នុងការកសាងពីរ៉ាមីឌរាងជាថ្នាក់ៗ ហើយនៅពីលើនេះ គេអាចអភិសេកលិង្គមួយទៀត ។ តួប្រាសាទប្រហែលជាត្រូវបានអភិសេកជាមួយគ្នានេះដែរ ។ នេះជាការរៀបចំប្រាសាទភ្នំរបស់ប្រទេសកម្ពុជា ។

ពេលណាដែលមឈូសធ្វើពីថ្ម ពុំបានបង្ហាញភស្តុតាងអ្វីថាជាមុខងាររបស់វា សំរាប់ខ្មោចទេ ។ មួយក្នុងចំណោមមឈូសទាំងនោះ ដែលពុំមានគំរប ហើយលំអដោយក្បាច់ផ្ទេរណាព័ទ្ធជុំវិញប្រហែលជាមឈូសធម្មតាសំរាប់ដាក់ទឹក ។

សិលាចារឹកទាំងឡាយ បានអោយការណ៍ថា ជានិច្ចកាលស្តេចទទួល diksha នៅក្នុងខណៈពេលធ្វើពិធីប្រសិទ្ធិស្តេច ។ ក្នុងខណៈនោះ ព្រះអង្គដែលមានីកាយគោរពព្រះសិវៈនោះ ក្រោយពេលសោយទិវង្គត់ទៅ ព្រះកាយរបស់ព្រះអង្គមិនត្រូវបានគេធ្វើពិធីឈាបនកិច្ចទេ តែត្រូវបានគេតំកល់នៅលើម៉ុងរបស់ព្រះអង្គ ហើយពីរ៉ាមីឌត្រូវបានអភិសេកដោយតួប្រាសាទមួយ ដែលមានលិង្គមួយផង ។ យើងមិនបានក្រៀមក្រំដោយសារតែអ្វី ដែលគេត្រូវតែកាត់បន្ថយទាំងបង្វំ នូវគ្រឿងដំបូលទាំងពួង នៃប្រាសាទមួយដែលសង់នៅលើផ្នូរនៃគ្រប់ស្តេចទាំងឡាយ ។ ម្យ៉ាងទៀត ប្រាសាទភ្នំមិនមែនជាការបំបែកចេញមកពីផ្នូរខ្មោចទេ ។ ការស្ថាបនានៃតួប្រាសាទនៅពីលើផ្នូរខ្មោច អាចពន្យល់បានដោយឃ្លាមួយរបស់អ្នកដំណើរជាតិចិនឈ្មោះ ជីវតាក្វាន់ ដែលបានមកដល់ប្រទេសកម្ពុជានៅចុងសតវត្សទី ១៣ " សពព្រះមហាក្សត្រត្រូវបានគេបញ្ចុះនៅក្នុងតួប្រាសាទមួយ " ។

នៅប្រាសាទអង្គរវត្ត បញ្ហារបស់វាសាំញ៉ាំណាស់ ។ អទិទេពដែលរក្សាព្រះបាទសូរិយាវរ្ម័នទី ២ គឺជាព្រះវិស្ណុ ដែលព្រះអង្គមានមរណៈនាមថា បរមវិស្ណុលោក សំរាប់អះអាងបន្ថែម ។ វាជាការប្រាកដណាស់ មានរូបវិស្ណុមួយ ដែលត្រូវបានគេគោរពបូជា តំកល់នៅតួប្រាសាទកណ្តាល ប៉ុន្តែនៅពីក្រោមនេះគេបានកសាងរូបអទិទេព ? អស់រយៈកាលជាច្រើនសតវត្សមកហើយ តួប្រាសាទកណ្តាលមិនត្រូវបាន

បិទបាំងពីអទិទេពទេ ដែលគេបានរកឃើញមានស្លាកស្នាមមួយ បច្ចុប្បន្នគឺជារូបព្រះពុទ្ធ ដែលទទួលយកនូវពិធីក្នុងសាសនា នៅជាន់ខាងលើនៃប្រាសាទ ។ ប៉ុន្តែអនុស្សាវរីយ៍នៃមុខងាររបស់ពិធីបុណ្យសពនេះ បានស្ថិតនៅក្នុងទំនៀមទំលាប់ប្រពៃណីរហូតមកដល់ចុងសតវត្សទី ១៨ ដោយហេតុថា កំណត់ហេតុរបស់លោកជីវតាក្វាន់ បាននាំយករឿងដែលបានមកពីការព្រះដោយបានបញ្ជាក់ថា " ផ្នូររបស់ Lou Pan ស្ថិតនៅចំងាយប្រហែល ILi នៃទ្វារខាងត្បូង ហើយនៅជុំវិញមានប្រវែង ១០ li " ។ លោក P.Pellot ដែលបានផ្សាយជាសាធារណៈ អំពីការបកប្រែអត្ថបទរបស់ជីវតាក្វាន់នេះបានគិតថា Lou Pan គឺជាសិល្បៈករចិនមួយរូបដ៏អស្ចារ្យ ជាអ្នកនិពន្ធពីស្ថាបត្យករអទិទេពវិស្វក្មវ៍ន ( Viçvakaman ) ដែលជាជីវប្រវត្តិនៃសន្តបុគ្គលកម្ពុជាតំរូវលើការស្ថាបនាប្រាសាទអង្គរវត្ត ។

៦- <u>ប្រាសាទទាំងឡាយនៅក្នុងសម័យអង្គរវត្ត</u> :

នៅក្នុងតំបន់អង្គរមានប្រាសាទជាច្រើន ដែលបង្ហាញអោយដឹងថា បានត្រូវកសាងឡើងនៅដើម និង នៅពាក់កណ្តាលសតវត្សទី ១២ ប៉ុន្តែវាមានការអាក់ខានខ្លះពីសិលាចារឹក គេមិនអាចចាត់ទុកចូលទៅក្នុងរាជរបស់ព្រះបាទសូរិយាវរ្ម័នទី ២ បានទេ ។ នៅភាគខាងកើតធានីអង្គរ នៅសងខាងស្ពានផ្លូវចាស់ដែលតាមអ័ក្សរបស់រាជវាំង មានលេចឡើងនូវប្រាសាទពីរធ្វើពីថ្មភក់ គឺប្រាសាទធម្មនន្ទ ( Thommanan ) និង ចៅសាយទេវតា ។ ប្រាសាទទាំងពីរនេះ រួមមានតួប្រាសាទមួយដែលនៅជាប់ខាងមុខមានបន្ទប់សំរាប់ពិធីសាសនា មានបណ្ណាល័យមួយ និងកំពែងព័ទ្ធជុំវិញមួយ ដែលមានរោងសំរាប់ធ្វើគោបុរៈ (ទ្វារ)។

នៅទិសខាងកើត មិនឆ្ងាយប៉ុន្មានពីបារាយណ៍ខាងកើត មានប្រាសាទបន្ទាយសំរែមួយទៀតដែលមានទំរង់លក្ខណៈដូចគ្នា ហើយដែលគួរអោយគោរព ។ តួប៉មកណ្តាលរបស់ប្រាសាទនេះ បានសង់ជាប់ពីក្រោយបន្ទប់ សំរាប់ធ្វើពិធីសាសនា ហើយមានបណ្ណាល័យពីរនៅអមសងខាង និង ព័ទ្ធជុំវិញដោយកំពែងពីរជាន់ ( double ) ។ គេអាចទៅដល់ប្រាសាទនេះបានតាមផ្លូវដែលមានក្រាលថ្ម ហើយនិងទីលានមួយទៀត ដែលគួរអោយស្ញើចសរសើរ ។

នៅក្នុងធានីអង្គរធំ ប្រាសាទព្រះពិធូ T និង U ក៏មានចុះកាលបរិច្ឆេទរួមជាមួយ និង យុគសម័យនេះដែរ ។ ប្រាសាទទាំងពីរនេះបានសង់នៅភាគខាងជើង នៃប្រាសាទឃ្លាំងទាំងពីរ ។ ប្រាសាទទាំងបីនៅផ្នែកខាងក្រៅធានីនេះ គឺជាប្រាសាទព្រហ្មញ្ញសាសនា ។ នៅខាងជើងព្រះរាជវាំងមានប្រាសាទមួយទៀត ដែលប្រហែលជាសាងឡើងនៅក្នុងសម័យនេះដែរ ។ គឺប្រាសាទព្រះពុទ្ធសាសនាមួយឈ្មោះ ព្រះប៉ាលិល័យ ដែលឈ្មោះត្រូវបានគេហៅតាមឈុតមួយនៃពុទ្ធប្រវត្តិ ដោយមានជាប់ទាក់ទិនទៅនឹងជីវិតរបស់ព្រះពុទ្ធ ៖ អំណោយដែលបានប្រគេនដោយដំរីមួយឈ្មោះ ប៉ារិលេយ្យ (Parileyya ) ហើយនិងស្វាមួយក្បាលទៀត ដែលជាសហជីវិនរបស់ខ្លួន ។ លោក G. Coedès បានអោយយោបល់ថាប្រាសាទព្រះប៉ាលិល័យ ប្រហែលជាអាចសាងសង់ដោយព្រះបាទជ័យវរ្ម័នទី ៨ ។ វាហាក់ដូចជាងាយស្រួលក្នុងការបង្ហាញអំពីកាលបរិច្ឆេទមុនសម័យនេះ ។

ការខ្វះខាតនូវពត៌មានទាំងឡាយ ពីសិលាចារឹកនៅក្នុងប្រាសាទនេះ ពុំបានបង្ហាញអោយយើងដឹងពីពិធីសាសនាទាំងឡាយ ដែលមានប្រារព្ធនៅទីនេះ ឬ ក៏អទិទេពអ្វីដែលត្រូវបានគេគោរពដែរ ។ ភាពរួមរបស់ប្រាសាទទាំងអស់នេះ មិនទំនងជាត្រូវសាងសង់ឡើងមុនប្រាសាទអង្គរវត្តទេ ។

៧- <u>សង្គមខ្មែរនៅសតវត្សទី ១២ តាមការពិនិត្យលើក្បាច់ក្រឡោតទាបនៅប្រាសាទអង្គរវត្ត</u> :

បដិមាសាស្ត្រនៅសតវត្សទី ១០ និងទី ១១ មិនបានធ្វើអោយយើងសិក្សាពីវត្ថុអ្វីប្រាកដទៅលើជីវភាពប្រជាជនខ្មែរកាលនៅជំនាន់នោះទេ ។ នៅប្រាសាទអង្គរវត្ត ទោះបីមានផ្ទាំងក្បាច់ក្រឡោតទាបធំៗ

លាតបង្ហាញនៅគ្រប់ជ្រុងនៃក្បូនដង្ហែរស្តេច សមាសធាតុទាំងឡាយនៃរឿងរ៉ាវទេវកថា ឬ ក៏ពាក្យកាព្យដែលមានលាបពណ៌ សំរាប់បញ្ជាក់ជាការធ្វើឡើងដោយការផុសគំនិតចេញមកពីសិល្បៈករ ទៅតាមល្បែងនៃជីវិត ។

នៅប៉ែកខាងលិចនៃក្បាច់ក្រឡោតទាប "ប្រវត្តិសាស្ត្រ " បានបង្ហាញពីព្រះបាទសូរិយាវរ្ម័នទី ២ នៅចំកណ្តាលព្រះរាជនិវេសន៍របស់ព្រះអង្គ ។ ស្តេចគង់តាមលក្ខណៈបែបឥណ្ឌា គឺអង្គុយពែនភ្នែននៅលើអសនៈមួយ លំអដោយសត្វនាគ នៅពីក្រោមព្រះអង្គបានបង្ហាញអោយឃើញនូវអ្នកបាំងក្លស់ អ្នកបក់ផ្លិត និង អ្នកបក់រុយ ។ នៅពីខាងមុខព្រះអង្គមានមនុស្សជាច្រើនអង្គុយលុតជង្គង់ធ្វើគារវកិច្ចជាមួយព្រះអង្គ ។ នៅជុំវិញព្រះអង្គមានសមាជិកនៃព្រះរាជនិវេសន៍ នៅក្នុងចំណោមមនុស្សទាំងនោះ គេបានស្គាល់ជាងគេ គឺព្រាហ្មណ៍ជាច្រើននាក់ទៀត ។ ព្រះភ័ក្ត្ររបស់ព្រះអង្គរាងទ្រវែង ច្រមុះល្មិត កោងបន្តិចដែលមានលក្ខណៈដើមជាប្រជាជនឥណ្ឌា ហើយគ្រប់គ្នាទាំងអស់មានសក់វែង ។ ពិតប្រាកដណាស់ពួកគេស្លៀកសំពត់ក្រណាត់ ដោយមានការតុបតែងយ៉ាងសំបូរបែប ហើយមានផ្នត់រាប ។ ពួកព្រាហ្មណ៍របស់ព្រះអង្គទាំងនោះ មានឯកសណ្ឋានខុសពីគេ ដែលគេដឹងថា ជាមន្ត្រីថ្នាក់ខ្ពស់ ។ មនុស្សផ្សេងទៀតស្លៀកសារុងធម្មតា មានលំអនៅគ្រប់កន្លែងគ្មានសេសសល់ ឯឥសិរបស់ព្រះអង្គកំពុងអង្គុយប្រឡេះគ្រាប់ផ្លាំ ១ - ២...... ។

នៅខាងលើស្តេចមានជននឹករដែលជាអ្នកប្រាជ្ញ ដោយមានកាន់កេតភ័ណ្ឌផង ។ ស្ត្រីទាំងឡាយដែលចូលរួមក្នុងព្រះរាជនិវេសន៍នេះ មានពាក់ម្កុដអំពីលោហៈធាតុដ៏មានតំលៃនៅលើថ្ងាសដ៏ហ៊ឺហា ហើយនៅលើស្មាលំអដោយខ្សែកយ៉ាងសំបូរបែប ឯអ្នកកាន់ដង្វាយទាំងឡាយមានខ្សែក ច្រវ៉ាក់ ឬ ក៏កងធម្មតាធ្វើពីលោហៈនៅជុំវិញក ។ ប្រសិនបើអ្នកណាម្នាក់ពុំមានការលំអនៅលើសក់ទេ នោះគេត្រូវតែរកអ្វីដែលជាភាពសង្ហារផ្សេងទៀតមកជំនួស ។

នៅក្នុងខណៈនោះ ស្តេចក្រោយពីការទទួលធ្វើគារវកិច្ច និង សួយសារអាករ ដែលបានមកពីព្រះរាជនិវេសន៍ទាំងឡាយនោះ ព្រះអង្គ និងប្រុងប្រៀបរៀបចំចាកចេញពីរាជធានីរបស់ព្រះអង្គ ។ ក្រោយពីបានទស្សនានូវទស្សនីយ៍ភាពនៅក្នុងរាជវាំងនៅធានីអង្គរមក យើងក៏បានបន្តទៅមើលពីក្បួនដង្ហែរមួយដែលបានបង្ហាញពីព្រះបាទសូរិយាវរ្ម័ន ចាកចេញពីធានីយសោធរបុរៈ ដើម្បីទៅច្បាំងជាមួយពួកចាមពួកវៀតណាម ឬ ក៏ពួកមននៅទន្លេមេណាម ។ មេទ័ពឈរនៅលើខ្នងដំរីយ៉ាងឱឡារិក ដោយនៅជុំវិញមានអ្នកបរទេះពីរនាក់ ហើយនិងអ្នកដើរក្បួនព្យុះហយាត្រាជាដំណើរក្អែក នៅមុខក្បួនដង្ហែរ មានដើរក្បួនខុសប្លែកពីគេ ដែលមានមុខដូចពួកម៉ុងហ្គោលី ។ សក់របស់ពួកគេបួងឡើងដោយមានលំអដោយស្លាបសត្វ ឬ ក៏ស្លឹកឈើ ហើយសំលៀកបំពាក់របស់ពួកគេ គឺជាសំពត់ហ៊្វើបលំអដោយកំរងមាលាយ៉ាងវែង ។ មានសិលាចារឹកខ្លីមួយ ដែលធ្វើអោយយើងបានយល់ពីរូបភាពនៅទីនេះ គឺជាយុវជនសៀម ដែលបានត្រូវកេណ្ឌមកអោយធ្វើទាហាន ។ អ្នកចំបាំងផ្សេងៗទៀត មានពាក់មួកកាតិបគួរអោយចាប់អារម្មណ៍ គឺមានបណ្ឌិតពីលើដោយរបុំស្លាបសត្វ ក្បាលសត្វ ស្លាប ឬ ក៏ក្បាលសត្វព្រៃ ( ម្រឹគ ) ។ នៅដៃរបស់ពួកគេមានកាន់លំពែង និង ខែល ហើយជាទូទៅនៅលើករបស់ពួកគេមានពាក់ខ្សែកមួយទៀត ដោយមានប្រយុទ្ធកូនកាំបិតស្លៀតមួយផង ។

នៅនឹងដៃនៃនាយទាហានទាំងឡាយមានកាន់ធ្នូ និង ព្រួញ ខ្លះមានខែល និង កាំបិតផ្គាក់ដែលមានផ្លែរាងខុប ដោយដងរបស់វាធ្វើពីឈើវែង ។ នាយទាហានទាំងនោះឈរនៅលើខ្នងដំរីរបស់ពួក

គេ ។ ចំនួនក្អមទាំងឡាយ ដែលមនុស្សកាន់នៅជុំវិញពួកគេ បញ្ជាក់ប្រាប់អោយដឹងពីឫកពារថ្លៃថ្នូរបស់ពួកគេ ។

ការចេញទៅធ្វើសង្គ្រាម ដូចមានបញ្ជាក់នៅក្នុងសៀវភៅសាសនា វាដូចដែលយើងបានឃើញនៅទីនេះ គឺមានព្រាហ្មណ៍ទៅតាមជាមួយ ដោយជិះលើគ្រែស្នែង វាដូចនឹងលក្ខណៈដែលបានបញ្ជាក់នៅក្នុងសិលាចារឹក គឺពួកនេះបានរក្សាទុកនូវភ្លើងពិសិដ្ឋ ។ ចុងបញ្ចប់នៅប្រទេសកម្ពុជាបានសេចក្តីសុខសប្បាយរីករាយ មិនត្រូវបានឃ្លាតឆ្ងាយពីច្បាប់ទេ អ្នកលេងកល្បិចទាំងឡាយ ពួកត្លុកកំប្លែងទាំងឡាយនិយាយលើកដៃលើកជើង និង វាយឫកតាមបែបការចេះគួរសម ហើយប្រជាជនក៏បានសំលឹងមើលយ៉ាងយកចិត្តទុកដាក់ នូវក្បួនព្យុះហយាត្រានេះ ។

ឯកសារដ៏ចំលែកនេះ ដែលធ្វើអោយយើងបានយល់ជ្រាបដល់បេះដូង ក៏ដូចជាធាតុទាំងមូលដែលពុំមែនមានតែកស្តុតាងនៅប្រាសាទអង្គរវត្ត ដែលបង្ហាញពីជីវភាពខ្មែរនៅសតវត្សទី ១២ នោះទេ ក្បាច់ក្រឡោតទាបផ្សេងៗទៀត ក៏មានបង្ហាញពីអ្នកស្រុក និង ពីសំណង់នៃការរៀបចំក្រុងផងដែរ ។ នៅក្នុងឱកាសនេះគេក៏មានបង្ហាញពីទេវកថា គេឃើញអ្នកគង្វាលនៅក្បែរហ្វូងសត្វរបស់ពួកគេ ឥសីកំពុងតែនិយាយរៀបរាប់នៅក្នុងរូងភ្នំ ឬ ក៏អ្នកប្រម៉ាញ់នៅក្នុងព្រៃ ។ ការបង្ហាញពីសំណង់ទាំងឡាយនោះ មិនសូវពានទេ ហើយនិងភាពសំខាន់នៃភាពសង្ហា នៃមណ្ឌបរបស់រាជវាំង ការរស់នៅរបស់អ្នកស្រែពុំមានបង្ហាញអោយឃើញនៅប្រាសាទអង្គរវត្តទេ ។

ភាពស្អាតបាតនៃសំណង់ ត្រូវបានគេបង្ហាញជារូបភាពស្ថាបត្យកម្មលើទឹក វាបានធ្វើអោយវិថីរួមត្តនូវិមានលើសំពៅ ដែលដំបូលបើក " ជារបស់ប្រជាជនចិន " ដោយបង្អួចមានចំរឹងសំរាប់ការពារ ។ នៅក្នុងខណៈនោះ អ្នកថែវមានការហាត់នឿយ ឯមនុស្សនៅខាងកន្សៃទូក កំពុងតែភ្នាល់នៅជុំវិញវង់ជល់មាន់មួយ ដោយភ្នែករបស់ពួកគេកំពុងតែចាប់អារម្មណ៍យ៉ាងខ្លាំង ហើយមានឪពុកម្នាក់ កំពុងតែអៀវកូនពីរនាក់នៅលើខ្នង ។ នៅខាងក្នុងវិមាននៃសំពៅមានមនុស្សពីរនាក់ កំពុងតែអង្គុយលេងអុក ។ នៅផ្នែកខាងមុខមានពួកត្លុកកំប្លែងកំពុងតែបញ្ចេញកាយវិការលើកដៃលើកជើង នៅជិតមនុស្សម្នាក់ឈរយកខ្យល់អាកាសដោយមានកាន់បំពង់បឺតទឹកនៅក្នុងដបមួយ ។ ចំលាក់នៃសំពៅនេះ គឺជារូបភាពរចនានូវទស្សនីយភាពជីវភាពប្រចាំថ្ងៃ ក្រោមក្រសែភ្នែករបស់សិល្បៈករនៅស្ទឹងសៀមរាប ឬ ក៏នៅបឹងទន្លេសាប ។

ចុងបញ្ចប់នៃក្បាច់ទាំងឡាយនៅប្រាសាទអង្គរវត្ត បានផ្តល់អោយយើងយ៉ាងច្រើននូវរូបភាពនៃជីវភាពក្នុងគ្រួសារ ៖ ទីនេះមានស្រីម្នាក់កំពុងដក់ទៅរកកូនក្មេងម្នាក់ ហើយនៅទីនោះមានបុរសម្នាក់បានលែងកូនប្រុសរបស់គាត់ ដែលកំពុងតែអង្គុយត្បោងកាលផង្គង់ទល់ខ្នងជាមួយនឹងគាត់ ។ គុណវិបត្តិនៃផ្ទាំងចំលាក់ដែលរៀបរាប់ពីជីវភាពប្រចាំថ្ងៃនេះ សិល្បៈករទាំងឡាយបានជួបនូវបរិយាកាសគ្រួសារនៃប្រជាជនខ្មែរ ។

៨- សារៈសំខាន់នៃសាសនានៅប្រាសាទអង្គរវត្ត :

ការចាប់ផ្តើមនៃចំលាក់រឿងរ៉ាវ ដែលទាក់ទងទៅនឹងជីវភាពគ្រួសារ និង ជីវភាពអ្នកស្រុកនេះ គឺជារបាយការណ៍ជាមួយនិងការអភិវឌ្ឍន៍ នៃពិធីគោរពបូជាក្នុងសាសនារបស់ក្រឹស្នៈ ( Krishna ) ។ នៅប្រាសាទអង្គរវត្តក៏បានបង្ហាញពីក្បាច់ក្រឡោតទាប ស្តីពីឈុតរបស់វីរៈជនវ័យក្មេងនេះដែរ ដែលជាអវតារបស់ព្រះវិស្ណុ ។ នៅមណ្ឌបនៃជ្រុងខាងត្បូងឈៀងខាងកើត គេឃើញព្រះក្រឹស្នៈកំពុងតែលួចទឹកដោះគោ ( beure ) ហើយនៅមណ្ឌបជាមួយគ្នានេះដែរ នៅលើផ្តែទ្វារជាច្រើនទៀត និង នៅលើសសរផ្ចោង គេបានឆ្លាក់រូបភាពរបស់ក្រឹស្នៈលើកភ្នំគោវ្រធនៈ ( Govardhana ) ដើម្បីការពារហ្វូងសត្វ និង អ្នក

គង្វាលកុំអោយទទួលរងនូវភ្លៀង និង រន្ទះដ៏ខ្លាំងក្លារបស់ព្រះឥន្ទ្រ ។ ការវិវត្តន៍នូវខ្សែរឿង របស់ក្រិស្នះ មិនត្រូវបានបោះបង់ចោលនៅក្នុងស្រមោល នៃអវតារផ្សេងៗទៀតទេ ។ ការបង្ហាញឡើងវិញ នូវរឿង រាមកេរ្តិ៍ ដោយខ្សែកក៏បានប្រកាន់យកនូវកន្លែងមួយ ដែលនាំអោយគេយកចិត្តទុកដាក់ពីទេវកថានៅ ប្រាសាទអង្គរវត្ត ។

គ្មានទេនៅប្រទេសកម្ពុជា ដែលមានប្រាសាទឧទ្ទិសទៅព្រះវិស្ណុ អាចមកប្រៀបធៀបជាមួយ ប្រាសាទអង្គរវត្តបានទេ ។ ការតំរង់ទិសថ្មីនៃសាសនានេះ ប្រាកដជាត្រូវបានដាក់ទៅក្នុងរបាយការណ៍ ជាមួយចលនាសម្បត្តិ ទស្សនវិជ្ជាដែលតំនួរនេះនៅប្រទេសឥណ្ឌាដើមសតវត្សទី ១២ បានធ្វើរូបភាព ដោយសាសនាវិទូ រាមនុជះ ( Ramanuja ) ។

វាទំនងដែលក្នុងកំឡុងពេលយ៉ាងខ្លីនោះ ភាពវាំសរវៃប្រតិបត្តិតាមរបស់ប្រាសាទអង្គរ វាបាន ឆ្លងកាត់នៃព្រំដែនទាំងឡាយរបស់ប្រទេសកម្ពុជា ហើយក៏ដូចជានៅអាស៊ីអគ្នេយ៍ទាំងមូលដែរ ។ នៃគូម្រ បូរណៈ ( Kurmapurana ) លោក J. Filliozat បានដកស្រង់សេចក្តីពីក្នុងអត្ថបទមួយ ដែលជា របាយការណ៍របស់លោកនៅ Harivarsha គឺ "ឧបទ្វីប Hari ( ហរិ ) ( : Vishnu ) " ។ អត្ថបទនេះ អាចបូកបញ្ចូលភាពយ៉ាងយឺត និង បូរណ ( Purana ) នោះដែលពិតជាកើតមុនសតវត្សទី ១២ ដូច្នេះការ ចង្អុលបង្ហាញរបស់លោក J. Filliozat អំពីការឆ្លងកាត់របស់ Kurmapurana គឺពិពណ៌នាអំពីប្រាសាទ របស់វ៉ាសុទេវៈ ( Vasudeva ) = ( Vishnu ) គឺជាការពន្យល់យ៉ាងល្អពីប្រាសាទអង្គរវត្ត ៖

XLVII,10 " ទីនេះ ដែលចាំងរស្មីដូចព្រះច័ន្ទភ្លឺ ដែលដូចជាត្បូងកែវបរិសុទ្ធ គឺជាតួប្រាសាទ វ៉ាសុទេវៈ គាំទ្រដោយឈើប៉ារិជាតៈ ( Parijata ) ។

១១- ដោយទ្វារ ៤ ពុំអាចប្រៀបបាន បានផ្គត់ផ្គង់នូវគ្រឿងចាំបាច់ដល់ទ្វារទាំង ៤ ផ្គត់ផ្គង់ នូវគ្រឿងចាំបាច់ដល់កំពែងទាំងនោះ ។

១២- ផ្គត់ផ្គង់នូវគ្រឿងចាំបាច់ដល់សាលទូលាយអំពីថ្មកែវ ដូចគ្នានឹងគ្រឹះស្ថានធំៗរបស់ស្តេច អទិទេពទាំងឡាយ លំអនៅគ្រប់ទិសដោយសសររាប់ពាន់អំពីមាស ។

១៣- ផ្គត់ផ្គង់នូវគ្រឿងចាំបាច់ដល់ជណ្តើរទាំងឡាយ ភាពស្រឡះដល់គ្រប់រតនៈវត្ថុសព្វបែប យ៉ាង បានផ្គត់ផ្គង់ដល់បល្ល័ង្កជាទម្ររបស់អទិទេព មាននិស្ស័យទៅគ្រប់សំរស់ទាំងអស់ ។

១៤-១៥- ភាពស្រឡះនៃបឹង និង ស្ទឹងទាំងឡាយ ដែលទឹកមានឱជារស ហើយបំពេញទៅ ដោយយោគិន ( Yogin ) ( : អ្នកប្រព្រឹត្តយោគជាប្រតិបត្តិ ) តាំងសច្ចាប្រណិធានទាំងស្រុងចំពោះ ណារាយនៈ ( Narayana ) បរិសុទ្ធទាំងអស់ គ្រប់ការរវល់នៃការសូត្រទាំងឡាយអំពីវេទៈ ( Veda ) ការ ភាវនានៅលើហរិ ។

១៦- ហើយបរិបូណ៌ដោយសំរស់ ដែលជាទីនាំអោយត្រេកត្រអាល នៃស្ត្រីទាំងឡាយ ច្រៀង និង រាំដោយពណ្ណរាយនៃយុវជនក្មេងទាំងឡាយ ជារឿយៗតែងតែសច្ចាប្រណិធានទៅរកភាពយ៉ាង ស្រឡះជានិច្ច ។

យ៉ាងប្រាកដណាស់ ចំនួននៃកំពែងទាំងឡាយ ការបំប្លែសខ្លះ យ៉ាងប្រាកដណាស់អ្នកតែងនិពន្ធ បានលើកតំកើងនូវសំភារៈទាំងឡាយ ដោយនិយាយថាជាត្បូងកែវ ហើយការពិពណ៌នាអំពីមាស ទាំងនេះ ពុំមានធ្វើអំពីមាសទេ ។ មាសហើយនិងរតនៈវត្ថុទាំងឡាយ ត្រូវបាត់បង់អស់ ប៉ុន្តែឥសីទាំងឡាយទំនង ជានៅភាវនារាល់ថ្ងៃ ព្រោះគេឆ្លាក់នៅផ្នែកខាងក្រោមសសរ និង ទេវតាក៏ដូច្នោះដែរ "បរិបូរណ៍ទៅដោយ សំរស់គួរជាទីត្រេកត្រអាល " ជានិច្ចកាលស្រឡាញ់ចូលចិត្តនូវជញ្ជាំងទាំងឡាយរបស់ប្រាសាទ ។

## ជំពូក V
## គោណហល់ជាំខក្សាយនៅសតវត្សទី ១២ ហើយ និងព្រឹត្តិការណ៍របស់ព្រះបាទជ័យវរ្ម័នទី ៧

### ១- អ្នកស្នងរាជបន្តពីព្រះបាទ សូរិយាវរ្ម័នទី ២ :

នៅចន្លោះឆ្នាំ ១១៤៥ គឺជាកាលបរិច្ឆេទចុងក្រោយ ដែលគេបានដឹងថា ជារជ្ជកាលរបស់ព្រះបាទសូរិយាវរ្ម័នទី ២ និងឆ្នាំ ១១៨១ ជាកាលបរិច្ឆេទរបស់ព្រះបាទជ័យវរ្ម័នទី ៧ រាជាណាចក្រខ្មែរនៅមានជីវិតនៅឡើយ ដោយជួបនឹងភាពជ្រួលច្របល់ ដែលពេលនេះយើងពុំបានដឹងពត៌មានអ្វីអោយច្បាស់លាស់ទេ ។ យើងពុំបានដឹងពីការសោយទិវង្គត់របស់ព្រះបាទសូរិយាវរ្ម័នទី ២ ទេ ។ មានគ្រប់កន្លែងទាំងអស់ ដែលបញ្ជាក់ថា ព្រះអង្គបានសោយទិវង្គត់ក្នុងចន្លោះឆ្នាំ ១១៥០ និងឆ្នាំ ១១៥៥ ។ រាជទូតខ្មែរម្នាក់ ត្រូវបានបញ្ជូនទៅស្រុកចិនក្នុងឆ្នាំ ១១៥៥ មានប្រាស្រ័យគ្នាល្អនៃរាជថ្មី ។

លោក G. Coedès បានធ្វើអធិប្បាយយ៉ាងចំឡែក អំពីរាជស្តេច ៤ រាជ ក្រោយពីព្រះបាទសូរិយាវរ្ម័នទី ២ សោយទិវង្គត់ទៅ ហើយព្រះបាទធរណិន្ទ្រវរ្ម័នទី ២ ក៏បានសោយរាជ្យរហូតដល់ឆ្នាំ ១១៦០ ព្រះបាទយសោវរ្ម័នទី ២ ដែលទំនងខុសពីធម្មតា ហើយនិងចូលទិវង្គត់វិញក្នុងឆ្នាំ ១១៦៥ ដោយអ្នកដណ្តើមរាជម្នាក់ឈ្មោះ ទ្រិភវណអាទិត្យវរ្ម័ន ( Tribhuvanadityavarman ) ដែលខ្លួនព្រះអង្គបានសំលាប់អ្នកកាតក្បាត គឺពួកចាមក្នុងឆ្នាំ ១១៧៧ ហើយនៅចុងក្រោយគេ គឺព្រះបាទជ័យវរ្ម័នទី ៧ សោយរាជ្យបន្ត ។ ស្តេចចុងក្រោយនេះ គឺត្រូវជាបុត្ររបស់ព្រះបាទ ធរណិន្ទ្រវរ្ម័នទី ២ ( Dharnindra varman II ) បានធ្វើអោយប្រទេសខ្មែរមានសេរីភាព ដោយមានការទៅប្រទេសចាម ហើយត្រូវបានអភិសេកអោយឡើងគ្រងរាជ្យក្នុងឆ្នាំ ១១៨១ ។ វាទំនងជាមានចំងល់យ៉ាងខ្លាំងដែលព្រះបាទជ័យវរ្ម័នទី៧ ពុំបានស្នងរាជបន្តផ្ទាល់ពីបិតារបស់ព្រះអង្គទេ ។ លោក G. Coedès បានពន្យល់ថា ការស្នងរាជបន្តនេះ តាមលក្ខណៈមិនធម្មតា ដោយសារអវត្តមាននៃស្តេចនេះ គឺជាប់រវល់ធ្វើចំបាំងជាមួយពួកចាមនៅចំប៉ា ដែលកាលនោះ គឺជាព្រឹត្តិការណ៍របស់ព្រះបាទយសោវរ្ម័នទី ២ ។ ក្នុងខណៈនេះលោក J. Boisselier បានទាយថា អនាគតព្រះបាទជ័យវរ្ម័នទី ៧ ពុំមានមូលហេតុយកអំណាចនៅឆ្នាំ ១១៦០ ទេ អញ្ចឹងគាត់គិតថា ព្រះបាទធរណិន្ទ្រវរ្ម័នទី ២ មិនអាចធ្វើជាស្តេចនៅប្រទេសកម្ពុជាបានសោះនោះទេ ។

### ២- តើអ្នកណាជាព្រះបាទ ធរណិន្ទ្រវរ្ម័នទី ២ ?

យើងបានទទួលយកមកភ្លាម នូវភស្តុតាងទាំងឡាយ ដែលលោក J.Boisselier បានគិតគូរជាដំបូង ដើម្បីលុបចោលឈ្មោះព្រះបាទ ធរណិន្ទ្រវរ្ម័នទី ២ ចេញពីបញ្ជីឈ្មោះស្តេច នៃប្រទេសកម្ពុជា ។ គេបានស្គាល់ព្រះបាទ ធរណិន្ទ្រវរ្ម័នទី ២ តាមរយៈសិលាចារឹកទាំងឡាយ ដែលព្រះអង្គបានបង្កើតអោយមានបុត្រាមួយព្រះអង្គ គឺព្រះបាទជ័យវរ្ម័នទី ៧ ។ ព្រះអង្គមានអំបូរជាប់មកពីខាង មហិនធរបុរៈ ( Mahindharapura ) ។ អត្ថបទនៃសិលាចារឹកទាំងឡាយ បានសង្កត់លើការពិនិត្យពិច័យលើកទីមួយ ។ ព្រះបាទធរណិន្ទ្រវរ្ម័ន បានបន្តរាជទៅអោយព្រះបាទជ័យវរ្ម័នទី ៧ សោយរាជ្យបន្ត ប៉ុន្តែព្រះអង្គពុំមានឈ្មោះនៅក្នុងបញ្ជីឈ្មោះព្រះមហាក្សត្រជាអ្នកស្នងរាជបន្តពីព្រះបាទសូរិយាវរ្ម័នទី ២ ទេ ។ ម្យ៉ាងទៀត ព្រះបាទធរណិន្ទ្រវរ្ម័នទី ២ ពុំបានទទួលយកនូវមរណៈនាមអ្វីទេ ។ អទិទេពដែលព្រះអង្គគោរពបូជាក្នុងសម័យនោះមានឈ្មោះថា ជ័យវរ្មេស្វរៈលោកេសៈ ( Jayavarmçvaralokeça ) "លោកេសៈជាម្ចាស់

របស់ជ័យវរ្ម័ន " នេះពុំមែនជាមរណៈនាមរបស់ព្រះមហាក្សត្រទេ ប៉ុន្តែគឺជាអទិទេព ដែលដាក់នៅក្រោមកិច្ចគាំពាររបស់ព្រះបាទជ័យវរ្ម័នទី ៧ ។ ចុងបញ្ចប់ព្រះអង្គបានធ្វើអោយគេភ្ញាក់ផ្អើលយ៉ាងខ្លាំង ដោយព្រះអង្គជាមាតា និង បិតារបស់ព្រះបាទជ័យវរ្ម័នទី ៧ បានទទួលរាជកិច្ចជាការគួរសមដោយបានសាងសង់ប្រាសាទទី ១ គឺប្រាសាទតាព្រហ្ម ទី ២ ប្រាសាទព្រះខ័ន ។ វាមិនសូវចំឡែកពីគេទេ ដែលការសាងសង់ប្រាសាទព្រះខ័ន គឺដើម្បីឧទ្ទិសទៅដល់ព្រះបាទ ធរណិន្ទ្រវរ្ម័ន ហើយបានត្រូវកសាងនៅឆ្នាំ ១១៩១ គឺ ១០ឆ្នាំ ក្រោយពីពិធីអភិសេកឡើងសោយរាជ្យរបស់ព្រះអង្គ ហើយប្រាំឆ្នាំក្រោយមកទៀត ព្រះបាទជ័យវរ្ម័នទី ៧ បានសាងប្រាសាទមួយទៀត ដើម្បីឧទ្ទិសទៅដល់ព្រះមាតារបស់ព្រះអង្គដែរ ។

គ្រប់ចំណេះដឹងទាំងអស់ ដែលគេបានកត់សំគាល់នៅក្នុងសំដីអួតសរសើរអំពីព្រះបាទជ័យវរ្ម័នទី ៧ ដែលព្រះមាតារបស់ព្រះមហាក្សត្រ ជាអ្នកបន្តវង្សត្រកូលដ៏មានតេជានុភាពជាងព្រះអគ្គមហេសីរបស់ព្រះអង្គ ។ ព្រះមាតារបស់ព្រះបាទជ័យវរ្ម័នទី ៧ គឺជាម្ចាស់ក្សត្រីជ័យរាជាចូឌាមនី ( Jayaraja chudamani ) បានចងភ្ជាប់ទៅនឹងសន្តតិវង្សដ៏ចំណាស់មួយរបស់ខ្មែរ ។ ព្រះបាទធរណិន្ទ្រវរ្ម័ន គឺជាមនុស្សនៅក្នុងជួរមន្ត្រីថ្នាក់ខ្ពស់ ហើយមានអំណាចល្មមនឹងគំរូតាមច្បាប់អាចអូសទាញទៅតាមឋានៈស្តេចបាន ប៉ុន្តែវាដូចជាការគិតរបស់លោក J.Boisselier ដែលថាព្រះអង្គមិនអាចជាស្តេចនៅធានីអង្គរទេ ។

ព្រះបាទធរណិន្ទ្រវរ្ម័ន គឺជាមនុស្សម្នាក់ ដែលគោរពព្រះពុទ្ធសាសនាដែល " មានងារកិត្តិយសជាជើងទាំងឡាយរបស់ Jina ( ព្រះពុទ្ធ ) " ។ ព្រះបាទជ័យវរ្ម័នទី ៧ បានសំរេចចិត្តគោរពបូជាសាសនាដូចព្រះបិតារបស់ព្រះអង្គដែរ ដែលព្រះអង្គផ្ទាល់បានទទួលជ័យជំនះពីពួកចាម ។ គឺដោយសារតែរឿងនេះហើយ ទើបព្រះអង្គទទួលនូវរាជកិច្ចគោរពអទិទេព " ជ័យវរ្ម្រេស្វរលោកេសៈ ( Jayavarmeçvara lokeça ) " ។

៣- ព្រះបាទយសោវរ្ម័នទី ២ ( ?- 1165 )

ក្រោយពីសោយទីវង្គត់របស់ព្រះបាទសូរិយាវរ្ម័នទី ២ រាជាណាចក្រត្រូវស្ថិតនៅក្រោមការកាន់អំណាចនៅចន្លោះមហាក្សត្រជាច្រើន ។ នៅចុងបញ្ចប់នៃរាជព្រះអង្គ មានស្តេចឡើងគ្រងរាជ្យជំនួស តែត្រូវទទួលបរាជ័យ ។ នៅប្រទេសចាមមានការឡើងគ្រងរាជ្យដោយស្តេចឈ្មោះ វិជ័យ ត្រូវជាបងប្អូនថ្លៃរបស់ស្តេចខ្មែរមួយអង្គ ហើយនៅពេលព្រះអង្គវិលត្រលប់មកវិញ ក៏បានធ្វើគត់ស្តេចតែម្តង ។ នៅទន្លេមេណាម ការធ្វើដោយសាកល្បងទាំងឡាយ ដើម្បីប្រឆាំងនិងធានី ហរិបុញ្ជយ ( Haripunjaya ) បានបកត្រលប់ក្រោយវិញយ៉ាងខ្លី ហើយនៅឆ្នាំ ១១៥៥ រាជាណាចក្រ លុបបុរី ( Lopburi ) បានធ្វើលិខិតរាយការណ៍អំពីឯករាជ្យមួយច្បាប់ទៅរាជទូតចិន ។ នៅភាគខាងដើមពាក់កណ្តាលទី ២ នៃសតវត្សទី ១២ ប្រទេសកម្ពុជាបានឆ្លងកាត់នូវដំណាក់កាលភ័យព្រួយមួយដ៏អាក្រក់ ។

យើងពុំបានដឹងទេថា តើព្រះបាទយសោវរ្ម័នទី ២ បានចូលមកជំនួសព្រឹត្តិការណ៍នេះពីពេលណាមកទេ ទាំងទីកន្លែងដែលស្តេចអង្គនេះបានពង្រីកអំណាចរបស់ព្រះអង្គ ។ វាទំនងដូចជាព្រះអង្គបានរៀបចំ និង តាំងទីលំនៅឡានីអង្គរ ប៉ុន្តែអំណាចរបស់ព្រះអង្គ គឺមិនអាចប្រកែកបានទេ ។ សិលាចារឹកមួយនៅប្រាសាទបន្ទាយឆ្មា ដែលបានសិក្សានោះ បានថាព្រះបាទយសោវរ្ម័នទី ២ បានត្រូវវាយប្រហារដោយបុរសម្នាក់ឈ្មោះ Bharatarahu ( ភរតរាហ ) ហើយស្តេចនេះត្រូវបានជួយសង្គ្រោះ ដោយស្តេចក្មេងមួយអង្គទៀតនាម ស្រីន្ទ្រកុមារ ( Çrindrakumara ) ដែលមានន័យថារាជកុមារ " កូនស្តេច " គេបានគិតថាស្រីន្ទ្រកុមារ គឺជាបុត្ររបស់ព្រះបាទជ័យវរ្ម័នទី ៧ ដែលបានសាយភាយឡើងនៅសិលាចារឹកមួយ និយាយពីរបាយការណ៍នៃព្រឹត្តិការណ៍នេះ ។ នៅក្នុងករណីនេះ គេត្រូវទទួលយល់ព្រមថាស្រីន្ទ្រកុមារ បានបញ្ចប់

បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

នូវជីវិតបុរសនេះ នៅក្រោមរាជព្រះបាទ យសោវរ្ម័នទី ២ ទ្រង់អាចជាបុត្រារបស់ព្រះបាទជ័យវរ្ម័នទី ៧ ប្រសិនបើទ្រង់ត្រូវបានប្រសូត្រនៅឆ្នាំ ១១២៥ ប៉ុន្តែកាលបរិច្ឆេទនេះ ទំនងជានៅខ្ពស់ជាង ។ ក្នុងករណីនេះ ប្រសិនបើយកតាមការគិតស្មានរបស់លោក J.Boisselier វិញនោះថា រាជកុមារអាចជាបុត្ររបស់ព្រះបាទយសោវរ្ម័នទី ២ ខ្លួនព្រះអង្គតែម្តង ។

គេមិនដឹងថា តើភរតរាហុជានណា ហើយដឹងដោយសារអ្វី ដែលជាមូលហេតុនាំអោយមានការបះបោររបស់គាត់ ។ ឈ្មោះរបស់គាត់ គឺយកតាមឈ្មោះយក្សមួយឈ្មោះ Râhu ( រាហ ) ដែលប៉ុះប៉ងក្នុងខណៈនោះអោយមានគ្រាសជាញយៗ ដោយតាមលេបព្រះអាទិត្យ និង ព្រះច័ន្ទ យក្សរូបនេះបានស្វែងរកសងសឹកជាមួយនិងអទិទេពទាំងពីរ ដែលបុព្វហេតុមកពីពួកគេទាំងពីរនេះ បានឃាត់រាហុក្នុងការលួចទឹកអម្រិត ដែលបានមកពីលទ្ធផលនៃការកូរសមុទ្រទឹកដោះ ។ រាហុគឺជាឈ្មោះរបស់ក្រុមពួកឧទាមមួយដែលចង្រៃគួរអោយភ័យខ្លាច និង គ្រោះថ្នាក់ ។

រជ្ជកាលរបស់ព្រះបាទយសោវរ្ម័នទី ២ បានត្រូវបញ្ចប់នៅក្នុងអំឡុងពេលដែលប្រទេសធ្លាក់ដល់នូវភាពអន្តរាយ ។ នៅឆ្នាំ ១១៦៥ មានមន្ត្រីម្នាក់បានបញ្ជូនកូនប្រុសរបស់ខ្លួនម្នាក់អោយឡើងមកជំនួសអ្នកដែលស្លាប់ទៅ ដោយយកឈ្មោះដូចស្តេចគឺ ទ្រីភុវណអាទិត្យវរ្ម័ន ( Tribhuvanàdityavar man ) " នេះគឺមានន័យថា ត្រូវការពារដោយព្រះអាទិត្យរបស់ពិភពទាំង ៣ " ។

គេពុំបានដឹងទេថា តើព្រះបាទយសោវរ្ម័នទី ២ បានសាងសង់អ្វីខ្លះនៅធានីអង្គរទេ ។ វាទំនងជាអាចមានប្រាសាទខ្លះនៅរចនាបថអង្គរវត្ត ដែលត្រូវបានសាងសង់នៅក្រោមរាជរបស់ព្រះអង្គ នៅក្នុងរាជធានី ឬ នៅតាមខេត្ត ។

៤- ការដណ្តើមរាជរបស់ព្រះបាទ ទ្រីភុវណអាទិត្យវរ្ម័ន :

ព្រះបាទ ទ្រីភុវណអាទិត្យវរ្ម័ន បានសោយរាជ្យនៅធានីអង្គរអស់រយៈពេល ១២ឆ្នាំ ។ គេពុំដឹងពីមូលហេតុអ្វី បានជាគេទទួលស្គាល់នូវការដណ្តើមរាជរបស់ព្រះអង្គទេ ។ សិលាចារឹកនៅប្រាសាទវិមានអាកាស ដែលយើងបានរកឃើញនៅពេលកាប់ឆ្ការព្រៃ នៅកន្លែងដែលមានបេសកកម្មយោធាប្រឆាំងនឹងពួកចាមរបស់អនាគតជ័យវរ្ម័នទី ៧ បានសរសេរថា ការទទួលយកពួកឧទ្ទាមរបស់ព្រះបាទ ទ្រីភុវណអាទិត្យវរ្ម័ន គឺធ្វើឡើងប្រញាប់ប្រញាល់បំផុត នៅក្នុងប្រទេសកម្ពុជា ។ ប៉ុន្តែ " ព្រះបាទយសោវរ្ម័នបានដកហូតយករាជាណាចក្រ និង ជីវិតដោយអ្នកជ្រែករាជ ឯព្រះបាទជ័យវរ្ម័នរស់នៅក្នុងប្រទេសកម្ពុជានៅឡើយ ដើម្បីជួយសង្គ្រោះទឹកដី ដែលទទួលរងនូវឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរ ដោយរង់ចាំឱកាសល្អ " ។

ព្រះបាទជ័យវរ្ម័ន បានតាំងទីលំនៅឡធានីអង្គរ ឬ ក៏វិលមកដកហូតយកទឹកដីរបស់ព្រះអង្គវិញនៅមហីធរបុរៈ ? សមត្ថិកម្មទី ២ ដែលយើងទំនងគួរទុកជាការពិតបាននោះ គឺព្រះអង្គបានគង់នៅក្នុងរាជធានីរហូតដល់មានព្រឹត្តិការណ៍ ដែលបង្កអោយមានមហន្តរាយដ៏ធំក្នុងឆ្នាំ ១១៧៧ ។

៥- ការចូលកាន់កាប់ធានីអង្គរដោយពួកចាម ( ឆ្នាំ ១១៧៧ ) :

មួយ ឬ ពីរឆ្នាំក្រោយ គឺមានការរំលោភដណ្តើមអំណាច ដោយព្រះបាទទ្រីភុវណអាទិត្យវរ្ម័នដល់វេនពួកចាមត្រូវមកដណ្តើមរាជ ដើម្បីអោយព្រះបាទជ័យឥន្ទ្រវរ្ម័នទី ៤ បានសោយរាជ្យម្តង ។ នេះគឺជាការសំរេចចិត្តធ្វើសង្គ្រាមនៅចំកណ្តាលបេះដូង នៃប្រទេសកម្ពុជា ៖ " ព្រះបាទជ័យឥន្ទ្រវរ្ម័នបានវាយឫកដូចរាវនៈ ( Ràvana ) ( : សត្រូវរបស់ព្រះរាម ) ដោយដឹកជញ្ជូនទ័ពរបស់ព្រះអង្គដោយរទេះ ឆ្ពោះទៅប្រយុទ្ធជាមួយនឹងប្រទេសកម្ពុ ( Kambu ) ប្រៀបដូចនៅលើមេឃ " ។ មុនមកដល់រាជធានី ជ័យឥន្ទ្រវរ្ម័នបានប្តូរកល្បិចក្រោយពីការប៉ុនប៉ងដឹកទ័ពតាមរទេះទាំងឡាយ មកតាមសំពៅវិញម្តង ។ ព្រះអង្គបាន

ជ្រើសរើសយកអ្នកនាំផ្លូវម្នាក់ ជាអ្នកដើរទូតជាតិចិន ដែលស្គាល់ច្បាស់ពីផ្លូវចិត្ត ។ នៅឆ្នាំ ១១៧៧ ទាហានជើងទឹកចាមបានធ្វើដំណើរតាមឆ្នេរ នៃប្រទេសវៀតណាមបច្ចុប្បន្ន រួចឡើងតាមទន្លេមេគង្គ ដោយឆ្លងកាត់តាមតំបន់ដីសណ្ដរ រួចមកដល់បឹងទន្លេសាប ហើយ និង តាមពាមស្ទឹងសៀមរាប ។

លទ្ធផលនៃការផ្ទុកបានសំរេច ដោយពេញលេញ ។ ធានីអង្គរពុំមែនជាវន្ទមួយ ដែលមានការ ការពារដោយយាមល្បាតទេ ។ តាំងពីការស្ថាបនារាជធានីរបស់ខ្លួនមក ធានីនេះមិនដែលទទួលរងការ គំរាមកំហែងម្ដងណាទាល់តែសោះ ។ កំពែងការពាររាជធានីរបស់យសោវរ្ម័ន ត្រូវធ្លាក់ទៅក្នុងភាពទ្រុឌ ទ្រោម ម្យ៉ាងទៀតខ្សែក្រវ៉ាត់ដែលព័ទ្ធពីក្រៅដោយមជ្ឈមណ្ឌលនយោបាយ និង សាសនាបានខិតនៅជិត និង នៅជុំវិញព្រះបរមរាជវាំង ។ មានតែប្រាសាទអង្គរវត្តមួយគត់ ដែលកំពែងរបស់វាជាជញ្ជាំង និង មានគូរទឹកព័ទ្ធជុំវិញ ។ ជាការពិតណាស់ ជញ្ជាំងនៃកំពែងប្រាសាទអង្គរវត្តក៏ដូចជាគូរទឹកដែរ ពុំមែន កសាងឡើងជាមូលដ្ឋាន ដើម្បីរៀបចំជាសំណង់ការពារសឹករបស់សត្រូវទេ ។ ការការពារធានីយសោធរ បុរៈ ពុំមែនសំរាប់ការពារដោយទាហានទេ គឺការពារដោយសាសនា ។ តាំងពីព្រះបាទយសោវរ្ម័នទី ១ មកម្លេះ ស្ដេចខ្មែរទាំងឡាយបានខំប្រឹងរៀបចំនៅក្នុងធានីអង្គរ ដែលជាពិភពនៃអទិទេព ហើយត្រូវការពារ ដោយអទិទេពខ្លួនឯង ទើបធានីបានគង់នៅរហូត ។ ឬក៏ធានីបានទទួលយកនូវការការពារនេះ ដោយខុស ពីធម្ម: ។ ភយន្តរាយបានកើតឡើងពេញធានី ។ ពួកចាមទាំងឡាយបានដណ្ដើមយកបានធានីអង្គរ ហើយនិងប្លន់យកទ្រព្យសម្បត្តិសស់ជាច្រើន ។ ព្រះបាទត្រិភុវនាទិត្យវរ្ម័ន បានត្រូវគេធ្វើគត់យ៉ាង សាហាវយង់ឃ្នងនៅក្នុងពេលច្បាំងគ្នានោះ ហើយក៏បានប្រគល់ទឹកដីអោយទៅគេទៅ ។ សិលាចារឹកនៅ ប្រាសាទវិមានអាកាសបាននិយាយពីស្ដេចចាម ៖

នៅក្នុងការជួបច្បាំងគ្នាមួយដ៏លំបាក ដោយយមភូបាល ( Yama ) ដើម្បីចូលកាន់កាប់នៅតំបន់ ខាងត្បូង ហើយនិងភាពបន្ទោរទន់របស់ព្រះអាទិត្យ ( ចុះចាញ់ ឬ ក៏បរាជ័យ ) វាដូចជាការដណ្ដើម អំណាចរបស់ស្ដេច ( នៅប្រទេសកម្ពុជា ) បានផ្ទុកទៅដោយភាពប្រុងប្រយ័ត្ន ( អំពើទាំងឡាយរបស់ ស្ដេច ) រួចគេក៏បានសំលាប់ចោលតែម្ដង " ។

៦- <u>ផលវិបាកនៃជ័យជំនះរបស់ពួកចាម</u> :

សំរាប់រយៈពេល ៤ ឆ្នាំនេះ ពួកចាមបានប្រគល់តំណែងអោយទៅពួកចៅហ្វាយនៅធានីអង្គរ ។ ប្រព័ន្ធសាសនា ការស្ថាបនារបស់ព្រះបាទយសោវរ្ម័នទី ១ ហើយនិងអ្នកស្នងរាជបន្តក្រោយៗមកទៀត ក៏ត្រូវចុះខ្សោយ ។

តើគេប៉ាន់ស្មានធានីអង្គរទៅជាយ៉ាងណា នៅពេលដែលនៅក្រោមការគ្រប់គ្រងរបស់ពួកចាម រយៈពេល ៤ឆ្នាំនោះ ? ការប្លន់ទឹកដីនេះ មិនមែនចំរុងយកតែរតនៈសម្បត្តិរបស់ស្ដេច និង ទ្រព្យសម្បត្តិ របស់ប្រជាជនប៉ុណ្ណោះទេ ។ អទិទេពទាំងឡាយដែលថែរក្សានៅធានីអង្គរ ត្រូវបាននាំយកទៅប្រទេស ចាម ឬ កាត់យកអវៈយវៈណាមួយ ក្នុងអំឡុងពេលដែលពួកគេកាន់អំណាច ។ ប៉ុន្តែរាជធានីមិនត្រូវបាន បំផ្លាញទេ ។

គោលបំណងរបស់ជ័យវរ្ម័ន គឺការបង្រួបបង្រួមចំពោះការសុំប្រោសប្រណីរបស់ព្រះអង្គ ចំពោះរាជាណាចក្រខ្មែរ ដែលពេលនោះ រាជាណាចក្រកំពុងតែគ្រប់គ្រងដោយអ្នកជ្រែករាជម្នាក់ ។ អគ្គបទរបស់ចិនបានទទួល ដោយមិនអាចស្ងប់បានអំពីការគាបសង្កត់របស់ពួកចាម មកលើប្រទេសកម្ពុជា អគ្គបទនោះមានរបាយការណ៍ថា ៖

" ស្តេចរបស់ពួកចាម បានវាយលុកចូលទៅក្នុងរាជធានីរបស់ចេនឡា ដោយពុំបានដឹងខ្លួនមុនឡើយ ជាមួយនឹងទ័ពជើងទឹកបានរុញច្រាន លួចប្លន់ទ្រព្យសម្បត្តិ ហើយនិងសំលាប់ស្តេចខ្មែរអោយស្លាប់តាយហោង ដោយពុំស្តាប់អ្នកណាម្នាក់ ដែលបានអង្វរករសុំសន្តិភាពឡើយ ។ មហាទោសៈមួយ ដែលកាន់ថ្លៃលើសជាច្រើន នៅដៃទីប្រាំក្នុងឆ្នាំ King - Yuam ( ឆ្នាំ ១១៩៩ គ.ស ) " ។

មហាទោសៈនៅក្នុងខណៈនោះបង្កបានជាចលនា ដើម្បីសេរីភាពទៅអនាគត ព្រះបាទជ័យវរ្ម័នទី ៧ ជាអ្នកចាប់ផ្តើមគំនិត ហើយនិងត្រូវបន្តរហូតដល់ចុងបញ្ចប់នៃសតវត្ស ដោយបណ្តាលអោយពួកចាមធ្លាក់ចុះចាញ់យ៉ាងទាន់ហន់ ។

៧- <u>សេរីភាពនៅក្នុងប្រទេសកម្ពុជាដោយព្រះបាទជ័យវរ្ម័នទី ៧ :</u>

យើងពុំបានដឹងពីមូលហេតុដូចម្តេច ដែលព្រះបាទជ័យវរ្ម័នទី ៧ បានរៀបចំអោយមានចលនាបះបោរ ដើម្បីប្រឆាំងនឹងពួករាតត្បាតនៅក្នុងប្រទេសខ្មែរទេ ។ នៅក្នុងសិល្បៈសាសនាដែលគេមើលឃើញនោះ គឺជាសិលាចារឹកទាំងឡាយបាននិយាយពីចលនាសម្ព័ន្ធកងទ័ព នៃសេរីភាពនេះមានគុណសម្បត្តិសំខាន់ៗជាច្រើន បានប្រមូលមកទុកក្នុងបំណងដូចគ្នា ដោយព្រះមាតា ព្រះបិតាដ៏ជិតស្និតបំផុតរបស់ព្រះអង្គ ។ ភើរហេតុអ្វីបានជាសិលាចារឹកមួយផ្ទាំងធំ នៅវិមានអាកាសបានសរសេរយ៉ាងវែងនូវកុបកម្ម ( ការកាន់គឹងរឹង ) ដែលម្ចាស់ក្សត្រីយ៉ាងសំខាន់របស់ព្រះបាទជ័យវរ្ម័នទី ៧ ព្រះនាម ជ័យរាជទេវី ( Jayarâjadevi ) បានអនុវត្តន៍ ។ " នៅចុងបញ្ចប់នៃការជឿងប់នឹងសាសនារបស់អគ្គមហេសីព្រះអង្គអ្នកបំរើនេះ និង អទិទេពម្ចាស់ក្សត្រីបានប្រាថ្នាចង់ឃើញនូវដីរបស់សមុទ្រ ដែលអកុសល ដែលនៅទីនោះព្រះនាងបានលង់ទឹក " ។ អត្ថបទជាមួយគ្នានេះដែរក៏បានរៀបរាប់យ៉ាងខ្លី អំពីចំបាំងដែលនាំដោយព្រះបាទជ័យវរ្ម័នទី ៧ ៖

គាថា LXX " តាមសេចក្តីអំណាត់របស់ព្រះអង្គ នៅក្នុងសេចក្តីអកុសលដោយទទួលបរាជ័យនៅក្នុងចំបាំងរបស់ ( ពួកចាម ) ដែលការធ្វើសង្គ្រាមរបស់ពួកគេប្រៀបបីដូចជាមហាសមុទ្រគ្មានកោះត្រើយ ក្រោយពីបានទទួលការអភិសេកអោយឡើងសោយរាជ្យសម្បត្តិមក ព្រះបាទវិជ័យបានវក់នឹងរបស់របរដែលច្បាំងបានពីប្រទេសដទៃ ដោយចាប់ផ្តើមជំរះសំអាតដី ដែលអាចសង់រាជវាំងរបស់ព្រះអង្គបាន"។

យើងពុំបានដឹងល្អិតល្អន់អំពីបេសកកម្មយោធា ដែលគេលាតត្រដាងនៅពេលនោះ ។ ការច្បាំងដ៏សំខាន់មួយ ដែលបានចុះក្នុងបញ្ជីនោះ ទំនងជាកើតមាននៅលើរមណីយដ្ឋានប្រាសាទព្រះខ័ន នៅខាងជើងធានីអង្គរ ។ ការជាប់ដៃច្បាំងគ្នានោះ បានសំរេចឆ្លាក់ជាក្បាច់ក្រឡោតទាបឡើងពីចំបាំងជើងទឹកទី ១ នៅប្រាសាទបន្ទាយឆ្មារទី ២ នៅប្រាសាទបាយ័ន ។ ប្រាសាទចុងក្រោយនេះ (បាយ័ន) វាមានសារៈសំខាន់ខ្លាំងណាស់ ពីព្រោះចំលាក់ទាំងអស់ ត្រូវបានឆ្លាក់ឡើងពេញជញ្ជាំងថែវនៃប្រាសាទតែម្តង ។ នៅលើបញ្ជីជាច្រើនបានបង្ហាញពីទាហានជើងទឹកខ្មែរ និង ចាមច្បាំងទល់មុខគ្នា ។ នៅខាងលើជិតក្បាលទូកទាំងឡាយ អ្នកចំបាំងបានប្រុងប្រៀបខ្លួនស្ទុះចេញទៅវាយលុកគាវា ដែលគេស្គាល់កងទ័ពខ្មែរដោយក្បាលទទេ និង សក់មានសិតសំអាតដោយប្រាស់ ឯពួកចាមនៅលើក្បាល មានពាក់មួកកាតិបយ៉ាងចំឡែក មានទំរង់ដូចផ្កាដែលដាក់ផ្កាប់ពីលើក្បាល ។ មាន់គោកទាំងឡាយរបស់ពួកនាវិកកំពុងតែជល់គ្នា។ ការច្បាំងរវាងខ្លួន និង ខ្លួនបានផ្តើមឡើង អ្នករបួស ឬ អ្នកស្លាប់ បានត្រូវធ្លាក់ចូលទៅក្នុងទឹក ដែលនៅទីនោះមានសត្វក្រពើជាច្រើនកំពុងតែរង់ចាំស្រាប់ ។ នៅលើបញ្ជីផ្នែកខាងលើ គេបានឆ្លាក់អំពីចំបាំងនៅលើដីដែរ ។ នៅផ្នែកខាងលើនៃក្បាច់ក្រឡោតទាប តែនៅខាងក្រោមដំបូល ស្តេចបានគ្រប់គ្រងការប្រតិបត្តិការនេះដោយខ្លួនព្រះអង្គផ្ទាល់ ហើយបានសង្គ្រោះ ដើម្បីគេចចេញពីសត្រូវទាំងឡាយ ។

នៅផ្នែកខាងក្រោមនៃទំបាំង ចំលាក់ទាំងឡាយបានបង្ហាញពីក្បាច់ខ្សែមួយ អំពីជីវភាពប្រចាំថ្ងៃរបស់ប្រជាជនខ្មែរ ជាមួយនឹងផ្ទះទាំងឡាយ និង ផ្សារលក់ដូររបស់ពួកគេ បង្ហាញពីសកម្មភាពស្មោះសបន្ទរហូត ដោយលាតត្រដាងពីសេរីភាពនៅធានី ដោយសារជ័យជំនះរបស់ព្រះបាទជ័យវរ្ម័នទី ៧ ។

កាលបរិច្ឆេទនៃជ័យជំនះរបស់ព្រះបាទជ័យវរ្ម័នទី ៧ ពុំមានច្បាស់លាស់ទេ ។ វាត្រូវដាក់កាលបរិច្ឆេទនេះអោយប្រាកដ គឺមុនឆ្នាំ ១១៨១ ជាការបរិច្ឆេទនៃការអភិសេកឡើងសោយរាជ្យរបស់ស្ដេច ពិធីនេះមិនអាចកើតមានក្រោយពីការចូលលុកលុយពីពួកចាម និង ក្រោយការជួសជុលឡើងវិញនៅភាគខ្លះនៃធានីអង្គរហូតដល់ធានីនេះ ត្រូវគេប្លន់យកទ្រព្យសម្បត្តិ ហើយនិងតួប្រាសាទទាំងឡាយត្រូវគេដកហូតយករូបចំលាក់យ៉ាងប្រាកដ និង ដកហូតយកពីភាពសំបូរបែបរបស់វា ។

ការសង់ឡើងវិញនូវសំណង់សាសនា ដែលជាសំភារៈរបស់ព្រះបាទយសោវរ្ម័ន គឺជាបន្ទុកមួយដ៏ធ្ងន់ធ្ងរ ដែលព្រះបាទជ័យវរ្ម័នទី ៧ ត្រូវតែទទួលបន្ទុកនេះ ប៉ុន្តែជាដំបូងព្រះអង្គត្រូវតែបំពេញនូវជ័យជំនះលើពួកចាមរបស់ព្រះអង្គសិន ដើម្បីជៀសវៀងការវាយបកវិញរបស់គូរសត្រូវ ។

- ចំបាំងតទល់ជាមួយពួកចាមអស់រយៈកាលយូរអង្វែង ធ្វើឡើងដោយពិបាក យើងពុំមានខុមាលទោសអ្វីទាំងអស់ ព្រះបាទជ័យវរ្ម័នទី ៧ បានបញ្ចប់នូវការដឹកនាំរបស់ព្រះអង្គ ខាងចុងបញ្ចប់នៃរាជព្រះអង្គ ៖ អ្នកនិពន្ធជាតិចិនម្នាក់ឈ្មោះ Matouanlin បានហៅព្រះមហាក្សត្រថា ៖ " ជាជន ជាអ្នកត្រូវជ្រើសតាំងអោយវិនិច្ឆ័យសេចក្ដីពីរឿងការនាំយកពួកសត្រូវ អោយមកសងសឹកនៅចំពោះមុខមហាជនការណ៍នេះបានមកដល់ និង ធ្វើបានសំរេចក្នុងរយៈពេល ១៨ឆ្នាំ ក្រោយបន្ទាត់ទ្រាំចាំ និង លក់ខ្លួនដោយអត់ធ្មត់មក " ។ នៅឆ្នាំ ១១៩០ មានចំបាំងវាយចាមថ្មីមួយទៀត បានកើតឡើងប្រទាញប្រទង់ដើម្បីចង់បានការតស៊ូធ្វើអោយវិនាសតែម្ដង ។ សិលាចារឹករបស់ចាមមួយនៅប្រាសាទពោនគរ ( Po Nagar ) នៅស្រុក Nhatrang បានរៀបរាប់អំពីកងទ័ពខ្មែរវាយដណ្ដើមយកបានធានីរបស់ចាម ហើយនិងប្រមូលយកវិញនូវលិង្គដែលពួកចាមបានលួចយកទៅ ។ ស្ដេចចាមបានបញ្ជូនអ្នកទោសខ្មែរ អោយត្រលប់មកស្រុកខ្មែរវិញ ហើយប្រទេសរបស់ពួកគេ បានបែងចែកចេញជាពីរអាណាចក្រ ។ ព្រះបាទជ័យវរ្ម័នបានរៀបចំអោយដូចព្រះមហាក្សត្រមួយចំណែក អោយទៅខាងបងប្អូនថ្លៃគ្រប់គ្រង និង មួយផ្នែកទៀត គឺស្ដេចចាមទំនងជាប្រតិបត្តិតាមព្រះអង្គ ។ ការច្បាំងគ្នានៅលើកចុងក្រោយនេះ ត្រូវបានបញ្ចប់នៅពេលមានប្រតិបត្តិការទ័ពថ្មី ហើយនៅឆ្នាំ ១២០៣ ព្រះបាទជ័យវរ្ម័នទី ៧ បានបង្ខំប្រទេសចាមអោយចូលមកជាអាណាខេត្រមួយរបស់អាណាចក្រខ្មែរ ។

- ការវិលត្រឡប់វិញដ៏ជូរចត់ រាល់ចំបាំងថ្មីៗជាមួយពួកចាម វាមិនគ្រប់គ្រាន់ទេ គេត្រូវតែការពារជានិច្ច ដែលប្រទេសកម្ពុជាពីមុនមកមិនដែលជួបប្រទះសោះ ហើយប្រឆាំងតទល់ដាច់ខាតជាមួយភាពមហន្តរាយ កុំអោយទទួលរងការឈឺចាប់ដូចកាលពីឆ្នាំ ១១៧៧ ទៀត ។ ការវាយយកធានីអង្គរ និងការប្រមូលកេតនភ័ណ្ឌអោយតែឈ្នះដៃរបស់ពួកចាម បានបញ្ជាក់នូវភស្តុតាងមិនអាចប្រកែកបានថា រាជធានីមិនត្រូវបានបែកធ្លាយដោយងាយនោះទេ វាជាការបង្ហាញអោយឃើញច្បាស់ពីពិភពអទិទេពនៅលើដី។ គេត្រូវតែរកអោយឃើញអំពីការការពារនៅពីខាងលើ ដែលបានរៀបចំក្នុងអំឡុងពេលសតវត្សមុន ។ អំពើទាំងនេះគឺជាប្រធាន នៃការកង្វល់ដ៏សំខាន់របស់ព្រះបាទជ័យវរ្ម័នទី ៧ ។ ព្រះអង្គបានស្ដាបនាធានីអង្គរឡើងវិញ ដោយផ្ទុកនូវនិម្មិតរូបមិនអាចបញ្ចប់ ពីភាពសំបូរបែបនៃជាងសំណង់ ដែលបានសាងសង់នៅថ្ងៃកាលមុនព្រះអង្គ ។

## ជំពូក VI
## ព្រះបាទ ជ័យវរ្ម័នទី ៧ ហើយនិងការ
## សាងសង់ធានីអង្គរធំ

១- ព្រះបាទជ័យវរ្ម័នទី ៧ ( ១១៨១-១២១៨ ? )

ក ព្រះបាទជ័យវរ្ម័នទី ៧ ជាបុត្ររបស់ព្រះបាទធរណីន្ទ្រវរ្ម័ន ជាការប្រហាក់ប្រហែលថា ជាស្តេចមួយអង្គរស់នៅក្នុងស្រុក ហើយនិងព្រះអគ្គមហេសីនាម ជ័យរាជចូឌាមនី ( Jayarājachudāmani ) ចេញមកពីខ្សែស្រឡាយ ស្រេសថបុរៈ ( Çreshthapura ) ដែលជាអតីតអ្នកសោយរាជនៅចេនឡា ។ គឺព្រះមាតារបស់ព្រះអង្គនេះហើយ ដែលជាអ្នកត្រូវសោយរាជ្យទៅតាមច្បាប់ ។ នៅគ្រប់ពេលដោយការបន់ស្រន់ " អំណាចរបស់ព្រះអង្គ បានបញ្ចេញពន្លឺព្រោងព្រាត " ហើយពិត់លៃរបស់ព្រះអង្គ ដែលជាមេបញ្ជាការនៃកងទ័ពនោះ សិលាចារឹកនៅប្រាសាទព្រះខ័ន បានសរសេរអំពីគុណសម្បត្តិរបស់ព្រះអង្គប្រកបដោយបញ្ញាឈ្លាសវៃ និង មានសីលធម៌ ៖ " គួរអោយចូលចិត្ត ដោយសារតែសម្បជញ្ញៈរបស់ព្រះអង្គបានជំរុញអោយមានការលូតលាស់ នៃគុណធម៌ល្អៗទាំងឡាយ ដែលប្រសព្វក្នុងការងារ ហើយមានឫកពារល់នាំជាអ្នកខ្ពង់ខ្ពស់ ក្នុងការគោរពគ្រូបាធ្យាយទាំងឡាយ ព្រះអង្គបានប្រតិបត្តិតាំងពីពេលនៅវ័យក្មេងម្លេះ ដែលមើលអោយច្បាស់ទៅ គឺស្របតាមប៉ានិនិ ( Pānini ) " ។

សិលាចារឹកទាំងឡាយបានសរសេរអោយឃើញ ប្រៀបបីដូចជាវីរៈបុរសមួយរូប និង មានចំណេះវិជ្ជាជ្រៅជ្រះ ។ ជួនកាលបើគេពិនិត្យមើលអោយច្បាស់ទៅ ព្រះអង្គក៏បានបោះបង់ចោលខ្លះ ដោយដើរហួសខ្នាតមាត្រា ឬចិត្តក្នុងការប្រតិបត្តិសាសនានៅទីនេះ ក៏ដូចជាការដកហូតយកអាករពីការលាក់ពុតត្បុត ។*ឬ ក៏បុគ្គលិកលក្ខណៈរបស់ព្រះបាទជ័យវរ្ម័នទី ៧ ដែលឥតមានទិបញ្ញប់ និង សាំញ៉ាំបំផុត ។ គុណសម្បត្តិរបស់ព្រះអង្គ ហើយនិងមនុស្សសង្គ្រាម គឺជាការក្រឡឹបមិនកើត ។ លោក Matouanlin បាននិយាយពី " ការលាក់បំពួនដោយភាពអត់ធ្មត់របស់ព្រះអង្គ " ប៉ុន្តែពុំមែនជាការលាក់ពុតទេ ។ ការវិលត្រលប់មកពីប្រទេសចាមវិញ ក្នុងពេលនោះ អ្នកជ្រែករាជបានគង់នៅយ៉ាងរឹងមាំនៅក្នុងប្រទេសកម្ពុជា ព្រះអង្គបានធ្វើការប្រម៉ែប្រមូលដោយខ្លួនព្រះអង្គ នៅលើទឹកដីទាំងឡាយ ដែលត្រូវយាយីមិនឈប់ឈរ ប្រហែលត្រូវធ្វើឡើងដោយការបង្ខំចិត្តរបស់ព្រះអង្គ មានការគ្រប់គ្រងនៃអំណាចរបស់ព្រះគ្រូដែលនិយាយពីរឿងខ្លួនឯង ហើយបានអោយយោបល់ពីគុណសម្បត្តិ នៃអ្វីដែលជិតមកដល់ មិនមែនសំរាប់ការចាត់ចែងកំលាំងទ័ព ដោយគ្មានលទ្ធផលនោះទេ តែសំរាប់ក្តោបក្តាប់ដោយបំរុងទុក ដើម្បីបំពីអោយចលនាដែលប្រកបដោយសមិទ្ធិជោគ ។ ៥

គេបានបញ្ចេញអោយឃើញ នូវរូបចំលាក់ជាច្រើន ដែលទំនងជាទំរង់មុខរបស់ព្រះបាទជ័យវរ្ម័នទី ៧ គ្រប់រូបភាពទាំងអស់ ព្រះអង្គស្ថិតនៅក្នុងអកប្បកិរិយានៃការសញ្ជឹង បានលាតបង្ហាញអោយឃើញនូវគ្រប់សារព័ន្ធរបស់ស្តេច ។ មានរូបចំលាក់មួយ ដែលគេរកឃើញនៅប្រាសាទក្រោលរមាស ដែលស្ថិតនៅភាគខាងជើងធានីអង្គរធំ ។ គឺជារូបចំលាក់ដែលបង្ហាញពីមនុស្សម្នាក់ ដែលមានដងខ្លួនធំ ហើយសក់ត្រូវបួងឡើងមកខាងលើ ដោយមានផ្នួងសក់តូចៗមួយផង នៅពីលើព្រះកេស ។ ផ្ទៃមុខកំពុងតែសញ្ជប់ d នៅក្នុងការធ្វើតបធម៌ ។ ៦

យើងបានស្គាល់ពីអគ្គមហេសីទី ១ របស់ព្រះបាទជ័យវរ្ម័នទី ៧ គឺម្ចាស់ក្សត្រី ជ័យរាជទេវី ដែលមានអនុគ្រោះដល់មនុស្សដទៃ ហើយបានចារជាសិលាចារឹកធំមួយ នៅប្រាសាទវិមានអាកាស ពោរពេញទៅដោយការសរសើរនៅលាយឡំជាមួយ និងកិត្តិយសរបស់ព្រះនាង តាមចំណាររបស់ប្អូនស្រីឈ្មោះ ឥន្ទ្រទេវី ។

មោះមុតនិងព្រះពុទ្ធសាសនា ព្រះនាងគិតតែស់គីអំពីការធ្វើតបកម្ម ( ការកាន់តឹងរឹង ) ហើយក្នុងខណៈនោះ មហេសីរបស់ព្រះអង្គ បានដឹកនាំទ័ពដើម្បីប្រយុទ្ធប្រឆាំងនឹងពួកចាម មុនដំបូងនៅឆ្ងាយរួចមកនៅលើទឹកដីខ្មែរ ។ អត្ថបទបានសរសេរ " បានឆេះដោយអ្នកដែលនៅតាមរបៀបតាបសឥសីចុះស្គមដោយការគោរពប្រតិបត្តិយ៉ាងហ្មត់ចត់ " ។ ចុងបញ្ចប់ " គេបានរកឃើញឡើងវិញនូវមហេសីរបស់ព្រះអង្គ ហើយនិងស្តេចជាច្រើនអង្គទៀត ដែលមានកតញ្ញូ ព្រះនាង ( បានដួលទៅលើដី ) មានភ្លៀងមួយមេ ដែលប្រកបដោយមានរន្ទះពន្លឺ " ។ កិត្តិយសរបស់ម្ចាស់ក្សត្រី គឺកើតមានក្នុងរយៈពេលខ្លីរួចព្រះនាងបានសោយទីវង្គត់ទៅ ។ ក្រោយពីបានអភិសេកអោយស្តេចឡើងគ្រងរាជ្យសម្បត្តិមក ។ ក្នុងខណៈនោះបានប្រគល់អោយនូវមុខតំណែងជាម្ចាស់ក្សត្រីទី ១ ដល់ឥន្ទ្រទេវី "ដែលមានចំណេះវិជ្ជាខ្ពង់ខ្ពស់ពីកំណើត ជាអ្នកប្រាជ្ញដែលបរិសុទ្ធជានិច្ច " ។

២- <u>គំនិតសាសនាធំទូលាយរបស់ព្រះបាទជ័យវរ្ម័នទី ៧</u> :

ជាបុត្រារបស់ព្រះបាទ ធរណិន្ទ្រវរ្ម័ន ដែលបានរកឃើញនូវសេចក្តីពេញចិត្ត " នៅក្នុងទឹកដមនៃផ្កាឈើនេះ " គឺជាសាសនារបស់ សក្យៈមនី ( Çakyamoni ) ហើយព្រះបាទជ័យវរ្ម័នទី ៧ ក៏បានសាងព្រះពុទ្ធរូបមួយអង្គ ដែលយល់ហើយជឿ និងអកប្បកិរិយាក្នុងជំនឿសាសនារបស់ព្រះអង្គ បានពន្យល់ពីគំនិតរបស់ព្រះអង្គ នៃអំណាចរបស់ស្តេច ហើយនិងកិច្ចការទាំងឡាយបានជំរុញអោយសង្កត់ធ្ងន់លើមហាក្សត្រ ។

ឧត្តមគតិរបស់ព្រះបាទជ័យវរ្ម័នទី ៧ គឺជាព្រះមហាក្សត្រ ចក្រពត្តិ ( Cakravartin ) ដោយសារតែភាពប្រសើរខ្ពង់ខ្ពស់ ដូចស្តេចឥណ្ឌាព្រះនាម អសោកៈ ( Açoka ) ។ ព្រះអង្គមានព្រះបំណងដោយខ្លួនព្រះអង្គ ដើម្បីអោយក្លាយទៅជាមហាក្សត្រចក្រពត្តិ ប្រហែលដោយសារតែរស់ជាតិនៃអំណាចហើយមើលទៅ ប៉ុន្តែជានិច្ចកាល ក៏ព្រោះតែព្រះមហាក្សត្រអង្គនេះដែរ ធ្វើអោយព្រះរាជាណាចក្រទទួលបាននូវវិបុលភាព និង ស្ថិរភាពក្នុងសង្គម ។

ក្រោយពីមានការវាយកំចាត់ពួកចាមអោយចេញពីប្រទេសកម្ពុជាមក ព្រះបាទជ័យវរ្ម័នទី ៧ បានមានព្រះបន្ទូលអះអាងថា អំណាចរបស់ព្រះអង្គបានលាតសន្ធឹងរហូតដល់ទន្លេមេណាម និង ភាគខាងត្បូងប្រទេសឡាវ ដែលនៅទីនោះគេបានរកឃើញសិលាចារឹកខ្មែរ នៃរាជរបស់ព្រះអង្គ នៅសាយហ្វុងជិតនឹងប្រទេសវៀតណាម ។ ប៉ុន្តែព្រះមហាក្សត្របានដឹងពីអាណាចក្ររបស់ព្រះអង្គ ធ្លាប់ទទួលបរាជ័យ ហើយអាចរៀបចំឡើងវិញ ដូចជាការរៀបចំប្រទេសកម្ពុជាអោយមានការគ្រប់គ្រងបានល្អឡើងវិញ ។ ព្រះអង្គចង់អោយប្រទេសរបស់ព្រះអង្គ ក្លាយជាប្រទេសមួយដែលមានការថែទាំ ហើយមិនអាចបំផ្លាញបាន ។ នៅក្នុងការសាងសង់ឡើងវិញនៅក្នុងរាជធានី ព្រះអង្គបានកសាងជារូបភ្នំព្រះសុមេរុមួយ ដែលបុព្វាធិការី ( អ្នកមុន ) ទាំងឡាយបានគិតថា បានរៀបចំអោយមានពិភពអទិទេពនៅចំកណ្តាលរាជាណាចក្រ ។ សេចក្តីសង្ឃឹមរបស់ព្រះអង្គ គឺត្រូវបំផ្លាញអោយសាបសូន្យ នូវការលុកលុយរបស់ពួកចាមកាលពីឆ្នាំ ១១៧៧ ។ ព្រះបាទជ័យវរ្ម័នទី ៧ ត្រូវតែរៀបចំការការពារសាសនាដ៏ខ្ពង់ខ្ពស់មួយ ។ គឺដើម្បីបញ្ជាក់

រឿងនេះ ព្រះអង្គបានសាងប្រាសាទជាច្រើនរួមមាន ប្រាសាទ និង វត្ត នៅពាសពេញប្រទេសកម្ពុជា ពិសេសនៅតំបន់អង្គរ ។

៣.- សំណង់ធំៗពាំងឡាយ :

នៅក្នុងអំឡុងពេលនៃរាជរបស់ព្រះបាទជ័យវរ្ម័នទី ៧ មានសំណង់ធំៗជាច្រើន ត្រូវបានសាងសង់ឡើងនៅជុំវិញរាជធានី ។ សំណង់ទី ១ របស់ព្រះអង្គ គឺជាប្រាសាទបន្ទាយក្តី រួចប្រាសាទតាព្រហ្មកសាងនៅឆ្នាំ ១១៨៦ ហើយនៅឆ្នាំ ១១៩១ កសាងក្រុមប្រាសាទព្រះខ័ន ។ មានសំណង់ភាគច្រើនជាសំណង់សប្បុរស ហើយនិងប្រាសាទសំខាន់បន្ទាប់បន្សំជាច្រើនទៀត ដូចជាតាណី ក្រោលគោ បន្ទាយព្រៃ តាសោមជាដើម ដែលប្រាសាទទាំងនេះសង់នៅជិតៗគ្នា ។ រាជធានីគឺក្រុងអង្គរធំ បានត្រូវសាងសង់ឡើងវិញ និង ព័ទ្ធជុំវិញដោយកំពែងជាជញ្ជាំងថ្ម ។ ប្រាសាទដែលនៅចំកណ្តាលធានីជួសជុលថ្មី គឺជាប្រាសាទបាយ័ន ដែលជាសំណង់មួយសង់ឡើងនៅចុងបញ្ចប់នៃរាជរបស់ព្រះអង្គ ។

នៅតាមអាណាខេត្ត ព្រះអង្គបានសាងសង់ប្រាសាទនៅពាសពេញប្រទេសទាំងមូល តាំងពីទន្លេមេណាម តាមដងទន្លេមេគង្គ នៅប្រទេសឡាវផ្នែកខាងក្រោម និងភាគខាងត្បូងប្រទេសកម្ពុជា ។ ប្រាសាទតាមខេត្តដែលគួរអោយចាប់អារម្មណ៍ ហើយកសាងនៅក្នុងរាជរបស់ព្រះបាទជ័យវរ្ម័នទី ៧ នោះ គឺប្រាសាទបន្ទាយឆ្មារ ។

ប្រាសាទដែលយើងបានឃើញសព្វថ្ងៃនោះ គឺប្រាសាទដែលសង់ឡើងដោយប្លង់សាំញ៉ាំបំផុត ។ លើកលែងតែប្រាសាទបាយ័នមួយចេញ ដែលជាប្រាសាទមួយមិនសង់នៅលើគ្រឹះតែមួយទេ ។ កំពែងជញ្ជាំង ឬ ថែវទាំងឡាយគឺត្រូវចោះ ដើម្បីធ្វើទ្វារទាំងអស់ ។ ទាំងនេះគឺជាការអភិវឌ្ឍន៍មួយយ៉ាងធំ ហើយជារឿយៗអាចភ្ជាប់ពីកន្លែងមួយទៅកន្លែងមួយទៀត ដោយបន្ទប់ជាច្រើន ដែលមានការតុបតែងលំអយ៉ាងប្រញាប់ប្រញាល់ជាទីបំផុត ។ ទ្វារចូលទាំងអស់នេះ បានបើកចំហរដោយមានប្រក់ដំបូលរហូតដល់ប្រាសាទកណ្តាល ។ ប្រាសាទពយរងជាច្រើនទៀត ប្រហែលជាត្រូវហ៊ុំព័ទ្ធដោយថែវ ដែលតងរបៀបគ្នានៅខាងក្នុងកំពែងប្រាសាទ ។

ប្រាសាទជាច្រើន ដែលបានសាងសង់នៅក្រោមរាជព្រះបាទជ័យវរ្ម័នទី ៧ នោះ បានបង្ហាញពីតួប្រាសាទ ឬទ្វារចូលទាំងឡាយ ដោយមានប្រក់ពីលើតួប្រាសាទ ដោយមុខមនុស្ស ៤ ។ ករណីពិសេសនេះ មិនអាចនៅគ្រប់ប្រាសាទ នៃរាជរបស់ព្រះអង្គទេ ។ គេបានសាកល្បងបញ្ចប់ដែលបង្ហាញពីតួប្រាសាទទាំងឡាយមានមុខមនុស្ស ។ លោក J.Boisselier បានកត់សំគាល់ថា មិនមែនរូបភាពដែលបង្ហាញពីអទិទេពតែមួយជារៀងរាល់ថ្ងៃទេ ។ តាមការសិក្សាដោយខ្លីៗ អំពីលក្ខណៈខុសគ្នានៃសំណង់ទាំងឡាយរបស់ព្រះបាទជ័យវរ្ម័នទី ៧ រួចយើងបាននាំមកនូវសញ្ញាអ្វីដែលជាការកែតំរង់ទិស នៃមុខមនុស្សទាំងឡាយ នៃតួប្រាសាទរបស់សំណង់ទាំងនេះ តាមរយៈនៃការលំអរបស់សំណង់ ។ ជាការពិតណាស់តួប្រាសាទមុខមនុស្ស ដែលដាក់បន្តពីលើទ្វារចូលខាងក្រៅរបស់ប្រាសាទបន្ទាយក្តី បានញែកអោយឃើញពីភាពខុសគ្នា អំពីអ្វីដែលគេបានឃើញនៅទ្វារអង្គរធំ ។

វាមានការពិបាកក្នុងការយល់អោយកាន់តែច្បាស់អំពីអទិទេព ដែលគេបានគោរពបូជានៅប្រាសាទបន្ទាយក្តី ដោយហេតុថា យើងពុំមានគោលចារឹកដែលនិយាយពីការសាងសង់ប្រាសាទនេះទេ ។ គួរអោយស្តាយប្រាសាទនេះណាស់ ដែលទទួលរងការខូចខាតយ៉ាងធ្ងន់ធ្ងរ ។ នៅពីមុខផ្លូវចូលមានស្រះទឹកមួយធំ ដែលអោយឈ្មោះថាស្រះស្រង់ " កន្លែងស្តេចស្រង់ទឹក " នៅទីនោះបង្កាន់ដៃជុំវិញលំអដោយសត្វនាគជាច្រើន ។

៤- ប្រាសាទតាព្រហ្ម :

Râjavihâra " វត្តរបស់ស្តេច " បច្ចុប្បន្នគេបានស្គាល់នៅក្រោមឈ្មោះថា តាព្រហ្ម" Vieux Prahma " ត្រូវបានសង់ឡើងនៅក្នុងឆ្នាំ ១១៨៦ ដើម្បីឧទ្ទិសទៅដល់ព្រះមាតារបស់ព្រះបាទជ័យវរ្ម័នទី ៧ ហើយនិងព្រះរាជគ្រូ ( Guru ) របស់ព្រះអង្គ ។ ម្ចាស់ក្សត្រីបានសោយទិវង្គត់ទៅនោះ ទំនងជាបានបង្ហាញអោយឃើញពី Prajnâpâramitâ ( : ប្រាជ្ញាបារមិតា ) " សុក្រិតភាពនៃគតិបណ្ឌិត " ម្តាយដែលកាន់សាសនាតឹងរឹងបំផុត នូវវិន័យរបស់សាសនា ។

ការបង្ហាញមួយផ្នែកផ្សេងទៀត អំពីប្រាសាទតាព្រហ្ម គឺបានបង្ហាញភស្តុតាងអំពីប្រាសាទនេះថាជាវត្ត ដោយប្លង់របស់វាមានរួមបញ្ចូលដោយបន្ទប់តូចៗអំពីថ្ម សំរាប់បំរើអោយផ្នែកសាសនា ។ តួប្រាសាទកណ្តាលបានត្រូវសង្កត់ធ្ងន់ ដោយនៅគ្រប់ផ្ទៃខាងក្រៅទាំងអស់ មានផ្ទុកទៅដោយជំរថ្នាំខាប់សំពប់លាប ។

នៅចន្លោះកំពែងទី ៣ និងទី ៤ បានបង្កើតអោយមានសួនមួយ ដោយរួមមានផ្ទៃសរុប ៦០ ហិចតា ។ នៅទីនេះ បើតាមសិលាចារឹកថាមានមនុស្សចំនួន ១២.៦៤០ នាក់រស់នៅ ។ បន្ទប់តូចៗទាំងឡាយដែលធ្វើអំពីថ្ម មិនអនុញ្ញាតិអោយមានសាសនាច្រើនជ្រកនៅជាមួយទេ ។ មនុស្សត្រូវតែរស់នៅក្នុងផ្ទះដែលធ្វើអំពីឈើ ។ ក្រៅពីនេះមានបុព្វជិតសំខាន់ចំនួន ១៨អង្គ និង ចៅក្រមបុព្វជិត ២.៧៤០នាក់ អ្នកជំនួយការដែលបំរុងទុកសំរាប់ប្រាសាទមាន ២.២៣២នាក់ ។ គឺជាអំណោយមនុស្សដែលបានមកពីធានីដ៏តូចនេះ ដែលមករស់នៅក្នុងរាជវិហារ ។ វត្តនេះសំបូរបែបណាស់ ហើយមានការឧបត្ថម្ភមកពីភូមិចំនួន ៣.១៤០ នៃប្រទេសកម្ពុជា ។

៥- ប្រាសាទព្រះខ័ន :

កំពែងខាងក្រៅរបស់ប្រាសាទព្រះខ័ន កំណត់បានជាចតុកោណកែងមួយ រួមមានទំហំ ៧០០ម×៨០០ម ។ ប្រាសាទនេះសង់ព័ទ្ធទីកន្លែងមួយ ដែលព្រះបាទជ័យវរ្ម័នទី ៧ បានដណ្តើមបានជ័យជំនះពីពួកចាម ។ សិលាចារឹកនៅប្រាសាទព្រះខ័នដ៏ល្អ ដែលនិយាយពីការបង្កើតធានីនេះ ដោយយកឈ្មោះថា ជ័យស្រី ( Jaya Çri ) " ភ័ព្វសំណាងនៃជ័យជំនះ " ។

គាថា xxx II " នៅទីនេះ នៅក្នុងពេលច្បាំងគ្នា មានប្រជុំទៅដោយសត្រូវជាច្រើន ដែលមានឈាមហូរជោគជាំលើប្រថពី ហើយព្រះអង្គក៏ទទួលបាននូវជ័យជំនះ ( Jay Sri ) ព្រះអង្គបានស្ថាបនាធានីដោយយកឈ្មោះថា ជ័យស្រី ដែលថ្មហើយផ្កាឈូកមាសទាំងឡាយមានប្ញូរពណ៌ដី ហើយដែលចាំងមកម្តងទៀតរហូតដល់សព្វថ្ងៃនេះ ដូចជាជំរថ្នាំឈាមដែលគេយកមកបូកពាសពីលើ ។

ឈ្មោះសព្វថ្ងៃ គឺឈ្មោះព្រះខ័ន មានន័យថា ដាវពិសិដ្ឋ ត្រូវបានគេរក្សាទុកនៅក្នុងព្រះបរមរាជវាំងភ្នំពេញ ដែលគេចាត់ទុកថា ជាគ្រឿងសំរាប់ការពាររាជាណាចក្រ ។

គេចូលទៅដល់ប្រាសាទព្រះខ័នបានតាមផ្លូវចូល ៤ ដែលមានអមដោយយក្ស និង ទេវតាទាញព្រ័ត្រអំពីថ្មពីរជួរ ឈរទាញនាគមួយម្ខាង ។ ផ្លូវចូលទាំងនេះ គឺធ្វើដូចផ្លូវចូលធានីអង្គរធំ ។ ប្រាសាទព្រះខ័នពុំមែនមានតែតួប៉មមួយប៉ុណ្ណោះទេ ប៉ុន្តែវាជាធានីមួយដូចធានីអង្គរធំដែរ ។ នៅពីមុខផ្លូវចូលនៃទិសខាងកើត និង ខាងលិចមានក្រាលកំរាលថ្មបាយក្រៀម នៅសងខាងមានបង្គោលសីម៉ាអំពីថ្មភក់ ។

កាលពីឆ្នាំ ១១៩១ នៅក្នុងប្រាសាទព្រះបាទជ័យវរ្ម័នទី ៧ បានឆ្លាក់រូបព្រះបិតារបស់ព្រះអង្គក្រោមរូបភាពជាលោកេស្វរៈ ( Lokeçvara ) គឺរូប " លោកេស្វរៈនេះហើយដែលមានឈ្មោះថា ស្រីជ័យវរ្មេស្វរៈ ( Çrijayavarmeçvara ) " ជាអទិទេពមួយអង្គ ដែលព្រះបាទជ័យវរ្ម័នចូលចិត្តជាងគេ ។ ការ

បង្ហាញពីអទិទេពលោកេស្វរៈ ដែលមានគាលបរិច្ឆេទក្នុងសម័យនេះមានចំនួនច្រើន អញ្ជឹងការជឿ ចំពោះព្រះពោធិសាត់ ដែលបង្ហាញអោយឃើញនោះ មានច្រើនណាស់នៅពេលនោះ ។ នៅក្នុងប្រាសាទ ហើយនៅលើហោជាងនៃប្រាសាទទាំងឡាយ គេបានរកឃើញនូវរូបភាពទាំងឡាយ ដែលគេអាចស្គាល់ថា ជារូបភាពរបស់ព្រះពុទ្ធ អមិតាភៈ ( Amitabha ) " ពន្លឺចិញ្ចាចគ្មានទីបញ្ចប់ " ... លោកេស្វរៈបាន ស្ថិតនៅក្នុងផ្ចិតសក់ ។

នៅជុំវិញជ័យវរ្ម័នស្វរៈលោកេសៈ គេបានសាងរូបអទិទេពចំនួន ២៨៣ ទៀត ។ ក្នុងចំណោម ស្តេចរៀមច្បងសំខាន់ៗ ៨អង្គ ព្រះបាទជ័យវរ្ម័នទី ៧ បានហៅព្រះបាទ ស្រីជយរាជវរ្ម័នស្វរៈ និង ស្រីទ្រីភូវណាវរ្មស្វរៈ ។ នៅមុនដល់តួប្រាសាទកណ្តាល ក្នុងទិវ្ធដែលសំណង់ដោយថ្មី ... មួយ គេ កសាងតួប្រាសាទតូចៗ ដែលលោក G. Coedès បានហៅថា " ជាកុដិគ្រឹះសំរាប់ ... " ដែលសង់ ឡើងសំរាប់ឧទ្ទិសដល់អ្នកដែលស្លាប់ទៅ ។

តាមសិលាចារឹកបានរៀបរាប់ពីជង្វាយទាំងឡាយ ដែលគេបាននាំមកថ្វាយជារៀងរាល់ថ្ងៃដល់ អទិទេពនៅប្រាសាទព្រះខ័ន ដែលចាប់ផ្តើមដោយលោកេស្វរៈ ។ ជង្វាយទាំងនោះ រួមមានសមាសធាតុអំពីអង្ករ ល្ង សាច់ ខ្លាញ់ ទឹកដោះរាវ ទឹកដោះខន ទឹកដោះបំរុង ( សោហ៊ុយ ) ទឹកឃ្មុំ ស្ករ ហើយ និងខ្លាញ់ត្រី ។ គេបានចង្អុលបង្ហាញនៅក្នុងសិលាចារឹកមួយនេះដែរ នូវជង្វាយផ្សេងៗទៀត ជាក្រណាត់ សំរាប់ស្លៀកពាក់អោយរូបចំលាក់ទាំងឡាយ ក្រណាត់សំពត់ម៉ន្តលស និង ក្រណាត់សំរាប់ធ្វើជា សំលៀកបំពាក់ ហើយនិងនាំសូតមកពីស្រុកចិនដ៏វិសេសឡើយ សំរាប់ការពារមុងទាំងឡាយ ការពារ ធ្វើងបដិមាករលោកេស្វរៈ និង អទិទេពផ្សេងៗទៀត អត្ថបទបានចុះនិទ្ទេសនៅខាងចុងបញ្ចប់អំពី អំណោយទាំងឡាយ ដែលគេប្រគល់អោយដល់មនុស្សដែលថែរក្សាប្រាសាទ អំណោយទាំងនោះ គឺ សំរាប់តែមនុស្ស ក៏ដូចជាជង្វាយសំរាប់អទិទេពដែរ ប៉ុន្តែបើពិនិត្យពីគុណភាពវិញ មានតំលៃ និង មាន សារៈសំខាន់ជាងផលនេះ គឺដោយសារតែមនុស្សមានចំនួនច្រើនជាង បើគេរាប់ទៅមានចំនួន ១០ ពាន់ នាក់ ។

២- ប្រាសាទនាគព័ន្ធ :

សិលាចារឹកនៅប្រាសាទព្រះខ័ន បានចុះនិទ្ទេសយ៉ាងច្បាស់ពីចំនួនប្រាសាទ ដែលមានចំនួន ច្រើន ហើយងាយស្រួលក្នុងការកំណត់ ។ មួយពីរ ដោយដួយសំរួលដល់ ... សំគាល់ វាបានបង្ហាញនៅ ទីនេះ គឺជាកោះរាជ្យស្រី ( Rājyaçri ) ដែលវាបានភ្ជាប់នឹងប្រាសាទនាគព័ន្ធ នាគរមួ ជារមួខាងកន្ទុយ ។ វាបានលេចឡើងនៅចំកណ្តាលស្រះទឹកបុកណា ជ័យតតាក ( Jayata ... ) ដែលសិលាចារឹកបាន សរសេរដូចថា " កញ្ចក់ភ្លះអោយដឹងនៃក័ភ្នសំណាង ដែលរៀប ... ទៅដោយ ... នូវមាស ហើយ ... គាំង មាសទាំងឡាយ " នាគព័ន្ធមានប្រាសាទមួយ ដែលទ្រូវដោយភ្លក្ក ... កម្ពុជ ... ដែលដាក់នៅលើគ្រឹះ របស់ប្រាសាទ ។ សត្វនាគពីរកំពុងតែរុំជុំវិញគ្រឹះនេះ ... នាគទាំងពីរនេះ ... ដែលត្រូវបានគេអោយ ឈ្មោះដល់ប្រាសាទ ។ ស្រះទឹកកាងការ មានជំរៅ ... ហើយព័ទ្ធជុំវិញ បថ្មកក់តំរៀបជាជញ្ជាំងជា កាំថ្នាក់ៗ ។ ដើម្បីជុំសលាងជំរះកាយ នៅ ... មណ្ឌបទាំងឡាយ ដែលគេក ... ទៅជញ្ជាំងថ្ម វាបានត្រង់ យកទឹកដោយបំពង់បង្ហូរ ទឹកមានទំរង់ជាក្បាលមនុស្សនៅទិសខាងកើត ... លតោមាននៅខាងត្បូង ក្បាលសេះខាងខាងលិច និង នៅខាងជើងមានក្បាលដំរី ។ ក្រោម ... ភ្លូ ... តំនុំ ... រូបលាងជំ កាយទាំងឡាយនោះរួច ទឹកក៏ត្រូវធ្លាក់ចូលទៅក្នុងស្រះបួន ដែលគេរកនៅលើជ្រុង ៤ នៃស្រះទឹក ដ៏សំខាន់ ។

នៅឆ្នាំ ១៩២៣ លោក L. Finot និងលោក V. Goloubew បានដឹងពីប្រាសាទនាគព័ន្ធ គឺជាចំលើយតបមួយចំពោះស្រះ អណវតប្ត: ( Anavatapta ) ដែលនៅទីនោះជាកន្លែងបរិសុទ្ធនៃទេវកថាហិមាល័យ ។ បឹងនោះហូរចាក់ទៅក្នុងទន្លេ ៤ ទៀត ដែលហូរឆ្ពោះទៅកាន់ទីកន្លែងរៀងៗខ្លួន ដែលវាត្រូវទៅ ។ លោក J.Boisselier បានធ្វើការសិក្សាពីប្រាសាទនាគព័ន្ធ ដែលមាននៅក្នុងសិលាចារឹកនៃប្រាសាទព្រះខ័ន ហើយនៅលើអត្ថបទដែលប្រមូលយកបានផ្សេងៗពីគ្នា ចំពោះស្រះ Anavatapta ។ គាត់បានបង្ហាញពីលក្ខណៈសំខាន់ខ្លះៗ ពីប្រាសាទនាគព័ន្ធនៅក្នុងនិម្មិតរូបនៃទីក្រុង ហើយនិងការចាប់ផ្តើមរបស់វា ។ តាមរយៈអត្ថបទឥណ្ឌាជាច្រើនបានបញ្ជាក់ថា ទឹកទាំងឡាយរបស់ Anavatapta រាល់ថ្ងៃនៅស្រស់ជានិច្ច អញ្ជឹងវាមិនអាចទទួលយកកាំរស្មីផ្ទាល់ពីព្រះអាទិត្យទេ ប៉ុន្តែពន្លឺតូចៗដែលចាំងចូលទៅត្រូវបាំងត្រលប់មកវិញ ។ ឬក៏សិលាចារឹករបស់ប្រាសាទព្រះខ័នបាននិយាយយ៉ាងច្បាស់ថា ទឹកស្រះរបស់ប្រាសាទនាគព័ន្ធ " គឺចាំងដោយពន្លឺនៃប្រាសាទទាំងឡាយអំពីមាស " ដែលតាមរយៈនៃភាពថ្លាឆ្វង់មិនអាចចាំងត្រឡប់វិញដោយផ្ទាល់ ដោយព្រះអាទិត្យទេ ។ នៅក្នុងលោកធាតុវិទ្យារបស់ព្រះពុទ្ធ ស្រះ Anavatapta គឺជាស្រះចុងក្រោយគេ ដែលគេបង្ហូតទឹកទឹកអស់ នៅពេលចុងក្រោយរាជាណាចក្រដែលអាស្រ័យប្រើប្រាស់ គឺជាអំណោយសំរាប់ធានាអោយមានជីវិតរស់នៅបានយូរអង្វែងអោយពិភពបច្ចុប្បន្នដែរ ។ មួយផ្នែកទៀត ទឹកទាំងឡាយរបស់ស្រះមានលក្ខណៈពិសេស គឺបរិសុទ្ធ ដែលកាលនោះគេបានអភិសេកស្តេចចក្រពត្តិ គេត្រូវប្រព្រឹត្តទៅតាមពិធី មហាសិទ្ធិបណ្តោះអាសន្ន នៃព្រះមហាក្សត្រជាមួយទឹកដែលហូរចាក់ទៅក្នុងស្រះ Anavatapta ។ លោក J Boisselier បានធ្វើការកត់សំគាល់ថា " សំណង់ដែលមានមូលហេតុទ្វេ ( double ) គឺសំរាប់តែប្រទេសកម្ពុជា ៖ គឺវាធានាចំពោះរាជាណាចក្រនៅក្នុងរយៈពេលដូចគ្នា ដែលវាធានាចំពោះការពាក់ព័ន្ធនឹងសកលនិយមរបស់ព្រះមហាក្សត្រ " ។

នៅក្នុងស្រះដែលព័ទ្ធជុំវិញតួប្រាសាទកណ្តាលនោះ គេបានរកឃើញនូវបំណែកជាច្រើននៃក្បាច់ចំលាក់ជាសារពើទៀត ទាំងអស់ ៤ ( Rondes - bosses ) នៅទិសខាងត្បូងមានបំណែកថ្មពីរ បីដែលគេមិនបានស្គាល់ពីប្រភពដើម ប៉ុន្តែនៅទិសខាងលិច វាមានសេសសល់នូវបំណែកជាច្រើននៃរូបចំលាក់វិស្ណុថ្មី នៅខាងជើងគេបានស្គាល់ច្បាស់ថាជាលិង្គ ។ ចុងបញ្ចប់នៅខាងកើត គេបានផ្គុំឡើងវិញនូវរូបសេះ ប:ល:ហ: ( Balaha ) ដែលល្អជាងគេ ។

សេះដែលគួរអោយកោតសរសើរនេះ គឺជាលំនាំនៃកិច្ចការនាំយកលោកេស្វរៈ ដើម្បីសង្គ្រោះពួកមនុស្សលង់ទឹកទាំងឡាយ ។ ទាំងនេះបានបង្ហាញពីការឡើងទៅប្រហារមនុស្ស និង យក្សបានខាំហែកមនុស្សស៊ីនៅលើកោះ ហើយនៅចំណុចនៃការខាំហែកស៊ីនោះ សេះបានអន្ទងហៅព្រះពោធិសាត់ ( bodhi sattva ) ដែលមានករុណាអោយមកជួយសង្គ្រោះ ។

គេពុំបានភ្លេចក្រំ នូវអ្វីដែលធ្វើអោយភ្ញាក់ផ្អើលនូវសេះ Balaha ដែលចំលងមនុស្សលង់ទឹកដែលតោងចង្កេះគ្នាឆ្ពោះទៅកាន់ប្រាសាទ ដែលមានលោកេស្វរៈនៅទីនោះ ប៉ុន្តែគេកាន់តែភ្ញាក់ផ្អើលជាងនេះទៅទៀត ដែលគេបានឃើញរូបអទិទេព ព្រហ្មញ្ញសាសនា ២អង្គទៀត នៅក្នុងស្រះ Anavatapta នេះដែរ ។ សិលាចារឹកនៅប្រាសាទព្រះខ័នបាននិយាយថា ព្រះបាទជ័យវរ្ម័នទី ៧ បានដាក់រូបអទិទេព ៤អង្គ " នៅក្នុងកោះជ័យស្រី នូវលិង្គចំនួន ១០០០លិង្គ " ។ លោក P. Mus បានស្នើរឿងនេះក្រោយពីបានកត់សំគាល់រួចមក ដែលគាត់បានស្រុះស្រួលចិត្តដាក់ជាក្រុមឡើងវិញ នៅជុំវិញព្រះពុទ្ធបដិមានូវលទ្ធិសាសនា ដែលធានាមហាអំណាចនៅប្រទេសកម្ពុជាតាំងពីសន្តតិវង្សដើមរបស់សម័យអង្គរ ប៉ុន្តែអ្នកណាដែលបានបះជើងឡើង នៅក្នុងពេលដែលចាមបានមកគ្រប់គ្រងធានីអង្គរ កាលពីឆ្នាំ ១១៧៧ នោះ ។

លោក J Boisselier បានគិតថាវាត្រូវតែធ្វើអោយមានជីវិតជាថ្មី នូវពិធីសាសនាចាស់ៗទាំងឡាយ ដោយយកមកជំនួសនៅក្នុងរូបភាពថ្មី ។ ក្រោយពីគាត់បានបង្ហាញនូវអទិទេព ព្រហ្មញ្ញសាសនានៅជុំវិញព្រះពុទ្ធរូប ការគោរពសក្ការៈរាជ្យស្រីយ៉ាងពេញទំហឹងអោយដូចអរហន្ត ហើយនឹងបានជួយទំនុកបំរុងការស្ថាបនាស្រះនេះអោយបានសំរេច " រមណីយដ្ឋានមួយដែលប្រវៃជាងគេដោយនិយាយបំភ្លឺសដូចគ្នា និង និម្មិតរូបស្រះ Anavatapta ដោយហេតុថាជាកន្លែងស្នាក់នៅបណ្ដោះអាសន្នរបស់ពពួកអទិទេព ដើម្បីគេចពីការបំផ្លាញលោក " ។

៧- <u>ការចាប់ផ្ដើមនៃធានីអង្គរធំ វិហារតូចៗរបស់មន្ទីរពេទ្យ និង ផ្ទះសំណាក់ធម៌ទេសចរ</u> :

ធានីអង្គរធំ គឺជាបេះដូងនៃរាជាណាចក្រ គ្រប់ផ្លូវគមនាគមន៍ទាំងអស់បានភ្ជាប់ពីទីនេះដោយឆ្ពោះទៅកាន់គ្រប់ខេត្តទាំងអស់នៃប្រទេស ។ ផ្លូវទាំងឡាយគឺកើតឡើងដោយស្នាដៃនៃចិត្តសប្បុរសជន និង ព្រះបាទជ័យវរ្ម័នទី ៧ បានធ្វើខ្លួនអោយជាសន្តបុគ្គល ដោយបានសង់ផ្ទះសំណាក់ និង មន្ទីរពេទ្យជាច្រើនទៀតតំរៀបគ្នានៅតាមផ្លូវ ។ ជាការពិតណាស់ ចិត្តសប្បុរសទាំងអស់នេះ បានរៀបចំអោយមានរួចមកហើយ តាំងពីការចាប់ផ្ដើមកសាងអង្គរធំផ្ទាល់មកម្ល៉េះ ។

មន្ទីរពេទ្យទាំងឡាយ ស្ថាបនាឡើងដោយព្រះបាទជ័យវរ្ម័នទី ៧ មានចំនួនសរុប ១០២ ។ សំណង់ទាំងឡាយត្រូវបានសាងសង់ឡើង ដោយសំភារៈងាយនឹងវិនាសណាស់ ហើយវាក៏បានបាត់បង់ទៅតាំងពីយូរយារមកហើយ ប៉ុន្តែរមណីយដ្ឋានទាំងឡាយ ត្រូវបានថែរក្សាដោយវិហារតូចៗ ហើយនិងគោលចារឹកនៃការសាងសង់ ។ អត្ថបទទាំងឡាយនៃ " គោលចារឹករបស់មន្ទីរពេទ្យ " គឺវាស្ទើរតែដូចគ្នា គឺបាត់បង់ទាំងអស់ ។ មានវិហារតូចៗនៃមន្ទីរពេទ្យចំនួន ៤ ដែលគេបានរកឃើញនៅជុំវិញធានីអង្គរធំ នៅខាងកើតជិតប្រាសាទតាកែវ " ជាវិហារតូចរបស់មន្ទីរពេទ្យ " នៅខាងត្បូងក្រុងអង្គរធំ គឺជាប្រាសាទតាព្រហ្មកិល នៅខាងលិចក្រុងអង្គរធំមានវិហារតូចមួយ ដែលគេមិនទាន់បានដាក់ឈ្មោះដោយខ្មែរអោយ ។ នៅខាងជើងក្រុង ដែលគេរកឃើញគោលចារឹកនៅឆ្នាំ ១៩៥៤ នោះ គឺប្រាសាទទន្លេស្ងួតដូចគ្នានឹងវិហារតូចៗរបស់មន្ទីរពេទ្យដែរ ។ សិលាចារឹកដែលដាក់នៅតាមវិហារតូចៗរបស់មន្ទីរពេទ្យទាំងនោះ បានបញ្ជាក់អោយដឹងថា បានឧទ្ទិសទៅដល់ព្រះពុទ្ធ Bhaishajyaguru Vaidurya prabhâ " ម្ចាស់នៃឱសថទាំងឡាយ ដែលចាំងពន្លឺមកពីត្បូងពេជ្រពណ៌បៃតង" ។ មន្ទីរពេទ្យទាំងអស់នោះ ត្រូវបានគ្រប់គ្រងនៅមើលថែរក្សាដោយគ្រូពេទ្យ ហើយនិងមនុស្សជាច្រើនទៀត ដែលរួមមានអ្នកបួសជាមេក្នុងបញ្ជី ២អង្គ ហើយនិងហោរាម្នាក់ ។ សិលាចារឹកដែលបានចារនោះ បាននិយាយថាថ្នាំពេទ្យទាំងឡាយគឺត្រូវបានផ្គត់ផ្គង់យ៉ាងស្ថិតស្ថេរ ។ អ្នកជំងឺនៃ " វណ្ណៈទាំង ៤" អាចមកព្យាបាលបាននៅក្នុងមន្ទីរពេទ្យទាំងនេះ ។

ក្រោយពីបានសិក្សាសិលាចារឹកនៅប្រាសាទព្រះខ័ន ព្រះបាទជ័យវរ្ម័នទី ៧ បានបញ្ជាអោយគេស្ថាបនាផ្ទះសំណាក់ចំនួន ១២១ នៅតាមផ្លូវ " ជាផ្ទះដែលមានភ្លើងស្រាប់ " នៅទីនេះជនយាត្រាហើយនិងអ្នកដំណើរទាំងឡាយ អាចរកកន្លែងសមរម្យមួយ សំរាប់សំរាកខ្លួនឯង ហើយនិងលើកកំលាំងខ្លួនឯង ។ មានតួប្រាសាទពីរ ឬ បី ប៉ុណ្ណោះ ដែលគង់វង់នៅដល់សព្វថ្ងៃ ។ វារួមមានអសនៈមួយនៅពីមុខ ហើយមានបន្ទប់វែងមួយទៀតកងជាបន្ទប់លយ ( Avant - Corps ) ។ ផ្ទះសំណាក់ទាំងនោះត្រូវបានសាងនៅផ្នែកខាងក្នុងកំពែងរាជធានី ដែលមានជាប្រាសាទធំៗ ឬ ជាវត្តវាទំនងមាននៅដោយដាច់ពីប្រាសាទតាព្រហ្ម និង ព្រះខ័ន ។

៨- <u>កំពែងធានីអង្គរធំ</u> :

ធានីយសោធរបុរៈ បានត្រូវធ្លាក់ចូលទៅក្នុងកណ្តាប់ដៃចាមក្នុងឆ្នាំ ១១៧៧ ប៉ុន្តែវាមិនត្រូវបាន ឆេះ ឬ ក៏បំផ្លាញអោយខ្ទេចទេ ។ នៅពេលនោះធានីរបស់ព្រះបាទជ័យវរ្ម័នទី ៧ មិននៅជាប់ជាមួយនឹងធានីរបស់ព្រះបាទយសោវរ្ម័នទេ វាមានវិសាលភាពតូចជាង ហើយបានទិត និង លាតសន្ធឹងទៅខាងជើង ។ ចំណុចកណ្តាលរបស់វា គឺជាប្រាសាទបាយ័ន ។

កំពែងព័ទ្ធជុំវិញធានីអង្គរធំ មានផ្ទៃជារាងការេ ដែលមានមួយជ្រុង ៣គម កំពែងនេះត្រូវបានសាងសង់ឡើងអំពីថ្មបាយក្រៀម ដោយមានលើកដីខ្ពស់ សំរាប់ទប់ជ្រែងពីខាងក្នុង ហើយនៅពីក្រៅមានព័ទ្ធជុំវិញដោយគូទឹក ដែលមានទទឹង ១០០ម ។ ទ្វារចំនួនប្រាំ ដែលគេសង់ពុះកាត់តាមជញ្ជាំងកំពែងមានមួយនៅជ្រុងខាងជើងខាងត្បូង និង ខាងលិច ។ ហើយជ្រុងខាងកើតមាន ២ គឺទ្វារជ័យ និង ទ្វារមរណៈ « ខ្មោច » នៅពីមុខផ្លូវចូលទាំងឡាយនោះមានស្ពានហាលមួយៗសង់កាត់ទទឹងគូទឹក ។ នៅតាមជ្រុងទាំងឡាយ នៃកំពែងគេសង់ប្រាសាទជ្រុង នៅគ្រប់ជ្រុងអនុទិស និង មានសិលាចារឹក ៤ផ្ទាំងរាងការេ នៅគ្រប់ជ្រុងអនុទិសដែរ ។

នៅក្នុងសិលាចារឹករបស់ប្រាសាទជ្រុងទាំងនោះបាននិយាយថា ព្រះបាទជ័យវរ្ម័នទី ៧ បានកសាង " Jayagiri មួយ ( ភ្នំនៃជ័យជំនះ ) កោសល្យដោយពិតពីឋានសួគ៌ ដែលចែងចាំងដោយពន្លឺ " ហើយ " Jaya Sindhu ( សមុទ្រនៃជ័យជំនះ ) បានទៅពាល់ដល់ជំរៅរបស់វា ដែលគេពុំអាចស្មានបាននៅឯឋានភូជុងនាគ " ។ ដូច្នេះកំពែងធានីអង្គរធំមានន័យជាស្លាដៃ សំរាប់ការពារយ៉ាងល្អៗ វាបានផ្ទុកទៅដោយនិម្មិតរូបដូចជា ៖ ជញ្ជាំងកំពែងគឺជាជួរភ្នំដែលព័ទ្ធជុំវិញពិភពរបស់យើង និង គូទឹកគឺជាមហាសមុទ្រនៃលោកធាតុកាន់កាប់ដោយសត្វនាគ ៨ ដែលទ្រទ្រង់ពិភពលោក ។

នៅពីមុខទ្វារចូលទាំងឡាយ ស្ពានដែលឆ្លងកាត់គូទឹកនោះ បានព័ទ្ធពីក្រៅដោយពួកយក្សពីរជួរកំពុងតែទ្រសត្វនាគមួយ ។ នៅទីនេះប្រសិនបើគេត្រៀមខ្លួនទៅក្នុងរាជធានី គេនឹងឃើញនៅខាងឆ្វេងនូវពួកទេវតា ដែលមានទឹកមុខស្លូតបូត ដែលនៅលើក្បាលមានពាក់មកុដនៃអទិទេព ហើយនៅខាងស្តាំមានមនុស្សដែលមានភ្នែកលៀន ដែលនៅលើក្បាលមានពាក់មួកជាអ្នកចំបាំង និង សំអរដោយស្លឹកឈើ ។ ពួកយក្សទាំងអស់នេះទំនងជាទាញនាគមកវិញ ដើម្បីឃាត់ក្នុងការដែលរត់គេចខ្លួន ។ លោក G.Coedès បានមើលនាគ បានបង្ហាញអោយឃើញថា នាគនេះមានទំរង់ជាធ្នូរបស់ព្រះឥន្ទ្រ ( ឥន្ទ្រធ្នូ ) ដែលភ្ជាប់ពីពិភពអទិទេពមកភពមនុស្ស ។ មានទៀតនៅតាមជ្រុងនៃក្លោងទ្វារ គេបានឆ្លាក់ជាក្បាច់ក្រឡោតខ្ពស់នូវរូបព្រះឥន្ទ្រផ្ទាល់តែម្តង កំពុងតែជិះនៅលើសត្វដំរីក្បាល ៣ ។

ក្លោងទ្វារទាំងឡាយរបស់កំពែងអង្គរធំ មានសង់បន្ទិតពីលើ ដោយមុខមនុស្ស ៤ ។ លោក J.Boisselier បានធ្វើការកត់សំគាល់ថា គេបានបង្ហាញពីក្បាល ៤ ពុំមែនជាក្បាលមួយមានមុខ ៤ នោះទេ ហើយគាត់បានគិតថា គំរូរបស់រូបនេះ គឺគេចង់បង្ហាញអទិទេព ៤ ដែលសោយរាជ្យនៅតាមទិស ដែលផ្លូវទាំងនោះបែរទៅរក ( មានទិសលិច កើត ជើង ត្បូង ) ។

ការបង្ហាញពីស្នាដៃស្ថាបត្យកម្ម នៃផ្លូវចូលទាំងនេះ គឺជាអនុភាពមួយដ៏អស្ចារ្យ ដែលគួរអោយកោតសរសើរ នៅមុខក្លោងទ្វារដែលខ្ពស់ៗនោះ មានខ្សែបន្ទាត់ខ្ពស់ស្រឡះមួយ បានបន្លាយខ្លួនជាយក្ស ២ ជួរដ៏ខ្លាំងពូកែហើយធ្ងន់ ។

៩- ប្រាសាទបាយ័ន :

ប្រាសាទដែលសាងសង់នៅចំកណ្តាលធានីអង្គរធំ គឺជាប្រាសាទបាយ័ន ដែលជាប្រាសាទមួយបញ្ជាក់ពីបុគ្គលិកលក្ខណៈ នៃរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧ ។ ប្រាសាទនេះត្រូវបានសាងឡើងនៅក្នុង

អំឡុងភាគទី ២ នៃរាជរបស់ព្រះអង្គ ។ ប្លង់របស់វាមានការចំឡែកជាងគេ ដែលពុំមានកំពែងព័ទ្ធជុំវិញទេ ។ គឺប្រាសាទបាយ័ននេះហើយ ដែលមានជញ្ជាំងកំពែងរបស់វារួមជាមួយនឹងកំពែងរបស់ធានី ហើយទីក្រុងគឺស្ថិតនៅខាងក្នុងកំពែងពិសិដ្ឋនេះ ។ ប្រាសាទបាយ័នមានតួប្រាសាទពិសេសពីគេ ហើយសាំញ៉ាំបំផុត ដែលមានទំរង់ខ្ពស់ក្រាស់ កំពែងជារាងថែវពីរ ដែលជញ្ជាំងរបស់វាមានចំលាក់ជាក្បាច់ក្រឡេកទាបពេញទាំងអស់ ។

តួប្រាសាទកណ្តាល គឺជាកន្លែងអសនៈ ដែលព័ទ្ធជុំវិញដោយកន្លែងដែលគេដើរលេង ហើយនិងវិហារតូចៗចំនួន ១៦ ដែលបើកចំហរទៅខាងក្រៅ ហើយមានពន្លឺចូលផង ។ គំនូរប្លង់របស់ប្រាសាទនេះមានលក្ខណៈប្លែក ដោយប្លង់រាងរង្វង់មានទំរង់ដូចជាស្ថានភាពយន្ត្រ ( Yantra ) ដែលមានវិជ្ជាលេខនៃមន្តអាគមន៍ ។ តួប្រាសាទផ្សេងទៀត រៀបចំនៅជុំវិញតួប្រាសាទក្រាស់កណ្តាល ។ តួប្រាសាទទាំងអស់មានលំអដោយមុខ ៤ គំរៀបជាប្រាសាទដាក់នៅផ្នែកខាងលើនៃសំណង់ ។ លោក Ph. Stern បានចង្អុលបង្ហាញប្រាប់ពីតួប្រាសាទ ដែលមានបន្ថែតដោយមុខមនុស្សនោះថា បានត្រូវកើតឡើងនៅក្នុងសម័យទី ២ នៃរចនាបថបាយ័ន ដែលគេបានអោយឈ្មោះរចនាបថនេះទៅតាមប្រាសាទតូចចុងក្រោយនៃរាជព្រះបាទជ័យវរ្ម័នទី ៧ ។

ការខូចខាតផ្នែកខាងលើនៃសំណង់ នៃតួក្រាស់កណ្តាល មិនបានអនុញ្ញាតិអោយគេបានយល់ដឹងយ៉ាងច្បាស់ពីទំរង់មុខ នៅផ្នែកខាងលើនោះបានទេ ។

គេបានស្រាវជ្រាវរកអ្វីដែលអាចបញ្ជាក់បានពីអត្តសញ្ញាណពិត នៃតួប្រាសាទមុខមនុស្សទាំងអស់នោះ ។ លោក P. Mus បានគិតថា មុខទាំងអស់នោះ គឺជាមុខរបស់ពោធិសាត់ លោកេស្វរៈ (Bodhisattva Lokeçvara Samanta mukha ) មុខរបស់លោកេស្វរៈទាំងឡាយ គឺបែរទៅគ្រប់ទិសទាំងអស់ ។ នៅក្នុងពេលនោះលោក J.Boisselier បានធ្វើការកត់សំគាល់ថា មុខទាំងអស់នៃតួប្រាសាទបាយ័នមានពាក់មកុដនៅលើក្បាល លំអទៅដោយស្លឹកឈើដែលជាកម្មសិទ្ធិ នៃមួករបស់អ្នកចំបាំងប្រចាំថ្ងៃ និង មិនអាចយកមកពាក់ដោយលោកេស្វរៈបានទេ ។

តួបំមកណ្តាលរបស់ប្រាសាទបាយ័ន ត្រូវបានឧទ្ទិសទៅដល់ព្រះពុទ្ធ ។ នៅឆ្នាំ ១៩៣៣ គេបានរកឃើញនៅក្រោមតួប្រាសាទកណ្តាល នូវរូបពុទ្ធបដិមាករធំប្រក់នាគ ។ សិលាចារឹកទាំងឡាយ ដែលគេបានចារនៅលើមាត់ទ្វារចូលនៃវិហារ ដែលបែរចេញក្រៅ អាចអោយគេរកឃើញថា បានប្រាប់អោយយើងដឹងថា : ប្រាសាទនេះធ្វើឡើង គឺបំរុងសំរាប់រៀបចំធ្វើពិធីសាសនារបស់គ្រួសារស្តេច ហើយនិងពិធីសាសនានៃអ្នកខេត្ត ។ តើហេតុអ្វី ? លោក G.Coedès បានសរសេរថា " ដូចគ្នាទៅនឹងទីក្រុងដែលផ្តល់អោយជាមួយនឹងកំពែងរបស់វា រួមនឹងភ្នំកណ្តាលរបស់វាមានរូបភាពបង្រួម នៃពិភពលោកនៅឆ្ងាយពីគេនោះ ប្រាសាទបាយ័នគឺជារូបភាពនៃរាជាណាចក្រ " ។

១០- ព្រះបរមរាជវាំងហើយភិមមុខខារ ( សំខាន់ ) រៃឆាគីអត្តរធំ :

សំណង់សំរាប់លំនៅដ្ឋាន នៅក្នុងព្រះបរមរាជវាំងទាំងអស់ ត្រូវវិនាសសាបសូន្យ ប៉ុន្តែគេអាចឃើញនៅក្នុងរាជវាំងនូវស្រះទឹក ២ ដែលមួយចំពាក់ទៅដោយរូបចំលាក់នៅក្នុងរចនាបថបាយ័ន ។ ចំលាក់ទាំងនេះ បានបង្ហាញនៅជួរខាងលើ នូវរូបគ្រុឌឈ្មោល ញី ឈរជាជួរ ហើយនៅលើថ្នាក់ផ្នែកខាងក្រោមបានបង្ហាញពីសត្វទេវកថា ដែលរស់នៅក្នុងទឹក ។

នៅពីមុខកំពែង និង គោបុរៈខាងកើត ដែលកសាងនៅចុងសតវត្សទី ១០ គេបានកសាងទីលានជល់ដំរីមួយ ដែលលាតសន្ធឹងប្រវែង ៣០០ម នៅដើមសតវត្សទី ១៣ ។ គេអាចទៅដល់

ព្រះបាទជ័យវរ្ម័នទី ៧ គឺបំផ្លាញ ព្រោះប្រឆាំងជាមួយសាសនាព្រះពុទ្ធ ។ នៅលើហោជាងលើបង្គោលសីម៉ា ហើយនិងនៅលើសសរទាំងឡាយ នៃប្រាសាទរបស់ព្រះបាទជ័យវរ្ម័នទី ៧ ត្រូវបានគេវាយយកចេញនូវព្រះពុទ្ធរូបទាំងឡាយនោះ ។ រូបលោកេស្វរៈទាំងឡាយ មិនត្រូវបានគេរុះរើវាយបំផ្លាញទេ ប៉ុន្តែគេបានឈូសយកចេញនូវព្រះពុទ្ធរូបតូចៗ ដែលឆ្លាក់នៅលើផ្ទួងសក់ ឯកេតនកណ្ឌដែលកាន់នៅដៃគឺនៅដដែល ។

នៅក្នុងអំឡុងសតវត្សទី ១៣ ព្រះពុទ្ធសាសនា Singhalai បានចាប់ផ្តើមសំដែងចេញអោយឃើញនៅក្នុងប្រទេសកម្ពុជា ។ ការស្នាក់នៅមួយដំណើររបស់បុត្រាជ័យវរ្ម័នទី ៧ បានធ្វើឡើងនៅ Ceylan បានកត់សំគាល់នៅភាគខាងដើម នៃការគំរង់ទិសសាសនាថ្មីនេះ ។ រហូតមកដល់ពេលនេះប្រទេសកម្ពុជាបានត្រូវស្គាល់ ប្រហែលមិនរាប់បញ្ចូលជាមួយ និងសាសនាព្រះពុទ្ធមហាយាន ( Mahà yàna ) ( ភាសាសំស្រ្កិត ) ។ ចាប់ផ្តើមពីសតវត្សទី ១៤ មកគេបានឃើញនូវការអភិវឌ្ឍន៍ទំរង់សាសនាព្រះពុទ្ធមួយថ្មីទៀត គឺថេរវាទ ( Theravàda ) ដែលអត្ថបទទាំងនេះមានទាក់ទងនឹងភាសាបាលី ។ សាសនាព្រះពុទ្ធថេរវាទ ត្រូវបានគេអនុម័តយកមកប្រតិបត្តិនៅក្នុងប្រទេសកម្ពុជា ថៃ និង ឡាវ វាបានបន្សល់ទុកនូវសាសនានៅក្នុងប្រទេសបីនេះ ។

នៅឆ្នាំ ១២៩៥ ព្រះបាទជ័យវរ្ម័នទី ៨ ស្ថិតនៅក្នុងព្រះជន្មមួយ ដែលនៅរឹងប៉ឹងនៅឡើយ ។ សិលាចារឹកមួយបានចុះនិទ្ទេសថា " គឺមានទទួលការជ្រោមជ្រែងដោយស្តេចចំណាស់មួយអង្គ ដែលត្រូវទទួលរងនូវពិការភាព ហើយបានបោះបង់ចោលនូវសេចក្តីលំបាកទាំងឡាយ " ។ ប្រទេសត្រូវបានបែងចែកគ្នា " មនុស្សត្រូវលាក់ចំពួននៅក្លោះពណ៌សទាំងឡាយរបស់ស្តេច " ។ ព្រះបាទជ័យវរ្ម័នទី ៨ បានដាក់រាជ្យសម្បត្តិដោយការសំដែងនូវភាពពេញចិត្ត ចំពោះមុខកូនប្រសារប្រុស ស្រិន្ទ្រវរ្ម័ន ( Çrindra varman ) ។ ជនជាតិចិនម្នាក់ឈ្មោះ ជីវតាក្វាន់ ដែលបានមកប្រទេសកម្ពុជាក្នុងឆ្នាំ ១២៩៦ បានរៀបរាប់អំពីការដាក់រាជ្យសម្បត្តិនេះ ដែលយើងបានដឹងច្បាស់លាស់ ហាក់ដូចជាការធ្វើបដិវត្តន៍នៅក្នុងព្រះបរមរាជវាំង ។ សេចក្តីដំណាលរបស់គាត់ធ្វើអោយតឹងចិត្តណាស់ ក្នុងការដោះស្រាយ ។

" ស្តេចថ្មី គឺជាកូនប្រសាររបស់ស្តេចមុន ទ្រង់បានទទួលហាត់ក្បាច់គុនដាវនៅទីវាល ដែលមានរបងព័ទ្ធជុំវិញ ។ បិតាក្មេកបានសព្វព្រះទ័យ នឹងបុត្រីរបស់ព្រះអង្គណាស់ ទើបបុត្រីស្តេចបានលបលួចយកដាវមាសដោយដៃព្រះអង្គផ្ទាល់ ហើយបានយកទៅបំពាក់អោយព្រះស្វាមីព្រះនាង ។ ម្យ៉ាងទៀតបុត្រីបានរួមគំនិតទៅបកស្បែកយកទ្រព្យសម្បត្តិ អ្នកស្នងរាជបន្ត ដើម្បីលើកដំកើងពួកទ័ពព្រៃ ។ ស្តេចថ្មីបានដឹងទាន់ក៏បានគាត់ម្រាមជើងដោយខ្លួនទ្រង់ផ្ទាល់ យកទៅទុកក្នុងគុកងងឹត ។ ស្តេចថ្មីនេះ មានដងខ្លួនពាក់អាវក្រោះដែក គឺជាមោទនភាពនូវអ្វីៗ ដែលគេធ្វើឡើងដោយប្រុងប្រយ័ត្នជានិច្ច ដែលខ្លាចក្រែងសេចក្តីអង់អាចរត់ចេញពីខ្លួន " ។

ព្រះបាទស្រិន្ទ្រវរ្ម័ន បានរៀបចំទឹកដី ទំនងជាមានឯកភាពរៀបចំទឹកដី " នៅក្រោមម្លប់ក្លោះពណ៌សតែមួយ " ។

២- ការធ្វើដំណើររបស់ជីវតាក្វាន់ ( ១២៩៦ ) :

- នៅឆ្នាំក្រោយ មានការដាក់រាជ្យសម្បត្តិរបស់ព្រះបាទជ័យវរ្ម័នទី ៨ នោះ មានអគ្គរាជទូតនម្នាក់បានមកប្រទេសកម្ពុជា ជាបន្តមកទៀតអគ្គរាជទូតជីវតាក្វាន់ ក៏បានត្រលប់ទៅស្រុកចិនវិញរួចក៏បានរសេរនិក្ខេបទមួយ អំពីប្រពៃណីនៅប្រទេសកម្ពុជា ។ នៅក្នុងអត្ថបទនេះ គាត់បានសរសេរពិពណ៌នាព្រឹត្តិការណ៍ផ្សេងៗ ដែលគាត់បានឃើញ ឬ បានឮដោយខ្លួនគាត់នៅធានីអង្គរ នៅចុងសតវត្សទី ១៣ នោះ

ធានីស្ថិតនៅក្នុងវិសាលភាពមួយដ៏ធំល្វឹងល្វើយនៅឡើយ ហើយក៏មិនទាន់ត្រូវមានការលុកលុយពីពួកសៀមនៅឡើយដែរ ។ អ្នកមុខអ្នកការនៃរបបរាជានិយមនេះ បានសំដែងនូវក្តីរីករាយ ដើម្បីទទួលអ្នកដំណើរជាតិចិននេះ ។

លោកជីវតាក្វាន់ បានកត់សំគាល់ជានិច្ច នូវអ្វីដែលឃើញពីជីវភាពប្រជាជនកម្ពុជា ដែលឆ្លងកាត់នូវសំណើរបស់ជនរួមជាតិគាត់ ដែលរៀបចំរស់នៅធានីអង្គរ ។ ជាការពិតណាស់ ជនជាតិចិនបានមករស់នៅប្រទេសកម្ពុជា តាំងពីយូរយារមកហើយ ។ ពួកគេរស់នៅទីនេះ បានរាយការណ៍ប្រាប់ដូចដែលសំដីរបស់លោកជីវតាក្វាន់ ៖

" ស្រូវមានភាពងាយស្រួលក្នុងការផលិត ប្រពន្ធស្រួលរក ផ្ទះងាយស្រួលរៀបចំ អចលនវត្ថុមានប្រភពងាយស្រួលរកអោយបានដោយខ្លួនឯង ពាណិជ្ជកម្មមានភាពងាយស្រួល ក្នុងការចាត់ចែងរកស៊ី ។ ជារឿយៗគេតែងតែនាំរបស់របរចូលមកក្នុងប្រទេសនេះដែរ " ។

ដើម្បីអោយច្បាស់ ក្នុងខណៈនោះលោកជីវតាក្វាន់ បានទៅពិនិត្យពីការងារជាច្រើននៅក្នុងផ្ទះនៃគ្រួសារខ្មែរមួយ ដើម្បីដាក់បញ្ចូលទៅក្នុងរបាយការណ៍របស់គាត់ ។ ការរៀបរាប់ពីធានីអង្គរ ហើយនិងជីវភាពប្រជាជនប្រចាំថ្ងៃ ដែលយើងមើលឃើញនាពេលនោះ គឺមានភាពស្រដៀងគ្នា ។ ពណ៌មានដែលគាត់ទទួលដឹងពីជីវភាពប្រជាជនក្នុងសម័យនោះ វាដូចគ្នាទៅនឹងរឿងរ៉ាវដែលមាននៅលើក្បាច់ផុស ដែលគេឆ្លាក់ភ្ជាប់នឹងជញ្ជាំងរបស់ប្រាសាទបាយ័ន ឬ ដូចគ្នានឹងអ្វីដែលគេអធិប្បាយនៅក្នុងសិលាចារឹកខ្លះៗ ។

៣- <u>ទិដ្ឋភាពប្រាសាទនៃរាជធានី</u> :

ការអធិប្បាយពីធានីអង្គរ ដោយលោកជីវតាក្វាន់អាចអោយយើងបានស្គាល់ពីប្រាសាទអង្គរវត្តជញ្ជាំងកំពែងក្លោងទ្វារអង្គរធំ ប្រាសាទបាយ័ន ហើយនិងប្រាសាទបាពួន ប៉ុន្តែក្នុងពេលឥឡូវនេះ យើងមិនអាចមើលអោយបានច្រើន នៅគ្រប់សំណង់បាក់បែកទាំងអស់បានទេ អ្នកដំណើរជីវតាក្វាន់មាននិស្ស័យបានចូលទៅក្នុងធានី កាលពីពេលដែលមានមនុស្សរស់នៅ ។ រួមដំណើរជាមួយនឹងគាត់ ដោយបានមកដល់ធានីអង្គរ យើងក៏បានបន្តដំណើរតាមផ្លូវចូលមួយ ដែលអមសងខាងផ្លូវដោយយក្សពីរជួរកំពុងតែទ្រសត្វនាគពីរ ហើយយើងក៏បានឆ្លងកាត់ក្លោងទ្វារ ដែលមានបន្ទើតទៅដោយមុខមនុស្ស ។ សំរាប់យើងបច្ចុប្បន្ននេះ មាត់ច្រកដែលបើកចំហរនេះ មានតែផ្លូវដែលដុះព័ទ្ធទៅដោយព្រៃ ។

លោកជីវតាក្វាន់បានឃើញ " ទ្វារធំបិទនៅពេលយប់ ហើយបើកនៅពេលព្រឹក " ហើយ "ឆ្មាំទាំងឡាយឈរយាមទ្វារចូល សូម្បីតែឆ្កែមួយក៏ពុំអាចអនុញ្ញាតិអោយលោតផ្លោះចូលបានដែរ " ។ ហើយគេក៏បានហាមមិនអោយចូលក្នុងរាជធានីផងដែរ " ឧក្រិដ្ឋជនដែលគេបានកាត់ម្រាមជើងចោល " ។

ការធ្វើដំណើរទៅមុខ ដោយឆ្លងកាត់ផ្លូវទាំងឡាយរបស់ធានី អ្នកដំណើរជាតិចិនរូបនេះ មានការស្ញើចសរសើរអំពីដំណាក់សម្តេច ហើយនិងការិយាល័យធំៗ ដែលសុទ្ធតែសង់បែរមុខទៅរកទិសខាងកើត ហើយខ្លះដំបូលមានប្រក់ក្បឿង និង សំណង់ប្រជាជនទូទៅខ្លះទៀត មានប្រក់ស្បូវធម្មតា ។ ក្បាច់ផុសដែលគេឆ្លាក់ភ្ជាប់នឹងជញ្ជាំងរបស់ប្រាសាទបាយ័ន បានបង្ហាញពីលក្ខណៈសំណង់ ដូចគ្នានេះដែរ គឺដំបូលប្រក់ក្បឿងរាងស្រទបចេករាងមូល ។ ចំណែកនៅជាន់ក្រោមវិញ អ្នកបំរើកំពុងតែធ្វើការយ៉ាងប្រញាប់ប្រញាប់ ឯចៅហ្វាយនាយគេកំពុងតែនៅមើលថែរក្សា ដោយក្តីរីករាយនៅជាន់ខាងលើ ។ នៅឈមពីមុខផ្ទះរបស់អភិជនទាំងឡាយ មានផ្ទះតូចៗធម្មតា ដែលជួយលំអភូមិគ្រឹះ មិនសូវអោយឃើញឆើតឆាយពេក ( វម្យទម ) ។

លោកជីវតាក្វាន់ បានឃើញប្រាសាទធំៗជាច្រើន ។ វាទំនងដូចប្រាសាទបាយ័ន ។

" ការកត់សំគាល់នៅចំកណ្ដាលរាជាណាចក្រ មានប្រាសាទមាសមួយ ដែលមាននៅអមសងខាង ដោយតួប្រាសាទអំពីថ្មច្រើនជាង ២០ ហើយនិងមានវិហារង្ហានធ្វើអំពីថ្មកក់រាប់រយទៀត ។ នៅជ្រុងខាងកើត មានស្ពានមាសមួយ និង មានគោមាស ២ទៀត ដាក់នៅតាមជ្រុងនៃស្ពាន " ។

ដោយបញ្ចេញអោយឃើញនូវទិសខាងកើត គេអាចចូលទៅកាន់ប្រាសាទបាយ័នបានដោយទីលានធំមួយ សង់ពីលើសសរជាច្រើន ដោយឆ្លងកាត់តួទឹក ឯគោទាំងឡាយនោះបានត្រូវដាក់នៅតាមជ្រុងនៃមាត់ច្រក ។

" នៅទិសខាងជើងប្រហែល ១លី មានប្រាសាទស្ពាន់មួយ ដែលមានកំពស់ខ្ពស់ជាងប្រាសាទមាស ហើយប្រសិនបើគេមើលដោយពិតៗវិញ វាធ្វើអោយរំភើបណាស់ " ។

ប្រាសាទស្ពាន់នេះ ប្រាសាទបាពួន ដែលលោកជីវតាក្វាន់ ប្រហែលជាបានឃើញពីចំងាយនូវតួប្រាសាទកណ្ដាល ដែលយើងអាចស្រមៃឃើញយ៉ាងដូច្នេះ ។

៤- __ព្រះរាជវាំង__ :

ចុងបញ្ចប់នៃបេសកកម្មរបស់ជនជាតិចិនរូបនេះ ក៏បានឈប់នៅព្រះរាជវាំង ដែលមានប្រាសាទភិមានអាកាស ។ នៅពីមុខរាជវាំងមានទីលានរបស់អង្គរធំមួយ ដែលមានគេមព័ទ្ធជុំវិញ ( ក្រុប ) ដែលវាបន្លាយខ្លួនរបស់វា ជាឈ្មោះលានជល់ដំរី ហើយវាបានទ្រសំណង់ស្រាលៗជាច្រើននៅពីលើ ។ សំណង់ទាំងនេះ បានត្រូវបាត់បង់អស់រលីងហើយ ។ ហើយលោកជីវតាក្វាន់បានឃើញសំណង់ទាំងនេះ គឺប្រហែលជានៅទីនេះហើយ ដែលគេសង់បន្ទប់សំរាប់មន្ត្រី ២ ក្នុងការចូលរួមទស្សនាអំពីក្បួនសត្វដំរី ។ បន្ទប់របស់មន្ត្រីទាំងនោះ គឺជាសំណង់យ៉ាងល្អឯករួមជាមួយ នឹងសសរទាំងឡាយរាង ៤ជ្រុង ដោយមានភ្ជាប់ដោយកញ្ចក់ និង ស៊ុមបង្អួចទាំងឡាយធ្វើពីមាស " ។

លោកជីវតាក្វាន់ ពុំបានចូលទៅក្នុងព្រះរាជវាំងទេ គាត់បានឆ្លើយទទួលសារភាពដោយខ្លួនគាត់ថា ៖

" ខ្ញុំបានឮគេនិយាយថា នៅក្នុងវាំងមានកន្លែងដ៏អស្ចារ្យជាច្រើន ឯការយាមកាមគឺតែងមានការប្រុងប្រយ័ត្នណាស់ ហើយវាមានការពិបាកក្នុងការចូលទៅកាន់ខាងក្នុងវាំងទៀតផង ។

គឺជាអំណោយមួយ ក្រោយពីការរៀបរាប់ទាំងនេះ ដែលគេបានធ្វើចំពោះគាត់ ដែលគេអាចមានវិនិច្ឆ័យនៃតួសំណង់ល្អៗ ។ មានរានហាលដ៏វែង ច្រកទ្វារខាងក្នុងទាំងឡាយដែលបិទ " ជាការហ៊ានពេក និង ខុសសីលធម៌ ហើយពុំមានឋានៈស្មើគ្នា " ។ ថ្វីត្បិតតែពុំអាចចូលទៅក្នុងវាំង ហើយនិង ការស៊ើបអង្កេតថា តើគេរស់នៅយ៉ាងរបៀបម៉េចទៅ គាត់បានឮសួរគេនិយាយគ្នានៅក្នុងចំណោមមនុស្សឋានៈតូចតាចដែលរស់នៅក្នុងដំណាក់ស្ដេចដែរ ។ គឺវាដូច្នេះ ដែលគាត់បានរៀបរាប់នោះថា ជារាងរាល់ល្ងាចព្រះមហាក្សត្របានឡើងទៅលើ " ប្រាសាទមាស " ភិមានអាកាសនៃព្រះរាជវាំង ។

គ្រប់ប្រជាជនដែលរស់នៅក្នុងស្រុកទាំងអស់បានអួតថា នៅក្នុងតួប្រាសាទមានព្រលឹងនៃសត្វនាគក្បាល ៩ ដែលជាម្ចាស់ដីនៃទូទាំងរាជាណាចក្រស្ថិតនៅទីនោះ ។ នៅរៀងរាល់រាត្រី ព្រលឹងសត្វនាគនេះ នឹងមកបង្ហាញខ្លួនក្រោមរូបភាពជាមនុស្សស្រីដ៏ស្អាត ។ គឺជាមួយនឹងស្រីនេះហើយ ដែលព្រះមហាក្សត្របានផ្ទុំជាមួយជាដំបូងរួច ក៏រួមរ័ក្សជាមួយគ្នា ។ ព្រះមហាក្សត្រនឹងចាកចេញមកវិញនៅយាមទី ២ ហើយក៏មកផ្ទុំជាមួយ និងអគ្គមហេសី ហើយនិងសាហាយឯទៀតបាន ។

ប្រសិនជាយប់ណាមួយព្រលឹងរបស់សត្វនាគនេះ មិនបានបង្ហាញខ្លួនទេនោះ គឺជាសញ្ញាប្រាប់ថា ការចូលទីវង្គត់របស់ស្តេច នឹងមកដល់ហើយ ។ ប្រសិនបើព្រះមហាក្សត្រខកខានទៅកាន់ទីនេះ ដោយ យប់ណាមួយនោះ ភាពចង្រៃអុបទ្រុប នឹងចូលមកយាយីភ្លាម " ។

អ្នកកាល្បប្រវត្តិជាតិចិនរូបនេះ មានចិត្តរីករាយយ៉ាងខ្លាំង ដើម្បីនឹងសរសេរពីរាជសវនាការនៅ ទីនេះ ដែលគាត់អាចចូលប្រជុំជាមួយ នឹងឯកអគ្គរាជទូត ដែលមកពីប្រទេសរបស់គាត់ ៖

" ជារៀងរាល់ថ្ងៃ ស្តេចបានបើកសវនាការ ២ដង ដើម្បីជាភារកិច្ចរាជរដ្ឋាភិបាល មន្ត្រីរាជការ ដែលចូលរួមពិធីនោះ ឬ ប្រជាជនដែលចូលរួមមើលការកាត់ក្តីរបស់ស្តេច ត្រូវអង្គុយផ្ទាល់លើដី ដើម្បី រង់ចាំ ។ នៅវេលាដល់ គាត់បើកសវនាការ គេឮសូរភ្លេងនៅឆ្ងាយ ឯនៅរោងខាងក្រៅគេបានផ្លុំស័ង្ខ ប្រៀបបីដូចជា ទទួលស្វាគមន៍នៃការយាងមកដល់របស់ស្តេច ។ មួយសន្ទុះក្រោយមក គេឃើញស្រីស្នំ ២នាក់ បានបើកវាំងននឡើងដោយដៃ ហើយក៏លេចស្តេចចេញមកតាមបង្អួចមាស ដោយមានកាន់ដាវ នៅដៃផង មន្ត្រី និង ប្រជាជនលើកដៃសំពះ ហើយអោនក្បាលរហូតដល់ថ្ងាសដល់ដី នៅពេលណា សំលេងស័ង្ខឈប់ ទើបអាចងើបក្បាលវិញបាន ។ បន្ទាប់មកពួកគេក៏ខិតចូលទៅអង្គុយជិតស្តេចទៅតាម ទំនើងចិត្តរបស់ស្តេច ។ ពេលណាការងារត្រូវបានបញ្ចប់ ស្តេចក៏យាងវិលត្រលប់ចូលទៅក្នុងវិញ ស្រីស្នំទាំងពីរក៏ទំលាក់វាំងននចុះវិញដែរ ឯប្រជាជនក៏ងើបដើរចេញរៀងៗខ្លួនទៅ " ។

ដូច្នេះហើយ នៅលើក្បាច់ផុសដែលគេឆ្លាក់ភ្ជាប់នឹងជញ្ជាំងរោងទង គេឃើញស្តេចនៅក្នុង មណ្ឌបដ៏ស្រស់ស្អាត ដែលលើកតំកែលដោយក្រុមបរិពាររបស់ព្រះអង្គ កំពុងតែទទួលយកនូវជង្វាយ ឬ ក៏ការសុំទោសក្រោមប្រធានបទនៃការក្រាបថ្វាយបង្គំ ។ លោកជីវតាក្វាន់ បានផ្ចិតយកនូវភាពជាក់ស្តែង តាមរយៈពិធីបុណ្យនេះ ។ គាត់បានសន្និដ្ឋានប្រជាជនកម្ពុជាទាំងឡាយ " មិនបានបោះបង់ចោលពីចំណោះ ដឹង តើអ្វីទៅជាព្រះមហាក្សត្រ " ។

អ្នកដំណើរជាតិចិន បានសរសេរពីការស្លៀកពាក់យ៉ាងស្រស់ស្អាតរបស់ព្រះមហាក្សត្រអង្គនេះ៖

" មានតែព្រះមហាក្សត្រតែមួយអង្គគត់ ដែលស្លៀកសំពត់ក្រណាត់ ដែលមានក្បាច់លើកនៅលើ សាច់ ហើយពង់តែរួត ។ ព្រះអង្គពាក់មកុដមាស ។ ពេលណាព្រះអង្គមិនពាក់មកុដទេ ព្រះអង្គបានមូរសក់ ជាមួនៅជុំវិញផ្នួងកំរងផ្កា ដែលសាយភាយដោយក្លិនក្រអូបបែបជាក្លិនម្លិះ ។ នៅជុំវិញកព្រះអង្គមានពាក់ ដោយគុជ ៣គ្រាប់ធំៗ ។ ម្រាមដៃ មេដៃ កដៃ របស់ព្រះអង្គមានពាក់ដោយខ្សែដៃ និង ចិញ្ចៀនមាស ដោយមានដាំត្បូងពេជ្រភ្នែកឆ្មាជាច្រើនគ្រាប់ ។ ព្រះអង្គយាងដោយបាតជើងទទេ ហើយបាតជើង និង បាតដៃមានលាបថ្នាំក្រហម ដោយគ្រឿងផ្សំឱសថពណ៌ក្រហម ។ ពេលណាព្រះអង្គយាងចាកចេញពី ព្រះរាជវាំង ព្រះអង្គមានកាន់ដាវមាសនៅនឹងដៃផង " ។

៧- សង្គម :

រចនាសម្ព័ន្ធសង្គមមិនសូវកែខែរូបសណ្ឋានអ្វីទេ នៅចន្លោះសតវត្សទី ១១ និងទី ១៣ ទេ ក៏ប៉ុន្តែនៅក្នុងកំណត់ហេតុរបស់ជីវតាក្វាន់ ដែលយើងបានរកឃើញនូវគំនូរនៃសង្គម ដែលគេពុំបានជួប ប្រទះទាល់តែសោះ ទៅក្នុងអត្ថបទសិលាចារឹក ។ នៅក្នុងកំណត់ហេតុរបស់គាត់ អ្នកកាល្បប្រវត្តិជាតិចិន បានផ្តល់អោយនូវតួនាទីយ៉ាងសំខាន់ ចំពោះព្រះពុទ្ធសាសនា ដោយព្រាហ្មណ៍សាសនា ដែលគាត់អោយ ឈ្មោះថា Panki តាមជំហររបស់ជនជាតិចិនរូបនេះ គាត់មិនបានធ្វើរបាយការណ៍អំពីមនុស្សឋានៈទាបទេ វាមិនទំនងទេ ដែលសម័យនេះ វណ្ណៈដែលជាសង្ឃសមណៈ បានបាត់បង់នូវតួនាទីសំខាន់របស់លោក ទាំងនេះ ដោយមូលហេតុនៃការអភិវឌ្ឍន៍ព្រះពុទ្ធសាសនាថេរវាទ ។

លោកជីវតាក្វាន់បានទទួលសារភាព អំពីការមិនស្គាល់អ្វីពិតប្រាកដរបស់លោក ចំពោះអទិទេព ដែលត្រូវគេគោរពបូជាដោយអ្នកកាន់ព្រហ្មញ្ញសាសនា ហើយនិងគម្ពីររបស់ពួកគេ ។ គាត់បានធ្វើការកត់សំគាល់ថា Panki ទាំងឡាយបានស្លៀកពាក់ដូចប្រជាជនខ្មែរដទៃទៀតដែរ ប៉ុន្តែពួកគេបានកំណត់ខ្សែព្រះសត្វចរបស់ព្រហ្មញ្ញសាសនា ដែលពួកគេចងភ្ជាប់ទៅនឹងក ហើយដែលពួកគេចាកចេញពីជីវិតធម្មតារបស់ពួកគេ ។ ពួកគេបានពិនិត្យពិច្ច័យពីអំណាចរបស់គេនៅក្នុងជីវិតនៃសង្គម ព្រោះគេបាននិយាយ " Panki ទាំងឡាយដែលដើរមកដល់ទទួលយកនូវមុខដំណែងខ្ពស់ " ។ ការបង្ហាញនេះ បានឆ្លងកាត់យ៉ាងត្រឹមត្រូវទៅគ្រប់នៃការរំលឹក ដែលមាននៅលើសិលាចារឹក ស្តីពីអាជីពរបស់អ្នកកាន់ព្រហ្មញ្ញសាសនាទាំងឡាយ ។

អ្នកកាល្យប្រវត្តិជាតិចិននេះ ពុំបានភ្លេចនូវសញ្ញាសំខាន់នៃមុខងារទាំងឡាយ ហើយនិងលំដាប់ថ្នាក់របស់ពួកគេទាំងនោះ ដែលមាននៅក្នុងរចនាសម្ព័ន្ធសង្គមរបស់ពួកគេឡើយ ៖

" នៅក្នុងប្រទេសនេះមានមន្ត្រី ឧត្តមសេនីយ៍ និង អ្នកតារាសាស្ត្រជាច្រើននាក់ ។ល។ ហើយនៅពីក្រោមពួកអ្នកទាំងនេះ មាននយោជិកគ្រប់បែបយ៉ាងទាំងអស់ ។ មួយផ្នែកធំនៅពេលវេលា គេត្រូវជ្រើសរើសស្តេចទាំងឡាយ ដើម្បីជាអ្នកកាន់កាប់ការងារ បើមិនបានទេ អ្នកដែលត្រូវគេជ្រើសរើសទាំងនោះត្រូវតែអោយកូនស្រីរបស់គេ អោយមកបំរើដូចជាស្រីស្នំស្តេច ។ គ្រឿងឥស្សរិយៈយស្តទាំងឡាយ និង អ្នកនៅក្រោមគេជាបន្តបន្ទាប់មកទៀត ក៏ស្ថិតនៅតាមលំដាប់ថ្នាក់ដែរ " ។

នៅពីក្រោមនៃអ្នកដែលជាវណ្ណៈកណ្តាល លោកជីវតាក្វាន់បានធ្វើនិទ្ទេសថា ជាប្រជារាស្ត្រ "មានមាឌធំ ហើយខ្មៅព្រិល ។ ហើយពួកគេរស់នៅក្នុងតំបន់ឆ្ងាយៗពីភូមិ នៅលើកោះនៃមហាសមុទ្រ ឬនៅតាមថ្នល់ទាំងឡាយ ដែលគេទៅមកញឹកញាប់ " ។ អ្នកដែលអោនលំទោនខ្លាំង គឺបាវបំរើ ៖

" ដូចអ្នកបំរើដែលជំពាក់លុយគេ គេបានទិញពួកមនុស្សព្រៃ និង អ្នកដែលមានច្រើន គឺទាសាទាសីមានដល់ជាង ១០០នាក់ ។ ឯអ្នកដែលមានតិច ក៏មានត្រឹមតែ ១០ ឬ ២០នាក់ លើកលែងតែអ្នកក្របំផុត ទើបគ្មានសោះ ។ ចំណែកពួកមនុស្សព្រៃទាំងនោះ គឺជាអ្នករស់នៅក្នុងតំបន់ព្រៃភ្នំ ។ ដែលជាពូជមួយដែលខុសប្លែកពីអ្នកស្រុក ។ ពួកទាសាទាសីទាំងនេះ គេអោយអង្គុយ និង ដេកនៅតែក្រោមផ្ទះលុះត្រាតែមានការប្រើចាំបាច់ ទើបគេអនុញ្ញាតិអោយឡើងលើផ្ទះ ហើយត្រូវលុតជង្គង់លើកដៃសំពះគេជាមុនសិន ទើបអាចដើរចូលទៅក្នុងផ្ទះបាន ។ ប្រសិនបើមានកំហុសត្រូវពួកគេវាយដំធ្ងន់ធ្ងរ ហើយពួកនេះសុខចិត្តអោយគេវាយតាមចិត្ត មិនហ៊ានរើបំរះឡើយ ។

៦- <u>សកម្មភាពរបស់ប្រជាជន</u> :

យើងខ្ញុំបានដឹងយ៉ាងតិចតួចណាស់ អំពីជីវភាពរបស់ប្រជាជននៅធានីអង្គរ នៅមុនចុងបញ្ចប់សតវត្សទី ១២ ព្រោះថា ស្ទើរតែគ្រប់ពត៌មានដែលគេទទួលបានទាំងអស់ គឺមាននៅលើសិលាចារឹក ដែលគេបានភ្លេចពីចំណុចមួយ គឺប្រជាជន ។ តែផ្ទុយមកវិញ នៅចុងបញ្ចប់សតវត្សទី ១២ ហើយនិងចុងបញ្ចប់សតវត្សទី ១៣ ក្បាច់ក្រឡោតទាបទាំងឡាយ ហើយនិងកំណត់ហេតុរបស់លោកជីវតាក្វាន់បានផ្តល់អោយយើងនូវឯកសារ នៃផលប្រយោជន៍មួយយ៉ាងធំ នៅគ្រប់នៃបច្ច័យទៅដល់សកម្មភាពប្រចាំថ្ងៃរបស់ប្រជាជនខ្មែរ ដែលមានលក្ខណៈសម្បត្តិដ៏ទំនើប ។ បើពិនិត្យពិច្ច័យទៅវាពុំមានការខុសប្លែកគ្នាទេ រវាងកំណត់ហេតុរបស់លោកជីវតាក្វាន់ ដែលមានការប្រហែលយ៉ាងខ្លាំងទៅនឹងក្បាច់ក្រឡោតទាបនៅប្រាសាទបាយ័ន ។

នៅតាមផ្លូវ បានធ្វើអោយអ្នកដំណើរជាតិចិននេះ បានឃើញរទេះ ដែលមានដំបូលជាបន្ទោះ ឬស្សីបះទ្វាត់ខ្វែងគ្នា មានមនុស្សជាច្រើនជិះសេះ ឬ ក៏អង្គុយលើគ្រែស្នែង ដែលសែងដោយកម្មករ ២នាក់ គឺគេអាចឃើញសកម្មភាពដូចគ្នានេះ នៅលើក្បាច់ក្រឡោតភ្លាមដែរ ។ គាត់បានដើរកាត់តាមផ្សារ គឺបានជួបនឹងមនុស្សជាច្រើនកំពុងតែរវែកឥវ៉ាន់ ។ គេអាចឈប់នៅជិតកញ្ច្រែងអ្នកមានមុខជំនួញតូចតាច មានផ្លែឈើ ឬ ត្រីសាច់ជាដើម ។ ប្រហែលជាគាត់រវល់តែឈរមើលការជល់មាន់ ឬ ជល់ជ្រូកដូច ដែលយើងបានឃើញមាននៅលើក្បាច់ក្រឡោតទាបទាំងឡាយ នៅប្រាសាទបាយ័នដែរ ។

- ពាណិជ្ជកម្ម គឺជាសកម្មភាពដ៏សំខាន់នៃទីក្រុង ។ លោកជីវតាក្វាន់បាននិយាយថាការងារនេះ គឺមានតែស្រីៗទេ ដែលជាអ្នកលក់ដូរ ។ ការរៀបចំដាក់លក់របស់សំរាប់លក់ គឺមានលក្ខណៈជាធម្មតា ៖

" ពួកឈ្មួញតូចតាចទាំងនេះ គ្មានគ្រែ ឬ ផ្ទះសំរាប់លក់ឥវ៉ាន់ទេ គេច្រើនតែក្រាលវត្ថុម្យ៉ាង ហាក់បីដូចជាកន្ទេលផ្ទាល់ និង ដីតំរៀបគ្នា ។ ម្នាក់មួយកន្លែង ។ ខ្ញុំឮគេនិយាយថាមានបង់ពន្ធដីជាលុយ អោយពួកមន្ត្រីទៀតផង ។ អ្នកជំនួញតូចតាច គឺគេជួញស្រូវអង្ករ និង របស់មកពីស្រុកចិន ។ បន្ទាប់មក មានលក់ដូរក្រណាត់សំពត់ផ្សេងៗ ហើយមុខជំនួញធំ គឺគេជួញមាស ឬ ប្រាក់ " ។

អ្នកព្រៃទាំងឡាយបាននាំយកផលិតផល ដែលពួកគេបានដាំដូចជា ៖ ខ្ទឹមបារាំង គ្រប់វែង ឃ្លោក ផ្លែឈើ បិតស្រា ។ ក្នុងអំឡុងនៃការដើរកំសាន្តនៅក្នុងទីក្រុង អ្នកដំណើរជាតិចិនបានឃើញ អំពីការងារតម្បាញសំពត់ព្រៃ ហើយនិងការប្រកួតប្រជែងជាមួយក្រណាត់ដែលនាំចូលមកពីបរទេស ។

" មានក្រណាត់ល្អៗជាច្រើន ។ ស្លេទស្លៀកសំពត់ដែលមានតំលៃ ២ ឬ ៣ តំឡឹងមាសនេះ គឺជាសំលៀកបំពាក់ដែលល្អជាង ហើយមានពណ៌ស្រស់ស្អាតជាច់គេទៀត ។ នៅក្នុងប្រទេសគេបាន ត្បាញសំពត់ព្រៃពីសរសៃផ្សេងៗ ដែលនាំយកមកពីប្រទេសសៀម និង ប្រទេសចាម ហើយគេបានគិតថា ទំនិញទាំងនេះក៏ប្រហែលជានាំចូលមកពីប្រទេសនៃសមុទ្រខាងលិច ដើម្បីបំរើអោយការផលិតសំលៀក បំពាក់អោយបានល្អដែរ " ។

លោកជីវតាក្វាន់ បានចូលចិត្តនូវទំនិញពិសេស ដែលប្រជាជនរួមជាតិរបស់លោកចូលចិត្តទិញ នៅក្នុងប្រទេសកម្ពុជាដូចជា ៖ ភ្លុកដំរី ស្លាបចាចាត កុយរមាស ក្រមួនឃ្មុំ ក្រវាញ ម្រេច ជ័រទុង ។ល។

៨- ជីវភាពផ្ទាល់ខ្លួន :

ទាល់តែមានជនបរទេសទាំងឡាយ បានយល់ជ្រួតជ្រាបពីការរស់នៅយ៉ាងមានរបៀប ដោយការ ឈ្លាតឆ្ងាយខុសគ្នាពីព្រឹត្តិការណ៍ ពីជីវភាពផ្ទាល់ខ្លួនរបស់ប្រជាជនកម្ពុជា ដូចលោកជីវតាក្វាន់បានធ្វើ របាយការណ៍យ៉ាងត្រឹមត្រូវ អំពីប្រពៃណីដែលគាត់បានសង្កេតក្នុងអំឡុងពេល ដែលគាត់បានស្នាក់នៅ ក្នុងផ្ទះនៃគ្រួសារខ្មែរ ឬ គាត់បានស្គាល់ពីការរៀបរាប់ដោយជនរួមជាតិរបស់គាត់ ដែលបានទទួលពត៌មាន ច្រើន ឬ ក៏តិច ។

ការយល់ដឹងនៅក្នុងផ្ទះទាំងឡាយ មានរបស់ប្រើប្រាស់ ដែលអាចឃើញសំភារៈនៅផ្ទះមាន ពាងទឹក ២ ឬ ៣ ដាក់ផ្ទាល់ដី កញ្ជ្រោង ២ ឬ ៣ ព្យួរនៅលើថ្នោងរបស់ផ្ទះ ឆ្នាំងហើយនិងចង្ក្រាន គឺធ្វើ ពីដីឥដ្ឋដុតពាងធំ ។ សំភារៈឧបភោគបរិភោគទាំងឡាយ ដែលគេបានឃើញនៅក្នុងផ្ទះរបស់អ្នកស្រុកនោះ បើតាមចំណាំ គេអាចឃើញមាននៅលើចំលាក់ នៃចំបាំងយ៉ាងធំរបស់ទាហានជើងទឹក នៃថែវខាងត្បូង ក្នុងប្រាសាទបាយ័ន ប៉ុន្តែគេអាចឃើញទៀតដែរនៅតាមផ្សារសព្វថ្ងៃនេះ នៅតាមផ្សារនៃទីក្រុងភ្នំពេញ ឬ នៅខេត្តកំពង់ឆ្នាំង " កំពង់របស់ឆ្នាំង " ។ ជួនកាលសំភារៈទាំងនេះ ជាគ្រឿងបន្ទាប់បន្សំ ។

" អ្នកស្រុកនៃវណ្ណៈមធ្យម ( ធម្មតា ) មានផ្ទះនៅហើយ តែគ្មានតុកៅអី ចានដែក ឬ ធុងទឹកសំរាប់ប្រើប្រាស់ទេ ។ គេប្រើឆ្នាំងដី ដើម្បីដាំបាយ គេប្រើចាន់ទាបបាតរាក់ សំរាប់ដាក់ទឹកជ្រលក់ដោយដាក់លើដី ។ គេយកថ្មបីដុំតំកល់ធ្វើជាជើងក្រាន ហើយយកត្រឡោកដូងមកធ្វើជាវែកសំរាប់ដួសសំឡ ។ គេប្រើចានទាបមកពីស្រុកចិន ដែលធ្វើពីដីឥដ្ឋ ឬ ស្ពាន់សំរាប់ដាក់បាយ ។ គេយកស្លឹកឈើមកកេរខ្ទាស់ធ្វើករទ្នាង មិនអាចលិចទឹកបានទេ សំរាប់ដាក់សម្លរ និង ទឹកជ្រលក់ " ។

គេហដ្ឋានរបស់មន្ត្រីថ្នាក់ខ្ពស់ទាំងឡាយ ប្រកបទៅដោយអចលនៈវត្ថុដ៏សំបូរបែប ។

" គេហដ្ឋានរបស់មន្ត្រី ឬ ក៏អ្នកមាន ជួនកាលគេប្រើថូធ្វើពីប្រាក់ ជួនកាលធ្វើពីមាសក៏មានដែរ ។ នៅក្នុងពិធីបុណ្យកំណើត នៃប្រទេសនេះ គេមានប្រើភាជន៍ភ័ណ្ឌអំពីមាសយ៉ាងច្រើន ។ នៅលើដីគេបានក្រាលកន្ទេលជាច្រើន ឬ ក៏ក្រាលស្បែកខ្លាធំ ខ្លាទិន ស្បែករប្រើស ស្បែករមាំង ឬ ក៏ប្រើកន្ទេលដែលធ្វើអំពីផ្ដៅ ។ នៅពេលថ្មីៗនេះ គេប្រើតុទាបៗ ហើយដែលមានកំពស់ប្រហែល ១ ហត្ថ ។ សំរាប់ជាកន្លែងដេក គឺមិនប្រើកន្ទេលទេ តែគេដេកនៅលើរនាប ។ ហើយម៉្យាងគេប្រើគ្រែទាបៗសំរាប់ដេកដែរនាំចូលមកដោយប្រជាជនទាំងឡាយ " ។

ទៅតាមព្រេងសំណាងរបស់ប្រជាជនខ្មែរ គឺស្លៀកពាក់ក្រណាត់ ដោយក្រណាត់ក្រាស់ៗថ្លៃបំផុត ។ សំលៀកបំពាក់ដែលកត់ត្រាដោយលោកជីវតាក្វាន់នោះ គឺវាដូចគ្នាទៅនឹងអ្វីដែលយើងបានឃើញដោយរូបចំលាក់ដែលមាន " មនុស្សស្រីក៏ដូចពួកប្រុសៗដែរ ។ គឺមិនបានស្លៀកពាក់នៅកន្លែងផ្សេងទៀតក្រៅពីចិតត្រឹមកន្លែងកេរ្តិ៍ខ្មាស់របស់គេតែបន្តិចនោះទេ " ដោយទុកអោយដើមទ្រូងនៅកណ្ដាលវាល ។ "នៅពេលណាពួកគេចេញដើរ គេគ្រាន់តែថែមបន្តិច នូវចំរៀកសំពត់ព្រែមកគ្របពីលើកេរ្តិ៍ខ្មាស់របស់គេបន្តិចប៉ុណ្ណោះ " ពួកគេដើរដោយជើងទទេ ។ សក់របស់ពួកគេបួងជាផ្នួងឡើង ។ អ្នកដំណើរជាតិចិននេះមុនធ្វើកំណត់ហេតុពី " មនុស្សស្រីនៅក្នុងភូមិមិនមានប្រើអ្វីជាលំអនៅលើក្បាលទេ ប៉ុន្តែពួកគេពាក់កងដៃ ឬ ចិញ្ចៀនធ្វើពីមាស " ។

លោកជីវតាក្វាន់មិនបានរាយការណ៍ប្រាប់យើង សូម្បីតែបន្តិចបន្តួចអំពីពិធីបុណ្យក្នុងសាសនាតាមបែបឯកជនទេ ដែលមានលំនាំជាព្រឹត្តិការណ៍សំខាន់ៗនៅក្នុងជីវិត ដូចជា ការកើត អាពាហ៍ពិពាហ៍ហើយនិងការស្លាប់ ។ គាត់បាននិយាយតែពិធីធ្វើអោយអស់ព្រហ្មចារីយ៍នៃស្រីក្រមុំដែលគ្រប់ការ ហើយការយកខ្មោចទៅបោះចោលក្នុងព្រៃអោយត្មាត ឬ ឆ្កែស៊ីតែប៉ុណ្ណោះ ។

៨- <u>អំពីពិធីបុណ្យផ្សេងៗ</u> :

ក្នុងចំណោមបុណ្យប្រចាំឆ្នាំទាំងឡាយ ពិធីបុណ្យចូលឆ្នាំ គឺជាបុណ្យមួយដែលមានសារៈសំខាន់ជាងគេ ដោយមានការគោរពដោយដុតកាំជ្រួច និង គោះពគ្រឿងចំបាំងទាំងឡាយ ។ បុណ្យនៃពួកនាវាជើងទឹកមួយ ត្រូវបានគេប្រារព្ធធ្វើឡើងនៅខែទីប្រាំ ដែលគេសន្និដ្ឋានបានមកដល់សព្វថ្ងៃនេះថា ជាពិធីបុណ្យអុំទូក ( Fête des Eaux ) នៅសម័យថ្មីនេះ គេបានធ្វើដំណាច់រដូវវស្សា ហើយទឹកក៏បានហូរត្រឡប់ពីទន្លេសាបវិញដែរ ។ នៅខណៈនោះលោកជីវតាក្វាន់បានបន្ថែមពិធីបុណ្យប្រមូលផលស្រូវមួយទៀត គឺពិធីបុណ្យនៃពិធីមហាសិទ្ធទៅដល់ព្រះពុទ្ធរូប ។

ការគាក់តែងពិធីបុណ្យនេះដោយព្រះរាជា បានហៅពិធីនេះថា ជាល្បែងកំសាន្តនាំអោយរីករាយក្នុងចិត្ត ដែលបានរក្សាទុក ហើយបានប្រារព្ធពិធីនេះឡើងនៅទីលាននៃក្រុងភ្នំពេញ ដែលមានបន្តរហូតដល់សម័យបច្ចុប្បន្ននេះ " គេបានមកជួបជុំគ្នានៅលើវេទិកាដ៏ធំមួយ ដែលមានលំអដោយគោមព្យួរ និងផ្កាភ្លើងទាំងឡាយនៅទីលានព្រះបរមរាជវាំង " " គេបានយាងព្រះមហាក្សត្រអោយយាងទៅទតពីទស្សនីយ៍

ភាពនេះ " ។ មនុស្សទាំងអស់រួមមានមន្ត្រី នាម៉ឺនផងជាអ្នកមានចំណែកក្នុងការរៀបចំចាត់ចែងពិធីបុណ្យដ៏មានសារៈសំខាន់នេះ ។ បន្ទាប់មកទៀត " ព្រះមហាក្សត្របានអញ្ជើញអង្គទូតបរទេសអោយចូលរួមទស្សនា នូវទស្សនីយ៍ភាពនេះផងដែរ ។

ជួនកាលនៅតាមដងផ្លូវនៃទីក្រុង គេបានធ្វើពិធីក្បួនព្យុះហយាត្រាយ៉ាងសម្បើម ដែលក្នុងខណៈនោះព្រះមហាក្សត្រក៏យាងទៅទតនូវវត្ត និង ព្រះពុទ្ធរូបមាស ដែលដាក់តាំងនៅពីមុខក្បួននេះ ។ លោកជីវតាក្វាន់បានធ្វើកំណត់ហេតុ ដោយបន្ទន់ទៅតាមមនោ្យបាយដែលមាន ។ នៅពីមុខក្បួនដង្ហែរមានអ្នកជិះសេះជាច្រើនអ្នកប្រកបដោយទង់ចំបាំង ទង់ផ្កាលា និង មានភ្លេងផង ។

សេនាអាមាត្រស្រីៗ ដែលចូលរួមក្នុងការហែរក្បួននេះមានច្រើនជាង ៣០០នាក់ ដោយមានកាន់ទៀន ភាជន៍ធ្វើអំពីមាស និងអំពីប្រាក់ ឯស្រីស្នំអ្នកការពារឯទៀតមានកាន់ស្នរ លំពែង ខែល ។ល។ ពួកនាហ្មឺនសព្វមុខមន្ត្រី មហាក្សត្រ ព្រះមហេសីធំតូច និង ស្រីស្នំរបស់ស្តេចជាច្រើនទៀតបានយាង និងដើរបន្តពីក្រោយ ។ បន្ទាប់មកទៀតទើបព្រះរាជា " ទ្រង់ឈរនៅលើខ្នងដំរី ដោយព្រហស្ថកាន់ព្រះខ័នទិព្វ " ។ ប្រសិនបើស្តេចយាងទៅណាជិតៗ ឬ គ្មានការងារសំខាន់ក្នុងពេលនេះ " ព្រះអង្គមិនគង់នៅលើគ្រែស្នែងមាស ដែលសែងដោយស្រីស្នំ ៤នាក់ នោះទេ " ។

កំណត់ហេតុទាំងឡាយរបស់លោកជីវតាក្វាន់ បានអធិប្បាយអំពីអធិកភាពក្នុងកិត្តិយសនៃព្រះមហាក្សត្រ និង ក្រុមមន្ត្រីនាសម័យអង្គរ ដោយមានលំនាំតាមក្បាច់ក្រឡោតទាប " ជាប្រវត្តិសាស្ត្រ " នៅប្រាសាទអង្គរវត្ត ។ សកម្មភាពនៅទីនេះ គឺជាសន្តតិវង្សខ្មែរ ដែលយើងបានឃើញពីអំណាច ពីភាពរីកចំរើនដែលបានរក្សាទុកនូវភាពហ្វឹកហាត់ ដែលជាភស្តុតាងរបស់អ្នកកាល្យប្រវត្តិជាតិចិននេះ វាជាតំណែមួយដែលគេប៉ាន់ស្មានលើជីវភាពនៃប្រជាជន ដែលរស់នៅក្នុងរាជធានី ហើយធានីនេះក៏ត្រូវបានបោះបង់ចោលដោយព្រះមហាក្សត្រ ក្នុងរយៈពេលប៉ុន្មានរយឆ្នាំក្រោយមក ។ ជួនកាលដើម្បីដំណាលពីប្រវត្តិសាស្ត្រធានីអង្គរនៅក្នុងសម័យកាលនេះ យើងត្រូវប្រើប្រាស់ខ្លះ ដែលមានប្រភពដើមពីជនជាតិបរទេសខ្លះដូចជា ៖ ជនជាតិចិន ថៃ វៀតណាម ប៉កទុយហ្គេ និង ជនជាតិអេស្ប៉ាញញ៉ុល ។ល។

## ជំពូក VIII
## អង្គរ រាជធានីដែលត្រូវគេបោះបង់ចោល

### ១- ស្តេចចុងក្រោយទាំងឡាយ ដែលសោយរាជ្យនៅធានីអង្គរ :

ព្រះបាទស្រីន្ទ្រវរ្ម័ន បានទទួលយកអំណាចនៅក្នុងឆ្នាំ ១២៩៥ គឺជាឪពុកក្មេករបស់ព្រះអង្គព្រះនាមជ័យវរ្ម័នទី ៨ បានដាក់រាជដោយស្មគ្រចិត្ត ឬ ដោយមាន..។ នៅក្នុងរាជស្តេចអង្គនេះ សិលាចារឹកខ្មែរបានចុះនិទ្ទេសថា មានស្តេចពីរអង្គ ។ នៅឆ្នាំ ១៣០៧ ព្រះបាទស្រីន្ទ្រវរ្ម័នបានដាក់រាជដោយចេញពីតំណែងជាស្តេច ហើយប្រគល់អោយស្តេចមួយអង្គទៀត ដែលជាប្អូនរួមព្រះមាតាព្រះបិតា ជា ( ប្អូនបង្កើត ) មានព្រះនាមស្រីន្ទ្រជ័យវរ្ម័ន ( Çrindrajayavarman ) ។ ស្តេចអង្គនេះហើយ ដែលបានថែរក្សាអំណាចបានរហូតដល់ឆ្នាំ ១៣២៧ កាលបរិច្ឆេទនេះ គឺព្រះបាទជ័យវរ្ម៉ាធិបរមេស្វរៈ ( Jayavarmâdiparameçvara ) បានឡើងជាស្តេចគ្រងរាជ្យក្នុងប្រទេស ។ យើងពុំមា ពត៌មានអ្វីច្បាស់លាស់ពីមហាក្សត្រទាំងនេះទេ ។ នៅក្នុងរាជរបស់ព្រះអង្គលទ្ធិព្រះសិវៈ ត្រូវបានគេគោរព បូជាជារៀងរាល់ថ្ងៃ ដោយព្រះមហាក្សត្រ និង ក្រុមមន្ត្រីទាំងឡាយ ដូចមានភស្តុតាងនៃអត្ថបទសិលាចារឹកទាំងឡាយ ដែលត្រូវបានចុះនៅ

បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

លើប្រាសាទ Mangalârtha ដោយព្រះបាទស្រិន្ទ្រជ័យវរ្ម័ន ។ នៅក្នុងពេលនោះ ព្រះពុទ្ធសាសនាថេរវាទ គឺប្រហែលជាសាសនាមួយកំពុងតែមានសារៈសំខាន់ណាស់ដែរ ។ ជាមួយ នឹងព្រះអង្គដែលបានទ្រទ្រង់អោយ ចំណោះដឹងខាងភាសាបាលីកាន់តែរីកចំរើនឡើង ។ សិលាចារឹកទីមួយ ដែលចារជាភាសាបាលី ត្រូវបាន បង្ហាញអោយឃើញឡើងនៅឆ្នាំ ១៣០៩ ។

បន្ទាប់ពីសិលាចារឹកជាភាសាសំស្ក្រឹតមកជា « កពិលបុរៈ » ( Rapilapura ) ដែលចារដោយ ព្រះបាទ Jayavarmâdiparameçvara នោះក៏លែងមានសិលាចារឹកជាភាសាសំស្ក្រឹតអ្វីទៀតហើយ ។ ប្រវត្តិសាស្ត្រនៅប្រទេសកម្ពុជា ក្នុងអំឡុងពេលដែលសតវត្សរ៍ក្រោយៗមក គឺមានកាលប្បវត្តិខុសៗគ្នា ដែលបានរៀបរៀងសេចក្តីឡើងនៅចុងសតវត្សទី ១៨ ឬ ដើមសតវត្សទី ១៩ ។ អត្ថបទដែលមាន ចំណាស់បំផុត គឺជាចំណែកមួយនៃកាលប្បវត្តិ ដោយមានកាលបរិច្ឆេទក្នុងឆ្នាំ ១៧៩៦ ហើយប្រែជា ភាសាសៀម ដែលស្តេចខ្មែរមាននាមអង្គអេង បានថ្វាយដល់ស្តេចសៀម ។ កាលប្បវត្តិមួយទៀតបាន រៀបរៀងសេចក្តីថ្មីឡើងត្រង់រាជ្យនៅដើមសតវត្សទី ១៩ ដោយមន្ត្រីថ្នាក់ខ្ពស់ម្នាក់ឈ្មោះ ឧកញ្ញា នង ដែលនៅក្រោមរាជរបស់ព្រះបាទអង្គច័ន្ទ ។ អត្ថបទចុងក្រោយនេះ បានត្រូវបកប្រែដោយលោក Doudart de la grée ហើយរៀបចំបោះពុម្ពដោយលោក Fran cis Garnier ។ កាលប្បវត្តិទាំងពីរនេះមាន កំណត់ហេតុដោយការគាប់ជួន នៃអកុសលអ្វីទេ ។

យើងពុំបានដឹងពីចំណងមិត្តភាពរវាងព្រះបាទ Jayavarmâdiparameçvara ជាមួយនឹងព្រះបាទ និវ៌ានបទ: ( Nirvâpuda ) ដែលជាឈ្មោះខ្មែរមានន័យថា " និពានបាត " ជាស្តេចទីមួយដែលសោយ រាជ្យនៅក្នុងកាលប្បវត្តិ តមកទៀត ក្រោយពីការបកប្រែមក ព្រះបាទ និពានបាត នេះគឺជាកូនប្រុសនៃអ្នក ចំការដែលបានធ្វើគត់ស្តេច គឺនាយត្រសក់ផ្អែម " ម្ចាស់ចំការត្រសក់ផ្អែម " ។

រឿងនិទានប្រជាប្រិយ៍មួយដ៏ល្អ ដែលបាននិទានអំពីអ្នកថែសួនម្នាក់ឈ្មោះ ត្រសក់ផ្អែម ដែល បានដាំផ្លែត្រសក់ផ្អែម នៅក្នុងសួនចំការរបស់គាត់ ដែលមានរសជាតិឆ្ងាញ់ប្លែកពីគេ ។ ស្តេចដែលកំពុង តែសោយរាជ្យសម្បត្តិមានការសព្វព្រះទ័យខ្លាំង ចំពោះផ្លែត្រសក់ទាំងនេះណាស់ ក៏បានបង្គាប់បញ្ជា អោយអ្នកថែចំការនោះទុកផ្លែត្រសក់ សំរាប់តែព្រះអង្គមួយអង្គឯងគត់ ។ ចំពោះអ្នកដទៃវិញមិនមានសិទ្ធិ ហូបផ្លែត្រសក់ដ៏ល្អនេះទេ សូម្បីតែមួយផ្លែក៏ដោយ ហើយស្តេចក៏បានប្រទានលំពែងមួយ សំរាប់សំលាប់ ចោរដែលចូលមកលួចបេះត្រសក់នៅក្នុងចំការត្រសក់ ។ មានយប់មួយនោះស្តេចដែលជាមនុស្ស ដែល ល្ហោកសោយ បានជំរុញដោយព្រះអង្គរអិលដើងចូលទៅក្នុងចំការ ដែលហ៊ុំដោយរបងនោះ ។ ដោយ តំនិតរពាក្រក់ ព្រះអង្គក៏បានបេះផ្លែត្រសក់នៅតាមជលង ។ តាត្រសក់ផ្អែមមិនបានស្គាល់ថាជាស្តេចទេ នោះក៏យកលំពែងបុកចំស្តេចស្លាប់ទៅ ។ ព្រះអង្គមិនបានបន្សល់ទុកនូវបុត្រណាមួយអោយសោយរាជ្យ បន្តទេ ។ គេបានព្រលែងសត្វដំរីអោយដើរជ្រើសរើសរកអ្នកមានបុណ្យ ដែលត្រូវស្នងរាជបន្ត ។ សត្វដំរី ក៏បានឈប់នៅមុខតាត្រសក់ផ្អែម ហើយគាត់ក៏បានទទួលគារវកិច្ចអោយត្រលប់ចូលវាំងវិញ ។ អ្នកជា ម្ចាស់ចំការបានរៀបអភិសេកជាមួយបុត្រស្តេចដែលអភ័ព្វអង្គនេះទៅ តាមទំនៀមទំលាប់ដែលបំពេញច្បាប់ ជាអ្នកជ្រែករាជ ។

ព្រះអង្គបានសង្កត់ធ្ងន់អំពីអំណាចរបស់ព្រះអង្គ ទៅលើកជាណាចក្រដ៏ធំ ដែលបង្ហាញអោយ ឃើញពីមនុស្សចរចសមុខរឹង ។ ព្រះបាទ និវពានបាត ដែលត្រូវជាបុត្រារបស់ព្រះអង្គ ជាអ្នកមកជំនួស តំណែងតាមក្រោយ ។ មានអត្ថបទជាច្រើន ដែលចុះពីព្រឹត្តិការណ៍ទាំងនេះ នៅក្នុងឆ្នាំ ១៣៤៦ ។ ស្តេច អង្គនេះ ហើយនិងអ្នកស្នងរាជបន្តទាំងឡាយ គឺសុទ្ធតែបានតាំងទីលំនៅនៅធានីអង្គរ ។

វាពុំមានការងាយស្រួលនៅក្នុងការស្រាវជ្រាវអោយដឹងច្បាស់ អំពីកាលបរិច្ឆេទ ដែលព្រះមហាក្សត្រខ្មែរទាំងឡាយបានបោះបង់ធានីអង្គរ ដើម្បីទៅតាំងទីនៅតាមដងទន្លេមេគង្គ ដោយសារតែមានការឈ្លានពានពីសំណាក់ពួកសៀម ។ ប្រសិនបើគេជឿតាមកាល្បប្រវត្តិរបស់លោក នង នោះ ស្តេចនាមរាមាធិបតិ ( Ràmàdhipati ) ដែលបានកសាងអាណាចក្រអាយុធ្យា ( Ayudhyà ) បានមកឡោមព័ទ្ធហើយកាន់កាប់ធានីអង្គរនៅឆ្នាំ ១៣៥៣ នៅក្រោមរាជស្តេចដែលត្រូវជាបុត្ររបស់ព្រះបាទ និពានបាត ។ មានស្តេចសៀមជាច្រើនទៀត ដែលបានបន្តសោយរាជ្យលើបល្ល័ង្កនៅធានីអង្គរ ប៉ុន្តែរហូតមកដល់ឆ្នាំ ១៣៥៨ បើតាមលោក នង បានថា ស្តេចខ្មែរមួយអង្គបានដណ្តើមធានីអង្គរមកវិញ ហើយស្តេចដែលបានទទួលគ្រងរាជ្យក៏បានរៀបអភិសេកអោយសោយរាជ្យនៅក្រោមនាមថា សុរិយាវង្សរាជាធិរាជ ( Surya vamçaràjadhiràja ) ។

- ដោយចេញមកពីកាលបរិច្ឆេទនេះ ស្ថានភាពនៃសង្គ្រាមរវាងខ្មែរសៀម ប្រហែលជាមានជាអចិន្ត្រៃយ៍ ។ រហូតមកដល់ឆ្នាំ ១៣៧០ មានការវាយប្រហារពីសំណាក់ពួកសៀមម្តងទៀត មកលើប្រទេសកម្ពុជា ដោយប្រទាញប្រទង់គ្នាធ្វើអោយធានីអង្គរធ្លាក់ចុះទៅក្នុងការវិនាសម្តងទៀត ហើយស្តេចខ្មែរដែលសោយរាជ្យនៅក្រុងអង្គរ ក៏ត្រូវបានគេធ្វើគត់ទៀត ពួកសៀមក៏បានមករៀបចំ និង អោយស្តេចសៀមមកសោយរាជ្យលើបល្ល័ង្កខ្មែរ ។ បើតាមកាលប្រវត្តិរបស់លោក នង គឺក្នុងខណៈនោះហើយ ដែលស្តេចខ្មែរនាមចៅពញាយ៉ាតបានទៅធ្វើគត់ស្តេចសៀម រួចដណ្តើមអំណាចបានមកវិញ ។ ក្រោយពីរៀបចំឡើងគ្រងរាជ្យសម្បត្តិអស់រយៈកាល ១២ឆ្នាំ នៃរាជរបស់ព្រះអង្គ ព្រះអង្គបានសំរេចចិត្តចាកចេញពីធានីអង្គរ ហើយបានទៅរៀបចំធានីថ្មីមួយផ្ទាល់ព្រះអង្គ នៅតាមដងទន្លេមេគង្គ ជាដំបូងតាំងទីនៅទួលបាសាននៅក្នុងតំបន់ស្រីសន្ធរ រួចមកតាំងនៅរាជធានីភ្នំពេញ ។ កាល្បប្រវត្តិដែលបានប្រមូលចងក្រងដោយលោក Moura ដែលបានផ្តល់អោយសំរាប់ព្រឹត្តិការណ៍ទាំងនេះ គឺជាកាលបរិច្ឆេទដ៏យឺតយ៉ាវណាស់ ហើយបានដាក់ជំនួសព្រឹត្តិការណ៍របស់ព្រះបាទ ពញាយ៉ាត ហើយនិងការបោះបង់ចោលធានីអង្គរក្រោយពីមានការវាយដណ្តើមយកធានីនេះ ស្តេចក្រុងអយុធ្យានាម "បរមរាជៈII " ( Paramaraja II ) ក្នុងឆ្នាំ ១៤៣១ ។ អ្នកប្រវត្តិសាស្ត្រជាតិអាមេរិកាំងម្នាក់ឈ្មោះ M.O.W Wotters ក្រោយពីការធ្វើការបកប្រែជាថ្មីនូវឯកសារដើមរបស់ពួកចិន និង ខ្មែរ បានគិតថា រហូតដល់ការរាតត្បាតជាបន្តបន្ទាប់មកទៀត នៅក្នុងឆ្នាំ ១៣៧០ ស្តេចខ្មែរមួយអង្គបានមកតាំងទីនៅទួលបាសាក់រួចជាស្រេចហើយ ប៉ុន្តែអ្នកស្នងរាជបន្តពីព្រះអង្គបានរុះរើ និង ត្រលប់មកតាំងទីនៅអង្គរវិញ ។ វាសមហេតុសមផលដែរ ដែលធានីចាស់បានត្រូវគេចោលដោយសន្តតិវង្សជាច្រើន ដែលបានមកកាន់កាប់វិញក្រោយពីការត្រូវបោះបង់ចោលជាស្ថាពរ ។

- នៅក្នុងស្ថានភាពបច្ចុប្បន្ន នៃចំណេះដឹងរបស់យើង វាមានការងាយស្រួលក្នុងការពិពណ៌នាឡើងវិញ អំពីអ្វីដែលបានវិលត្រលប់មកធានីអង្គរវិញ ក្នុងអំឡុងពេលសតវត្សទី ១៥ ។ ជារួមការបោះបង់ចោលធានីអង្គរ ដោយសារតែមកពីផលវិបាកនៃការរាតត្បាតរបស់ពួកសៀមនៅឆ្នាំ ១៤៣១ ។ លោក J Boisselier បានគិតថា កាលបរិច្ឆេទនេះ គឺធ្វើឡើងក្រោយពីធានីត្រូវបានគេលួចប្លន់រួចហើយ ។ ដោយព្រះបាទ Paramaraja II ( ស្តេចសៀម ) បាននាំមកនូវទាហានដែលចាប់ជាឈ្លើយសឹក អទិទេពហើយនឹងគេគនភ័ណ្ឌរបស់រាជាណាចក្រជាច្រើនទៀត " ដោយខ្សែកពួកអ្នកតាំងទីនៅ Rajyçri ( រាជ្យស្រី ) ដោយលើកទៅតាមជញ្ជាំងកំពែងទាំងឡាយ ដែលគេបានចោះទំលាយ រួចបើកចំហរនៅកំពែងខាងត្បូង " របស់ប្រាសាទនាគព័ន្ធ ។ គាត់បានបន្ថែមថា ៖

" ដោយចូលចិត្តឈឺឆ្អាលជួយគេ គេគនតែណ្ហទាំងឡាយ និង អ្នកធានាអះអាងចំពោះអ្នកដទៃ នៃរាជអំណាចក្រអំពីការផ្លាស់ប្ដូរអ្នកគ្រប់គ្រង ដោយសួយសារអាករយកមកពីអយុធ្យា គឺជាអំណាចនៃស្ដេចចក្រពត្តិ ដែលព្រះបាទ Paramaràja II បានគិតថា ការទាក់ទាញយកគុណប្រយោជន៍នៃសន្តតិវង្ស របស់ព្រះអង្គ បើពិនិត្យទៅដូចជាការរក្សាទុកនូវអំណាចត៏ទៅមុខទៀត ដែលព្រះបាទជ័យវរ្ម័នទី ៧ បានប្រមូលផ្ដុំនៅក្នុងរមណីយ៍ដ្ឋានអង្គរ " ។

រាជធានីទំនងជាត្រូវបោះបង់ចោល ហើយចំពេញដោយព្រៃព្រឹក្សាដែលក្នុងពេលនោះស្ដេចបានវិលមកតាំងទីនៅទីនេះជាថ្មីឡើងវិញ នៅក្នុងពាក់កណ្ដាលទី ២ នៃសតវត្សទី ១៦ ។

២- ការរស់ឡើងវិញនៃសតវត្សទី ១៦ :

នៅឆ្នាំ ១៥២៨ ព្រះបាទអង្គច័ន្ទក្រោយពីទទួលបរាជ័យក្នុងនាមជាអ្នកជ្រែករាជម្នាក់ នៅរាជធានីលង្វែក ស្ថិតនៅខាងត្បូងទន្លេសាបចំពាក់កណ្ដាលផ្លូវពីភ្នំពេញទៅបឹងទន្លេសាប ។ ដោយបានវាយកំចាត់ពួកសៀមចេញពីប្រទេស ព្រះអង្គមានសិទ្ធិក្នុងការគ្រប់គ្រងអំណាច ។ ព្រះអង្គបានរកឃើញធានីយសោធរបុរៈ ដែលត្រូវបានគេបោះបង់ចោលអស់រយៈកាលជាងមួយសតវត្សមកហើយ ។ អ្នកកាលប្បវត្តិជាតិព័រទុយហ្គែម្នាក់បានកត់ត្រាក្នុងកំណត់ហេតុ នៃការរុករកឃើញធានីនេះឡើងវិញ ។

" មកដល់ឆ្នាំ ១៥៥០ ឬ ១៥៥១ ស្ដេចខ្មែរបានយាងរកទាក់ដំរីនៅក្នុងព្រៃដ៏សែនក្រាស់ដែលចេញទៅទូទាំងអាណាចក្រទាំងមូល មនុស្សទាំងនោះបានកាប់កូនឈើតូចៗ សំរាប់ផ្ដល់ទុកធ្វើជាលំនៅដ្ឋានទាំងឡាយ និង ការលុកព្រៃនេះគួរអោយអធិកអធម្ម នៅខាងក្នុងក៏មានកូនឈើដុះដេសដាស ដែលរីកសាយយ៉ាងខ្លាំង ហើយគេមិនអាចផ្ដួលដើមឈើអោយបានស្អាត ពីទីកន្លែងដែលជោគជាំបានទេ ។ នេះគឺជារបាយការណ៍អំពីស្ដេច ព្រះអង្គបានបន្សាក់នូវសេចក្ដីពិរោះពិរាយនៃទីកន្លែងដែលបានឃើញ បានពួតិកំពស់នៃជញ្ជាំងខាងក្រៅ ដើម្បីចង់គោពីខាងក្នុង ព្រះអង្គបានបញ្ជាអោយគេកាប់ និង ដុតកូនឈើតូចៗអោយអស់ពីចំការនេះ ។ រួចព្រះអង្គអោយគេសង់ដំណាក់នៅជិតមាត់ស្ទឹងដ៏ស្រស់ស្អាត មានទាសាទាសិចំនួន ៥ ឬ ៦០០០នាក់ ធ្វើការនៅកន្លែងនេះ ។ ហើយក្រោយពីបានសំអាតស្អាតគ្រប់កន្លែងរួចមកស្ដេចបានយាងទតសារចុះសារឡើងជាច្រើនដង រួចបានពួពីការរកឃើញ នូវសំណង់ជាច្រើននៅប៉ែកខាងក្នុង ហើយព្រះអង្គក៏មានការស្ងើចសរសើរពីសំណង់ទាំងនោះ ។ សំរាប់តំបន់នេះ ព្រះអង្គបានសំរេចព្រះទ័យដឹកនាំក្រុមបរិពារទាំងឡាយមកតាំងនៅទីនេះ ដែលមាននៅជារូបភាពខ្លាំងក្លាជាងធានីដទៃទៀត ។

- ជារមណីយ៍ដ្ឋានមួយ ដែលល្អជាងគេបំផុតលើលោក ហើយក៏សប្បាយជាងគេដែរ ។

- កាលពីឆ្នាំ ១៥៤៦ ក្រុងអង្គរធំមិនត្រូវបានគេយកចិត្តទុកដាក់ដូចប្រាសាទអង្គរវត្តទេ ព្រោះថានៅក្នុងឆ្នាំនេះ ស្ដេចបានបញ្ជាអោយគេឆ្លាក់ក្បាច់ក្រឡោតទាប នៅជ្រុងខាងជើងឈៀងខាងកើតនៃកំពែងទី ៣ របស់ប្រាសាទអង្គរវត្ត ។ នេះគឺបានមកពីលទ្ធផលនៃចំលាក់ពីរផ្ទាំង នៃថែវទាំងនេះ ដែលបានរៀបចំធ្វើឡើងខុសពីចំលាក់របស់ប្រាសាទនៅរជ្ជកាលព្រះបាទសូរិយាវរ្ម័នទី ២ ។ លោក G.Coedès បានបកប្រែសិលាចារឹកជាច្រើន ដែលបានចុះពីការចាប់ផ្ដើមធ្វើ និង ការបញ្ចប់នៃការងារនេះ ។ ដោយជឿទៅតាមកាលប្បវត្តិរបស់លោក និង បានថាក្បាច់ក្រឡោតទាបនេះបានបង្ហើយនៅឆ្នាំ ១៥៦៦ គឺដំណាលគ្នានឹងឆ្នាំដែលព្រះបាទអង្គច័ន្ទសោយទីវង្គត់ ។ ពួកគេបានឆ្លាក់ជារឿងនៃទេវកថារបស់ព្រះវិស្ណុ ។ ប្រសិនបើមានរូបជាច្រើន ដែលត្រូវបានគេឆ្លាក់បំពេញនោះ ជាមួយនឹងភាពសាមញ្ញ ដែលនាំមកនូវអ្វីជាទីទុក្ខសោកចំពោះចំលាក់អទិទេពទាំងឡាយពីធម្មជាតិ ។

- បុត្រាដែលត្រូវស្នងរាជបន្តពីព្រះបាទអង្គច័ន្ទទី ១ នាមព្រះបាទបរមរាជ ( Paramarâja ) បានសោយរាជ្យនៅកំពង់ក្រសាំង ស្ថិតនៅក្នុងតំបន់អង្គរ ដើម្បីដឹកនាំកងទ័ពប្រយុទ្ធប្រឆាំងនឹងពួកសៀម។ វាជាការពិបាកណាស់ ក្នុងការដឹងអោយបានច្បាស់ថា ស្តេចអង្គនេះបានតាំងលំនៅនៅធានីអង្គរ ដោយនៅជាប់លាប់បានយូរប៉ុនអត់ ។ ប៉ុន្តែគេបានដឹងច្បាស់ថា បុត្រារបស់ព្រះអង្គព្រះនាម សថាទី ១ ( Satha Ier ) ដែលបានឡើងគ្រងរាជ្យបល្ល័ង្កក្នុងឆ្នាំ ១៥៧៦ បានរៀបចំប្រាសាទមួយនៅក្នុងកំពែងធានី ដែលសំរាប់ធ្វើបុណ្យប្រជាភិវឌ្ឍន៍ លោក F. Joaodossanto បានអោយសញ្ញាអំពីការតាំងទីនៅទីនេះរបស់ស្តេច ។ " គេបានក្រាយផ្លូវទាំងឡាយឆ្ពោះទៅកាន់ធានី ដែលនៅតាមផ្លូវនេះ ស្តេចខ្មែរបានដឹកនាំជាមួយនឹងក្រុមបរិពាររបស់ព្រះអង្គ ហើយនឹងបានគង់នៅទីនេះ " ។ បេសកកម្មទាំងឡាយរបស់ជាតិពរទុយហ្គេ នឹង អេស្ប៉ាញ ដែលពេលនោះបានស្នាក់នៅក្នុងធានីអង្គរ រួមជាមួយនឹងអ្នកកាល្យប្រវត្តិផ្សេងៗទៀត ដែលគេបានបញ្ជូនមកអោយយើងអំពីការពិពណ៌នាពីរាជធានីរបស់អ្នកទាំងនោះ ។

- គេបានរកឃើញនូវស្លាកស្នាមនៃការមកតាំងទីឡើងវិញ នៅក្នុងធានីអង្គរធំ ។ នៅប្រាសាទ N.486 ហើយនឹងនៅប្រាសាទព្រះពិថូ និង មានបំណែកចំលាក់ជាច្រើន ដែលមានចុះកាលបរិច្ឆេទក្នុងសតវត្សទី ១៦ ។ នៅខាងជើងលានជល់ដំរី មានចំលាក់ពីរបី និង កន្លែងពីរបីទៀត ត្រូវបានគេរៀបចំសំរួលជាថ្មី ដោយមានកាលបរិច្ឆេទនៅក្នុងសម័យកាលនេះ ។ នៅអង្គរវត្តនៅក្នុងសិលាចារឹកមួយ ដែលមានកាលបរិច្ឆេទនៅឆ្នាំ ១៥៧៧ ម្ចាស់ក្សត្រីដែលត្រូវជាមាតារបស់ Satha បានមានព្រះរាជបន្ទូលដោយក្តីបិតិសោមនស្សរីករាយ នៅពីមុខស្នាដៃនៃការជួសជុលឡើងវិញនេះ របស់បុត្រាព្រះនាងនៅប្រាសាទអង្គរវត្ត ដែលនៅទីនោះព្រះនាងបានហៅថា ជាព្រះវិស្ណុលោក " គពពិសិដ្ឋរបស់ព្រះពិស្ណុ " ។ នៅក្នុងសិលាចារឹកដ៏វែងមួយ ដែលមានកាលបរិច្ឆេទឆ្នាំ ១៥៧៩ ហើយចារដោយព្រះហស្ថរបស់ស្តេចផ្ទាល់ បាននិយាយពីព្រះមហាក្សត្រ " ដែលបានជួសជុលជញ្ជាំងកំពែងរបស់ព្រះពិស្ណុលោក ដោយយកថ្មជំនួសដោយថ្ម បានជាដំបូលអោយជាប់មាំឡើងវិញ ដោយព្រួញរបស់ព្រះអង្គចំនួន ៩ ចំណុច សំរាប់លំអដោយប្រក់មាស " ។

- ពិធីបុណ្យទាំងឡាយ ត្រូវបានប្រព្រឹត្តិជាប់ជាមួយគ្នានៅក្នុងប្រាសាទ ។ សិលាចារឹកជាមួយគ្នានេះ បានធ្វើរបាយការណ៍ពីពិធីទាំងឡាយ ដែលបានតាក់តែងពិធីបុណ្យយ៉ាងឧឡារិកនៃការប្រសូត្របុត្រាមួយអង្គរបស់ព្រះបាទ Satha និង ការដាក់ឈ្មោះអោយបុត្រានេះ ។

" នៅថ្ងៃអាទិត្យមួយ ក្រោយពីការប្រសូត្របុត្រាបាន ១២ មក គេបានធ្វើការជំនុំ S.M រួមមានម្ចាស់ក្សត្រី ព្រះរាជគ្រូ ហោរាសាស្ត្រ ហើយនិងព្រះគ្រូទាំងឡាយ នៃព្រហ្មញ្ញសាសនា ដោយបានសំដែងអោយឃើញពីពិធីបុណ្យ នៃការដាក់ឈ្មោះ ។ S.M បានសំរេចចិត្តដាក់ឈ្មោះបុត្រាស្តេចនូវឈ្មោះដ៏មានពសិណ្ឌ គឺឈ្មោះ ព្រះបរមរាជាធិរាជ ( Brah Paramrâjadhirâja ) ដោយឱនលំទោន" ។

- ក្រោយពីពិធីនេះ គេបានលើកយកនូវការកកើតថ្មី ចំពោះព្រះពិស្ណុលោកថា ជាកន្លែងដែលប្រជុំទៅដោយអទិទេពថែរក្សាទឹកដីទាំងឡាយ ហើយនិងបុព្វបុរសជាច្រើនទៀត តាំងពីពេលនោះមកគេបានបង្ហាញអោយឃើញដូចជា សាវ័ក ( អរិយៈ ) របស់ព្រះពុទ្ធ ។ កំណាត់ហេតុនេះត្រូវបានគេកត់ត្រាឡើងនៅសតវត្សទី ១៦ អំពីរាជពិធីបុណ្យមួយដ៏ឧឡារិកទៅតាមពិធីព្រហ្មញ្ញសាសនា ដើម្បីព្រះមហាក្សត្រដែលកាន់ព្រះពុទ្ធសាសនា ដូចដែលគេបានឃើញរហូតមកទល់នឹងសម័យបច្ចុប្បន្ន អំពីព្រះមហាក្សត្រ និង នាម៉ឺនសព្វមុខមន្ត្រីនៅភ្នំពេញ ។

- នៅក្នុងអំឡុងពេលពីរបីសតវត្ស ក្រុងអង្គរបានលាតត្រដាងអោយឃើញពិសមិទ្ធិជាគម្ពីរទាំងឡាយនៅក្នុងកាជាណាចក្រ ។ ក៏ប៉ុន្តែវាទំនងដូចជារាជធានីកំពុងតែលើកតំកើងអោយតំលៃទៅលើលទ្ធិសាសនា ។ ក្រុងលង្វែក គឺស្ថិតនៅជាមជ្ឈមណ្ឌលគ្រប់គ្រងដោយរដ្ឋបាល ដែលនៅទីនោះព្រះមហាក្សត្របានយាងវិលត្រលប់ទៅគង់នៅទីនោះ ប្រហែលជាពីរបីឆ្នាំក្រោយមក ។ មូលហេតុមកពីព្រះបាទ Satha បានវិលទៅលង្វែកវិញ នៅក្នុងពេលដែលស្តេចនៃក្រុងអយុធ្យាព្រះបាទ នរេស្វរៈ (Nare Svara ) បានវាយលុកចូលមកប្រទេសកម្ពុជា ក្រោយពីព្រះអង្គមានជ័យជំនះទៅលើពួកភូមា ។ ពួកសៀមបានមកដាក់ល្បីនៅធានីលង្វែក ដែលត្រូវធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់ពួកគេនៅក្នុងខែមករា ឆ្នាំ១៥៩៤ ។

- ការចូលលុកលុយធានីលង្វែក បានធ្វើអោយទីនេះធ្លាក់ទៅក្នុងហាយនភាព ដែលប្រទេសខ្មែរមិនអាចនឹងបានស្តារឡើងវិញបាន ។ រីឯស្តេចក៏បានសោយទិវង្គត់នៅប្រទេសឡាវ ដែលព្រះអង្គបានរត់ទៅជ្រកនៅទីនោះ ឯបុត្រទាំងឡាយរបស់ព្រះអង្គ បានទៅរស់នៅយ៉ាងកំសត់នៅស្រីសន្ធរ ធានីអង្គរត្រូវកូនឈើតូចៗដុះពាសព្រាតជាថ្មីឡើងវិញ ។ នៅក្នុងខណៈនោះ ជីវិតសាសនាមិនត្រូវបានគេកាត់ផ្តាច់ឡើយ នៅប្រាសាទអង្គរវត្តនោះ គេបានប្រមូលរូបសំណាកព្រះពុទ្ធ សំរាប់ធ្វើការគោរពបូជាជារៀងរាល់ថ្ងៃនៃពុទ្ធបរិស័ទទាំងឡាយ ហើយមានវត្តអារាម ២ ក៏ត្រូវបានគេស្ថាបនាខាងក្នុងកំពែងប្រាសាទអង្គរវត្ត ដែលសព្វថ្ងៃនេះគេហៅថា វត្តអង្គរខាងជើង និង វត្តអង្គរខាងត្បូង ។

៣- <u>ធានីអង្គរនៅសតវត្សទី ១៧ និងសតវត្សទី ១៨</u> :

ធានីមិនត្រូវបានផ្លាស់ប្តូរច្រើនដែរទេ ជាដំបូងនៅធានីអង្គរ រួចស្តេចទៅតាំងនៅស្រីសន្ធរ រួចទៅឧត្តុង្គដែលប្រហែលជានៅលង្វែក ។ នៅក្នុងខណៈនោះ ព្រះមហាក្សត្រទាំងឡាយបានចុះនិទ្ទេសរយៈពេល ២ ឬ ៣ ឆ្នាំក្រោយនៃការមកស្នាក់នៅរបស់ស្តេចនៅធានីអង្គរ ។ ការប្រែប្រួលការណ៍ដោយលោក Moura ពីការតាំងទីនៅប្រាសាទអង្គរវត្ត និង ការចាប់ផ្តើមទាំងឡាយនៃសេចក្តីស្នេហាដែលត្រូវបង្ហូរឈាមយ៉ាងសម្បើម នៃក្សត្រចៅ ពញ៉ាថូ ( Chau panneatho ) ៖

ក្នុងរយៈពេលពីរបី ខែក្រោយពិពុកមានរបស់ស្តេចក្មេងម្នាក់ បានបង្កើតអោយមានរាជានុសិទ្ធិដោយបានប្រគេននូវគ្រឿងអម្ពរដល់សាសនា ដើម្បីអោយស្តេចក្មេងមួយអង្គ ដែលបានលួងលោមនាំយកសង្សាររបស់ទ្រង់ឈ្មោះ អង្វូ ហើយរត់ទៅដើម្បីអោយបានរៀបការនឹងគ្នាផង ។ នៅឆ្នាំ ១៦៣០ នៅក្នុងខណៈពេលដែលមហាក្សត្រធ្វើដំណើរកំសាន្តនៅទីផ្លានៃធានីអង្គរ ទ្រង់បានជួបជាមួយនឹងនាង អង្វូវដេយ ( Angvodey ) ហើយព្រះអង្គក៏ទៅជួបជាមួយនឹងនាងយ៉ាងសំងាត់ នៅលើជណ្តើរនៃទីលានខាងក្រៅប្រាសាទអង្គរវត្ត ។ ស្នេហាទន់ភ្លន់កៀកកើយ ដែលផុសចេញពីក្នុងចិត្តពិតៗ បានតម្រូវអោយគេបញ្ចប់ជីវិតដោយការបង្ហូរឈាមយ៉ាងសម្បើម ដោយហេតុថានៅពេលបន្ទាប់មក អ្នកសាហាយស្មន់ទាំងពីរនេះក៏បានបបួលគ្នាលបរត់ចេញទៅ ។ តែត្រូវគេរុករក និង ស្ទាក់ចាប់បានមកវិញ ហើយក៏យកទៅសំលាប់ចោលតែម្តងទៅ ។

ស្តេចមួយអង្គទៀតនាម ចៅពញាច័ន្ទ បានគង់នៅជាអធិរាជ្យនៅធានីអង្គរ ។ នៅទីនេះព្រះអង្គបានឃើញពួកអេស្ប៉ាញ ដែលទើបតែធ្វើដំណើរមកពីក្រុងម៉ានីល ។ ហើយព្រះមហាក្សត្រក៏អោយពួកនេះចូលគាល់ ដើម្បីបំពេញបេសកកម្មរបស់ពួកគេ នៅខណៈពេលដែលពួកបរទេសទាំងនេះស្នាក់នៅធានីអង្គរ ។ នៅក្នុងខណៈពេលដែលបាត់ឈ្មោះព្រះបាទ ចៅពញាច័ន្ទ ក្នុងឆ្នាំ ១៥៦៨ កាលប្បវត្តិទាំងឡាយមិនបានចុះនិទ្ទេសអោយបានច្រើន ពីការស្នាក់នៅនៃរបបរាជាធិបតេយ្យនៅធានីអង្គរ ដែលត្រូវបានបោះបង់ចោលដោយស្តេចទាំងឡាយ រហូតដល់សម័យបច្ចុប្បន្ននេះ ។

- ស្តេចទាំងឡាយ ប្រហែលជាមិនបានវិលទៅអង្គរវិញទេ ប៉ុន្តែចំពោះប្រជារាស្ត្រនៅតែបន្តការវិលទៅកាន់បូជនីយដ្ឋានទាំងនោះវិញ ។ សិលាចារឹកជាច្រើនបានបញ្ជាក់ពីភស្តុតាងនៃឧបាទាន ( ការប្រកាន់យកការគោរព ) របស់ប្រជាជនខ្មែរ ចំពោះប្រាសាទបូរាណចាស់ ។ អត្ថបទទាំងនោះ ជាទូទៅត្រូវបានគេចារនៅលើសសរទាំងឡាយ ហើយជារឿយៗវាកើតចេញមកពីភាពសប្បាយរបស់មនុស្ស ឬ ក៏អ្នកមានមុខនាទីខ្ពស់ៗ ដែលចូលវ័យចាស់ ហើយបានខិតខំស្វែងរកជាវ នូវអ្វីដែលនាំអោយបានកុសលដើម្បីបំពេញករណីកិច្ច នូវស្នាដៃសប្បុរសក្នុងការអោយទាន ដែលជាប់ទាក់ទិនច្រើនទៅនឹងការចុះនិទ្ទេសនៃដង្ហាយពីការត្រាច់ចរទៅកាន់បូជនីយដ្ឋាន ត្រូវបានគេចារនៅលើថ្ម គឺសូមអោយគ្រប់ក្រុមជនតូចតាចទាំងឡាយ និង មនុស្សទាំងឡាយ ដែលរស់នៅក្នុងភូមិ ។ ដូចដែលយើងបានដឹងថា មានគ្រហស្ថ ៨នាក់ " មានប្រុស និង ស្រី ដោយមានចិត្តស្មោះស " បានមកដល់ទីនេះកាលពីឆ្នាំ ១៦៣០ ដើម្បីនាំយកព្រះពុទ្ធរូប ៨អង្គ មករក្សាទុកនៅទីនេះ ។ ជួនកាលការត្រាច់ចរទៅកាន់ប្រាសាទអង្គរវត្ត ក្នុងខណៈនោះគេចង់ទៅទស្សនាស្នាដៃរបស់បុព្វបុរស ដែលបានរៀបចំកសាងឡើងនៅក្នុងតំបន់នេះ ។

- ជារឿយៗការត្រាច់ចរទៅកាន់ប្រាសាទនេះ គឺគេបាននាំយកទៅជាមួយនូវព្រះពុទ្ធរូបជាច្រើនអង្គផង ។ អំណោយទាំងនេះ ជួនកាលមានច្រើនពេក ។ នៅឆ្នាំ ១៦៨៤ មានមន្ត្រីថ្នាក់ខ្ពស់ម្នាក់ខាងផ្នែកសាសនាបានប្រកាសថា គឺជារូបគាត់ដែលបាន " សាងព្រះពុទ្ធរូបអំពីមាសរាប់រយអង្គ និង ព្រះពុទ្ធរូបអំពីប្រាក់ចំនួន ៣៨អង្គ ព្រះពុទ្ធរូបថ្មីអំពីថ្ម និង រូបចំលាក់ផ្សេងទៀត សរុបទាំងអស់មានចំនួន ២១៤ ព្រះពុទ្ធរូប " ។ មានតែចំលាក់ទាំងឡាយអំពីថ្ម និង ឈើប៉ុណ្ណោះ ដែលស្ថិតនៅរហូតដល់សម័យកាលបច្ចុប្បន្ននេះ ។ រូបទាំងអស់នេះ ត្រូវបានដាក់តាំងនៅតួប្រាសាទកណ្តាលនៃប្រាសាទអង្គរវត្ត គឺស្ថិតនៅក្នុងថែវទាំងឡាយនៅប៉ែកខាងត្បូង និង វិហារដ្ឋានរាងជាកាកបាទ គឺកន្លែងនេះហើយដែលគេហៅថា ព្រះពាន់ " ១០០០ បរិសុទ្ធ ( ព្រះពុទ្ធ ) " ។ ចំលាក់អំពីឈើទាំងឡាយស្អាតណាស់ ។ ជាការពិតណាស់ រូបព្រះពុទ្ធមានគ្រងជីវរ ដែលជាប់ទាក់ទឹងបុព្វជិតដែលមានតបកម្ម ។ ការបង្ហាញរូបមួយបែបទៀត គឺបង្ហាញពីបរមសុខដោយមានពាក់គ្រឿងអលង្កា ស្តេចពាក់មកុដលើសក់ក្បាល នៅពីលើសំលៀកបំពាក់សាសនា ហើយក្រៅពីនេះ មានពាក់ខ្សែក កងដៃ និង ខ្សែក្រវ៉ាត់យ៉ាងសំបូរបែប ។ ចំលាក់ទាំងនេះ មានលាបទឹកមាសពីលើស្រទាប់ម្រ័ក្សូ ២ គឺពណ៌ខ្មៅ និង ក្រហម ។ តាមលទ្ធផលដែលបានសិក្សាពីគម្ពីររបស់ព្រះពុទ្ធបានថាបដិហាររបស់ព្រះពុទ្ធមានពន្លឺស្មើជាមាស ។ ការបង្ហាញពីរូបមនុស្សទាំងអស់អង្គុយលុតជង្គង់ គឺជាអកប្បកិរិយា ប្រណម្យ ពិសេសគឺរូបចំលាក់នៅអង្គរវត្ត ។ រូបចំលាក់ដ៏ល្អៗទាំងនោះ ដែលគេបានឃើញម្តងទៀត គឺជាចំណែកមួយនៃក្រុមចំលាក់នៅអង្គរវត្ត ដែលត្រូវបានគេនាំយកទៅដាក់តាំងនៅក្នុងសារៈមន្ទីរជាតិភ្នំពេញ ។ រូបទាំងអស់នេះមានរាងសង្ហាយ៉ាងសុក្រិត នៅក្នុងអកប្បកិរិយានៃការសញ្ជឹងគិតបានពន្យល់ដោយគុណសម្បត្តិអ្វីគួរអោយចូលចិត្តដែលមានរស់ជាតិ ។

- ជានិច្ចកាល គឺមានការសោកស្តាយដែលរូបចំលាក់ទាំងនោះបានទទួលរងខ្យល់បោកបក់ពីមួយថ្ងៃទៅមួយថ្ងៃ នៅត្រាំក្នុងកន្លែងសើមនៃថែវទាំងឡាយ និង រូបខ្លះទៀតក៏បានក្លាយទៅជាទ្រុឌទ្រោមអស់នៅដើមសតវត្សទី ១៨ មានមន្ត្រីថ្នាក់ខ្ពស់ម្នាក់បានសំដែងអោយឃើញនូវភាពខូចតំលៃ ដោយគាត់បានខំប្រឹងប្រែងដើម្បីផ្គួសផ្គុំរូបចំលាក់ខ្លះៗ ដែលបានបែកបាក់ ។ នៅក្នុងសិលាចារឹករបស់ប្រាសាទអង្គរវត្ត បានបង្ហាញពីស្ថានភាពអ្វីដែលបានខ្ទាតចេញពីរូបទាំងនោះ តាំងពីច្រើនឆ្នាំមកហើយ ៖

" បន្ទាប់មកខ្ញុំក៏បានរៀបចំ និង ផ្គួសផ្គុំនៃរូបបរិសុទ្ធទាំងឡាយ ( ព្រះពុទ្ធ ) ដែលត្រូវបាក់ជាចំណែកតូចៗនៅរាងកាយ និង បាក់បង់ដូចជាបែកនៅត្រង់ក គ្រប់ព្រះកេសដែលរអិលយ៉ាងងាយ

គ្រង់ជើងបាក់ជាបំណែកៗ និង ដៃនៅរាត់រាយឥតសណ្ដាប់ធ្នាប់ ។ ការទំប្រឹងប្រែងរបស់ខ្ញុំ ក្នុងការស្រាវជ្រាវប្រមូលយកនូវបំណែកទាំងនោះមកបិតឡើងវិញ ខ្ញុំបានជួសជុលរូបទាំងនោះ ហើយលាបទឹកមាស រួចដាក់អោយត្រូវតាមកន្លែងដើមវិញ និង ត្រូវតាមស្ថានភាពនៃសម្រស់ ។

ពិធីអភិសេករូបចំលាក់ទាំងនោះ រួមមានដង្វាយដទៃទៀត ដូចជាពាំទូកមាស ប្រាក់ ឬ ទង់ដែង ទង់សុវណ្ណ ផ្កាលា ដំបូលត្របរូបចំលាក់ ហើយនិងទឹកអប់ ។ ជួនកាលគេបានចុះនិទ្ទេសផងដែរនូវដង្វាយដែលជាម្ហូបអាហារ ស្បង់ជីវរ ករទ្ទួលសំរាប់អទិទេពទាំងឡាយតង់នៅក្នុងវត្តទាំងពីរ ដែលបានសង់នៅខាងក្នុងកំពែងប្រាសាទអង្គរវត្ត ។

ក្នុងនោះគ្រប់ជីវិតនៃការរៀបចំក្រុង ត្រូវបានបាត់បង់ពីក្រុងអង្គរធំតាំងពីយូរយារមកម្លេះ តួបំមប្រាសាទរបស់ប្រាសាទ ដែលទទួលគុណគាប់ពិសេសពីអទិទេព ដែលថែរក្សាអាណាចក្រ ស្ថិតនៅលើកំពូលរបស់តួប្រាសាទ ហើយត្រូវបានគោរពជារៀងរាល់ថ្ងៃ ឥឡូវនេះត្រូវបានគេឧទ្ទិសថ្វាយដល់ព្រះពុទ្ធវិញ ។

*ស ន្និ ដ្ឋា ន :*

ការកាប់ឆ្ការព្រៃនៅធានីអង្គរ :

គេមានឯកសារជាច្រើន ដែលនិយាយពីការរកឃើញធានីអង្គរ នៅចុងសតវត្សទី ១៩ ។ ជាការពិតណាស់ធានីអង្គរមិនបានទទួលនូវភាពស្រពាប់ស្រពោននៅក្នុងរយៈកាល ដែលត្រូវបានគេបំភ្លេចវាំទេ។ នៅភាគខាងចុងបូព៌ា ធានីអង្គរមិនត្រូវបានគេស្គាល់ទេ ។ នៅដើមសតវត្សទី ១៨ អ្នកត្រាច់ចរជាតិជប៉ុនម្នាក់បានមកដល់ប្រទេសកម្ពុជា ហើយបានគូរប្លង់ប្រាសាទអង្គរវត្ត ដែលរូបនេះបានធ្វើសំរេចនៅឆ្នាំ ១៩៦៥ ។ អត្ថបទរបស់លោក P.chevreul ដែលគាត់បានស្នាក់នៅក្នុងប្រទេសកម្ពុជា ក្នុងឆ្នាំ ១៧៦៨ នោះ គាត់ក៏បានបង្ហាញភស្តុតាងនៃភាពល្បីល្បាញ នៃគ្រប់ប្រទេសទាំងអស់នៅអាស៊ីអគ្នេយ៍ និង ប្រាសាទអង្គរវត្ត " ដោយបានហៅឈ្មោះពួកអតិជនទាំងឡាយនៅចន្លោះ ៥ ឬ ៦ អាណាចក្រដូចជានៅខាងកើតក្រុងរ៉ូមចន្លោះពួកក្រិច " ។ ក្នុងខណៈនោះ នៅប៉ែកខាងលិច ទោះបីមានសាក្សីជាច្រើនដែលជាបេសកជន ហើយជាទូទៅពួកគេទាំងនោះ មិនដែលធ្លាប់ស្គាល់ធានីដ៏ចំណាស់របស់ប្រទេសកម្ពុជាទេ ។ វាជាការពិតណាស់ ដែលមានកំណត់ហេតុរបស់បេសកជនទាំងឡាយមិនត្រូវបានផ្សព្វផ្សាយ ហើយនៅតែមិនសូវបានទទួលការរាប់អានអ្វីទេ នៅក្នុងឯកសារទាំងនោះ ។

គេបានដឹងថាលោក P.Bouilleneaux បានបោះពុម្ពពីសិលាចារឹកនៅអង្គរលើកទី ១ នាឆ្នាំ ១៨៥៨ ។ កំណត់ហេតុនេះ បានធ្វើអោយដឹងពីការគង់នៅនៃធានី ដែលត្រូវគេបោះបង់ចោល ប៉ុន្តែមិនបានចុះនិទ្ទេសពីសោភណ្ឌភាព ដែលអ្នកស្ថាបនាបានរត់ចោលទាំងស្រុង ។ អង្គរវត្តត្រូវបានគេបង្ហាញនៅប្រទេសលោកខាងលិច ក្នុងរយៈកាលពីរ ឬ បីឆ្នាំក្រោយមក ដោយកំណត់ហេតុរបស់អ្នកធម្មជាតិវិទ្យាម្នាក់ឈ្មោះលោក Mouhot ដែលបានស្ញើចចំពោះពន្លឺចិញ្ចាចចញ្ចែង នៃប្រាសាទបាក់បែកទាំងនេះ ។ លោក Mouhot បានត្រូវស្លាប់ក្រោយបន្តិចពីពេលដែលគាត់ស្នាក់នៅធានីអង្គរនាឆ្នាំ ១៨៦០ ប៉ុន្តែកំណត់ត្រាទាំងឡាយរបស់គាត់ ត្រូវបានគេបោះពុម្ពនៅក្នុងទស្សនាវដ្ដីមួយ ដែលមានការបោះពុម្ពយ៉ាងច្រើន គឺដំណើរទេសចរណ៍នៃពិភពលោក ( Tour du Monde ) ។ រំពេចនោះបេសកកម្មរុករកទាំងឡាយ និង ការស្រាវជ្រាវជាវិទ្យាសាស្ត្រ បានយកចិត្តទុកដាក់ក្នុងការសិក្សាពីធានីបុរាណខ្មែរ ។ លោក Doudart delagrée បានមកស្នាក់នៅធានីអង្គរធំចំនួន ៣ ដង ក្នុងចន្លោះឆ្នាំ ១៨៦៣ ដល់ ១៨៦៧ នៅក្នុងបេសកកម្មលើកទី ៣ គាត់បានមកជាមួយលោក F. Garnier ហើយ និងលោក L. De la porte ។

នៅឆ្នាំ ១៨៦៣ អ្នកដំណើរជាតិអាល្លឺម៉ង់ម្នាក់ឈ្មោះ Bastian បានប្រទាញយកការផ្ចង់ទៅលើចំណោះវិជ្ជាដ៏ជ្រៅជ្រះ ទៅលើសិលាចារឹកខ្មែរ ដែលជាប់ចិត្តទៅនឹងអ្នកចារឹកសាស្ត្រជាតិ ហុល្លង់ឈ្មោះ Kern ។ បេសកកម្មសិក្សាស្រាវជ្រាវមួយផ្សេងទៀត បានបំពេញដោយលោក Pavie លោក Four nereau ហើយនិងឧត្តមសេនីយ៍ Beylié ។

ការរុករកនៅឆ្នាំ ១៨៩៨ គឺជាបេសកកម្មមួយ នៅជាប្រចាំនៅឥណ្ឌូចិនតែម្តង និង ក្រោយមកផ្លាស់ទៅជាវិទ្យាស្ថានបារាំងចុងបូព៌ាប្រទេស ( EFEO ) ដែលកត់សំគាល់ពីលក្ខណៈបត់បែននៅក្នុងការស្រាវជ្រាវនៃអាណាចក្រចាស់របស់ខ្មែរ ។ ក្រោយពីអទិប្រាយជាភាសាពីរ គឺភាសាបារាំង និង សៀមនៅឆ្នាំ ១៩០៧ ដែលបានផ្តល់អោយនូវអភិរក្សដ្ឋានបុរាណប្រាសាទតំបន់អង្គរ ដើម្បីអោយថែរក្សាប្រាសាទបាក់បែកទាំងឡាយ នៃអតីតរាជធានីខ្មែរ ។ យើងសូមឧទ្ទិសទៅដល់អ្នកស្រាវជ្រាវ និង អ្នកប្រាជ្ញទាំងឡាយ ដែលបានចំណាយមួយផ្នែកខ្លះ នៃជីវិតរបស់ពួកគេ ដើម្បីមកជួសជុល និង ក្រេបយកចំណេះពីធានីអង្គរ ។ តែយើងពុំបានរៀបរាប់ឈ្មោះរបស់អ្នកទាំងនោះទេ ។

ដាដំបូងគេត្រូវកាប់ឆ្ការសំអាតប្រាសាទ ដែលត្រូវអោបរឹតដោយព្រៃ ជួនកាលត្រូវលិចកប់ចូលក្នុងដីពាក់កណ្តាល នៅក្រោមការពូនឡើងដោយដី ហើយនិងគំនររូបធាតុទាំងឡាយដែលស្រុត ។ មានតែប្រាសាទអង្គរវត្តមួយគត់ ដែលត្រូវបានគេចូលជិត ហើយបានតង់នៅជាកន្លែងមួយសំរាប់គោរពបូជាសាសនា ប៉ុន្តែប្រាសាទនេះផ្ទាល់ត្រូវចាស់ទ្រុឌទ្រោមណាស់ទៅហើយ ។ សាក្សីនៃការគោរពខ្ជាប់ខ្ជួនដែលមាននៅឆ្នាំ ១៧០១ បានធ្វើការជួសជុលនូវរូបចំលាក់ទាំងឡាយ ដែលជាភស្តុតាងមួយបានបញ្ជាក់ថាមិនសូវបានថែទាំប្រាសាទទេ ។ នៅឆ្នាំ ១៩០៨ អ្នកអភិរក្សទី ១ ឈ្មោះ J. Commaille បានចាប់ផ្តើមកាប់ឆ្ការព្រៃនៅឆ្លាដ៏ធំរបស់ធានីអង្គរធំ និង ទីធ្លាក្បៀនកោះរបស់វាដទៃទៀត ។ ក្រោយការស្លាប់របស់លោក Commaille អ្នកជំនួសតំណែងរបស់គាត់ គឺលោក H. Marchal បានលើកយករបស់ដែលកប់នៅក្នុងទីលានទាំងឡាយ ។ ចាប់ផ្តើមពីឆ្នាំ ១៩១៩ មកគេចាប់ផ្តើមធ្វើការជាមួយប្រាសាទទាំងឡាយ ដែលស្ថិតនៅក្រៅធានី ។

ការកាប់ឆ្ការសំអាតប្រាសាទ ពុំមាននូវផលវានល្អមទេ ។ គេត្រូវតែធ្វើការជួសជុលប្រាសាទទាំងឡាយ ហើយការរៀបចំបានជាធម្មតាហើយយ៉ាងសាមញ្ញបំផុត ការងារនេះធ្វើឡើងមួយដំណាក់កាលម្តងៗ ។ ដូចនៅប្រាសាទបាយ័នបានសិក្សាលើកទី ១ ដោយលោក Dufour និងលោក Carpeave នៅចន្លោះឆ្នាំ ១៩០១ និង ១៩០៤ ហើយបានធ្វើការកាប់ឆ្ការព្រៃនៅចន្លោះឆ្នាំ ១៩១១ និង ១៩១៣ ឯការជួសជុលគ្រប់គ្រងការងារដោយលោក G. Trouvé នាឆ្នាំ ១៩៣៣ ហើយបានធ្វើបន្តដោយលោក M. Glaize នាឆ្នាំ ១៩៣៩ ដល់ឆ្នាំ ១៩៤០ ។ ពេលថ្មីៗនេះគេបានធ្វើការសិក្សានៅប្រាសាទបាយ័ន ចំពោះមធ្យោបាយនៃការបង្ការជុំថ្ម កុំអោយរលុះបាក់ដោយសារតែដើមឈើដុះលើថ្ម ។ នៅឆ្នាំ ១៩៣០ គេបានជ្រើសរើសបច្ចេកទេសមួយ ដែលគេបានស្គាល់រួចហើយគឺ Anastylose ( គឺរើថ្មចេញអោយអស់រួចទើបរៀបឡើងវិញ ) ដែលមានសមាសធាតុជាការបង្ហាញពីប្រាសាទឡើងវិញ ដោយប្រើប្រាស់នូវសំភារៈទាំងឡាយល្អៗ ។ បែបផែនត្រូវប្រតិបត្តិអោយបានសំរេចផលនេះ ត្រូវបានអនុវត្តន៍នៅឆ្នាំ ១៩៣១ ដោយលោក H. Marchal ដើម្បីជួសជុលប្រាសាទបន្ទាយស្រី ។ លោក M.Glaize ក៏បានស្នើអោយជួសជុលប្រាសាទបន្ទាយសំរែ និង នាគព័ន្ធ ។ លទ្ធផលដែលបានមកពីការពិសោធន៍ប្រើប្រាស់សំភារៈទំនើបៗ ក្នុងការជួសជុលត្រូវបានគេផ្តល់ការងារ ត្រូវជួសជុលប្រាសាទបាយ័ន ដែល

ដឹកនាំដោយលោក B. Ph. Groslier ។ តែដោយសង្គ្រាមផ្ទុះឡើងនៅឆ្នាំ ១៩៧០ ការងារទាំងឡាយមិនអាចទៅមុខបានទេ ។

ក្នុងខណៈពេលនោះ អ្នកសិក្សាអក្សរសាស្ត្រ សិលាចារឹក អ្នកប្រវត្តិសាស្ត្រ និង បុរាណវិទូទាំងឡាយ បានខិតខំប្រឹងប្រែងអោយបានសំរេចនូវការងារស្រាវជ្រាវរបស់ពួកគេ ទៅលើអតីតកាលសម័យអង្គរ ។ ដូចដែលការសិក្សាតាំងពីប្រវត្តិសិល្បៈដោយលោក P. Stern ការស្រាវជ្រាវដោយមើលពីលើ ( ដោយយន្តហោះ ) ដោយលោក V Groloubew ហើយនិងការងារទាំងឡាយស្តីពីអក្សរចារឹករបស់លោក G Coedès អាចអោយគេរកឃើញនូវមេហាភិយ៍ដ្ឋាន នៃធានីយសោធរបុរៈទី ១ ហើយនិងរកគននក័ណ្ឌរបស់ព្រះបាទ ជ័យវរ្ម័នទី ៨ ។ ការសាងសង់ប្រាសាទបាយ័ន និង ធានីអង្គរធំ ។ តាំងពីយូរយារមកហើយ ធានីអង្គរត្រូវបានគេស្គាល់ទូទាំងពិភពលោក អំពីពិធីបុណ្យថ្មីៗ ដែលត្រូវបានធ្វើឡើងនៅប្រាសាទអង្គរវត្ត ហើយនិងមានបច្ច័យដល់ព្រះមហាក្សត្រ ។ ទិដ្ឋាធំរបស់ក្រុងអង្គរធំក៏ជូរថ្លោះដែរគឺនៅឆ្នាំ ១៩៦៨ សម្តេចសីហនុបានធ្វើអោយមានស្នាមគន្លងនង្គ័លដ៏ពិសិដ្ឋ ដែលជាកំណត់នៃការចាប់ផ្តើមការងារកសិកម្ម ។ នៅក្នុងសម័យនេះ កាលណាដល់ខែ មេសា ដែលជាពេលប្រារព្ធពិធីបុណ្យចូលឆ្នាំខ្មែរ ប្រជាជនទាំងអស់បានមកពីឆ្ងាយៗ មកស្នាក់នៅធានីអង្គរ ២ ឬ ៣ ថ្ងៃ ដើម្បីទស្សនានូវផ្ទាំងរឿងរាមកេរ្តិ៍ ឬ ក៏ពុទ្ធប្រវត្តិ ។ កាលពីដើមបរិស័ទដែលជាអ្នកស្រុកភូមិ និង ក្រុងតែងតែមកត្រិះរិះសញ្ជឹងមួយរយៈពេលខ្លី ( សមាធិ ) នៅតួប្រាសាទកណ្តាល នៃប្រាសាទអង្គរវត្ត ឬ នៅរូតព្រះពាន់ ហើយនៅចំពោះព្រះភក្ត្រព្រះពុទ្ធអង្គទាំងឡាយ គ្របដណ្តប់ទៅដោយផ្សែងធូប ធូបក្រអូបច្រើនរាប់រយ ។

របៀបរបបគ្រប់គ្រងអភិរក្សអង្គរ ចាប់ពីឆ្នាំ ១៩៦០ រហូតមកដល់ចុងឆ្នាំ ១៩៩៨ :

- ឆ្នាំ ១៩៦០ អភិរក្សអង្គរដាក់ក្រោមការដឹកនាំរបស់សាលាបារាំងនៅចុងបូព៌ាប្រទេស មានលោក ហ្គូលិយេរ៍ (B.P Groslier ) ជាអ្នកដឹកនាំរួមពីឆ្នាំ ១៩៦០ រហូតឆ្នាំ ១៩៧៣ ។

- ដោយមានបច្ចេកទេស និង បទពិសោធន៍ច្រើនក្នុងការជួសជុលប្រាសាទ គឺបានរើ និង រៀបឡើងវិញ (Anastylose) នូវប្រាសាទដូចខាងក្រោម ៖

- ប្រាសាទធម្មនន្ទរើនៅឆ្នាំ ១៩៥៩ ដល់ឆ្នាំ ១៩៦២

- រើ និង រៀបវិញកាំជណ្ដើរស្រះស្រង់ ផ្នែកខាងលិច និង ធ្វើកំណាយ ចាប់ផ្ដើមឆ្នាំ ១៩៥៩ រួចនៅឆ្នាំ ១៩៦៣

- ឆ្នាំ ១៩៦១ ដល់ឆ្នាំ ១៩៦៦ រើនិងរៀបឡើងវិញស្ពានហាលខាងលិចមួយចំហៀងខាងត្បូង ចាប់ពីមុខនាគរហូតទល់គោបុរៈខាងក្រៅ និងកាំជណ្ដើរផ្នែកខាងត្បូងខាងលិចខាងកើតស្មើនឹងក្លោងទ្វារដំរី ។

- ជួសជុលប្រាសាទក្រវ៉ាន់ ចាប់ពីឆ្នាំ ១៩៦១ រហូតឆ្នាំ ១៩៦៦ ។

- ជួសជុលស្ពានប្រាបទោស ( ក្នុងស្រុកជីក្រែង ) ពីឆ្នាំ ១៩៦១-១៩៦៣

- រើ និង រៀបឡើងវិញលានជល់ដំរី និង លានស្ដេចគំលង់ រើនៅឆ្នាំ ១៩៦៦ រៀបវិញមិនទាន់រួច ។

- រើពេងទងកូរសមុទ្រទឹកដោះ រើនៅឆ្នាំ ១៩៦៨ រៀបវិញបានត្រឹមខឿនជាន់ទី ២ ។

- ជួសជុលប្រាសាទបាយក្អែក និង ប្រាសាទល្មុងបានរួច ។

- ប្រាសាទបាពួនរៀបចំគោបុរៈខាងកើត ស្ពានហាលភ្ជាប់ទៅខាងលិច កំពែងជាន់ទី ៣ បានរើហើយចាក់បេតុង គំរោងផែនការ ១០ឆ្នាំ តែដោយសារសង្គ្រាមជំនាន់លន់ណុល ដោយចេញចូលមិនបាន ( តំបន់អង្គរ ) ការដ្ឋានជួសជុលត្រូវបិទ នៅថ្ងៃទី ២០-០១-១៩៧១ ។ ពីឆ្នាំ ១៩៧១-១៩៧៥ : ត្រូវបើកការដ្ឋានជួសជុលក្នុងខេត្តសៀមរាប ។

- រើ និង រៀបឡើងវិញប្រាសាទឥន្ទកោសិយ៍

- ធ្វើកំណាយនៅប្រាសាទតាពាំង ( ផ្លូវទៅវត្តទក )

- មានការប្រមូលឯកសារ និង រូបចំលាក់ល្អៗ ពីឃ្លាំងអភិរក្សអង្គរ យកទៅទុកនៅសារមន្ទីរជាតិភ្នំពេញ ។

- ជួសជុលប្រាសាទកណ្ដាល យ៉ខាងលិច និង កំពែងព័ទ្ធជុំវិញប្រាសាទអង្ករ ។

- ចាក់បេតុងជាផ្ទាំងធំៗបាំងឃ្លាំង និង ដញ្ជូនដីដាក់ការុងកៅស៊ូរៀបព័ទ្ធពីខាងក្រៅ ។

<u>នៅឆ្នាំ ១៩៧៤ ត្រីមាសទី ១</u> :

- បារាំងត្រឡប់ទៅវិញអស់ បានប្រគល់ការងារអភិរក្សអង្គរអោយលោក ពេជ កែវ គ្រប់គ្រងបន្តរហូតដល់ឆ្នាំ ១៩៧៥ ។

<u>ពីឆ្នាំ ១៩៧៥ រហូតដល់ចុងឆ្នាំ ១៩៧៩</u> : របបប៉ុល ពត ( ខ្មែរក្រហម ) បានធ្វើការជំលៀសអ្នកធ្វើការនៅអភិរក្សអង្គរអោយទៅរស់នៅភូមិ ឃុំ ល្វេស ស្រុកសុទ្រនិគមន៍ ខេត្តសៀមរាប ។

<u>និយាយរួម</u> : អ្វីៗដែលមានការរីកចំរើនលូតលាស់មុនឆ្នាំ ១៩៧០ បានប្រែក្លាយទៅជាវិនាសសាបសូន្យ ប្រជាជនគ្រប់ស្រទាប់ជាន់ថ្នាក់ ត្រូវរស់នៅក្នុងគុកឥតជញ្ជាំងធ្វើការជាទម្ងន់ រង់ចាំតែសេចក្ដីស្លាប់។

<u>ការងារបេតិកភណ្ឌវប្បធម៌ជាតិ</u> :

ចាប់ពីឆ្នាំ ១៩៧០ រហូតដល់ឆ្នាំ ១៩៧៩ ប្រាសាទទាំងឡាយត្រូវបានបោះបង់ចោលគ្មានអ្នកណា ឬ អង្គការអន្តរជាតិណាធ្វើការអភិរក្សជួសជុលឡើយ បណ្តាលអោយខូចខាតធ្ងន់ធ្ងរ ។

- ការខូចខាតដោយសារធម្មជាតិ និង ជម្ងឺថ្ម
- ការខូចខាតដោយសារមនុស្សបំផ្លាញ
- ការខូចខាតដោយសារសង្គ្រាម

<u>អំពីការងារសំខាន់ៗដែលអភិរក្សអង្គរសំរេចបានចាប់ពីឆ្នាំ ១៩៧៩ រហូតឆ្នាំ ១៩៩៨</u> :

- ពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៨២ អភិរក្សអង្គរដឹកនាំដោយលោក ពេជ កែវ ដោយខ្វះសាស្ត្រាចារ្យ សំរាប់បង្រៀននិស្សិតសកលវិទ្យាល័យ ក្រសួងបានផ្លាស់ទៅនៅភ្នំពេញ ។

- ពីឆ្នាំ ១៩៨២ រហូតឆ្នាំ ១៩៩៨ អភិរក្សអង្គរដឹកនាំដោយលោក អួង វន ជាអ្នកអភិរក្សខ្មែរ បានចាប់ផ្តើមពីបាតដៃទទេ រហូតមានសំភារៈគ្រប់គ្រាន់ រៀបចំរចនាសម្ព័ន្ធ និង កែប្រែរបៀបរបបដឹកនាំការងារ មានមន្ត្រីរាជការសរុប ១៣៤ នាក់ ។

- ការប្រមែប្រមូលរូប និង ទទួលរូបពីសមត្ថកិច្ចបានចំនួន រូប-ផ្ទាំង និង ធ្វើការរៀបចំជួសជុលឃ្លាំងដាក់រូបបានល្អប្រសើរ ធ្វើការគូរបចំលាក់ដែលបាក់បែកបានចំនួន ៥៦០ រូប ។

- បានតភ្ជាប់ខ្លួននាគ ជើងនាគតាមស្ពានហាលខាងក្នុង និង ទល់ទ្រប្រាសាទដែលត្រូវគ្រាប់ជំនាន់លន់ ណុល បានសមស្រប ។

- បានធ្វើការជួសជុលព្រះពុទ្ធអង្គធំៗ នៅអង្គរធំបានចំនួន ៨អង្គ ។
- បានឆ្លាក់ព្រះកេសតូចៗនៅព្រះវិហារវត្តព្រះសេរអញ្ញ វត្តព្រះអង្គខ្មៅ ប្រាសាទបុរីវិល័យ ។ល។
- បានចាក់ចម្លងពុម្ពក្បាលទាញព្រ័ត្រ នៅមុខក្លោងទ្វារជីឆ្នាំង ក្លោងទ្វារទន្លេអុំ ។

- ពិសេសបានធ្វើការត្រួសត្រាយព្រៃនៅតាមបណ្តាប្រាសាទក្នុងតំបន់អង្គរបានស្អាត រហូតទំនាក់ទំនងសហការជាមួយនឹងអង្គការ ILO ( អង្គការពលកម្មអន្តរជាតិ ) ជួយសំអាត បាររើកវេញពីស្រះបានស្អាតទៀតផង ចាប់ពីឆ្នាំ ១៩៩៣ រហូតដល់ឆ្នាំ ១៩៩៨ ។ គឺត្រួសត្រាយសារចុះសារឡើង រហូតគាស់ឫសចេញអស់ ។

- ធ្វើការទល់ទ្រប្រាសាទមួយចំនួនក្នុងតំបន់អង្គរ ដើម្បីទប់ស្កាត់ការរលុះប្រាសាទ ។

- បានធ្វើបញ្ជីសារពើភណ្ឌរូបចំលាក់ តាមបណ្តាប្រាសាទបុរាណ និង នៅក្នុងឃ្លាំងអភិរក្សអង្គរ ដោយសហការជាមួយវិជ្ជាស្ថានបារាំងនៅចុងបូព៌ាប្រទេស ។

<u>អំពីការងារសាងសង់ និង ជួសជុលសំណង់មូលដ្ឋាន</u> <u>( អភិរក្សអង្គរ )</u> :

- ជួសជុលអាគារក្នុងអភិរក្សអង្គរ និង សាងសង់របងព័ទ្ធជុំវិញអភិរក្សអង្គរ បំពាក់អគ្គិសនី ទឹក ទ្វារបង្អួចបានសមស្រប ។ ការងារនេះ គឺត្រូវយកអស់ស្មារតីទាំងកំលាំងកាយ កំលាំងចិត្ត ឈរលើទស្សនៈជាតិ មិនបានគិតពីជីវភាព ខ្វះខាតសំភារៈបរិក្ខា តស៊ូគ្រប់បែបយ៉ាងជាមួយជនទុច្ចរិត ចូលរួមយ៉ាងជិតស្និតជាមួយអង្គការអន្តរជាតិ ដើម្បីសង្គ្រោះអង្គរអោយរួចផុតពីគ្រោះធម្មជាតិមាន ៖

- <u>សកលវិទ្យាល័យសូហ៊ីយ៉ា</u>: យកប្រាសាទបន្ទាយក្តី ដើម្បីធ្វើការសិក្សាស្រាវជ្រាវ និង បណ្តុះបណ្តាលធនធានមនុស្សខ្មែរ និង កិច្ចអភិវឌ្ឍន៍ជីវភាពសង្គមរបស់ប្រជាជននៅជុំវិញស្រះស្រង់ និង បើកការដ្ឋានជួសជុលស្ពានហាលអង្គរវត្ត ។

- <u>ក្រុមបុរាណវិទូឥណ្ឌា</u> បានមកសិក្សាគំរោងជួសជុលប្រាសាទអង្គរវត្ត ហើយផ្ដើមជួសជុល ចាប់ពីឆ្នាំ ១៩៨៦ រហូតដល់ឆ្នាំ ១៩៩៣ មានការងារធំៗពីរគឺ ការងារដុសលាង និង ព្យាបាលដោយវិធីគីមី រ៉ែ និង រៀបឡើងវិញប្រាសាទអង្គរវត្ត ។

- <u>អង្គការមូលនិធិពិភពលោក</u>: ស្ដីពីការងារអភិរក្សប្រាសាទព្រះខ័ន បានចាប់ផ្ដើមពីឆ្នាំ ១៩៩២ ជាផែនការយូរអង្វែង ជួសជុលជាដំណាក់កាលៗ ។

<u>វិទ្យាស្ថានបារាំងនៅចុងបូព៌ាប្រទេស</u> :

- ជួសជុលលានស្ដេចគំលង់បន្តពីឆ្នាំ ១៩៧០ ចាប់ផ្ដើម 1,93 ហើយនៅឆ្នាំ ១៩៩៦ ។
- បើកការដ្ឋានជួសជុលប្រាសាទបាពួន ថ្ងៃទី ២០-២-៩៥ ។
- ជួសជុលលានជល់ដំរីផ្នែកខាងជើង ចាប់ផ្ដើមពីឆ្នាំ ១៩៩៦ ហើយនៅចុងឆ្នាំ ១៩៩៧ ។

<u>អង្គការជួយសង្គ្រោះអង្គររបស់រាជរដ្ឋាភិបាលជប៉ុន</u>: ( JSA ) ផែនការផ្ដើមពីថ្ងៃទី ១៧-៧-៩៦

- ជួសជុលប្រាសាទសួព្រ័ត្រ
- ជួសជុលបណ្ណាល័យខាងជើងប្រាសាទបាយ័ន
- ជួសជុលបណ្ណាល័យខាងជើងប្រាសាទអង្គរវត្ត ( ក្នុងកំពែងខាងក្រៅ )

<u>ឥណ្ឌូណេស៊ី ( ITASA</u> ) :

- ផែនការជួសជុលគោបុរៈកំពែងខាងក្រៅ នៃប្រាសាទភិមានអាកាស បើកការដ្ឋានជួសជុលនៅថ្ងៃទី ១៥-៥-១៩៩៥ រហូតដល់ឆ្នាំ ២០០០ ។

<u>រដ្ឋាភិបាលអ៊ីតាលី</u> ( បានផ្ដល់ថវិកាតាមរយៈអង្គការ UNESCO )

- ជួសជុលតួប៉មប្រាសាទផ្នែកខាងត្បូង ក្នុងកំពែងខាងក្រៅ តួប៉មកណ្ដាលមួយ
- ជួសជុលរយៈពេលខ្លីពីរសប្ដាហ៍ ថ្ងៃទី ២៩-៤-៩៦ ដល់ថ្ងៃទី ១៣-៥-៩៦ ត្រឡប់ទៅវិញ ។
- បន្តការជួសជុលលើកទី ២ រយៈពេល ៣ខែ គឺខែ មិនា ១៩៩៩ រហូតដល់ខែ មិថុនា ១៩៩៩

<u>អង្គការអភិរក្សអប្សរាប្រាសាទអង្គរវត្ត</u> : របស់ប្រទេសអាល្លឺម៉ង់ ( GACP ) ចាប់ផ្ដើមការងារថ្ងៃទី ២៤-២-៩៨ រហូតដល់ឆ្នាំ ២០០០ ។

<u>រដ្ឋាភិបាលចិនប្រជាមានិត</u> : ជួសជុលប្រាសាទចៅសាយទេវតា

- ចាប់ផ្ដើមធ្វើការសិក្សាលើកគំរោងជួសជុលនៅថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ គូរប្លង់ និង ធ្វើការត្រួសត្រាយសំអាតខ្លះៗ ចប់នៅថ្ងៃទី ១៣-៤-៩៨ ។

- បានមកបន្តការងារត្រួសត្រាយ និង គូរប្លង់បន្ថែមទៀត ចាប់ពីឆមាសទី ១ ឆ្នាំ ១៩៩៩ ។

ចាប់ពីឆ្នាំ ១៩៧៩ រហូតដល់ឆ្នាំ ១៩៩៣ ការអភិរក្សជួសជុលបណ្ដាប្រាសាទក្នុងតំបន់អង្គរ ក៏ដូចជាបណ្ដាប្រាសាទដទៃទៀតដែរ ត្រូវជួបការលំបាកច្រើនណាស់ ជាសមរភូមិមួយក្ដៅស្មើនឹងសមរភូមិប្រយុទ្ធជាមួយខ្មាំងសត្រូវ ថ្ងៃធ្វើការ យប់កាន់កាំភ្លើងយាមកាមជាប់នឹងដៃ ។

ងបណ្ដាអង្គការអន្តរជាតិ មិនទាន់បានទទួលស្គាល់ផ្ដែកម្ពុជានៅឡើយ ។

- នៅជំនាន់នោះមានមីនច្រើន ព្រៃឈើធំដុះទន្ទ្រានលើប្រាសាទ កំលាំងតិច ដំបូងគឺមានតែ ១៥នាក់ រដ្ឋាភិបាលបានតំលើងជាបន្តបន្ទាប់រៀងរាល់ឆ្នាំ រហូតដល់ឆ្នាំ ១៩៩៩ មានមន្ត្រីបុគ្គលិករាជការ ចំនួន ១៣៨នាក់ តែប៉ុណ្ណោះ ។

# ប្រាង្គប្រាសាទ

* * * *

នៅឆ្នាំ ១១៧៧ ក្រុងយសោធរបុរៈ ត្រូវពួកចាមវាយកំទេច ។ គឺព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់រៀបចំដួសជុលឡើងជាថ្មីអោយបានល្អជាងដើម ហើយព្រះអង្គបានសាងទីក្រុងថ្មីមួយទៀត ដែលមានទាំងប្រាសាទចាស់ៗ ក្នុងកំពែងនោះផងដែរ ។ សំខាន់ជាងនេះ គឺថាកំពែងជុំវិញ និង ប្រាសាទកណ្តាលសុទ្ធតែជាការងារថ្មីទាំងអស់ ។ សំណង់ប្រាសាទ ដែលមានរូបភាពនៅទំព័រខាងក្រោយ ព្រះអង្គទ្រង់កសាងឡើងដើម្បីឧទ្ទិសបុណ្យកម្ម ចំពោះមនុស្សជាតិទាំងអស់ ព្រមទាំងព្រះមាតា ព្រះបិតា ព្រះរាជបុត្រ និង ព្រះសេនាផង ។ ហេតុនេះហើយបានជាគេឃើញនៅលើសិលាចារឹក ( បញ្ញត្តិមន្ទីរពេទ្យ ) នូវសេចក្តីដូច្នេះថា " ព្រះរាជហឫទ័យពោរពេញទៅដោយសេចក្តីមេត្តា ដើម្បីសេចក្តីសុខចំរើនដល់លោកទាំងមូល ព្រះមហាក្សត្រទ្រង់ធ្វើសេចក្តីឧទ្ទិសដូចតទៅ : សត្វទាំងអស់ដែលលិចលង់ក្នុងសមុទ្រវដ្តសង្សារ សូមអោយខ្ញុំស្រោចស្រង់បាន ដោយអំណាចនៃអំពើដ៏ប្រសើរនេះ សូមអោយស្តេចគ្រប់អង្គក្នុងកម្ពុជប្រទេស ដែលជាប់ដោយសេចក្តីល្អ ហើយដែលជាអ្នកជួយថែរក្សាការកសាងរបស់ខ្ញុំ បានដល់ទីដែលចាកផុតទុក្ខដែលគ្មានជំងឺមួយអន្លើ ដោយព្រះរាជវង្សានុវង្ស ព្រះអគ្គមហេសី សេនាបតី និងមិត្តសំឡាញ់ទាំងអស់គ្នា ។

<u>សេចក្តីសន្និដ្ឋាន</u> :

ឥត្ថិសន្តិបរំសុខំ ពុំមានសេចក្តីសុខឯណាប្រសើរជាងសេចក្តីស្ងប់ឡើយ ។ សន្តិភាពគឺជាបំណងប្រាថ្នា នៃមនុស្សជាតិទាំងមូល ។ តែបើមនុស្សម្នាក់ៗជំពាក់ជំពិន តែក្នុងកិលេស និង តណ្ហាដែលបង្កើតជាគំនិតអញនិយម កេងប្រវ័ញ្ចបោកបញ្ឆោត ជិះជាន់សង្កត់សង្កិននៅលើមនុស្សដទៃ វាមិនមែនជាការបាត់បង់នូវតម្លៃរបស់មនុស្សទេឬអ្វី ? តម្លៃសីលធម៌សង្គម គឺការគោរពគ្នាទៅវិញទៅមក ការស្គាល់ខ្លួនឯង និង ស្គាល់អ្នកដទៃ ។ ព្រោះមនុស្សជាផ្នែកមួយរបស់សង្គម ជាសង្គមគ្រួសារក្តី សង្គមជាតិក្តី ដូច្នេះគ្រប់រូបត្រូវតែចាំបាច់មានគុណធម៌ ដើម្បីជាគុណប្រយោជន៍ដល់សង្គមទាំងមូល ។ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ លើកយកព្រះបាទជ័យវរ្ម័នទី ៧ មកជាទីអាងក្នុងទិវាវប្បធម៌ជាតិលើកទី ១ វប្បធម៌សន្តិភាពគឺ ដើម្បី ៖

១- យើងសិក្សាពីព្រះញាណរបស់ព្រះអង្គ ដែលក្នុងឋានៈជាក្សត្រដ៏អស្ចារ្យលើសស្តេចឯទៀត ទ្រង់មានឫទ្ធានុភាពប្រៀបបាននឹងព្រះទេវៈ តែព្រះអង្គទ្រង់គោរពមាគ៌ាដ៏ឧត្តម ជាគន្លងរបស់ព្រះសម្មាសម្ពុទ្ធដ៏ប្រសើរ ដែលដឹកនាំមនុស្សសត្វទៅរកសេចក្តីស្ងប់វៀងវៃទុកជាងទាំងពួង ។

២- អំពីតម្លៃនៃជីវិតរបស់មនុស្ស ព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់ត្រាស់បង្គាប់អោយលើកលែងទោសចំពោះអ្នកប្រព្រឹត្តខុសឆ្គងនូវអំពើដដែលៗ តែផ្តន្ទាឥតត្រាប្រណីចំពោះអ្នកដែលធ្វើអោយប៉ះពាល់ដល់ជីវិតមនុស្សសត្វទាំងអស់ ។

៣- ជនគ្រប់រូបដែលមានឋានៈដ៏ខ្ពង់ខ្ពស់ គួរលះបង់អំពើ សាងសេចក្តីសុខផ្ទាល់ខ្លួន លើគំនរទុក្ខនៃហ្វូងមនុស្សជាតិជាអនេក ។

៤- មានតែលុះក្នុងព្រះធម៌ គឺមានជំនឿដោយឥតបន្ថែមបន្ថយលើព្រះពុទ្ធសាសនាទេ ទើបនាំអោយកើតសន្តិភាព អស់ក្តីច្រណែនគុំគួនគ្នាទៅវិញទៅមក ។

ព្រះធម៌ជាគុណធម៌ដ៏ឧត្តមមាន ៥ ៖

១- បាណាតិបាត : កុំសម្លាប់ ឬ ប៉ុនប៉ងនឹងសម្លាប់

២- អទិន្នាទាន : កុំលួចកុហក ឬ ប៉ុនប៉ងនឹងលួចគេ

៣- មុសាវាទ : កុំធ្វើអោយប៉ះពាល់ដល់កិត្តិយសអ្នកដទៃ

៤- កាមេសុមិច្ឆាចារៈ កុំសេពមេថុនជាមួយកូន ប្រពន្ធគេ

៥- សុរាមេរយៈ : កុំសេពសុរានាំអោយវង្វេង

៥- តម្លៃនៃបុគ្គលដែលស្ថិតនៅទីខ្ពស់ លើអ្នកដទៃ គឺការយល់ដឹងពីទុក្ខលំបាក ដែលកើតមានពិតៗ ហើយចេះស្វែករកឱសថមកជួយរំងាប់នូវសេចក្ដីឈឺផ្សារទាំងនោះ អោយបានសះស្បើយទៅវិញ។

សន្តិភាពមិនមែនមានន័យថា ជាសុខភាពឥតមានទំនាស់នោះទេ តែវិធីសាស្ត្រនៃការដោះស្រាយទំនាស់នោះទេ ដែលជាឱសថសំខាន់ ក្នុងការអភិវឌ្ឍន៍សង្គមរបស់មនុស្ស ។ តើគួរបណ្ដោយអោយសេចក្ដីក្រេវក្រោធបោះទីតាំងនៅពួជផ្ទៃក្នុងរបស់ជនទាំងឡាយ ឬយ៉ាងណា ?

៦- ជាតិមួយមានវប្បធម៌មួយ ។ បេតិកភណ្ឌប្រាសាទ គឺជាផ្នែកមួយដ៏សំខាន់នៃវប្បធម៌ខ្មែរ ។ ទាំងទស្សនៈ និង អំពើប្រព្រឹត្តក្នុងកិច្ចការពារវប្បធម៌ ផ្នែកបេតិកភណ្ឌប្រាសាទ ជាកាតព្វកិច្ចរបស់ជនខ្មែរគ្រប់រូប ។ ព្រះបាទជ័យវរ្ម័នទី ៧ និង វីរៈបុរសខ្មែរដ៏ឧត្ដម បានអំពាវនាវសូមអោយខ្មែរគ្រប់រូបចូលចិត្តថែរក្សាស្នាដៃទាំងនោះ គឺថែរក្សាប្រជាជនខ្មែរទាំងមូល ។ ព្រះអង្គទ្រង់បួងសួងអោយជនទាំងឡាយដែលចេះស្រឡាញ់ ការពារមរតកទាំងនោះ បានទៅដល់ទីផុតទុក្ខ ពេកភ័យ ព្រមដោយក្រុមញាតិប្ដី ប្រពន្ធ និង មិត្តភ័ក្កទៀតផង ។

៧- បេតិកភណ្ឌវប្បធម៌ មានតាំងពីរបៀបរស់នៅ ស៊ីចុក ស្លៀកពាក់ របាំ ចម្រៀង គឺអ្វីដែលមនុស្សជំនាន់មុនបង្កើតមក ដើម្បីជីវិតរស់របស់សង្គម គឺជាអត្តសញ្ញាណរបស់ជាតិ ។ តើយើងគួរបណ្ដែតបណ្ដោយអោយអត្តសញ្ញាណនេះ រលាយបាត់បង់ទៅដោយសារព្យុះកំណាច នៃការរីកចំរើនខាងបច្ចេកទេស ដែលកំពុងហូរចូលយ៉ាងសន្ធោរសន្ធៅនាសព្វថ្ងៃនេះ ឬ យ៉ាងណា ?

៨- បើវប្បធម៌រលត់ ជាតិក៏រលាយដែរ

សូមអោយទិវាវប្បធម៌ជាតិលើកទី ១ ទិវាវប្បធម៌សន្តិភាព បានជាផ្នែកមួយ នៃទិសដៅអភិវឌ្ឍន៍សង្គមជាតិទាំងមូលទៅអនាគត ។

# ផ្នែករូបថត

ក្រុងអង្គរបុរី ឈ្មោះដើម "នរៈវរៈនគរ" ស្ថិតនៅភូមិតុកថ្នុក ឃុំតុកថ្នុក ស្រុកអង្គរបុរី ខេត្តតាកែវ



ទិដ្ឋភាពមើលពីចម្ងាយ ពីទិសខាងកើតទៅខាងលិច ភ្នំដានេះ បើនៅខែវស្សាខ្សែទឹកជន់ឡើងដល់ជើងភ្នំ មើលទៅស្អាតណាស់ (រូបថតទី១)



ប្រាសាទភ្នំដា

កាលបរិច្ឆេទ: បឋមកំណើតកសាងនៅសតវត្សទី៦ ហើយត្រូវបានសាងឡើងវិញនៅចុងសតវត្សទី១១

ស្តេចស្ថាបនិក: ឧទ័យាទិត្យវរ្ម័នទី២

ជំនឿសាសនា: ព្រហ្មញ្ញសាសនា (និកាយសិវៈនិយម)

ច្រកទ្វារចូលនេះគឺនៅចង្កេះភ្នំដា កាលពីជំនាន់នោះគេបោះភ្នំធ្វើជាប្រាសាទក្រាប់ផណ្ណា មានលយ (ជាឃឿ) ចេញពីក្រៅភ្ជាប់នឹងរូងភ្នំមួយខាងក្នុងគេពាក់ព័ន្ធជាទម្រយោនិ និងលិង្គពីលើ។

(រូបថតទី២)

ប្រាសាទព្រះគោកសាងនៅចុងស.វទី៩ ដោយព្រះបាទឥន្ទ្រវរ្ម័នទី១ ឧទ្ទិសដល់បុព្វបុរសរបស់ព្រះអង្គ



ទិដ្ឋភាពមើលពីកើតទៅលិច (រូបថតទី៣)

<u>រូបទ្វារបាល</u>

តាមជញ្ជាំងថែវតូប៉មប្រាង្គប្រាសាទអំពីឥដ្ឋ
ឃើញតួប៉មតែជញ្ជាំងឥដ្ឋ គេស្រទាបបាយអ
និងរចនាក្បូរក្បាច់យ៉ាងស្អាត តួប្រាសាទអំពីឥដ្ឋ
គេស្រឡាយកំបោរបាយអ រូចប្រាសាទពណ៌ស
(រូបថតទី៤)



ប្រាសាទបាគងកសាងនៅចុងស.វទី៩ ដោយព្រះបាទឥន្ទ្រវរ្ម័នទី១ ឧទ្ទិសដល់ស្រី ឥន្ទ្រេស្វរៈ



ទិដ្ឋភាពៈមើលពីកើតទៅលិច (រូបថតទី១)



ទិដ្ឋភាពមើលពីលើប្រាសាទ ពីលិចទៅកើត

(រូបថតទី២)

រូបចម្លាក់នៅប្រាសាទបាគង ត្រង់ជណ្តើរឡើងខាងត្បូងចំហៀងខាងកើត



រូបចម្លាក់នេះគួរឱ្យចាប់អារម្មណ៍ មានរូបយក្សមុខគួរឱ្យខ្លាច សក់កន្ទ្រើង ភ្នែកលាន រង្វះមាត់ទំ១ យក្សមួយដៃស្តាំព័ទ្ធទៅក្រោយ ដៃឆ្វេងកាន់ដាវ សំលឹងមើលយក្សដូចគ្នា (រូបថតទី៧)



តាមជញ្ជាំងនៃខឿនគឺមានរឿងរ៉ាវផ្សេង១ ត្រូវលុបគួរឱ្យស្តាយ ព្រោះនៅហាលថ្ងៃ ហាលភ្លៀង-ខ្យល់ បណ្តាលឱ្យស៊ឹករិចរឹលគ្មានសល់ ។ ជាបទពិសោធន៍ក្នុងការកសាងប្រាសាទអំពីថ្មភក់ ឆ្លាក់រូបលំអ គ្មានដំបូលគ្របពីលើ (រូបថតទី៨)

ប្រាសាទក្រវាន់កសាងមួយភាគ៤នៃស.វទី១០ (គ.ស ៩២១) កសាងដោយព្រះបាទហស៌វរ្ម័នទី១ ឧទ្ទិសដល់ព្រះសិវៈ



តួប៉មប្រាង្គប្រាសាទអំពិគដ្ឋ សាងតម្រៀបគ្នាជើង-ត្បូង ចំនួន៥តួប៉ម (រូបថតទី៩)



វិស្ណុដៃ៤ ជិះលើសត្វគ្រុឌ (រូបថតទី១០)



ទេវរូបភេទស្រីម្នាក់យកផ្កាឈូកទ្រជើងនាងលក្ស្មី ឃើញខ្សែទឹករលកអង្គាញ់១ក្នុងសមុទ្រកាលវិស្ណុគ្រាច់នៅក្នុងត្រៃភព (រូបថតទី១១)

ប្រាសាទបក្សីចាំក្រុង កសាងឆ្នាំ៩៤៧ ក្នុងរជ្ជកាលព្រះបាទហសិវរ្ម័នទី១
ជាព្រះរាជបុត្ររបស់ព្រះបាទយសោវរ្ម័នទី១ ។
ប្រាសាទនេះកសាងមិនទាន់រួច ត្រូវបានព្រះបាទរាជេន្ទ្រវរ្ម័ន បន្តកសាងបង្ហើយ ។



ប្រាសាទនេះត្រូវគ្រប់ដណ្ដប់ដោយភ្នំធម្មជាតិផ្នែកខាងត្បូង និងព្រៃព្រឹក្សាផ្នែកខាងជើង
ទិដ្ឋភាពមើលពីកើតទៅលិច (រូបថតទី១២)

ប្រាសាទបន្ទាយស្រី កសាងឆ្នាំ៩៦៧ ក្នុងរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័នទី២ និងព្រះបាទជ័យវរ្ម័នទី៥



ទិដ្ឋភាពរួមក្នុងកំពែងទី២ (រូបថតទី១៣)



តួប៉មប្រាសាទបន្ទាយស្រី ទាំងបី សាងនៅលើខឿនតែមួយ តំណាងឱ្យព្រះព្រហ្មញ្ញសាសនា:

- ខាងជើងតំណាងឱ្យព្រះវិស្ណុ
- កណ្តាលតំណាងឱ្យព្រះសិវៈ
- ខាងត្បូងតំណាងឱ្យព្រះព្រហ្ម

(រូបថតទី១៤)

ប្រាសាទអង្គរវត្ត កសាងឆ្នាំ១១១២-១១៥២ ក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី២ ឧទ្ទិសថ្វាយដល់ព្រះវិស្ណុ



ទិដ្ឋភាពមើលពីខាងលិចទៅកើត មើលបញ្ឆិតឃើញកំពូល៥ (រូបថតទី១៥)



ប្រាសាទអង្គរវត្ត ទិដ្ឋភាព[illegible] (រូបថតទី១៦)



រូបចម្លាក់រឿងរាមកេរ្តិ៍
ព្រះរាមជិះលើសុគ្រិព ដៃឆ្វេងកាន់ធ្នូ ដៃស្តាំកាន់ព្រួញបី សុគ្រិពជាជំនិះ ដៃស្តាំទ្រភ្នំ ហោះបំរុះហោះសត្រូវ ដៃឆ្វេងចង្អុលត្រង់ទៅទ័ពរបស់ក្រុងរាពណ៍ ។ ពីក្រោយគឺ ព្រះលក្សណ៍ជាប្អូន និងពិភេកអសុរ ជាហោរាសាស្ត្រសម្រាប់ទស្សទាយការចំបាំង ។
(រូបថតទី១៧)



ក្សត្រិយ៍អង្គុយលើទេន និងស្រីស្នំស្អាតអង្គុយចាំក្លួស់ និងបក់ផ្លិតឱ្យ (រូបថតទី១៨)

ប្រាសាទបន្ទាយសំរែ កសាងនៅដើមសតវត្សទី១២



ទិដ្ឋភាពមើលពីស្ពានហាលខាងកើតមកលិច

(រូបថតទី១៥)

ប្រាសាទបន្ទាយសំរ៉ែ កសាងនៅដើមសតវត្សទី១២



តួប៉មនៃប្រាសាទកណ្ដាល មើលផ្ទាក់ជ្រុង (រូបថតទី២០)

ប្រាសាទធម្មានន្ទ កសាងនៅចុងសតវត្សទី១១ និងពាក់កណ្ដាលទី១នៃសតវត្សទី១២ រចនាបថអង្គរវត្ត ឧទ្ទិសថ្វាយព្រហ្មញ្ញសាសនា ។ ប្រាសាទនេះស្ថិតនៅខាងកើតក្លោងទ្វារជ័យ



(រូបថតទី២១)

ប្រាសាទចៅសាយទេវតា ស្ថិតនៅខាងត្បូងថ្នល់ តាមបណ្ដោយផ្លូវវង់តូច ខាងកើតក្លោងទ្វារជ័យ



(រូបថតទី២២)

ប្រាសាទប៉ាលីល័យ

កសាងនៅចុងសតវត្សទី១២ និងដើមស.វទី១៣

ដោយព្រះបាទជ័យវរ្ម័នទី៧ ។

ឧទ្ទិសថ្វាយ ពុទ្ធសាសនាមហាយាន ។ ប្រាសាទនេះ

ត្រូវរងគ្រោះដោយសារធម្មជាតិ និងការបំផ្លិចបំផ្លាញ

របស់ជនទុច្ចរិត បណ្ដាលឱ្យខ្ទិចខាត ។

(រូបថតទី២៣)





ព្រះវិហារវត្តទេពប្រណម

ព្រះពុទ្ធបដិមា នាម ទេពប្រណម



ព្រះទេពប្រណម ស្ថិតនៅខាងកើតប្រាសាទបាំលិល័យ ខាងជើងលានស្តេចគំលង់ ព្រះពុទ្ធអង្គ អង្គនេះខ្វាំងពូកែ ក្នុងជំនាន់ប៉ុល ពត ដាក់មិនកំទេចឆេះ តែព្រះវិហារ រីឯតួអង្គព្រះពុទ្ធបដិមាមិនមានការខូចខាត

(រូបថតទី២៤)

ប្រាសាទបាយ័ន កសាងនៅចុងស.វទី១២ ដើមទី១៣ (គ.ស ១១៨២-១២២០)

ក្រោមរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ឧទ្ទិសថ្វាយពុទ្ធសាសនាយាន



ប្រាសាទបាយ័ន មើលពីត្បូងទៅជើង (រូបថតទី២៥)



ប្រាសាទបាយ័ន (ទិដ្ឋភាពមើលផ្ទាក់ជ្រុង) (រូបថតទី២៦)

រូបចម្លាក់នៅតាមជញ្ជាំងថែវខាងក្រៅរបស់ប្រាសាទបាយ័ន



បារក្សរបុរោហិតកំពុងតែចូលគាល់ស្ដេចនៅក្នុងវាំងជាន់ខាងក្រោមឃើញមានរូបសត្វគ្រប់ប្រភេទ (រូបថតទី២៧)



ល្បែងហត្ថពលកម្ម "ល្បែងសៀកខាងល្ខោនិង" (រូបថតទី២៨)

ប្រាសាទព្រះខ័ន កសាងនៅពាក់កណ្តាលទី២ស.វទី១២ (គ.ស ១១៩១)
ក្រោមរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ឧទ្ទិសថ្វាយលទ្ធិពុទ្ធសាសនានិកាយថេរវាទ



គោបុរៈខាងត្បូង "កំពែងខាងក្រៅ" មើលពីជើងទៅត្បូង (រូបថតទី២៩)



ផ្តែរលើប្រអប់ទ្វារនៃរោងរាំ (ផ្នែកខាងកើត) (រូបថតទី៣០)



ទិដ្ឋភាពមើលថ្នាក់ជ្រុង (ផ្នែកខាងត្បូងបង្អស់) (រូបថតទី៣១)



ប្រាសាទសួរព្រ័ត្រ កសាងនៅចុងបញ្ចប់ស.វទី១២ (គ.ស១១៨១-១២០១) រជ្ជកាលព្រះបាទជ័យវ័រ្មនទី៧ (រូបថតទី៣២)

លានជល់ដំរី កសាងនៅស.វទី១២ រជ្ជកាលព្រះបាទជ័យវរ្ម័នទី៧
សំណង់ជារបៀបវេទិកាគ្មានដំបូល លាតសន្ធឹងប្រវែង៣០០ម៉ែត្រ (ខាងជើង)



រាជពិធីទីព្រះលាននៅចំមុខក្លោងទ្វារខាងកើតនៃប្រាសាទភិមានអាកាស
ទិដ្ឋភាពមើលចំពីខាងកើតខាងលិច (រូបថតទី៣៣)



រូបលោកេស្វរៈតំណែងខ្លួនជាសេះពាលហ ស្ថិតនៅផ្នែកខាងជើងក្បែរលានស្ដេចគំលង់
ឡើងលើជណ្ដើរមុខខាងកើតនិងឃើញនៅជញ្ជាំងខាងក្នុង (រូបថតទី៣៤)

ឈានដល់ដីរ៍ កសាងនៅពាក់កណ្ដាលស.វទី១២ ដើមស.វទី១៣ (គ.ស ១១៨៦)
រជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ឧទ្ទិសថ្វាយពុទ្ធសាសនាមហាយាន



ប្រាសាទតាព្រហ្ម រោងទងទី៣
ទិដ្ឋភាពមើលពីខាងលិចខាងកើត ត្រង់គោបុរៈខាងលិច (រូបថតទី៣៥)

ប្រាសាទភ្នំក្រោម កសាងនៅចុងស.វទី៩ និងដើមទី១០ រជ្ជកាលព្រះបាទយសោវរ្ម័នទី១ ឧទ្ទិសថ្វាយព្រះសិវៈ



ទិដ្ឋភាពមើលពីខាងលិច (រូបថតទី៣៦)



ទិដ្ឋភាពមើលពីលើភ្នំ ឃើញទឹកទន្លេជន់តាមផ្លូវ ឃើញផ្ទះបណ្តែតទឹក (រូបថតទី៣៧)

ប្រាសាទបាពួន (ឈ្មោះដើម: ហេមាទ្រិ ភ្នំមាស) កសាងនៅស.វទី១១ (គ.ស ១០៥០-១០៦៦)
រជ្ជកាលព្រះបាទឧទ័យាទិត្យវរ្ម័នទី២



ប្រាសាទបាពួន
ទិដ្ឋភាពមើលពីកើតទៅលិច ស្ពានហាលទ្រដោយជើងសសរម្ជូរ (រូបថតទី៧៨)



រូបចម្លាក់ដែលរចនាជាចម្លាក់រូបតូចៗនៅតាមជញ្ជាំងនៃប្រាសាទ

(រូបថតទី៣៩)

ប្រាសាទតាកែវ កសាងនៅដើមស.វទី១១ រជ្ជកាលព្រះបាទជ័យវរ្ម័នទី៥ និងព្រះបាទសុរ្យទី១



ទិដ្ឋភាពមើលពិលិចទៅកើត (រូបថតទី៤០)

ប្រាសាទតំបន់ភ្នំត្នូលែន ក្បាលស្ពាន ក្នុងភូមិខ្នាររង្វាស់ ឃុំឃុនរាម ស្រុកបន្ទាយស្រី
ក្នុងចំណុចផែនទីខ្សែបណ្តោយ ១៥១៣០០០ និងខ្សែទទឹង ៣៩៤០០០



ទួលអារាមរោងចិន (រូបថតទី ៤១)



ប្រាសាទរោងចិន (រូបថតទី៤២)







ប្រាសាទតាសោម (មើលរូបទី ៤៣, ៤៤ និង៤៥)



ទិដ្ឋភាពគូបំមប្រាសាទកណ្តាល ( ដើមឈើដុះនៅលើកំពូលប្រាសាទ) (រូបថតទី ៤៦)



ទិដ្ឋភាពមើលពីលិចទៅកើត ( ត្រង់គោបុរៈខាងលិច រោងទងទី២) (រូបថតទី៤៧)

# ឯកសារបន្ថែម

# ស្តីពី

# រមណីយដ្ឋានប្រាសាទ វត្តអារាម

# ពុទ្ធបដិមា និង រឿងព្រេងនិទាន

ពុទ្ធសាសនបណ្ឌិត្យ បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

# អំពីរមណីយ៍ដ្ឋានខេត្តសៀមរាប

យើងទាំងអស់គ្នា ត្រូវយល់អោយច្បាស់កុំអោយច្រឡំ ហេតុអ្វីបានជាដាក់ឈ្មោះ ខេត្តសៀមរាប តាមទស្សនៈថៃ ( សៀម ) ថា ខេត្តសៀមរាប ជាខេត្តមួយរបស់ប្រទេសថៃ ( មិនត្រឹមត្រូវទេ ) ។

ជំនឿត្រូវយល់ថា យ៉ាងដូចខ្មែរយើងធ្លាប់ហៅថា ខេត្តនេះជាខេត្តសៀមរាប ក្នុងកំឡុងឆ្នាំ ១៨៣៤-១៩០៦ សៀម បានវាយយកតំបន់អង្គរកាន់កាប់ ហើយស្តេចក្រុងកម្ពុជាបានលើកទ័ពទៅច្បាំង ( ភូមិភាគលើកទី ១ ) ស្តេចអង្គឌួងទី ១ អោយកាត់បាន ៥០ឆ្នាំ ( ១៩០៥-១៩៥៥ ) បានវាយសៀមខ្ចាត់ខ្ចាយពីតំបន់អង្គរ ហើយដាក់ឈ្មោះតំបន់នោះថា ( សៀមរាប ) ត្រឡប់ទៅលង្វែកឆ្នាំ ១៥៥៤ ។

<u>គោលការណ៍នាំមុខក្នុងការរៀបចំបែងចែកខេត្តសៀមរាបជាក្រុងថ្មី</u> :-

១- ទីក្រុងចាស់ ( តំបន់អង្គរ ) Ville autantique ទុកនៅជាសភាពដើម ។

២- ទីក្រុងសព្វថ្ងៃ ( Ville traditionnel ) មិនត្រូវសង់អាគារខ្ពស់ៗទេ ដែលធ្វើអោយប៉ះពាល់សោភ័ណ្ឌភាពអង្គរ ត្រូវកំណត់ព្រំប្រទល់ការសាងសង់សណ្ឋាគារ ត្រូវអោយឆ្ងាយ ហើយពង្រីកក្រុងទៅទិសខាងត្បូង អោយឆ្ងាយពីតំបន់អង្គរ ( ជាក្រុងចាស់ ) ។

៣- ទីក្រុងថ្មី ( Ville moderne ) សាងសង់នៅ ( សសរស្តម្ភ ) ស្រុកពួក ឬ ក្រឡាញ់ ដើម្បីជីវភាពរស់នៅរបស់ប្រជាជនខ្ពស់ ( ក៏ដូចជាវិធីរកចំណូលជូនរាជរដ្ឋាភិបាលបានច្រើន ) ម្យ៉ាងធ្វើអោយភ្ញៀវមកស្នាក់នៅបានច្រើនថ្ងៃ ។

<u>រមណីយ៍ដ្ឋានខេត្តសៀមរាប</u> :

ខេត្តសៀមរាប ជាខេត្តមួយតូចក្នុងកម្ពុជរដ្ឋ បើនិយាយពីទីកន្លែង ជារមណីយ៍ដ្ឋានមិនមានបណ្តាក្រុង ខេត្តណាយកឈ្នះខេត្តសៀមរាបបានឡើយ ។

ខេត្តសៀមរាប មានផ្ទៃដីសរុបចំនួន ១៥.២៧០គម$^2$ = ១.៥២៧.០០០ហិចតា មានចែកចេញជាប្រភេទដីដូចខាងក្រោម :-

- ផ្ទៃដីបង្កបង្កើនផល : ២៥៣.៧០០ ហិចតា
- ផ្ទៃដីទំនេរ : ៣១៥.៩០២ ហិចតា
- ផ្ទៃដីលំនៅដ្ឋាន : ១៩២.៤៤៦ ហិចតា
- ផ្ទៃដីព្រៃ : ៧៦៤.៩៥២ ហិចតា

ប្រជាជនមានចំនួន ៦៨៨.២១០នាក់ ក្នុងនោះមានស្រីចំនួន ៣៣៤.០១៦នាក់ ត្រូវជា ១២០.៣៩៧ គ្រួសារ មានស្រុកចំនួន ១៤ ឃុំចំនួន ១០៨ និង ភូមិចំនួន ៩១៤ ភូមិ គិតទៅដើមឆមាសទី ១ ឆ្នាំ ១៩៩៦ ។

<u>អំពីព្រំប្រទល់ខេត្តសៀមរាប</u> :

- ខាងកើតទល់ និង ខេត្តកំពង់ធំ

- ខាងលិចទល់ នឹង ខេត្តបន្ទាយមានជ័យ
- ខាងជើងទល់ នឹង ភ្នំដងរែក
- ខាងត្បូងទល់ នឹង បឹងទន្លេសាប

- មានស្ទឹងមួយ ដែលមានប្រភពមកពីភ្នំគូលែន គឺកាត់ពីជើងទៅត្បូង មានផ្លូវនៅត្រើយសងខាង ប្រកបដោយព្រៃព្រឹក្សា ជាជំលាំ មានស្លឹកខៀវខ្ចី មានម្លប់ត្រជាក់ត្រឈឹងត្រឈៃ គួរជាទីកំសាន្ត ។

- នៅរដូវប្រាំង ទឹកស្ទឹងថ្លាឈ្វង់ រែងបន្តិច ទឹកហូររែ១ មើលឃើញខ្សាច់នៅបាតស្ទឹងល្អណាស់ មានកន្លែងខ្លះដីដុះបណ្ដាលអោយគោក ( ចាប់ពីស្ពានថ្មខាងលើមកដល់ស្ពានវត្តបូព៌ ) ។

នៅរដូវវស្សា ពេលមានភ្លៀងធ្លាក់ច្រើន ទឹកនាំហូរចាក់មកស្ទឹង បណ្ដាលអោយស្ទឹងសៀមរាបពេញប្រៀបមាត់ច្រាំង ហូរយ៉ាងលឿនឆ្ពោះទៅទិសខាងត្បូងចាក់បឹងទន្លេសាប ផ្នែកខាងក្រោមចាប់ពីវត្តស្វាយទៅ គឺទឹកហូរកាត់ថ្នល់តែម្ដងបើមិនបានលើកភ្លឺអមថ្នល់ផ្នែកខាងលិចមាត់ស្ទឹងទេនោះ ។

- ស្ទឹងនេះពីដើម ត្រើយខាងកើត គឺមានផ្ទះរបស់ប្រជាជនរស់នៅក្បែរមាត់ស្ទឹង ពីដើមមានទូក កាណូតតូច១ដឹកកាវ៉ាន់យកមកលក់នៅផ្សារចាស់យើងសព្វថ្ងៃបាន ( នៅខាងកើតផ្សារខាងលិចខាងត្បូងវត្តដំណាក់ ) គឺមានកូនកោះមួយទឹកហូរតាមប្រឡាយឆ្វេលកោះនោះ មកចូលស្ទឹងវិញ បច្ចុប្បន្ននេះ លក់បានដីក និង លើកទំនប់ធ្វើស្រះ ស្ទើរតែបាត់ដានអស់ហើយ ។

- ដោយថា បរិស្ថាននៅទីនោះមិនស្អាត រាជរដ្ឋាភិបាលបានលើកគោលការណ៍ដោះស្រាយរបបគោលនយោបាយអោយប្រជាជនរើលំនៅដ្ឋានចេញពីមាត់ស្ទឹងអស់ទៅ ។

- មុនឆ្នាំ ១៩៧០ កាលមិនទាន់មានទំនប់ក្រពើ ទឹកស្ទឹងសៀមរាបហូរទៅក្រោមជាប្រចាំ ប្រជាជនដែលរស់នៅក្បែរដងស្ទឹង គេនិយមប្រើរហាត់ទឹក ដោយបោះបង្គោលកាត់ស្ទឹងដាក់របាំងទឹក ទុកមួយច្រកចំមុខរហាត់ទឹក អូសរហាត់វិលខ្លាំង។ ឯរហាត់ គឺគេបោះបង្គោលសសរក្រាក់ ៤ ដើម្បីដាក់ដុំរហាត់ ( ដូចដុំរទេះគោ ) មានកាំវែង១នៅចុងកាំ គឺមានស្នាបសំរាប់កាប់ទឹកនៅចុងស្នាប គឺគេរុំព័ទ្ធដោយរចាប្ញស្សី និង ដាក់បំពង់ពេលរហាត់វិលទៅ គឺជ្រមុជដងទឹកចាក់ទ ហូរតាមប្រឡាយទៅស្រោចដំណាំក្នុងភូមិគេយ៉ាងស្រួល ( នេះជាវិធីបូមទឹកមិនពិបាកប្រើថវិកា ) ។ ភ្ញៀវទេសចរណ៍ជាតិ និង អន្តរជាតិតែងចំណាប់អារម្មណ៍ទៅមើលរហាត់ណាស់ គាប់ជួនពេលខ្លះ អែបរហាត់គឺមានបំពង់មុជទឹក គេឃើញនារីស្អាតចងពុងដងទឹកមុជលើស្ពានជាក់រាជ់លយទៅក្នុងទឹក នេះជាទំនៀមទំលាប់ និង ជាប្រពៃណីរបស់ខ្មែរយើងជំនាន់នោះ រហូតលោកសិល្បករជាជាងគំនូរបាននាំគ្នាគូររូបទាំងនោះទៀតផង ។

- ក្នុងកំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ក្នុងរបបប៉ុល.ពត បានរៀបចំធ្វើទំនប់មួយកាត់ស្ទឹង ( ជាលក្ខណៈស្ពានដង ) បានធ្វើអាងក្រពើមួយនៅក្បែរនោះ ប្រមូលក្រពើពីវាលយន្តហោះថ្មី មកដាក់ចិញ្ចឹមទីនោះ ។

<u>ស្ទឹងសៀមរាបមានប្រភពហូរមកពីភ្នំគូលែន</u> :

នៅលើភ្នំគូលែន មានអក្សរចារឹកដើម សរសេរជាភាសាសំស្ក្រឹត បានដាក់ឈ្មោះថា " ភ្នំមហេន្ទ្រ " ជារាជធានីទី ១ ឈ្មោះ មហេន្ទ្របពត ( ភ្នំគូលែន ) ឆ្នាំ ៨០២ ក្នុងរាជព្រះបាទជ័យវរ្ម័នទី ២ ( គឺកម្រង់គេងជតតករាជ ប្រែថា ( អ្នកធំលើលោក គឺស្ដេច ) ។

បើជាភាសាសំស្ក្រិត ប្រែថា ( ទេវរាជ ឬ ស្តេចនៃអទិទេព ) ក្នុងព្រហ្មញ្ញសាសនា មានអទិទេពបីគឺ : សិវៈ វិស្ណុ និង ព្រហ្ម មានលំនៅដ្ឋាននិគប្រាកដ ( ភ្នំកៃលាស ព្រៃហេមពាន្ត ) ។

- កំពូលភ្នំគូលែននេះ មានភ្នំជាប់ៗគ្នា បើមើលពីចម្ងាយឃើញមានជួរលងភ្នំតែមួយ តែទៅដល់ជិត ឃើញភ្នំដោយឡែកៗពីគ្នា ។ ប៉ុន្តែលើភ្នំគូលែន មានស្ទឹងមួយធំ ដែលមានទឹកផុសចេញឡើង ហើយហូរចុះពីលើភ្នំ ដើម្បីស្រោចស្រពវាលរាបមកសៀមរាបអង្គរ ពោះស្ទឹងមានចំលាក់ជារូបលិង្គយ៉ាងច្រើន ហើយខ្សែទឹកហូរមានលេកអង្កាញ់ៗ ជាអចិន្ត្រៃយ៍ ( ដែលគេហៅថាក្បាលស្ពាន ឬ ក្បាលស្ទឹង ១០០០លិង្គ ) កន្លែងនេះ ជាកន្លែងងូតទឹកដ៏ពិសិដ្ឋ និង ជាកន្លែងសំរាប់គោរពបូជាក្នុងសាសនាតាំងពីបុរេ ( ភ្នំគូលែនមានកំពស់ ៣៧០ម ) ។

ប្រភពទឹកលើភ្នំគូលែនមានឈ្មោះថា :-

១- ជប់ថ្មដាប់

២- ជប់សំពៅប្លាយ

៣- អូរសង្កែឡាក់

៤- អូរតាភេញ

៥- អូរក្បាលជប់ និង ពាមត្រែបូន

ស្ទឹងនេះគេហៅថា ស្ទឹងឫស្សី ជាស្ទឹងមួយរបស់ស្ទឹងសៀមរាប គឺហូរចេញពីផ្នែកខាងលើភ្នំគូលែន ផ្នែកខាងកើតទំលាក់ជ្រោះដ៏សែនជ្រៅ ( ទឹកធ្លាក់ ) ហូរចម្ងាយ ៤គម និងដល់ទីបំបែកស្ទឹងសៀមរាប និងស្ទឹងរលួសនៅត្រង់ដើមអង្គញ់មួយធំ ដែលមិនអាចអោយទឹកហូរច្រើនទៅស្ទឹងរលួសខួបប្រាំងខួបវស្សា ទឹកមានតែរដូវវស្សា នៅពេលដែលមានទឹកជំនន់ តែរដូវប្រាំងគឺទឹកឯងអស់នៅពោះស្ទឹង ( មកពីដើមអង្គញ់នោះបាំង ) ។ ឯស្ទឹងសៀមរាប គឺមានទឹកហូរខួបប្រាំងខួបវស្សាបាន មិនរាំងស្ទះ និង ដើមអង្គញ់ទេ ។

<u>រមណីយដ្ឋានលើភ្នំគូលែន</u> :

មានស្រះដីបណ្តោយ ១៥០ម x ៧០ម ជម្រៅ ៣ម ក្នុងស្រះមានចំលាក់ថ្មជារូបដំរី រូបកង្កែប និង រូបគោ ។

<u>អំពីព្រះធំ</u> :

មានបរិវេណដី ៦០ម$^{២}$ បដិមារូបព្រះពុទ្ធអង្គធំមានប្រវែង ៩ម ទទឹង ២.៥០ម កាលបរិច្ឆេទមិនច្បាស់លាស់ ខ្លះនិយាយថា ក្នុងចន្លោះសតវត្សទី ១៣ ទៅសតវត្សទី ១៦ ។

<u>ទាលស្តេចគំលង់</u> :

ក្រាលថ្ម ៣ហិចតា នៅកណ្តាលមានអូ និង កន្លែងអង្គុយត្រាំព្យាបាលរោគឃ្លង់ ព្រមទាំងមានរន្ធភ្លូចៗដូចរន្ធបាយខុម សំរាប់ត្រាំដើមថ្នាំ ។

<u>ស្ពានសំពៅប្លាយ</u> :

មានបណ្តោយ ១គម ទទឹង ៧០ម នៅផ្នែកខាងលិចមានវាលថ្មទំហំ ៣ហិចតា និង ព្រះបាទមួយ ហើយមានត្រពាំងមួយទៀត មានបណ្តោយ ៣០ម x ២៥ម ត្រពាំងនេះឈ្មោះថា ត្រពាំងរោង មានសណ្ឋានដូចរោងជំឡូង ។

<u>ទាលប្រុសញ</u> :

មានទំហំ ៣ហិចតា នៅលើវាលនោះមានវិហារមួយ ដែលសង់អំពីឈើប្រក់ឈើ ( សតវត្សទី ៩ ) ។

<u>ទាលព្រះគ្រាប</u> :

មានទំហំ ៣គម$^{2}$ មានរូបចំលាក់ភ្ជាប់ជាប់នឹងពើងថ្ម ( ខ្មែរអោយឈ្មោះថា ពើងថ្មព្រះ ៥អង្គ ) ។

<u>នៅក្បែរនោះមានប្រាសាទចំនួន ១១ អំពីឥដ្ឋ</u> :

- ប្រាសាទអ្នកតា មានភូប្រាសាទ ២
- ប្រាសាទអូរថ្មដាប់
- ប្រាសាទខ្ទឹងស្វាប់
- ប្រាសាទដីក្រាប
- ប្រាសាទអូរថ្មុង
- ប្រាសាទអូរគួប
- ប្រាសាទក្រហម
- ប្រាសាទខ្នាឃ្មុំ
- ប្រាសាទតាដុង
- ប្រាសាទថ្មជ្រើញ
- ផ្ទាំងចំលាក់ជាអន្ទោលធំ១ ចំលាក់ព្រះ ៥អង្គ ចំលាក់ព្រះពាន់ និង ចំលាក់ពើងព្រះពុទ្ធ ។

<u>នីគ្រួខនគរធំ</u> :

ក្រុងជំនាន់នោះ គឺមានស្ទឹងចាស់មួយ ដែលមានស្លាកនៅរហូតដល់សព្វថ្ងៃនេះ កន្លែងខ្លះត្រូវលប់បាត់អស់ កន្លែងខ្លះមានបាតស្ទឹងនៅសល់ ។

- នៅសម័យកាលនោះ គឺគេប្រើនាវាធ្វើដំណើរតាមផ្លូវទឹក ( ទូក ក្បូន ឬ សំពៅ ) ពីដើមខ្សែក្រវ៉ាត់ទីក្រុង ឬ កំពង់ផែ មាន ៣គឺ :-

- វត្តចេតិយ៍
- វត្តអធ្វារ ( មានទួល កាមឿងនៅខាងលិចប្រាសាទវត្តអធ្វារ )
- វត្តព្រីន ឬ ទួលក្រពាំងផុង ( ខាងត្បូងប្រាសាទក្រពាំងផុង )

- ពីដើមទឹកជន់ខ្លាំង រាជចូលដល់វត្តអធ្វារតែម្តង កប៉ាល់ សំពៅពីប្រទេសក្រៅតែតែងចតតាមកំពង់ផែដូចជំរាបខាងលើ ។ ការដឹកជញ្ជូនទំនិញ គឺតាមស្ទឹងចាស់ពីបុរាណមួយ កាត់តាមសាលាកន្សែង នៅភូមិឃ្មៀនឆ្ពោះទៅកម្ភុ ( ជ្រុងខាងត្បូងខាងលិចកំពែងអង្គរធំ ) ព្រោះមានលូ ៥ ចេញពីជ្រុងខាងត្បូងខាងលិចកំពែងអង្គរធំ ( គេហៅថា រន្ធតាដែង ) ។

- ព្រោះនៅជ្រុងកំពែងខាងកើតខាងជើងមានលូ ៥ដែរ សំរាប់បញ្ចូលទឹកពីស្ទឹង ដែលហូរពីភ្នំគូលែនចូលក្នុងក្រុងនគរធំ ( យកទឹកសំរាប់ប្រើប្រាស់ ) ។

ស្ទឹងចាស់នេះ ពីដើមគឺមានទូក កាណូត ដឹកទំនិញចូលមកដល់ក្រុងនគរធំ ។ ស្ទឹងសព្វថ្ងៃនេះ គឺស្ទឹងដែលកើតក្រោយ ដែលគេបំបែរពីទីក្រុងនគរធំ កាត់តាមស្ពានថ្មខាងលិចប្រាសាទតាកែវ កាត់ត្រង់មកទិសខាងត្បូង ធ្លាក់ចូលបឹងទន្លេសាប

ក្រោយមកទៀត ស្ពានថ្មមិនអាចហូរទឹកបានស្រួល គេបំបែរទៅខាងកើតបន្តិចវិញ ( ខែប្រាំងគឺគោកអស់ ) ។ ស្ទឹងនេះពីដើម ទឹកជ្រៅ កាណូត ទូក អាចបើកបរចូលដល់ផ្សារចាស់សៀមរាបសព្វថ្ងៃ ។ លំនៅប្រជាជន គឺច្រើនទៅក្បែរៗមាត់ស្ទឹង ក្រោយមក សម័យកាលនោះ ឃើញបរិយាកាសតាមមាត់ស្ទឹងមិនស្អាត គេមានរបបគោលនយោបាយ គឺអោយរើផ្ទះចេញពីមាត់ស្ទឹងអស់ទៅ និយាយរួម ពីដើមគេមានប្រព័ន្ធធារាសាស្ត្រគ្រប់គ្រាន់ អាចធ្វើស្រែបាន ៣ដង ក្នុងមួយឆ្នាំ ព្រោះមានបារាយណ៍ជាឃ្លាំងទឹកធំៗ សំរាប់ធ្វើស្រែបាន ។

តាមខែដែលគេធ្វើស្រែ តាមបណ្តាឆ្នាំនីមួយៗ មានដូចខាងក្រោម :-

ពីខែ ដល់ខែ ធ្វើស្រែវស្សា

ពីខែ ដល់ខែ ធ្វើស្រែបញ្ចៀញទឹក

ពីខែ ដល់ខែ ធ្វើស្រែតំលើងទឹក

ភោគផលដែលធ្វើស្រែបាន ១ភាគ សំរាប់សេចក្តីត្រូវការរបស់ប្រជាជន ២ភាគ គឺនាំចេញក្រៅប្រទេស ។

ទីកន្លែងគួរទស្សនាតាមដងស្ទឹង :

ត្រើយខាងកើតស្ទឹង :

១- វត្តព្រះឥន្ទ្រកោសីយ៍ :

កំណើតវត្តនេះ គឺស្ថិតនៅក្នុងបរិវេណ ( មន្ទីរអភិរក្សអង្គរ ) គេអាចដឹងបានថា នៅខាងកើតផ្ទះថ្មបាយក្រៀម មានសល់ចេតិយ៍ចាស់ និង បង្គោលសីមាខ្លះៗរហូតដល់សព្វថ្ងៃ ។ ក្រោយមកបារាំង គេយកទីវត្តនេះ ធ្វើជាមជ្ឈមណ្ឌល ហៅថា (Centre d'acceuil ) សំរាប់ការទទួលភ្ញៀវអន្តរជាតិ ( ជនជាតិគេ ) ទើបគេអោយរើវត្តនេះទៅសាងសង់នៅខាងកើតស្ទឹងវិញ មានឈ្មោះថា វត្តលិ ។ ព្រោះវត្តនេះនៅខាងលើគេបំផុត ផ្នែកខាងកើតស្ទឹង ទើបគេដាក់ឈ្មោះវត្តនេះថា វត្តព្រះឥន្ទ្រកោសីយ៍ គឺជាពាក្យចាប់ចុងជូនទឹងពាក្យតំណពីវត្តព្រះឥន្ទ្រកោសា ម្យ៉ាងទៀតវត្តនេះមានប្រាសាទបុរាណសង់អំពីឥដ្ឋ ( ឈ្មោះប្រាសាទឥន្ទ្រកោសីយ៍ ) កសាងនៅឆ្នាំ ៩៦៨ ឧទ្ទិសថ្វាយព្រហ្មញ្ញសាសនា ( សិវៈនិយម ) ជួសជុលដោយលោក B.PH. Groslier នៅឆ្នាំ ១៩៧២ ពេលដែលខ្មែរក្រហមឈប់អោយចេញចូលអង្គរ ។

២- វត្តព្រះឥន្ទ្រកោសា :

- មានកំណើតមុនវត្តព្រះឥន្ទ្រកោសីយ៍ ចៅអធិការទី ១ ព្រះនាម ប៊ុម មានងារជាព្រះធម្មភាសា ជាមេគណខេត្ត បានដាក់ឈ្មោះថា វត្តឥន្ទ្រកោសា ។

៣- វត្តពោធិលង្កា :

- មានពុទ្ធបរិស័ទម្នាក់ បានយកដើមពោធិពីរដើមពីវត្តលង្កាក្រុងភ្នំពេញ ធ្វើដំណើរតាមទូក កាត់បឹងទន្លេសាបមកដល់ខេត្តសៀមរាប ។ យកមួយដើមទៅដាំនៅអង្គរវត្ត មួយដើមទៀតយកទៅដាំក្នុងដីមួយកន្លែងនៅខាងកើតស្ទឹង ទល់មុខវត្តលង្កាចាស់ ។ ព្រះសង្ឃ និង ពុទ្ធបរិស័ទបានកសាងវត្តថ្មីមួយនៅក្បែរដីមួយកន្លែង ដែលដាំដើមពោធិ យកមកពីវត្តលង្កាក្រុងភ្នំពេញ ហើយដាក់ឈ្មោះវត្តថ្មីនេះថា វត្តពោធិលង្កាដែរទៅ ។

៤- វត្តបូព៌ :

- វត្តនេះនៅខាងកើតស្ទឹង សម័យអាណានិគមសៀម មេទ័ពសៀមបានបោះបង្គោលលក្ខ ធ្វើជាព្រំសីមាកំណត់ព្រំប្រទល់ប្រទេសគេ ត្រង់ផ្លូវបំបែកផ្លូវជាតិលេខ ៦ បែកទៅភូមិកំពង់ឃ្លាំង គោលសីមានេះ សំរាប់ខ័ណ្ឌដែនដីផ្នែកខាងកើតបំផុត ។

- គោលវត្តនេះ មានចំណាស់ជាងគេ ដែលស្ថិតនៅទិសខាងកើតផង ទើបគេដាក់ឈ្មោះថា វត្តបូព៌ រហូតដល់សព្វថ្ងៃ។

- វត្តនេះ មានកំណើតប្រហែល ៣០០ឆ្នាំ ព្រោះវត្តនេះមានវិហារ និង ចំលាក់ផុសចេញល្អណាស់ នៅក្នុងវិហារមានគំនូរជាគំរាណ រឿងរាមកេរ្តិ៍ ដែលមានអាយុប្រហែលគ្នា និងរឿងរាមកេរ្តិ៍ ដែលគេគូរនៅតាមថែវ នៃព្រះវិហារព្រះកែវ ( ព្រះភាជរាំង ) សព្វថ្ងៃ ។

៦- <u>វត្តដំណាក់</u> :

ជាទីស្នាក់អាស្រ័យរបស់កងទ័ពសៀម សំរាប់ធ្វើសមយុទ្ធ និង ហ្វឹកហាត់ក្បួនយុទ្ធសាស្ត្រ វត្តនេះពីដើមមានផ្កាគួរ តែក្រោយមកនៅពេលដែលសៀមដណ្តើមយកបានខេត្តសៀមរាប បាត់ដំបងមានមេទ័ពម្នាក់ឈ្មោះ ប្រាក់យ៉ាពិស្ត មានភារកិច្ចត្រួតត្រាខេត្តបាត់ដំបង បានកសាង និង ពង្រីកវត្តនេះអោយធំទូលាយ ព្រមទាំងបានសាងកុដិ ដែលមានមេទ័ពជួយក្រុមឈរជើងនៅម្តុំភូមិទឹកវិល ភូមិនេះកាលពីដើមឈ្មោះភូមិ ( ជាត់អារាម ) វត្តដំណាក់នេះ មានចេតិយ៍ធំ១ខ្ពស់១ មានកូប្រាង្គ និង កំពូលជុំវអង្គរ នៅខាងកើតចេតិយ៍មានស្រះមួយយ៉ាងធំ នៅកណ្តាលស្រះមានគុហារមួយតូច មានស្ពានឆ្លងពីកើត នៅក្នុងគុហារនោះមានព្រះបាតព្រះអំពីថ្មភក់ ដែលយកមកពីប្រាសាទបាយ័នមកតំកល់ទុក ។ នៅមុខខាងកើតព្រះវិហារ មានរូបដីរអំពីថ្មភក់ពីរមុខខាងលិចមានគោពីរ អំពីថ្មភក់ វិហារនេះមានអាយុប្រហែល ៧២ឆ្នាំ ហើយសង់ដោយទេជាងអាំងឆាយ ត្រូវជាឪពុកលោកអាំងគីមឈាន វត្តនេះពីដើមគេនិយមតែអ្នកមានទេ ។

៧- <u>វត្តស្វាយ</u> :

កំណើតវត្តពីដើម ស្ថិតនៅគោកតាមល់ ( ទួលខាងកើតវត្ត ) ព្រោះចៅអធិការព្រះនាម តាខល់ ជាអ្នកផ្តើមបង្កើតវត្ត ជំនាន់ថៃចូលមកគេហៅថា ( លោកម្ចាស់អង្គរ ) ឬ ពញាអនុភាពក្រៃកព ។ ដោយគោកតាមល់មានទីធ្លាតូចមិនសមស្របជាទីវត្តអារាម ឧបាសកម្នាក់ឈ្មោះ ស្វាយ និង ភរិយាឈ្មោះ មាស មានសទ្ធាជ្រះថ្លា វេរប្រគេនដីកម្មសិទ្ធិរបស់ខ្លួនមួយកន្លែងជាប់នឹងត្រើយខាងកើតស្ទឹងសៀមរាប ( នៅខាងលិចគោកតាមល់ ) ប្រមាណ ៤០០ម$^{2}$ សំរាប់សង់វត្តថ្មី ។ ក្នុងបរិវេណវត្តថ្មីនេះ មានដើមស្វាយមួយដើម មានដើមកំណើតមុនពេលកសាងវត្តស្វាយ ដើមស្វាយនេះធំប៉ុនកង់រទេះ មានរាងកោងដូចសត្វដំរី គឺសុខសប្បាយហើយ ទើបសន្មត់ដាក់ឈ្មោះវត្តថា ( វត្តស្វាយសុវណ្ណផល្លា វង្សជ័យ ) ដល់ក្រោយៗគេហៅកាត់ថា វត្តស្វាយតែប៉ុណ្ណោះ ។

វត្តនេះមានព្រះវិហារ និង ចំលាក់រចនាល្អណាស់ក្នុងព្រះវិហារ គឺមានរឿងព្រះវេសន្ត ( មហាជាតក ) ស្អាតណាស់ដែរ ។ នៅខាងកើតវត្តមានមែនមួយធំ រាងដូចប្រាង្គប្រាសាទ ដែលមេគណៈវត្តនេះ កសាងឡើងក្នុងកំឡុងឆ្នាំ ១៩៦៣ សំរាប់បូជាសពលោកចៅអធិការវត្តស្វាយនេះ ។

៨- <u>វត្តកង់ម៉ិច</u> :

វត្តនេះផ្លាស់ចេញពីវត្តស្វាយ ព្រះតេជគុណ ចាប ពៅ បានដាក់ឈ្មោះថា ( វត្តមុនីសុវណ្ណ ) វត្តតង់ម៉ុច ជាឈ្មោះម្ចាស់ដីកម្មសិទ្ធិរបស់តា តង់ និង យាយ ម៉ុច ។

៩- <u>វត្តពោធិបន្ទាយជ័យ</u> : ( ឈ្មោះពីដើម វត្តពោធិអារក្ស )

ឧបាសកម្នាក់ឈ្មោះ ប្រេង បានវេរប្រគេនដីមួយកន្លែង សំរាប់កសាងវត្ត ដីនោះមានដើមពោធិមួយដើម គេដំកល់រូបអ្នកតា ឬ រូបអារក្សនៅនឹងគល់ពោធិនោះ លុះតំណរក្រោយមក គេបានបង្កើតវត្តមកនិងខាងត្បូងបន្តិច ។ វត្តពោធិអារក្សនេះបានក្លាយទៅជាវត្តពោធិបន្ទាយជ័យ ក្នុងពេលកងទ័ពវៀតណាមបានធ្វើដំណើរតាមទូកតាមទន្លេសាប ក្នុងគោលបំណងមកវាយយកក្រុងអង្គរ កងទ័ពនេះបានចេញដំណើរពីបន្ទាយក្រាម ( បច្ចុប្បន្ននេះគេហៅថា ឥន្ទ្រាយគម ) មកស្នាក់បន្តនៅម្តុំភ្នំក្រោម រួចរុលដំណើរមកបោះទីតាំងនៅវត្តពោធិអារក្ស ចំពោះកងទ័ពខ្មែរក្នុងសម័យនោះ បានប្រមូលទ័ពរបស់ខ្លួនមកទប់ទល់វាយបំបែកទ័ពវៀតណាមនេះខ្ចាត់ខ្ចាយ បានជ័យជំនះត្រង់ម្តុំវត្តនេះ ទើបគេប្រែឈ្មោះថា វត្តពោធិអារក្ស មកជាវត្តពោធិបន្ទាយជ័យវិញ ។

១០- <u>វត្តអារញ្ញសាគរ</u> :

វត្តនេះមានព្រៃលេចទឹកជុំវិញ ឧបាសកម្នាក់ជានាយកំពង់ឈ្មោះ ស៊ូរី មានកូនប្រុសពីរនាក់ :- កូនបងឈ្មោះ មិត្ត កូនប្អូនឈ្មោះ មាស បានវេរប្រគេនដីវាលស្រែហោផ្ទានជួយជុំវត្តខាងត្បូងមាន ២បន្ទាត់ ខាងលិចទល់នឹងស្ទឹង ខាងកើតទល់នឹងផ្លូវ ដីនោះមានបណ្តោយ ១៥០ម x ១០០ម ។ នាយកំពង់ស៊ូរី រស់នៅក្នុងរាជអង្គវៀម ជាជនជាតិខ្មែរ ដែលសៀមបានលើកបន្តប់អោយធ្វើជាស្តេចក្រាញ់ មានសិទ្ធិអំណាចអាចទៅចូលរួមប្រជុំនៅបាងកកបាន ។

- ក្រោយមកទៀត មានរាជ្យអង្គអុង អង្គមួង អង្គជាតិ នៅពេលដែលកងទ័ពបារាំងចូលមកវាយសៀមក្នុងស្រុកខ្មែរលើកទី ១ ស្តេចក្រាញ់នេះបានអស់អំណាច ទាហានបារាំងជួយកសាងវត្តនេះ និង បានកសាងកុដិថ្វាយព្រះសង្ឃខ្មែរ អំពីឥដ្ឋ និង តំបោះបាយអ ដែលមានកំពែងបួនជ្រុងផ្ទះនៅរបស់ប្រទេសគេ ។ ពេលនោះលោក ហង់រីម៉ាកសារ ក៏បានចូលចាប់កុសលច្រើនដែរ ។

ក្រោមការគ្រប់គ្រងរបស់ព្រះតេជគុណព្រះនាម ម៉ក់ បានសាងរូបដីខានកំពស់ ៤ម សំរាប់តំកល់រូបអ្នកតា សំរាប់បំរើការបួងសួងបទស្រន់ និង សួងស្បែស្រែងៗ ពេលនោះព្រះអង្គមានទំនាស់ជាមួយព្រះគ្រូ ចាប ពៅ ដីនេះមានឈ្មោះថា វណ្ណ សក្តិវណ្ណរាជ បានសន្និតព្រលឹងលើប្រជាជនភេទប្រុសម្នាក់ នៅភូមិអារញ្ញមានឈ្មោះ ឈឿង អាយុប្រមាណជាង ៥០ឆ្នាំ ។

១១- <u>វត្តភ្នំក្រោម</u> :

ឈ្មោះដើម ( វត្តចែងអង្គសេដ្ឋាមហាសេដ្ឋី ) ស្ថិតត្រង់ជើងភ្នំក្រោម ( ផ្នែកខាងជើងខាងលិច ) ចម្ងាយពីផ្លូវដីវង់ឆ្វេលជើងភ្នំទៅលិចប្រមាណ ២០០ម និង ដល់វត្តជើងភ្នំហើយ ។

១២ <u>វត្តភ្នំខាងលើ</u> :

ឈ្មោះដើម " វត្តព្រះព្រហ្មភ្នំចែង " ជាឈ្មោះដែលព្រះតេជគុណចៅអធិការវត្តព្រះព្រហ្មរតន៍ ព្រះនាមលំបាកដាក់ឈ្មោះអោយ ។ វត្តនេះស្ថិតនៅលើកំពូលភ្នំក្រោម ដែលមានកំពស់ប្រមាណ ១៣៧ម ។

- ដោយសារព្រះតេជគុណ ខៀវ មានទំនាក់ទំនងជាមួយព្រះតេជគុណ យុត ទើបគេបំបែកវត្តខាងក្រោមអោយទៅជាវត្តមួយទៀតនៅលើខ្នងភ្នំ ។ ព្រះតេជគុណ ប៉ិល បានរើរុះ និង ជួសជុលវិហារចាស់អោយមានភាពថ្មីឡើងវិញ ហើយព្រះសង្ឃអង្គនេះសុគតក្នុងមន្ទីរពេទ្យខេត្តសៀមរាប ក្នុងរបបលន់ ណុល ឯព្រះតេជគុណ យៀន សុគតលើខ្នងភ្នំទៅ ។

- នៅលើភ្នំ : មានប្រាសាទភ្នំក្រោម

កសាង : ចុងបញ្ចប់នៃសតវត្សទី ៩ ដើមសតវត្សទី ១០

រាជ្យស្តេច : យសោវរ្ម័នទី ១

ឧទ្ទិសថ្វាយ : ព្រហ្មញ្ញសាសនា ( សិវៈនិយម )

<u>បែបផែនប្រាសាទ</u> : ប្រាសាទនេះមានគោបុរៈ និង កំពែងព័ទ្ធជុំវិញមួយជាន់ ក្នុងនោះមានបណ្ណាល័យ និង តួប្រាសាទ ៣ សង់នៅលើខឿនតែមួយ តំណាងអោយអទិទេព ៣ ដែរ :

- តួប្រាសាទខាងជើង តំណាងអោយព្រះវិស្ណុ
- តួប្រាសាទកណ្តាល តំណាងអោយព្រះសិវៈ
- តួប្រាសាទខាងត្បូង តំណាងអោយព្រះព្រហ្ម

<u>សំភារៈ</u> :- សំណង់អំពីថ្មភក់ ថ្មបាយក្រៀម និង ឥដ្ឋ

ប្រាសាទនេះ មានភាពទ្រុឌទ្រោមជាងគេ ( ក្បូរក្បាច់ជាប់នឹងជញ្ជាំងប្រាសាទ ) ស្អាតណាស់ តួរចាប់ចិត្ត ត្រូវរបេះធ្លាក់មកភាល់ថ្ងៃ ថ្មក៏ត្រៀកទៀតផង ។

- ដោយសារអាយុកាល ខ្វះការថែរក្សាការពារអោយបានជាប្រចាំ ។

- ការខូចខាតដោយសារធម្មជាតិយាយី ត្រូវកំដៅថ្ងៃ ត្រូវខ្យល់ ត្រូវទឹកភ្លៀងរំហាយទឹកទន្លេរសាត់មកប៉ះភាល់ថ្ងៃ ។

- សត្វប្រចៀវសំរានៅ នោមជុះ ពេលរដូវភ្លៀងហូរស្រោចស្រពលើថ្ម ធ្វើអោយថ្មឆាប់ពុកផុយ ។

- ការដាក់ម៉ៀរ៉ា និង ឃ្មុនដុតយកថ្មភ្នំសំរាប់បំរើការសាងសង់ និង ធ្វើអោយប្រាសាទរង្គួយ ។

- ការខូចខាតដោយសារសង្គ្រាម កងទ័ពកែងឈរជើងលើភ្នំក្រោម ដាក់កាំភ្លើងធុនធ្ងន់បាញ់ធ្វើអោយប្រាសាទរង្គួយដូចគេដុតយកថ្មដែរ ។

១៣- <u>វត្តលង្កា</u> :

វត្តនេះស្ថិតនៅត្រើយខាងលិចស្ទឹង កាលពីដើមជាវត្តរបស់ព្រះសង្ឃខ្មែរ តែក្រោយមកបានប្រគល់វត្តនេះទៅអោយព្រះសង្ឃវៀតណាម ។ សង្ឃវៀតណាមពេលសូត្រធម៌ គេឈរក្បែររូបចំលាក់ក្បាលត្រីធ្វើអំពីឈើ ឈរសូត្របណ្តើរវាយក្បាលត្រីបណ្តើរ និង វាយឱ្លលស្គាន់មួយយ៉ាងធំឮសូររង៉ុំនៅពេលថ្ងៃ ឬ ពេលអាធ្រាតស្ងាត់ជ្រងំ មានបដិមារូបព្រះពុទ្ធជាច្រើនក្នុងវិហារ ។

- សង្ឃវៀតណាមទាំងនោះ ស្លៀកពាក់ខោអាវពណ៌លឿង ក៏ទបង្អាន់បួសមានពោត សណ្តែក ល្ង ជាដើម ។ មានពិធីបុណ្យរបស់គេខ្លះ១ ដូចជាបុណ្យសែនក្បាលទឹក ( ធ្វើបុណ្យភ្ជុំបិណ្ឌខ្មែរ ) បរិស័ទវៀតណាមដែលកាន់សាសនាក្បាលត្រីបានឡើងមកពីបឹងទន្លេសាបច្រើនកុះករក្នុងវត្តនេះ ដើម្បីប្រារព្ធធ្វើពិធីចែកទានបន្ថែមដល់អ្នកដទៃ ក្នុងវត្តយ៉ាងសប្បាយ ។

- វត្តនេះត្រូវខូចអស់ក្នុងសម័យសង្គ្រាមជំនាន់លន់.ណុល ឃើញនៅសល់បាតគ្រឹះ និង សសរដងទង់ តឡូវនេះត្រូវប្រជាជនវាយកំទេច ដើម្បីរៀបធ្វើភូមិម្ករបស់គេអស់ហើយ ។

១៤- <u>វត្តព្រះព្រហ្មរតន៍</u> :

ឧបាសកឈ្មោះព្រហ្ម និង ឧបាសិកាឈ្មោះ រតន៍ បានប្រគេនដីមួយកន្លែងដល់ព្រះសង្ឃ សំរាប់កសាងវត្ត និង ថ្វាយខ្លួនទាំងពីរបំរើដល់សាសនាតរៀងទៅ ។

- វត្តនេះរៀបចំបានសក្តិសមឡើង ដោយមេទ័ពសៀមម្នាក់ឈ្មោះ ប្រាក់ យ៉ា មហាក្សត្រសឹកក្នុងសម័យអាណានិគមរបស់គេ ។ កាលសម័យនោះមានដើមពោធិធំមួយដើម នៅជ្រុងនិរតីព្រះវិហារសព្វថ្ងៃ ហើយមានអាស្រមអ្នកតាមួយឈ្មោះ តាជ័យ វត្តព្រះព្រហ្មរតន៍ មានចំណាស់ប្រហាក់ប្រហែលគ្នា និង វត្តអង្គរ តែមានភាពថ្កើងថ្កានជាងវត្តទាំងពីរនេះ ។ វិហារពីដើមសង់អំពីឈើ តែដល់ខូចខាតខ្ទេចខ្ទីទៅ គេបានកសាងព្រះវិហារថ្មីនៅកន្លែងដដែលវិញ ឯព្រះធំសព្វថ្ងៃនេះ គេកសាងបល្ល័ង្កអាយខ្ពស់ សំរាប់តំកល់ព្រះធំតែម្តង ឯព្រះចូលនិពាន្តពីដើម នៅបាតព្រះវិហារស្មើនឹងព្រះធំពីដើមនេះ ។

- យើងគួតឆ្ងល់ដែរថា ព្រះចូលនិពាន្តពីដើមនៅស្មើនឹងព្រះអង្គធំ ពេលគេលើកព្រះធំតំកល់លើបល្ល័ង្កខ្ពស់ ម្តេចគេមិនលើកព្រះចូលនិពាន្តអោយស្មើទៅ មូលហេតុ គេមិនលើកអោយស្មើ ព្រោះកាលណារើរុះ វាបាត់ភាពដើម ព្រះពុទ្ធអង្គនេះគេរៀបអដ្ឋស្រឡាងបាយអរពីលើ ហើយលាបទឹកមាស ( ក្នុងតួព្រះមានអាថ៌កំបាំងច្រើនណាស់ ) ។

- វិហារនេះមានរូបព្រះចូលនិពាន្តមួយអង្គធំ ( ក្រោយបល្ល័ង្កព្រះធំ ) ព្រះពុទ្ធអង្គនេះមានទំនាក់ទំនង និងរឿងព្រេង ( ទូកចង្ហាន់ហុយ ) ក្នុងសម័យលង្វែក ស្តេចបានអោយគេយកដើមគគីរមួយដើម ដែលមានរិទ្ធិនុភាពមកធ្វើជាទូកសំរាប់ប្រើប្រាស់ក្នុងរាជធានី ។

- ពេលវង្សា អត្តរាជ តែងប្រើលោកតាព្រហ្ម និង យាយ មាស កេស យកចង្ហាន់ពីក្រុងលង្វែកមកប្រគេនព្រះសង្ឃនៅវត្តអង្គរ ក្នុងពិធីបុណ្យផ្សេងៗ ដូចបុណ្យភ្ជុំបិណ្ឌ ចូលឆ្នាំជាដើម ។ ដោយអុំកាត់បឹងទន្លេសាបយ៉ាងឆាប់រហ័សបំផុត គឺចេញដំណើរពីព្រលឹមយកចង្ហាន់មកដល់ទាន់ពេល ( ឆាន់ត្រង់ ) ចង្ហាន់នេះនៅក្តៅហុយពុំទាន់ត្រជាក់ឡើយ ។ ថ្ងៃមួយចេញដំណើរពីលង្វែកមកដល់កណ្តាលទន្លេសាប ជួបសត្វឆ្មាមួយ បំងយាយ៏ទូកតា និង យាយ តែពេលនោះយាយឃើញសត្វសាហាវនោះមុនស្រែកប្រាប់តាថា កុំប្រហែសអោយសោះ តាឆ្លើយថា យាយកុំបារម្ភ ទូកយើងមានបារមីតែមួយភ្លេតដល់ត្រើយហើយ ចៃដន្យអាក្រក់សត្វឆ្មាមនោះកាត់ទូកតា-យាយដាច់ជាពីរកំណាត់ មួយកំណាត់មុខរសាត់មកដល់ត្រើយក្រុងអង្គរ ។ មួយកំណាត់ខាងកន្សៃររសាត់ទៅក្រុងលង្វែកវិញ ។ ក្រោយមកគេបានរក្សាទូកនេះ ដោយកសាងជារូបព្រះពុទ្ធគង់ឈរស្រោបទូក ធ្វើជាស្នូលតំកល់ទុកក្នុងវិហារវត្តបរិបូណ៌ ( ខេត្តកំពង់ឆ្នាំង ) មួយកំណាត់ខាងក្បាល គេកសាងរូបព្រះពុទ្ធចូលនិពាន្តស្រោបទូកដូចគ្នា តំកល់ក្នុងព្រះវិហារវត្តព្រះព្រហ្មរតន៍ រហូតដល់សព្វថ្ងៃនេះ ។

១៥- <u>វត្តអធ្វារ</u> : ( វត្តនេះសង់ក្នុងបរិវេណរបស់ប្រាសាទអធ្វារ ) ប្រជាជននៅទីនោះបាននាំគ្នាកសាងវត្តមួយនៅខាងកើតប្រាសាទ ដាក់ឈ្មោះ វត្តអធ្វារទៅរហូតសព្វថ្ងៃនេះ ។

- តាមពុទ្ធដិកាព្រះតេជគុណ អ៊ុម ថា ជាទ្វារស្រុកក្នុងសម័យមហានគរ កាត់ត្រង់ប្រាសាទបាយក្អែក ( វាជាខ្សែក្រវ៉ាត់ការពារក្រុងនគរធំ ) មានកាណូត ទូក សំពៅឆ្លងកាត់បឹងទន្លេសាប មកពីខេត្តនានា ឬ មកពីប្រទេសក្រៅ កាលនោះទឹកទន្លេជោរជមកដល់ខ្សែក្រវ៉ាត់ក្រុងតែម្តង ។

- <u>ទ្វារទី ១</u> : នៅទួលតាមឿង ( ខាងលិចវត្តអធ្វារ )

- <u>ទ្វារទី ២</u> : នៅប្រាសាទបឹង ( ខាងលិចវត្តព្រៃន )

- <u>ទ្វារទី ៣</u> : នៅត្រពាំងផុង ( ខាងត្បូងប្រាសាទត្រពាំងផុង មានទួលមួយខ្ពស់ ) ។

- ទ្វារទី ៤ : នៅប្រាសាទចេតីយ៍ ប្រើជាសំពៅ ឬ នាវាគ្រប់ប្រភេទ មានចម្ងាយប្រមាណ ៥គម ពីស្រុកសៀមរាប ស្តាំដៃរបស់ផ្លូវទៅភ្នំក្រោម ។

*ស្ថានីយ៍ចិញ្ចឹមក្រពើ :-*

ជំនាន់ លន់.ណុល គេចិញ្ចឹមនៅផ្លូវទៅវាលយន្តហោះថ្មី ( ផ្លូវទៅវត្តចក ) នៅឆ្នាំ ១៩៧៥-១៩៧៩ ប៉ុល.ពត បានកសាងទំនប់ និង ធ្វើជាស្ពានពីលើនោះ ។ ត្បែរនោះមានចិញ្ចឹមក្រពើ ( ធ្វើជាអាងសំរាប់ចិញ្ចឹមក្រពើ គេប្រមូលក្រពើមកចិញ្ចឹមនៅទីនេះតែម្តង ) ។

ការអោយចំណីក្រពើជំនាន់នោះ មានត្រី ឬ កូនក្មេងបោះអោយក្រពើធ្វើជាចំណី ក្នុងស្នាងនេះមានជម្រៅ ១៥ ទៅ ១.២០ម ក្នុងមួយអាទិត្យគេបញ្ចេញទឹកចោលម្តង តាមខ្ទុងសំរាប់បញ្ចេញ ឬ ពេលដឹងថាមានប្រភពភ្ញៀវមកមើល គេអាចបញ្ចេញទឹកដែរកុំអោយធុំក្លិនស្អុយ ។

ក្រពើនេះមានអាយុ :

- ៤០ ឆ្នាំខ្លះ
- ៣០ ឆ្នាំខ្លះ
- ២០ ឆ្នាំខ្លះ
- ១០ ឆ្នាំខ្លះ ប៉ុនកំភួនដៃ

ចំនួនក្រពើទាំងអស់មាន ១៤០ក្រពើ គេអោយចំណីក្នុងមួយអាទិត្យម្តង ក្នុងមួយស៊ីអស់មួយតោន ( តាមទូរលេខនៅឆ្នាំ ១៩៨៩ ) ។

ចំណីបោះទៅក្នុងទឹក គឺវាត្របាក់ស៊ីតែម្តង ព្រោះក្រពើវាពុំមានអណ្តាតទេ ។ រស់នៅជាមួយគ្នា វាខាំគ្នាដាច់រើមរវាម គឺមិនពិបាកព្យាបាលទេ ក្នុងមួយអាទិត្យ គឺវាអាចជាសះស្បើយខ្លួនវាតែម្តង ។

ក្រពើវាមានពងដូចសត្វស្លាបដែរ :

- ក្រពើពងក្នុងមួយឆ្នាំម្តង នៅខែ មីនា នៃឆ្នាំនិមួយ១ ជិតដល់ខែវាពង គេតែងដឹកយកដីល្បប់ពីមាត់ទន្លេសាប យកមកដាក់ ហើយដីនោះអោយផង់ លាយទឹងកំទេចស្លឹកឈើដាក់អោយវាពង ។ ពេលវាត្រូវពង គឺវាឡើងមកកកាយខ្លួនវា ( ដោយជើងក្រោយ ) ជម្រៅ ០.៤០សម ល្មមលិចខ្លួន ទើបវាពង ( នៅពេលពីរយប់ ឬ បីយប់ ) :-

- មេក្មេងពងពី ៦ ទៅ ១០ពង
- មេចាស់ពងពី ២០ ទៅ ៣០ពង រយៈពេល ៤០នាទី គឺវាពងអស់តែម្តង ពងហើយ គឺវាកកាយដីកបវិញ ។ វានៅចាំការពារមិនទៅណាទេ កាចណាស់ ។

មុនយកពងវាមកភ្ញាស់ ទាល់តែទាក់វាយកទៅម្ខាង បិតទារមិនអោយវាចូលបាន ការយកពងទៅភ្ញាស់តាមរបៀបវិទ្យាសាស្ត្រ រយៈពេល ៣០ ថ្ងៃ ទើបញាស់ ។

សៀមរាប. ថ្ងៃទី ខែ ឆ្នាំ ១៩៩៦

អ្នកស្រាវជ្រាវ

ប្រាសាទបាណន់ :

កាលពីដំបូងរបស់តួប្រាសាទនេះ ត្រូវបានបាក់ធ្លាក់មកដី ហើយស្ថិតនៅចម្ងាយប្រហែល ១០០ម ពីទីនោះ ហើយគេអាចទៅកាន់ប្រាសាទនេះបានតាមរយៈផ្លូវមួយ នាងខាងកើតប្រាសាទ និង លាតសន្ធឹងតាមបណ្តោយជណ្តើរមួយ ដែលមានប្រវែងជាង ៦០ម និង មកបញ្ចប់ត្រឹមក្លោងទ្វារកំពែងរបស់ប្រាសាទ ។ ប្រវែងជ្រុងនីមួយៗរបស់កំពែងមានប្រវែងប្រហែល ៤០ម ដោយមានទម្រង់ជាថៃវ ៤ តែបច្ចុប្បន្នត្រូវបាក់បែកអស់រលីងហើយ ។

តួប៉មកណ្តាលមានអសនៈមួយរាងបួនជ្រុង ហើយដំបូលរាងសាជីជារៀត ដែលបើកចំហរទៅកេទិសទាំង ៤ និង មានបន្ទប់លយជងដែរ ប្រកបដោយដំបូលវៀត ។ សិលាចារឹកដែលរកឃើញដោយលោក អេជេន អាយម៉ូនីញេ តែមានការបាត់បង់វិញ ( មិនដឹងដោយប្រការអ្វី ) ក៏មានការពន្យល់ដូចលោក ឡា ហ្សុងថែរវ៉ែរ ( Lajinquière ) គឺនាំអោយមានការចុះកាលបរិច្ឆេទរបស់ប្រាសាទនេះនៅក្នុងរចនាបថបាយ័ន ក្នុងសតវត្សទី ១២ និងទី ១៣ គឺតាមរយៈស្ថាដែស្ថាបត្យកម្ម និង ក្បាច់គុបតែងលំអ គឺមានអក្សរប្រហាក់ប្រហែលនឹងរចនាបថបាយ័នមែនទែន ។ នៅលើភ្នំនេះ មានវត្ត ២ ស្ថិតនៅខាងត្បូង គឺគុហារព្រះទឹក ។

ការរកឃើញប្រទេសកម្ពុជា : ការរកឃើញនូវបណ្តាខេត្តជាច្រើន នៅក្នុងប្រទេសកម្ពុជា ពុំមានបញ្ហាអ្វីចោទឡើយទេ ។ ពីព្រោះបណ្តាខេត្តទាំងនោះ ពុំមានវត្ថុអ្វីសំខាន់ខាងផ្នែកបុរាណវិទ្យាទេ ។ ប៉ុន្តែមកដល់ទីនេះ គឺជាកន្លែងមួយសាមញ្ញដែលគេបានស្គាល់ ហើយគេក៏បានបោះបង់ចោលអស់រយៈពេលដ៏យូរមកដែរ និង ជាកន្លែងដែលអ្នកទេសចរណ៍តែងតែស្រម័យនឹកចង់ទៅទស្សនាទៀតផង ។

## ខេត្តសៀមរាប

ស្ថិតនៅក្នុងខេត្តសៀមរាប នៃតំបន់មួយនាភាគនិរតីប្រទេសដែលបានលេចចេញឡើង នូវធានីមួយ នៃអាណាចក្រខ្មែរ និង ប្រកបទៅដោយប្រវត្តិសាស្ត្រជាច្រើនក្នុងសម័យបុរាណកាល ។

មុនការតាំងធានីនៅក្នុង : ក្រុមប្រាសាទរលួស

ក្រុមប្រាសាទរលួសមានប្រាសាទ ៣ នៅក្បែរៗគ្នា ដែលមានកាលបរិច្ឆេទចុងសតវត្សទី ៩ ហើយនៅចម្ងាយ ១៥គម នៃភាគអគ្នេយ៍នៃក្រុងសៀមរាប តាមបណ្តោយផ្លូវជាតិលេខ ៦ កាត់តាមកណ្តាលភូមិតែម្តង ។

ប្រាសាទបាគង : គឺជាប្រាសាទទី ១ ដែលសាងអំពីថ្មភក់សាគល្បងទៅចំកណ្តាលធានីហរិហរាល័យ នៃប្រាសាទឥន្ទ្រវរ្ម័ន ។ គឺជាប្រាសាទភ្នំ លើកដំបូងបំផុត ដែលគេសាងសង់នៅផ្ទាល់ដីរាងជាពីរ៉ាមីត ដែលមាន ៥ថ្នាក់ ( ជាន់ ) នៅជាន់ខាងលើមានបន្សល់ទុកនូវក្បាច់ក្រឡាតមួយផ្ទាំងតូច ដែលគេដឹងច្បាស់ថា ជាសិល្បៈខ្មែរ តែគេពុំបានដឹកដឹងរឿងរ៉ាវរបស់ប្រាសាទនេះច្បាស់លាស់ទេ ។

ប្រាសាទព្រះគោ :

ស្ថិតនៅខាងលិចផ្លូវ ដែលចូលទៅកាន់ប្រាសាទបាគង ។ គឺជាប្រាសាទមួយដែលសង់នៅផ្ទាល់ដីតែម្តង ( តំណាងអោយប្រាសាទភ្នំដែរ ) ជាទីកន្លែងសំរាប់បញ្ចុះអដ្ឋិធាតុ ( សព ) របស់ស្តេចព្រះបាទ ជ័យវរ្ម័នទី ២ ហើយនឹងបុព្វបុរសរបស់ព្រះបាទឥន្ទ្រវរ្ម័នផងដែរ ។

ប្រាសាទនេះធ្វើអំពីឥដ្ឋ ហើយនឹងបិតភ្ជាប់ដោយកំបោរបាយអ ។ តួប៉មប្រាសាទនេះ ខាងកើតមានលំអដោយទ្វារបាល ២ នាគអមសងខាងទ្វារ ដែលមានមាឌមាំ និង នៅពីមុខប្រាសាទមានរូបសំណាក គោអនន្ទិ ( ANANDIN ) ដែលជាយានជំនិះរបស់ព្រះសិវៈ បែរមុខទៅរកប្រាសាទតែម្តង ។

<u>ប្រាសាទលលៃ</u> : ស្ថិតនៅតាមបណ្តោយផ្លូវ ដែលទៅប្រាសាទបាគង ពីដើមប្រាសាទនេះ មានលំនាំដូចជាកោះមួយនៅចំកណ្តាលបារាយណ៍ ឥន្ទ្រតដាកៈ Indratataka ដែលមានទំហំ ៣៨០០ម x ៨០០ម ដែលជាអាងស្តុកទឹកទុកសំរាប់ប្រើប្រាស់នៅក្នុងធានី Harihara Laya ការតុបតែងលំអលើផ្តែទ្វារ ស៊ុំទ្វារ និង សសរពេជ្ររបស់ប្រាសាទនេះ គឺធ្វើតាមប្រាសាទព្រះគោទាំងអស់ ។

<u>ភាពចិញ្ចាចចិញ្ចែងរបស់ធានីនៅសតវត្សទី ១០ និងទី ១១ ភ្នំបាខែង</u> :

ព្រះបាទ យសោវរ្ម័ន ពុំបានថែរក្សាធានីហរិហរាល័យ ដែលកសាងឡើងដោយបុព្វបុរសរបស់ព្រះអង្គទេ ។ ព្រះអង្គបានកសាងធានីថ្មីមួយទៀតឈ្មោះថា <u>យសោធរបុរៈ</u> ដែលជាធានីទីមួយនៅអង្គរ ។ នៅលើភ្នំបាខែង ព្រះអង្គក៏បានសាងប្រាសាទមួយដែលជាការសន្មត់ថា ជាចំណុចកណ្តាលទីក្រុង ។ ប្រាសាទភ្នំបាខែងធ្វើរាងជាពីរ៉ាមីឌ ដែលមានខឿន ៥ថ្នាក់ យ៉ាងចង្អៀតដែលនៅជើងក្រោមព័ទ្ធជុំវិញដោយប្រាសាទឥដ្ឋចំនួន ៤៤ តួប៉ម និង នៅលើថ្នាក់ៗរបស់ពីរ៉ាមីឌ មានប្រាសាទតូចៗចំនួន ៦០ ប្រាសាទទៀត សាងអំពីថ្មភក់ ហើយនៅទីខ្ពស់ខាងលើបំផុតមានបន្សល់ទុក នូវប្រាសាទ ៥ទៀត រាងជាចំណិតក្រសក់ (quinconce) ។

<u>បារាយណ៍ខាងលិច</u> : កសាងក្នុងសតវត្សទី ១១ ដែលមានបណ្តោយ ៨គម x ២គម ។ ក្នុងការកសាងបារាយណ៍នេះ គឺគេលើកទំនប់យ៉ាងធំៗ ដែលមានទទឹង ១២០ម បាតក្រោម កំពស់ជា ៦ម ដើម្បីធ្វើអាងស្តុកទឹកទុកសំរាប់ប្រើប្រាស់ ។

នៅចំកណ្តាលបារាយណ៍ មានប្រាសាទតូចមួយឈ្មោះប្រាសាទមេបុណ្យខាងលិច ដែលមានប្លង់ប្រហាក់ប្រហែលប្រាសាទបាពួនដែរ ។ គឺនៅក្នុងប្រាសាទនេះ ហើយដែលគេបានរកឃើញនូវរូបចំលាក់ព្រះវិស្ណុផ្ទំលើនាគ អនន្តៈ អំពីស្ពាន់ដ៏ធំមួយ ។

<u>ប្រាសាទអកយំ</u> : ស្ថិតនៅភាគខាងនិរតី បារាយណ៍ខាងលិច ហើយប្រហែលជាត្រូវបានសាងសង់តាំងពីសតវត្សទី ៧ មកម្លេះ និង ប្រហែលជាត្រូវបានគេជួសជុលជាច្រើនលើកទៀតផង ហើយក៏ប្រហែលជាមកបញ្ចប់នៅសតវត្សទី ៩ ដូចមានភស្តុតាង នៃការប្រើប្រាស់ឡើងវិញនូវជុំថ្មជាច្រើន ។ កាប់ឆ្លាក់ព្រែសំអាតដោយលោក គុបតែងលំអលើផ្តែ ទ្វារសសរពេជ្រ រូបចំលាក់ដែលនៅសេសសល់នានា ដូចជា ទេវតា គឺជាភស្តុតាង នៃសិល្បៈសម័យបុរាណដ៏យូរលង់ ។

<u>បក្សីចាំក្រុង</u> :

មានទីតាំងស្ថិតនៅមុខផ្លូវចូលលើខាងត្បូងរបស់ធានីអង្គរធំ ។ ប្រាសាទនេះកសាងក្នុងសតវត្សទី ១០ ដែលមានរាងជាពីរ៉ាមីឌ និង មានលំនាំជាភ្នំកៃលាស ដែលជាភ្នំមួយមានព្រះសិវៈគង់នៅទីនោះ ។ តួប្រាសាទធ្វើអំពីឥដ្ឋ សង់នៅលើពីរ៉ាមីឌ ដែលជាការបង្រួបខ្នាតនៃនិមិត្តរូបកំពូលភ្នំដែលខ្ពស់ រហូតដល់ឋានសួគ៌ា ប៉ុន្តែគួរអោយស្តាយ ក្បាច់តុបតែងខាងក្រៅ ត្រូវបានបាក់បង់អស់ ។ សំណង់នេះគេអាចហៅម្យ៉ាងទៀតថាជា " ប្រាសាទភ្នំ " ។

<u>បណ្តាសំណង់ទាំងឡាយដែលល្បីល្បាញនៅសតវត្សទី ១០</u> :

ប្រាសាទបាតជុំ : កសាងឡើងដោយឥស្សរៈជនផ្នែកពុទ្ធសាសនារបស់ព្រះបាទ រាជេន្ទ្រវរ្ម័ន ក្នុងឆ្នាំ ៩៥៣ ។ ប្រាសាទនេះកសាងដោយមានតួប្រាសាទបី អំពីឥដ្ឋ ដោយបានគំកល់នូវព្រះពុទ្ធរូបមួយអង្គ ហើយបានបង្ហាញអោយឃើញនូវឥទ្ធិពលពុទ្ធសាសនាមហាយាន ៦ទៀត គឺជាសកម្មភាពមួយបញ្ជាក់ពីការរស់ឡើងវិញ នូវលទ្ធិពុទ្ធសាសនានៅសម័យអង្គរ ក្រោយពីសម័យកាល នៃការធ្លាក់ចុះផ្នែកសាសនានៅអង្គរ ក្រោយពីសម័យកាលនៃការធ្លាក់ចុះផ្នែកសាសនាក្នុងកំឡុងសតវត្សទី ៩ និង ដើមសតវត្សទី ១០ ។

<u>ព្រះបាទព្រះឥន្ទកោសី</u> :

ព្រហ្មញម្នាក់ បានមកពីប្រទេសឥណ្ឌា រួចបានរៀបការជាមួយបុត្រីម្នាក់ ក្នុងចំណោមបុត្រីជាច្រើននាក់ របស់ព្រះបាទ រាជេន្ទ្រវរ្ម័ន រួចក៏បានកសាងប្រាសាទព្រះឥន្ទ្រកោសិឡើងនៅឆ្នាំ ៩៦៨ នៅច្រាំងខាងឆ្វេងនៃស្ទឹងសៀមរាប ។

តួប្រាសាទបីកសាងឡើងដោយមន្ត្រីថ្នាក់ខ្ពស់ម្នាក់ទៀត ដែលនៅក្នុងពាក់កណ្ដាលទី ២ នៃសតវត្សទី ១០ គាត់បានកសាងប្រាសាទបន្ទាយស្រី ។

<u>ប្រាសាទប្រែរ៉ាន់</u> :

តាមសិលាចារឹកបានអោយដឹងថា ប្រាសាទក្រវ៉ាន់ ត្រូវបានសាងសង់ឡើងនៅឆ្នាំ ៩២១ គឺដើមសតវត្សទី ១០ ហើយប្រាសាទនេះមិនត្រឹមតែសាងឡើងដោយស្នាព្រះហស្ថរបស់ព្រះបាទ ហសេវរ្ម័ន ម្នាក់ឯងប៉ុណ្ណោះទេ គឺមានមន្ត្រីថ្នាក់ខ្ពស់ជាច្រើននាក់ទៀត ។ ជាមានតួប៉មប្រាសាទ ៥ សាងអំពីឥដ្ឋ សង់ទន្ទឹមគ្នា មានលំអដោយក្បាច់ក្រឡោតទាបនៅក្នុងតួប៉មប្រាសាទ ២ ក្នុងចំណោមតួប៉មប្រាសាទទាំង ៥ ដោយមានលក្ខណៈប្រហែលនឹងប្រាសាទនាងខ្មៅនៅជិតប្រាសាទភ្នំជីសូរ ។

<u>កំពែងព្រះបរមរាជវាំង និង ប្រាសាទភិមានអាកាស</u> :

ព្រះបរមរាជវាំង ស្ថិតនៅទិសខាងជើងប្រាសាទបាពួន ដែលកំពែងព្រះបរមរាជវាំង ស្ថិតនៅទិសខាងជើងប្រាសាទបាពួន ដែលកំពែងព័ទ្ធជុំវិញទំហំ ៦០០ម x ២៥០ម ហើយត្រូវបានកសាងឡើងនៅចុងសតវត្សទី ១០ ក្រោមរាជរបស់ព្រះបាទ រាជេន្ទ្រវរ្ម័ន ( Rajendravarman ) បើតាមការស្រាវជ្រាវរបស់លោក Henri Marchal បានបញ្ជាក់ប្រាប់ថា ប្រាសាទភិមានអាកាស សំរាប់ការគោរពបូជារបស់រាជវង្សស្ដេច ហើយនឹងស្រះធំ គឺជាអាងស្តុកទឹកទុកសំរាប់ស្រោចស្រព ។

ស្រះធំនេះមានទំហំ ១២៥ម x ៤៥ម ដែលមានកែមជាថ្នាក់១ បើតាមលោក ម៉ូរីគ្លេ បានបញ្ជាក់ប្រាប់ថា :- មាន ៣ថ្នាក់ ខាងក្រោមថ្នាក់ជាក្បាច់ក្រឡោតទាប ស្ដីពីសត្វនាគ គ្រុឌ និង មនុស្សមានស្លាប ឯខាងលើមានថ្នាក់ជាក្បាច់ក្រឡោតទាបយ៉ាងវែង ស្ដីពីសត្វក្នុងទេវកថា តាមបែបរចនាបថបាយ័ន ( ចុងសតវត្សទី ១២ ដើមសតវត្សទី ១៣ ) ។

ឯជាន់ទីមួយរបស់ប្រាសាទភិមានអាកាសវិញ ត្រូវបានសាងសង់ឡើងដោយព្រះបាទ រាជេន្ទ្រវរ្ម័ន នៅចុងសតវត្សទី១០ ដោយពុំមានថែវឡើង ។ ហើយប្រាសាទទាំងមូលត្រូវបានសាងសង់ចប់នៅដើមសតវត្សទី ១១ ក្រោមការដឹកនាំរបស់ <u>ព្រះបាទសុរិយាវរ្ម័នទី ២</u> :

នៅចុងសតវត្សទី ១៣ មានអ្នកដំណើរចិនម្នាក់ឈ្មោះ ជីវតាក្វាន់ បានមករៀបរាប់អំពីរឿងមួយ ដែលទាក់ទងនឹងប្រាសាទនេះ រៀងរាល់យប់តែងតែមានបីសាចមកជំណែងខ្លួនជាមនុស្សស្រី ហើយព្រះរាជា ត្រូវតែរួមរ័ក្សរួមភិរម្យជាមួយនាងនេះ សូម្បីតែមហេសី ឬ សំស្និតនឹងព្រះអង្គក៏មិនហ៊ានចូលទៅក្នុងទីនោះដែរ ។ លុះដល់ពេលរៀបភ្លឺ ទើបស្ដេចចេញមកវិញ ។ បើបាត់

ពស់នោះមិនចេញមកទេនោះ និង មានគ្រោះថ្នាក់ដល់អាយុស្តេចហើយ តែបើស្តេចមិនបានយាងចូលទៅទីនោះទេ និង មានភាពអពមង្គលកើតឡើងភ្លាមៗដែរ ។

**ប្រាសាទប្រែរូប :**

ប្រាសាទប្រែរូប ត្រូវបានកសាងឡើងក្រោមរាជព្រះបាទរាជេន្ទ្រវរ្ម័ន ក្នុងកំឡុងឆ្នាំ ៩៦១ ។ វាជាប្រាសាទមួយធ្វើឡើងអំពីថ្មបាយក្រៀម និង ឥដ្ឋ ដែលជាហេតុធ្វើអោយវាមានពណ៌ក្រហមឆ្អៅ ។ បើតាមរឿងដែលគេនិទានតៗគ្នាថា គេត្រូវប្រែងខ្លួនសាកសពនៅទីនោះទៅរកទិសសំខាន់ៗទាំង ៤ ។ ឯអ្នកបុរាណវិទូវិញ ក៏ធ្វើការឯកភាពចំពោះរឿងរ៉ាវដែលទាក់ទង និង ព្រេងនិទាននេះ ព្រោះគេឃើញមានជើងទម្រមួយរាង ៤ ជ្រុងទ្រវែង នៅក្នុងកំពែងទី ១ ប្រហែលជាជើងទម្ររបស់ គោអនន្ទិ (NANDIN ) ដែលជាយានជំនិះរបស់សិវៈ ។

នៅជ្រុងឦសាន នៃកំពែងទីមួយនេះ ដែលមានសំណង់តូចៗមួយទៀត មានរាង ៤ជ្រុង សំរាប់ថែរក្សាសិលាចារឹកនានា ហើយនិងឡូសមួយ សំរាប់បង្ហូរទឹកចេញ ពេលមានធានីផ្សេងៗ ។ នៅក្បែរសំណង់នោះ មានសិលាចារឹកមួយ ដែលចារអក្សរលើមុខទាំងសងខាង ។

ប្រភេទប្រាសាទក្នុងសម័យមុនអង្គរដំបូងគេ គុបកែងក្បាច់លំអខាងក្រៅរបស់សសរផ្ដោប ជាសសៃផ្ការៗ ហើយដំបូលរបស់វាមានទីធ្លា ៣ ថ្នាក់លើខ្ពស់បន្តិច និង ធ្វើជារាងដែកក្រចកជើងសេះ ។

សំរាប់ប្រាសាទទាំង ៣នេះ គេពុំប្រទះឃើញក្បាច់លំអលើផ្តែទ្វារណាមួយទេ ។ ដោយមានការខ្វះខាតឯកសារបុរាណវិទ្យា ធ្វើអោយមានការពិបាកក្នុងការកំណត់អោយបានច្បាស់ពីប្រាសាទបន្ទាយព្រៃនគរនេះណាស់ ។

ប៉ុន្តែកំពែងរបស់ប្រាសាទនេះ គួរអោយសាម្បើមណាស់ ហើយនិងសំណល់បាក់បែកដ៏ច្រើនរបស់ប្រាសាទនេះ គឺជាការសេះហេតុសមផលមួយ ក្នុងការធ្វើជាឯកសារចារឹកមួយ ដោយចំឡែកដែលអាចអោយគេសន្និដ្ឋានបានថា ទីនេះគឺជាធានីឥន្ទ្របុរៈ ( Indrapura ) ដែលជាធានីទីមួយរបស់ព្រះបាទ ជ័យវរ្ម័នទី ២ មុនពេលដែលព្រះអង្គផ្លាស់ទីលំនៅទៅនៅខាងជើងបឹងទន្លេសាប ដែលមានឈ្មោះថាធានី HARIHARALAYA ហើយបច្ចុប្បន្ននេះ គេស្គាល់យ៉ាងច្បាស់ថា ជាក្រុមរលួសនាភាគអន្លង់ នៃខេត្តសៀមរាប ។

<u>ខេត្តបាត់ដំបង ( ក្រុងបាត់ដំបង )</u> :

ប្រភពដើមរបស់ទីក្រុងនេះ គេពុំដឹងច្បាស់ទេ ។ បើតាមសិលាចារឹកបន្ទាយនាងដោយពួកចេនឡា ។ នៅសតវត្សទី១០ ខេត្តបាត់ដំបងត្រូវបានបង្កើតឡើងជាប្រជុំខេត្ត អមុឃបុរៈ ( Amoghapura ) ហើយស្ថិតនៅតែឯង ហើយចុងមានភាពរុងរឿងរហូតដល់សតវត្សទី ១៣ ។ ការបោះបង់ចោលធានីអង្គរនៅសតវត្សទី ១៥ បានធ្វើអោយទីក្រុងនេះនៅសែនឆ្ងាយពីធានីថ្មី ហើយគេស្ទើរតែបំភ្លេចចោល ប៉ុន្តែវាជាទីក្រុងដ៏សំបូរបែបមួយ ។

នៅលើច្រាំងខាងឆ្វេង ខាងលិចស្ទឹងសង្កែមានវត្តចំនួន ៣ ដែលមានសារៈសំខាន់ដល់អ្នកទេសចរណ៍គឺ : វត្តកំពែង វត្តដំរីស និង វត្តពិភិតារាម ( Phiphithearam ) ។

នៅលើច្រាំងខាងស្តាំ វត្តចំនួន ៥ តាំងនៅខាងកើត គឺជាវត្តសង្កែ ដែលក្លោងទ្វាររបស់វត្តធ្វើមានដំបូល ហើយទ្រឡើងដោយសសរ ៤ និង ក្រាលដោយថ្មម៉ាប ដែលមានរក្សាទុកនូវរូបចំលាក់ព្រះពុទ្ធក្រឡូវឆ្លាំងដ៏ជាច្រើន តែត្រូវបានបំផ្លាញទៅ

ពេលសង្គ្រាម ។ បន្ទាប់មកទៀត គឺវត្តបូណ៌ាក៍ម វត្តកណ្តាល វត្តពោធិក្នុង និង វត្តពោធិវាល ។ វត្តពោធិវាលតាំងពីមុនមក គឺជាគ្រឹះស្ថានសិក្សាមួយដ៏សំខាន់របស់ខេត្ត ។ នៅមុនសង្គ្រាម វត្តនេះគឺជាកន្លែងសំរាប់រក្សាទុកនូវសាស្ត្រាស្លឹករឹតជាច្រើន ដែលចារក្នុងសតវត្សទី ១៨ និងទី ១៩ ។

វត្តឯក ( Vat Ek ) :

ទៅខាងជើង ហើយឆ្លាយបន្តិចពីច្រាំងខាងឆ្វេងស្ទឹងសង្កែ ហើយធ្វើដំណើរតាមផ្លូវដែលមានចម្ងាយ ៩គម ដោយឆ្លងកាត់ភូមិតូចមួយនៅលើច្រាំងស្ទឹង យើងទៅដល់វត្តឯក គឺមានប្រាសាទព្រហ្មញ្ញសាសនាមួយ ដែលគេពុំបានដឹងពីកាលបរិច្ឆេទនៃការសាងសង់ច្បាស់ទេ ។ ទោះជាយ៉ាងណាក៏ដោយ គឺមានសិលាចារឹកមួយ ដែលត្រូវបានឆ្លាក់នៅលើមេទ្វារខាងកើតរបស់ប្រាសាទ ដោយដាក់កាលបរិច្ឆេទក្នុងរាជព្រះបាទ សុរិយាវរ្ម័នទី ១ ( ១០០២ - ១០៤៩ ) គឺមានន័យថា បានកសាងឡើងនៅពាក់កណ្តាលទី ១ នៃសតវត្សទី ១១ ។

ផ្លូវលើកខ្ពស់ ២ ចូលទៅកាន់ប្រាសាទដែលសង់នៅលើទីធ្លារាងចតុកោណកែង ដោយព័ទ្ធជុំវិញដោយប្រឡាយដែលមានប្រវែងជ្រុងនិមួយៗប្រវែង ៦០ម និង ព័ទ្ធដោយថែវជុំវិញទៀត ។ នៅមុខខាងកើត និង មុខខាងលិចមានក្លោងទ្វារដែលប្រកបដោយផ្លូវចេញចូល ៣ ហើយនៅខាងឆ្វេងទីធ្លានៃប្រាសាទនេះ មានបណ្ណាល័យ ២ បែរទៅរកទិសខាងលិច ។ តួប៉មកណ្តាលប្រកបទៅដោយបន្ទប់លយយ៉ាងធំទូលាយ ( Avant Corps ) និង មានសសរច្រើននៅខាងក្នុង ដោយចែកបន្ទប់ខាងក្នុងជាបីផ្នែក និង សង់នៅលើថ្នាមួយក្រាលដោយថ្មភក់ និង មាន ២ថ្នាក់ ។ ផ្តែទ្វារទាំងឡាយ ត្រូវបានគេដាក់បន្ថែមពីលើទ្វារទាំង ៤ នៃអសនៈរាងជាបាត ផ្តែទ្វារខាងកើត បង្ហាញពីការកូរសមុទ្រទឹកដោះ ឯផ្តែ ៣ ទៀតបង្ហាញពីព្រះសិវៈរាំ ឬ គង់ជិះនៅលើគោនន្ទិ ។

វត្តបាសែត ( Vat BASET ) : វត្តបាសិតតាំងនៅចម្ងាយ ១៤គម ភាគខាងពាយ័ព្យ នៃទីរួមខេត្តបាត់ដំបង ប្រាសាទនេះ មានការបាក់បែកជាខ្លាំង និង មានការសាងសង់ពីថ្មភក់ និង ឥដ្ឋផងដែរ ។ តួប៉មទាំងបីរបស់ប្រាសាទនេះ គឺនៅសល់តែស្លាកស្នាមទេ ។ តួប៉មប្រាសាទរាងការេ ហើយបើកចំហរទៅលើទិសទាំង ៤ ដែលដំបូលរូតរបស់វាត្រូវបានបាក់ធ្លាក់ដូចប្រាសាទវត្តឯកដែរ ទំហំនៃបន្ទប់លយ ( Avant Corps ) មានលក្ខណៈជាការវិវត្តមកពីតួប្រាសាទសម័យអង្គរ គឺសសរទាំងឡាយត្រូវបានចែកផ្នែកខាងក្នុងបន្ទប់វែង ៣ ( Nef ) គេប្រទះឃើញមានសិលាចារឹកមួយ ដែលកំណត់ពីតំលៃនៃប្រវត្តិសាស្ត្រខ្មែរ ដោយមានភាពរឹងដូចកាលពីសតវត្សទី ៧ ដែរ ។ នៅក្នុងសម័យនោះ ខេត្តបាត់ដំបង ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្តេចខ្មែររួចទៅហើយ ។

## ទួលវិហារព្រះអង្គខ្មៅ
### ទក្សិណទូក-ង ឬ តងជុំ ( អ្នកស្រុកហៅព្រះខ្មៅ )

+ ទួលវិហារទក្សិណទូក-ង ឬ ទួលតងជុំ ( អ្នកស្រុកហៅព្រះខ្មៅ )

- កាលបរិច្ឆេទ : ចុងសតវត្សទី ១៦ ដើមសតវត្សទី ១៧
- រាជស្តេចស្ថាបនិក : ជ័យវរ្ម័នទី ៧
- លទ្ធិសាសនា : ព្រះពុទ្ធសាសនា ថេរវាទ ( ជាទីប្រជុំជននានាផងដែរ )
- សំភារៈសំណង់ : សាងសង់លើដីទួលខ្ពស់ អំពីថ្មបាយក្រៀម និង ថ្មភក់ ព្រះវិហារអំពីឈើប្រក់ក្បឿង។ បែរមុខទៅរកទិសខាងកើត ត្រើះនេះមានការលួចជីកកកាយរកវត្ថុដ៏មានតម្លៃ តាំងពីយូរលង់ណាស់មកហើយ តែនៅសម័យកាលឆ្នាំ ១៩៨០ ដល់ឆ្នាំ ១៩៨៤ គឺមានការលួចជីកកកាយបន្ថែមទៀត ។

- ទីទួលវិហារព្រះអង្គខ្មៅនេះ ពីដើមគេកសាងជារបៀបអាសនៈ សំរាប់គ្របពីលើព្រះពុទ្ធបដិមា ។

ទីតាំង : ចូលតាមក្លោងទ្វារទន្លេអុំទៅជើងប្រហែលជាង ១គម ស្ថិតនៅខាងលិចថ្នល់ប្រហែលជាង ១០០ម ។

- ទីកន្លែងទួលនេះ សំរាប់ប្រសិទ្ធិពរអោយទូក-ង គេធ្វើពិធីតាមប្រពៃណី នៃព្រះពុទ្ធសាសនា ក្នុងនោះមានសូត្រមន្ត និង រៀបចំបាយសីគ្រប់ថ្នាក់ ដង្វាយមានបាយម្ហូបអាហារ សំរាប់សែនដល់បារមីជាម្ចាស់ទឹកម្ចាស់ដី ម្ចាស់ព្រៃព្រឹក្សាពាវស្លី មានអារក្ខ អារក្ស អ្នកតា ដែលនៅថែរក្សាទីនោះ ក្នុងនោះមាននំអន្សម នំគម នំធៃ និង ផ្លែឈើគ្រប់មុខ សំរាប់ជាដង្វាយថ្វាយដល់បារមីនៅទីនោះផង ។

- ពេលធ្វើពិធីរួចហើយគេហែរទូក-ង នោះប្រទក្សិណ ( វេ្ធល ) ចំនួន ៣ជុំ ទួលវិហារនោះ ដោយមានសូត្រធម៌ រួចឆាកហ៊ោផងដែរ ( និយាយរួមទីកន្លែងនោះ ជាទីប្រជុំជនមួយយ៉ាងសំខាន់ណាស់ ) ហើយព្រោះទឹកមន្ត និង ហែរប្រទក្សិណរួចហើយ ទើបគេដង្ហែទូក-ងនោះឆ្លងកាត់ទន្លេអុំ ទៅតាមដៃទន្លេជួនពៅ ( ឈ្មោះនេះជាឈ្មោះស្រីម្នាក់ ដែលបានកសាងដៃទន្លេនេះ ( ទើបគេអោយឈ្មោះដៃទន្លេជួនពៅរហូតដល់សព្វថ្ងៃនេះ ) ។ ដៃទន្លេជួនពៅ ស្ថិតនៅត្រង់ទោលខាងកើតដើមបេងធំមួយ ( ដែលមានស្រះអំពីថ្មបាយក្រៀម និង ថ្មភក់ ) ។

- វេទិកាប្រណាំង ស្ថិតត្រង់ទោលពីមាត់ទន្លេជួនពៅប្រហែល ៣០ម ( ខាងលិចផ្ទះលោកតា យ៉ង ) សព្វថ្ងៃនេះនៅសល់ទួលត្រើះអំពីថ្មបាយក្រៀមជាថ្នាក់ៗតែប៉ុណ្ណោះ ។

- ពេលគេប្រណាំង គេចេញទូកពីទន្លេអុំទៅកើតដល់ជ្រុងខាងកើត ទើបគេអុំផ្តាច់ព្រ័ត្រ នៅខាងមុខវេទិកានេះ

- ចំពោះអ្នកចូលរួមទស្សនាទូក-ង មាន : ព្រះរាជា និង ព្រះអគ្គមហេសី ស្ថានទូតនៃប្រទេសនានាប្រចាំកម្ពុជា មន្ត្រីរាជការតូចធំ គេចេញពីអង្គរតាមទន្លេជួនពៅ ( តាមសំពៅ ទូក ហើយមកឡើងវេទិកាតែម្តង ( មានស្នាមផ្លូវចុះទូកនៅខាងកើតកន្លែង គេលក់ដូរសព្វថ្ងៃនេះ ) ព្រោះកន្លែងនោះរៀបតែម្តង ពិធីអុំទូកនេះ គេប្រព្រឹត្តិទៅរៀងរាល់ឆ្នាំ នៅពេលដែលគេច្រូតស្រូវរួចស្រាច់បាច់ហើយ ( ឯទូកយកមកប្រណាំង គឺគេយកមកតាមបណ្តាខេត្តទូទាំងប្រទេសដែរ ) ។

( ព្រោះរាជដំណាក់ គឺនៅមុខខាងលិចខាងត្បូងអង្គរ )

- កាលពីដើមវត្តខាងជើង ( មានទីធ្លាទ្រង់ទ្រាយតូចបន្តិច )

- វត្តខាងត្បូង មានទ្រង់ទ្រាយធំជាងវត្តខាងជើង វត្តទាំងពីរនេះ កាលពីដើមនៅលើរូតបាការ ( របងទងទី I ) នៃប្រាសាទអង្គរវត្ត ពេលចារាំងកាន់កាប់ប្រាសាទខ្មែរទូទាំងប្រទេស ។ ពិនិត្យវាប៉ះពាល់នឹងឧបាសក ឧបាសិកា ចេញចូលធ្វើបុណ្យប្រសេចប្រសាទ ធ្វើអោយបរិស្ថាននៅទីនោះគ្រខ្វក់ ទើបសំរេចអោយចេញពីលើអង្គរមករៀបចំវត្តនៅកន្លែងរាំងចាស់មុខអង្គរវត្តទៅ ។

( បត់ USCO មកទាល់នឹងផ្លូវបត់កែងខាងលិច ( មាត់ទន្លេណាខាងត្បូង ) គេហៅទីនោះថា " ព្រៃរាំង " ( ទីនោះមានទួលខ្ពស់ សព្វថ្ងៃព្រៃដុះជុំជិត ពស់មានពិសទៅរស់នៅទីនោះ មនុស្សមិនហ៊ានចូលទៅទេ ) ។

- ទីវត្តនោះ ក្រោយមកទៀតរើពីកន្លែងព្រៃរាំងចាស់ ទៅនៅក្នុងអង្គរវត្ត តាមទីធ្លាដែលឃើញមានស្រាប់រហូតដល់សព្វថ្ងៃនេះ ។

- ទួលវិហារព្រះខ្មៅ ឬ ទួលកងជុំ ត្រូវឆេះប្រហែលសម័យឥស្សរៈ បណ្តាលអោយព្រះខ្មៅ ( ជំនាន់អាណានិគមនិយមបារាំង ) ពេលឆេះរោលឡើងខ្មៅ ទើបក្រោយមកអ្នកស្រុកហៅថាព្រះខ្មៅៗ តរហូតមក ។

- ដើម្បីកុំអោយហាលហាល ព្រះនៅកណ្តាលវាល ( នាំអោយមានភាពរាំងស្ងួតខ្លាំង ) ទើបមានការបន់ស្រន់សុំអោយមានភ្លៀង សំរាប់ការបង្កបង្កើនផលរដូវវស្សា ទទួលបានទិន្នផលខ្ពស់ ទើបឯកឧត្តម ម៉ៅ ចយ ជារដ្ឋមន្ត្រីក្រសួង........... ...............? បានកសាងព្រះវិហារតូចល្មម គ្រាន់ជាជម្រកការពារក្តៅ និង ភ្លៀង ដល់ក្រោយមកទៀតសត្វកណ្ដៀរស៊ី ព្រោះនៅក្រោមដើមឈើជុំជិត ធ្វើអោយជញ្ជាំងសសរពុកអស់ ទើបនៅឆ្នាំ ១៩៨៨ លោក តា សេង បានកសាងបុស្បុកអំពីឈើ ប្រក់ក្បឿង គ្របពីលើព្រះអង្គខ្មៅ កសាងរួចនៅឆ្នាំ ១៩៩៩ លោក ឈាង អ្នករកស៊ីបានទៅបន់ស្រន់សុំអោយសុខសប្បាយ រកស៊ីមានបាន ត្រូវឆ្នោត នឹងរៀបចំព្រះវិហារនេះអោយបានសមស្រប ។

- ការបន់ស្រន់នេះ ព្រះអង្គបានជួយតាមសេចក្តីប្រាថ្នា ( ប្រហែលត្រូវឆ្នោតធំ ) ដើម្បីលាបំណន់ ក៏រកអ្នកឆ្លាក់និង សុំច្បាប់យកព្រះកេសទៅតភ្ជាប់វិញ និង ធ្វើការត្រួសត្រាយព្រៃ លើកដីធ្វើផ្លូវចូលទៅកាន់ទួលព្រះអង្គខ្មៅ ប្រក់ដំបូលអំពីក្បឿងផង ។

- ពេលឆ្លាក់បានហើយ ក៏រៀបចំធ្វើពិធីដង្ហែរចេញពីអភិរក្សអង្គរ ដើម្បីយកទៅបំពាក់នឹងដងខ្លួន ពិធីនេះគេធ្វើតាមប្រពៃណីយ៍ និង ទំនៀមទំលាប់នៃព្រះពុទ្ធសាសនា ។

នៅថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៨ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានទៅបន់ស្រន់ដល់បារមីសក្តិសិទ្ធព្រះអង្គខ្មៅនេះ មុនពេលចូលប្រជុំរដ្ឋសភាលើកទី I និតិកាលទី II សុំអោយគណៈប្រតិភូគណបក្សប្រជាជនបានសេចក្តីសុខ និងសំរេចបានលទ្ធផលល្អប្រសើរពេលប្រជុំនេះ ។ សាងព្រះវិហារថ្មីអោយ នៅពេលនោះសម្តេចនាយក ហ៊ុន សែន បានចាក់កម្ពីរជាមួយលោកតា ងោញ គ្រួច ជាចៅអធិការវត្តវិហារខ្មៅ ។ ចំនួន ៣ដង ចាក់លើកទី ១ ត្រង់ទំព័រ ៣១ នេះកាលសេដ្ឋីយកឃោសកៈកុមារមកចិញ្ចឹមជាកូនធម៌ ទំនាយថាល្អណាស់ បើកចាក់ត្រូវត្រង់នេះ កុំបីចាក់ទៀតឡើយ ។

<u>ចាក់លើកទី ២</u> : ត្រង់ទំព័រ ៥៤ នេះកាលព្រះតេមិយ្យទេសនាប្រោសសត្វ ព្រះវបិតា មាតា នូវសត្វផងទាំងឡាយ ទំនាយថា បើធ្វើការអ្វីៗ បានសម្រេចដូចសេចក្តីប្រាថ្នាល្អណាស់ហោង ។

<u>ចាក់លើកទី ៣</u> : ត្រង់ទំព័រទី ២០ នេះកាលឃោសកៈកុមារ ម្តាយយកទៅចោលលើគំនរសម្រាមសេដ្ឋីរើសយកទៅអភិបាលថែរក្សាដូចជាកូន ទំនាយថា អាក្រក់ខាងដើម ខាងចុងល្អប្រសើរពេកហោង ។

- នៅព្រឹកថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៨ ត្រូវបើកប្រជុំរដ្ឋសភាលើកដំបូងនីតិកាលទី ២ រៀបចំពិធីប្រជុំនៅព្រះរាជដំណាក់ខេត្តសៀមរាប ក្រោមព្រះរាជអធិបតីភាពរបស់សម្តេចនរោត្តមសីហនុ ពេលនោះក្បួនដំណើរគណបក្សទាំង ៣ បានចេញដំណើរពីសណ្ឋាគារគោកធ្លក ក្បួនដំណើរចេញមុនគេ គឺក្បួនរបស់ សម រង្ស៊ី បន្ទាប់មកទៀត ក្បួនដំណើររបស់សម្តេច ហ៊ុន សែន ស្រាប់តែគ្រាប់ ដែលគេដាក់បង់កៃផ្ទុះឡើងទៅលើ មិនបណ្តាលអោយមានគ្រោះថ្នាក់អ្វីឡើយ ។

- ពេលឈ្នះឆ្នោតអាណត្តិទី ២ : ដើម្បីលាបំណន់ សម្តេចបានអោយក្រុមវិស្វកម្មក្មេងវត្តទៅកសាងព្រះវិហារព្រះអង្គខ្មៅ ឬ កងជុំ បានចាប់ផ្តើមកសាងនៅដើមឆ្នាំ ១៩៩៩ ហើយជាស្ថាពរនៅខែ កញ្ញា ឆ្នាំ ១៩៩៩ បានធ្វើពិធីសម្ភោធជាផ្លូវការនៅខែ កញ្ញា ឆ្នាំ ១៩៩៩ តាមទំនៀមទំលាប់នៃព្រះពុទ្ធសាសនា ។

- ពួអង្គព្រះខ្មៅ ឬ អង្គកងជុំនេះ តាមប្រជាជនទូទាំងប្រទេស ពិសេសប្រជាជននៅខេត្តសៀមរាប តែងមានជំនឿលើបារមី និង មហិទ្ធិឫទ្ធិរបស់ព្រះអង្គ ហេតុអ្នកខ្លះមកដេកក្បែរ ដើម្បីសុំលេខឆ្នោត ខ្លះបែរបន់សុំអោយប្រទេសជាតិមានសន្តិភាពបរិបូរចាប់ពីពេលនេះតទៅ ។ ខ្លះបែរបន់សុំលេខឆ្នោត ពុំមានកូនសុំអោយមានកូន គ្មានភ្លៀងសុំអោយមានភ្លៀង ។

ខ្លះធ្វើពិធីប្រសិទ្ធពរជ័យដល់ទូក-ង កាលសម័យដើម ខ្មែរយើងមានជំនឿលើការធ្វើការប្រគំព្រុំដល់កម្លាំងទ័ព ( ទាហ៊ាន ) មុនពេលចេញច្បាំង សូមអោយចេញច្បាំងឈ្នះសត្រូវ និង សូមកុំអោយមានស្លាប់ ពេលត្រឡប់មកវិញ គេនឹងធ្វើពិធីលាបំណន់ ក្នុងនោះគេរៀបចំពិធីតាមក្បួន និង ទំនៀមទំលាប់ និង ប្រពៃណីនៃព្រះពុទ្ធសាសនា ( ពិធីរៀប គឺអាស្រ័យលើអាចារ្យ ឬ ព្រះសង្ឃ ជាអ្នករៀបចំលាបំណន់ ) ។

## ប្រវត្តិរបស់បដិមារូប

## ព្រះអង្គថ្មី

កាលពីដំបូង បដិមារូបអង្គចេក អង្គចម និង អង្គថ្មី នៅនឹងប្រាសាទអង្គរវត្ត «រូកព្រះពាន់» ។

<u>កំណើតរបស់ប្រាសាទអង្គរវត្ត</u> :

កាលបរិច្ឆេទ : ពាក់កណ្ដាលទី ១ នៃសតវត្សទី ១២

«គ.ស. ១១១២-១១៥២»

រាជស្ដេច : សុរិយាវរ្ម័នទី ២

ឧទ្ទិសថ្វាយ : បរមវិស្ណុលោក

កាលជំនាន់នោះនៅគ្រប់ជ្រុងក្នុងប្រាសាទអង្គរវត្ត គេដំកល់បដិមាទេវរាជ «តិរូបវិស្ណុ» ឧទាហរណ៍ នៅប្រាសាទធំកណ្ដាល គេដំកល់បដិមាទេវរាជ តិរូបវិស្ណុ ហើយទ្វារចំហទាំងបួនទិស ។ ក្រោយមក គេគោរពព្រះពុទ្ធសាសនា មានព្រះសង្ឃដែលកាន់សាសនាកំលុងឆ្នាំ ១៥០០ ទៅឆ្នាំ ១៦០០ បានបិទសន្ធប់ប្រាសាទធំនេះ ហើយឆ្លាក់បដិមារូបព្រះពុទ្ធគង់ឈរ «លក្ខណៈវរមុទ្រៈ» (geste de charité) ។

- នៅគ្រប់ទ្វារចូលទាំង ៤ គេបានយកបដិមាទេវរូបវិស្ណុទៅចោលបាត់ទៅ ។

- នៅឆ្នាំ ១៩០៨ លោក ហ្សង់ កូម៉ៃ (Jean Commaille) ជាអ្នកអភិរក្សទី ១ បានចោះទំលាយទ្វារខាងត្បូង ដើម្បីធ្វើកំណាយ ។

- នៅពេលកាន់សាសនាព្រះពុទ្ធ មានព្រះសង្ឃកាន់កាប់អង្គរវត្ត ពេលនោះ គេបានកសាងព្រះពុទ្ធរូបជាច្រើនដែលមានគ្រប់មុទ្រៈសំរាប់ធ្វើសក្ការៈបូជា ក្នុងនោះមានបដិមារូបអំពីឈើ ថ្មភក់ ស្ពាន់ សំរិទ្ធ ។ល។ នៅពេលកសាងរួច គេតែងយកទៅដំកល់នៅរូកព្រះពាន់ ធ្វើពិធីអភិសេកទៅតាមទំនៀមទំលាប់ប្រពៃណីនៃសាសនា ។

- បដិមារូបព្រះអង្គចេក អង្គចម និង អង្គថ្មី គេបានកសាងអំពីសំរិទ្ធ លាយលង្ហិនជាលក្ខណៈវរមុទ្រៈ «ជាលក្ខណៈអប់រំចិត្តអោយសប្បុរស» គង់ឈរ ដៃឆ្វេងដាក់សំយុងចុះ ដាក់តាមបណ្ដោយដងខ្លួន ព្រះហស្ដស្ដាំលាទៅមុខ ។ លក្ខណៈត្រង់នេះនិយាយពីព្រះអង្គយាងទៅប្រោសពុទ្ធមាតា នៅស្ថានត្រៃត្រិង្ស ព្រះអង្គយាងទៅយូរពេក គេក៏កសាងបដិមារូបជំនួស ដល់ព្រះអង្គត្រលប់មកវិញ បដិមារូបនោះ រំកិលចុះពីលើបល្ល័ង្ក ព្រះអង្គរាព្រះហស្ដថា នែបដិមារូប កុំចុះទៅណា នៅកន្លែងដដែលនឹងហើយ ។

ពុទ្ធអង្គនេះមានលក្ខណៈមុទ្រៈ ដូចព្រះដទៃទៀតដែរ ក្រោយការកសាងរួច ប្រហែលម្ចាស់ដើមរៀបចំពិធីអភិសេក ទើបមានបរមី និង មហិទ្ធិរិទ្ធមកសន្ថិត ម្យ៉ាងដោយសារការជឿជាក់របស់មហាជនយើងផង ។

ព្រះពុទ្ធអង្គនេះមានកំពស់ ៥២សម ទទឹងស្មា ១៥សម កំពស់រួមទាំងពន្លួញមាន ៧៨សម ជាលង្ហិនលាយសំរិទ្ធ ពីដើមនៅរូកព្រះពាន់ អង្គរវត្តដែរ ។ នៅទសវត្សទី ៥០ រូបព្រះអង្គ

ជុំនេះនៅវត្តព្រះពាន់ ក្រោយមកពួកអាណានិគមបារាំងវង់បានព្រះនេះ ព្រះតេជគុណចៅអធិការ ខាងជើងព្រះនាម លីវ បានយកព្រះពុទ្ធអង្គនេះទៅលាក់ទុកក្នុងវត្ត ព្រះអង្គជាអ្នកស្នេហាសម្បត្តិ វប្បធម៌ជាតិ យល់ច្បាស់ពីភារកិច្ច និង កាតព្វកិច្ចជាអ្នកបន្តវេនការពារថែរក្សាមរតកវប្បធម៌ សំរាប់ ជាកេរ្តិ៍ដំណែលទុកអោយកូនចៅជាន់ក្រោយៗ ។

នៅទសវត្សទី ៦០ ព្រះចៅអធិការ លីវ ប្រឈួនខ្លាំង មុនសុគត ក៏ប្រគល់ព្រះអង្គជុំ នេះទៅអោយគ្រូសូត្រស្ដាំ ព្រះនាម គង់ យ៉ាវ ថែរក្សាបន្តរហូតមក ។

នៅឆ្នាំ ១៩៧២ ពួកខ្មែរក្រហមបានជំលៀសព្រះសង្ឃ និង ឧបាសក ឧបាសិកាចេញពី វត្តអង្គរ ព្រោះពេលនោះសង្គ្រាមរវាងខ្មែរវៀតកុង និង ទាហាន លន់ នល់ លោកគ្រូ គង់ យ៉ាង ត្រូវបានទៅគង់នៅវត្តប្រីយ៍ ឃុំខ្នារសណ្ដាយ ស្រុកបន្ទាយស្រី ក៏បានយកពុទ្ធអង្គនេះជាប់ជាប្ចូយ ដែរ គ្មាននរណាដឹង ។

នៅឆ្នាំ ១៩៩៣ ពួកខ្មែរក្រហមបានចាប់លោកគ្រូ គង់ យ៉ាវ ដោយចោទលោកថា ចង់ រត់ចូលមកតំបន់ លន់ នល់ ក្នុងក្រុងសៀមរាប លោកគ្រូ គង់ យ៉ាវ ដែលពួកខ្មែរក្រហមចាប់ទៅ ក៏បាត់ដំណឹងរហូតមកដល់សព្វថ្ងៃ មិនដឹងជារស់ ឬ ស្លាប់ ។ នៅពេលដែលពួកខ្មែរក្រហមចាប់ លោកគ្រូ គង់ យ៉ាវ ហើយពួកវាក៏ឡើងឆែកឆេរកុដិលោក ក៏ប្រទះឃើញព្រះពុទ្ធអង្គជុំនេះតែម្តង ហើយពួកវាក៏យកទៅប្រគេនលោកចៅអធិការវត្តប្រីយ៍ ព្រះនាម ញូង អោយថែរក្សាអោយពួកវា សិន ។

នៅឆ្នាំ ១៩៧៥ ពួកខ្មែរក្រហមបានអោយសឹកទាំងអស់នៅវត្តប្រីយ៍ ពេលនោះលោក ញូង ស្ពាយព្រះពុទ្ធរូបនេះ ក៏យកទៅអោយឈ្មោះ រឿន សំ ដែលជាសិស្សរបស់គ្រូ គង់ យ៉ាវ ថែរក្សាទុក ។ នៅពេលដែលគ្រូ ញូងប្រគល់អោយឈ្មោះ រឿន សំ គឺជាសង្ឃនៅឡើយ ដែលកូន សិស្សរបស់គ្រូ គង់ យ៉ាវ ផ្ទាល់ ដែលបានជំលៀសពីវត្តអង្គរខាងជើង ១៩៧២ ដូចគ្នា ។

ក្រោយបានតែ ២ ខែ ខ្មែរក្រហមអោយឈ្មោះ រឿន សំ សឹកដែរ ពេលនោះឈ្មោះ រឿន សំ ក៏យកព្រះពុទ្ធរូបអង្គនេះមកថែរក្សានៅផ្ទះ នៅភូមិសណ្ដាយ ឃុំខ្នារសណ្ដាយ ស្រុក បន្ទាយស្រី ចាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ។

ក្រោយថ្ងៃរំដោះ ៧-១-៧៩ ឈ្មោះ រឿន សំ ត្រូវបានវិលត្រលប់មកនៅស្រុកកំណើត វិញ គឺភូមិត្រពាំងសេះ ឃុំនគរធំ ស្រុកសៀមរាប សម័យនោះ ។ ហើយនាំយកព្រះពុទ្ធរូបអង្គជុំ នោះមកជាមួយផងដែរ ដើម្បីរក្សាទុក ។

ដោយគោរពស្រឡាញ់ជំនឿលើព្រះពុទ្ធសាសនា នៅឆ្នាំ ១៩៨១ រឿន សំ ក៏បានធ្វើ បុណ្យអភិសេកព្រះអង្គជុំ ហើយក៏ដង្ហែរទៅប្រគេនលោកគ្រូ ព្រួច នៅវត្តធានខាងជើងវិញទៅ ។

ក្រោយមកនៅឆ្នាំ ១៩៨២ លោកគ្រូ ព្រួច ត្រូវមានទំនាស់ផ្ទៃក្នុងរវាងលោកគ្រូ លឿង សេក ពេលនោះគ្រូ ព្រួច ក៏ឈប់គង់នៅវត្តធានខាងជើង ទៅគង់នៅព្រះដាក់ ស្រុកបន្ទាយស្រីទៅ ហើយក៏ប្រគល់ព្រះពុទ្ធរូបអង្គនេះមកអោយឈ្មោះ រឿន សំ ថែរក្សាទុកវិញ ។

នៅឆ្នាំ ១៩៩១ នៅពេលដែលគេរើភូមិត្រពាំងសេះ ឃុំនគរធំ ស្រុកសៀមរាបអោយ ទៅនៅភូមិថ្មី ឃុំគោកចក ស្រុកសៀមរាប សព្វថ្ងៃនេះ ។ ពេលនោះ រឿន សំ ក៏បានយកព្រះពុទ្ធ រូបនោះមកធ្វើទុកនៅជាមួយព្រះសង្ឃព្រះនាម លឿង ជុន សិន ។ ដោយដាក់ទុកហិបដែកយ៉ាង

ប្រុងប្រយ័ត្នបំផុត ។ ក្រោយមក ជនទុច្ចរិតបានភ្ជាប់ជាប់ថាមានព្រះសិរិទ្ធ ក្នុងវត្តខាងជើង គឺវា ប្រទាក់ក្រឡា ដើម្បីចង់លួចយករូបព្រះអង្គជុំនោះ ។

នៅថ្ងៃទី ១៧-១០-៩៤ ឈ្មោះ រឿន សំ ក៏បានយកព្រះពុទ្ធរូបអង្គជុំនោះទៅផ្ញើទុកនៅ ទីបញ្ជាការតំបន់សឹករងខេត្តសៀមរាប ដែលមានឧត្តមសេនីយ៍ទោ អ៊ុង អឿន មេបញ្ជាការតំបន់ ប្រតិបត្តិការរងខេត្តជាអ្នកទទួលរក្សាទុក ។

នៅថ្ងៃទី ០៩-៣-៩៥ លោកមេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្ត ក៏បានធ្វើការ ប្រគល់ព្រះពុទ្ធអង្គជុំរួមជាមួយនូវវត្ថុបុរាណអំពីថ្ម ៤ ទៀត អោយអភិរក្សអង្គរថែរក្សាទុកជាបេតិកភ័ណ្ឌវប្បធម៌ជាតិ ។

សៀមរាប, ថ្ងៃទី ១៦ ខែ ៧ ឆ្នាំ ១៩៩៥

ប្រធាននាយកដ្ឋានអភិរក្សអង្គរ

[illegible]

# វត្តព្រះព្រហ្មរតន៍ (ខេត្តសៀមរាប)

ឧបាសកឈ្មោះ ព្រហ្ម និង ឧបាសិកាឈ្មោះ រតន៍ បានវេរដីមួយកន្លែងដល់ព្រះសង្ឃសំរាប់កសាងវត្ត ហើយសុខចិត្តថ្វាយខ្លួនទាំងពីរនាក់បំរើដល់សាសនារៀងទៅ។ វត្តនេះបានរៀបចំឱ្យបានសក្តិសមឡើងទៀត ដោយមេទ័ពសៀមម្នាក់ឈ្មោះ ប្រាក់ យ៉ាមហាក្សត្រសឹកក្នុងសម័យអាណានិគមរបស់គេ។ កាលសម័យនោះមានដើមពោធិធំមួយដើមនៅជ្រុងនិរតិព្រះវិហារសព្វថ្ងៃ ហើយមានអាស្រមអ្នកតាមួយឈ្មោះ តាជ័យ នៅគ្រប់ទីវិហារបច្ចុប្បន្ន។ វត្តព្រះព្រហ្មរតន៍ មានចំណាស់ប្រហាក់ប្រហែលគ្នានឹងវត្តអង្គរ មានភាពថ្កើងថ្កានជាងវត្តទាំងពីរនោះ។

វិហារពីដើមសាងសង់អំពីឈើ តែដល់ខូចខាតខ្លះៗទៅ គេបានកសាងវិហារថ្មីនៅកន្លែងដដែលវិញ ឯព្រះធំសព្វថ្ងៃនេះគឺគេកសាងបល្ល័ង្កឱ្យខ្ពស់ ហើយដំកល់ព្រះធំតែម្តង ឯព្រះចូលនិពាន្ត ពីដើមបាតវិហារគឺស្មើនឹងព្រះចូលនិពាន្តនេះឯង (មូលហេតុដែលគេមិនលើកព្រះចូលនិពាន្តឱ្យស្មើនឹងព្រះធំ កាលណារើរុះ វាបាត់ភាពដើម ព្រោះព្រះនេះគេរៀបឥដ្ឋ ដីស្រឡាងបាយអរពីលើលាបទឹកមាស)។

វិហារនេះមានរូបចូលព្រះនិពាន្តមួយអង្គធំ (ក្រោយបល្ល័ង្កព្រះអង្គធំ) ព្រះពុទ្ធអង្គនេះមានទំនាក់ទំនងនឹងរឿង (ទូកចង្ហាន់ហុយ) ក្នុងសម័យលង្វែល ស្តេចបានឱ្យគេរើយកដើមឈើគគីមួយដើមដែលមានឫទ្ធានុភាពមកធ្វើជាទូកសំរាប់ប្រើប្រាស់ក្នុងរាជធានី។ លោក វង្សា អគ្គរាជ តែងប្រើលោកតាព្រហ្ម និងយាយមាសកេស ឱ្យអុំទូកយកចង្ហាន់ពីក្រុងលង្វែកមកប្រគេនព្រះសង្ឃនៅវត្តអង្គរក្នុងពិធីបុណ្យផ្សេងៗ ដូចជាបុណ្យភ្ជុំបិណ្ឌ ចូលឆ្នាំ ជាដើម ដោយអុំកាត់ទន្លេសាបយ៉ាងរហ័សបំផុត។ ចង្ហាន់រៀបចំដាក់ទូកចេញដំណើរពីព្រលឹម យកចង្ហាន់មកប្រគេនព្រះសង្ឃទាន់ពេលវេលា (ឆាន់ថ្ងៃត្រង់) ចង្ហាន់នៅតែក្តៅហុយពុំទាន់ត្រជាក់។ ធម្មតាធ្វើដំណើរពីក្រុងលង្វែកមកអង្គរវត្ត គេត្រូវធ្វើដំណើរអស់រយៈពេលមួយអាទិត្យយ៉ាងតិច តែទូកចង្ហាន់សារុបដំណើរតែមួយព្រឹកប៉ុណ្ណោះ។ ថ្ងៃមួយទូកតាព្រហ្ម យាយមាស ពេលចេញដំណើរពីលង្វែកមកដល់កណ្តាលទន្លេសាប បានជួបសត្វឆ្លាមមួយប៉ិងយាយើយាយតា ពេលនោះយាយឃើញសត្វសាហាវនេះមុន ក៏ស្រែកប្រាប់តាថា នែ៎ អ្នកតាព្រហ្មអ្នកកុំប្រហែស តាឆ្លើយថា អើនាងកេស នាងកុំបារម្ភ ទូកយើងមានបារមីធំ តែមួយភ្លែតយើងនឹងដល់ត្រើយ ចៃដន្យអាក្រក់សត្វឆ្លាមបានកាត់ទូកតាយាយដាច់ជាពីរកំណាត់ មួយកំណាត់មុខរសាត់លឿនស្នេវមកដល់ត្រើយក្រុងអង្គរ មួយកំណាត់ខាងកន្សៀងរសាត់ទៅក្រុងលង្វែកវិញ។ ក្រោយពីនោះមក គេបានរក្សាទូកមួយកំណាត់នោះដោយសាងជារូបព្រះពុទ្ធគង់ឈរ ស្រោបទូកធ្វើជាស្នូលតំកល់ទុកក្នុងវិហារវត្តបរិបូណ៌ (ខេត្តកំពង់ឆ្នាំង) មួយកំណាត់ខាងក្បាល គេកសាងរូបព្រះពុទ្ធចូលនិពាន្ត ស្រោបទូកដូចគ្នាតំកល់ក្នុងវិហារវត្តព្រះព្រហ្មរតន៍មកដល់សព្វថ្ងៃ។ សូមបញ្ជាក់ជូនថា កាលឆ្នាំ១៩៨៧ លោកតាទេព វង្ស ស្តេចសង្ឃជំនាន់របបវៀតណាមគ្រប់គ្រង បានមានគំនិតមួយចង់លើកព្រះចូលនិពាន្តនេះតំកល់ឱ្យស្មើនឹងព្រះអង្គធំ) ក៏នាំគ្នាជីកចំកណ្តាលពោះគឺឃើញមានរូបព្រះតូចៗអំពីមាស ប្រាក់ សំរិទ្ធ

ល។ ក្រោយលោក អ៊ូង វ័ន ពេលត្រឡប់ពីសិក្សានៅបរទេសមកកាន់ស្រុកវិញ ឃើញដូច្នោះក៏បញ្ឈប់មិនឱ្យជីកតទៅទៀត ហើយយករបស់ទាំងនេះមកកប់វិញ។

- គួរយល់ថា មូលហេតុដែលគេមិនរៀបចំជួសជុលពីការកសាងវិហារថ្មីនោះ ព្រោះគេដឹងថា មានរបស់អាថ៌កំបាំងហើយ។

វិធានការណ៍របស់យើង ដើម្បីរក្សាកេរ្តិ៍ដំណែលប្រវត្តិសាស្ត្រនេះឱ្យបានគង់វង់រៀងរហូត កុំឱ្យប៉ះពាល់ គួរធ្វើជាស៊ីមកញ្ចក់ព័ទ្ធជុំវិញ ដាក់ខ្សែក្រវ៉ាត់មួយជាន់កុំឱ្យមនុស្សដើរជិត គឺឱ្យមើលពីចំងាយ។

ព្រះចូលនិពាន្ទនេះ ដូចជាព្រះកេស គឺគេរៀបគង្គស្រឡាយបាយអរទេ មិនអាចផ្លាស់ប្តូរ ឬ ជួសជុលអ្វីបានឡើយ បើចង់ជួសជុលគឺគ្រាន់តែស្រឡាយបាយអរពីក្រៅ លាបទឹកមាសជានហើយ (បើពុំ គឺខូចទាំងអស់ហើយ)។

**អ៊ូង វ័ន**

# ព្រះអង្គគោកធ្លក

ព្រះអង្គគោកធ្លកៈ ប្រសិទ្ធគោកធ្លក ៖ គឺតំណាងអោយប្រទេសកម្ពុជាសម័យអតីតកាល ហៅនគរគោកធ្លក (សម័យហ្វូណន)។

អង្គគោកធ្លកៈ បើពិនិត្យតិនភាគប្រហែលក្នុងរចនាបថបាយ័ន សម័យព្រះបាទជ័យវរ្ម័នទី៧។

- សម័យក្រោយអង្គរមានព្រះពុទ្ធបដិមាអំពីសិរីតចំនួន៥អង្គ ដែលមានបារមីហើយមាន មហិទ្ធិឫទ្ធិខ្លាំងពូកែដែរ មានប្រសិទ្ធនាមដូចខាងក្រោមៈ

១- ព្រះអង្គចេក ៖ (នៅមុខដំណាក់ខេត្តសៀមរាប)

២- ព្រះអង្គចម ៖ (នៅមុខដំណាក់ខេត្តសៀមរាប)

៣- ព្រះអង្គថ្មុំ ៖ (សព្វថ្ងៃនៅក្នុងឃ្លាំងអភិរក្សអង្គរ) នៅឆ្នាំ ១៩៩៣ គេបំរុងលួចយកមកវិញ រូបព្រះអង្គ គឺមានទឹកដម (សំនើមទឹក) កាលពីដើមលោកគ្រូចៅអធិការវត្តខាងត្បូងប្រកាន់ជាប់ ពេលលោកចង់មើលជម្ងឺ ឬ ស្រោចទឹកតែងយក ព្រះពុទ្ធអង្គសិរតដាក់ត្រាំទឹក ហើយស្រោចទឹកគឺមានប្រសិទ្ធភាពតាមបំណង។

៤- ព្រះអង្គចាន់ ៖ កប់បាត់រកមិនឃើញទេពីយូរមកហើយ នៅឆ្នាំ ១៩៧០ ប្រហែលសង្ស័យជាកប់ទុកក្បែរព្រះវិហារ វត្តអង្គរមិនដឹងដែរ។

៥- ព្រះអង្គចែម ៖ នេះត្រូវបានតាម្នាក់ឈ្មោះ តាខ្មែមសម័យនោះគាត់ធ្វើឥស្សរៈ គាត់បានយកព្រះអង្គចែមធ្វើអំពិសិរត សំរាប់ការពារខ្លួនពិព្រោះអង្គនេះមានមហិទ្ធិឫទ្ធិពូកែណាស់ដែរ។ លុះមកដល់ឆ្នាំ ១៩៧១ ឈ្មោះ តាខ្មែមរស់នៅភូមិ ក្លង់ ឃុំ នគរធំ ស្រុក សៀមរាប ខេត្ត សៀមរាប ឈ្មោះ តាខ្មែម ត្រូវបានពួកវៀនកុងចាប់យកទៅសម្លាប់ចោលបាត់ នៅតែព្រះពុទ្ធរូបនោះមិនដឹងជាគាត់លាក់ទុកនៅទីណាឡើយ ហើយបាត់រូបនោះរហូតមក។ ចំពោះព្រះអង្គច័ន្ទ និង ព្រះអង្គចែម ឃើញនៅឆ្នាំ ១៩៥៤ម្តង និង ឆ្នាំ ១៩៧០ តែក្រោយមកក៏បាត់ទៅ។

## អំពីប្រវត្តិរបស់បដិមារូប

# ព្រះអង្គចេក ព្រះអង្គចម

••••••

កាលពីដំបូងបដិមារូបអង្គចេក អង្គចម នៅនឹងប្រាសាទអង្គរវត្ត (វត្តព្រះពាន់)

**ប្រាសាទអង្គរវត្តៈ**

កាលបរិច្ឆេទនៃការសាងសង់ៈ ពាក់កណ្តាលទី១នៃសតវត្សទី១២ (គ.ស ១១១២) រាជ្យស្តេចៈ សុរិយាវរ្ម័នទី២

កំណើតប្រាសាទអង្គរវត្តៈ គេឧទ្ទិសថ្វាយ បរមវិស្ណុលោក

- នៅគ្រប់ទីកន្លែងក្នុងប្រាសាទអង្គរវត្តគេដកល់បដិមា ទេវរាជ្យ *គីរូបវិស្ណុ* ។

ឧទាហរណ៍ : - នៅប្រាសាទធំកណ្ដាល គេដកល់បដិមាទេវរាជ្យ គឺរូបវិស្ណុនៅចំកណ្ដាលប្រាសាទធំ ហើយបើកទ្វារចំហរទាំង ៤ ទិស ។

– ក្រោយមកគោរពព្រះពុទ្ធសាសនា មានព្រះសង្ឃដែលកាន់ព្រះពុទ្ធសាសនា ក្នុងកំឡុងឆ្នាំ ១៥០០ ទៅ ១៦០០ ព្រះសង្ឃបានបិតសន្ធប់ប្រាសាទនេះហើយឆ្លាក់បដិមារូបព្រះពុទ្ធគង់ឈរ ( លក្ខណៈវរមុទ្រ: Geste de charite )

– នៅឆ្នាំ ១៩០៨ លោក ហ្សង់ កំម៉ៃ ( JEAN COMILLE ) ជាអ្នកអភិរក្សទី១ បានចោះទម្លាយទ្វារខាងត្បូងក្នុងឆ្នាំ ១៩០៨ ដើម្បីធ្វើកំណាយ ។

– នៅឆ្នាំ ១៩៣៤ លោក ហ្សក ទ្រូវេ បានធ្វើកំណាយចំប្រាសាទកណ្ដាលនៅឆ្នាំ ១៩៣៤ ជម្រៅ ២៥ម ស្មើនិងកំរិតដីរាបរបស់បរិវេណប្រាសាទខាងក្រៅ បាះខ្សាច់បញ្ចេញមកក្រៅដើម្បីសិក្សាស្រាវជ្រាវរកកេតនភ័ណ្ឌ ផ្សេងៗ ។

– ក្នុងកំរិត ២៣ម រកឃើញមាសសន្លឹករាងមូលវិជ្ជមាត្រ ( Diametre ) ០.១៨ម ទម្ងន់ ៦៥ ក្រាម ដែលបានដាក់បង្កប់ក្នុងចន្លោះថ្មបាយក្រៀម ។

– ពេលកាន់សាសនាព្រះពុទ្ធ មានព្រះសង្ឃកាន់កាប់អង្គរវត្ត ពេលនោះគេបានកសាងព្រះពុទ្ធរូបជាច្រើនសន្លឹកសន្ធាប់គ្រប់លក្ខណៈមុទ្រៈ សំរាប់ធ្វើសក្ការៈបូជា ក្នុងនោះមានបដិមារូបព្រះពុទ្ធអំពីឈើ ថ្មភក់ ស្ពាន់ សំរិទ្ធ ។ល។ នៅពេលកសាងរួចតែងយកទៅដកល់នៅរូបព្រះពាន់ និង ធ្វើអំពីអភិសែកទៅតាមទំនៀមទម្លាប់ និង ប្រពៃណីនៃសាសនា ។

– បដិមារូបព្រះអង្គចេក ព្រះអង្គចម គេបានកសាងអំពីសំរិទ្ធលាយលង្ហិន ជាលក្ខណៈវរមុទ្រ: ( Geste de charite) ជាលក្ខណៈអប់រំអោយមានចិត្តសប្បុរស ។

– ព្រះអង្គគង់ឈរ ដៃឆ្វេងដាក់សំយ៉ុងចុះ ដាក់តាមបណ្ដោយដងខ្លួន ព្រះហស្ដស្ដាំលាទៅមុខ ។ លក្ខណៈត្រង់នេះ និយាយអំពីព្រះអង្គ យាងទៅប្រោះពុទ្ធមាតា នៅស្ថានត្រៃត្រឹង ព្រះអង្គយាងទៅយូរពេកគេកសាង បដិមារូបជំនួសព្រះអង្គគង់លើបល្ល័ង្គ ដល់ព្រះអង្គត្រឡប់មកវិញ បដិមារូបនោះរំកិលចុះពីលើបល្ល័ង្គព្រះអង្គ រាព្រះហស្ដខិតថា នែបដិមារូប កុំចុះទៅណា នោកន្លែងដដែលហើយ ។

លក្ខណៈខុសប្លែករបស់ព្រះអង្គចេក ព្រះអង្គចម:

មានលក្ខណៈ មុទ្រៈ ដូចគ្នាតែអង្គមួយរាដៃស្ដាំ និង អង្គគង់មួយទៀតរាដៃឆ្វេង ក្រោយការសាងរួច ប្រហែលម្ចាស់ដើម ដែលជាបុព្វបុរសដូនតាយើង បានរៀបចំធ្វើពិធីឧបសេកខុសពីធម្មតា ហើយទើបមានបារមី និង មហិទ្ធិរិទ្ធមកសណ្ឋិតនឹងរូបនេះ ( គឺមានបារមីខ្លាំងពូកែជាងព្រះដទៃទៀត ) ។ ដោយសារការជឿជាក់របស់មហាជនផងដែរ ។

<u>ឧទាហរណ៍</u>: ដូចនៅក្នុងព្រៃ ឬកន្លែងណាមួយ មានមនុស្សម្នាក់រំលឹកដល់អ្វីមួយ ហើយកាន់អ្វីធ្វើជាសំគាល់ដោយក្រោយៗមកទៀត ធ្វើដូចគ្នា គឺច្បាស់ជាមានរូបអ្វីមួយមកសណ្ឋិតមិនខាន ( អរូបីយ៍ ) ។

បដិមារូបទាំងនេះ គឺបានយកមកដកល់នៅរូបព្រះពាន់ ល្បីមានរិទ្ធបារមី បានដឹងឮដល់បារាំង ( កាលសម័យអាណានិគមនិយមបារាំង ) វាស្រាវជ្រាវចង់បានព្រះពុទ្ធអង្គចេក អង្គចមនេះ ដោយមានមូលហេតុគួរចាប់ អារម្មណ៍ដូច

តទៅនេះ

១- ព្រះពុទ្ធបដិមារូបនេះ ជារបស់បូរាណ ហើយមានរិទ្ធបារមីខ្លាំងពូកែ ។

២- ព្រះបដិមារូបនេះ ជាសិរីសួស្តីលាភលាភផង គោលបំណងធំរបស់គេ គឺយកទៅទុកនៅប្រទេសគេតែម្តង។ ព្រះតេជគុណព្រះចៅអធិការវត្ត វត្តអង្គខាងជើង ជាអ្នកស្នេហាសម្បត្តិវប្បធម៌ជាតិ យល់ពីភារកិច្ច និង ជាកតញ្ញូកិច្ច របស់ខ្លួន ជាអ្នកបន្តវេន ការពារ ថែរក្សា មរតកវប្បធម៌ អោយបានគង់វង្សទុកជាកេរដំណែលកូនចៅជាន់ក្រោយ ១ ។ ការបើក្តាប់ជាប់ទុរសែកពាក្យការណ៍នេះ ក៏ប្រញាប់ប្រញាល់លើកចេញពីរូបព្រះពាន់ អង្គវត្ត› ទៅទុកនៅ ព្រះវិហារវត្តខាងជើង នៅពេលបាក់ងទៅរកមិនឃើញក៏នាំគ្នាទៅវិញ តែការតាមដានរបស់វា នៅតែមានបន្តទៀត ។

- គ្រូមេគណៈវត្តមានការព្រួយបារម្ភខ្លាំង ពេញមួយខ្លាចបាត់បង់វត្ថុដ៏មានតម្លៃមិនអាចកាត់ថ្លៃបាន។
- ក៏រំដោះរូបនោះចេញពីព្រះវិហារ ( ដោយអោយអាចារ្យវត្តយកទៅលាក់នៅពាក់ស្វែងទៅ› ។
- ក្រោយមកបាក់ងដឹងថា នៅព្រះវិហារវត្តខាងជើង វានាំគ្នាទៅតែករអេររកមិនឃើញទៀត ។
- សម័យដាបឈូន វិទ្ធិមេឥស្សរៈរស់នៅក្នុងព្រៃមុនឆ្នាំ ១៩៦០ គឺមុនសម័យសម្តេចឪទាមទារឯករាជ្យឆ្នាំ ១៩៥៤ ដាបឈូនក្តាប់បាន ក៏យកពុទ្ធអង្គទាំងពីរអង្គនេះទៅលាក់ទុកនៅឃុំស្តៅ ស្រុកបន្ទាយស្រីឃើងសព្វថ្ងៃនេះ ក្នុងខេត្តសៀមរាប ។
- យកទៅលាក់ទុកនៅក្បែរទួលបុរាណមួយ › ទួលប្រាសាទចាស់ទ្រុឌអស់›ក្បែរដើមធ្នូកមួយដួល ‹ ក្រោយមកស្រាប់តែដើមធ្នូកនោះចេះរៀវ ទើបគេអោយឈ្មោះកន្លែងនោះថា ទួលធ្នូករៀវ› ។
- ដោយសារបារមី និង ការជឿជាក់លើព្រះអង្គ ទើបបារមីនេះជួយការពារដាបឈូនរៀងរហូត ពេលមានការចេញទល់នឹងបាក់ង។
- ក្រោយមកបាក់ងស្រាវជ្រាវដឹងទីកន្លែងលាក់ទៀត ដាបឈូនកាលនោះអាចបិលិព្រះអង្គបាន ‹ គឺសំពល› អោយបិបាន។› ម្យ៉ាងទៀតដាបឈូន បានស្បថស្បែរចំពោះព្រះភ័ក្ត្ររបស់ព្រះអង្គទាំងពីរអង្គថា: មិនក្បត់ ជាតិទេ› ។
- ក្រោយមកទៀត ពេលដែលដាបឈូនក្បត់ជាតិ ‹ កំឡុងឆ្នាំ ១៩៥៨›រត់ចូលព្រៃវិញ ពេលនោះទៅយកព្រះអង្គចេក ព្រះអង្គចមទៅជាមួយ ( ពេលនោះគឺលើកមិនរួចឡើយ› ព្រោះវាក្បត់ពាក្យសម្បថខ្លួនឯង។
- ក្រោយមកដាបឈូនគេសម្លាប់ទៅសម្តេចឪ ‹ ព្រះបាទនរោត្តម សីហនុវ៉ែន› បានអោយចៅហ្វាយខេត្តសៀមរាប ទៅដឹកយករូបមកតំកល់នៅមុខដំណាក់របស់ព្រះអង្គ ខាងជើងផ្ទាល់ត្រង់វិហារសព្វថ្ងៃនេះ រហូត ដល់ឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ប៉ុល ពត បានដាក់មិនដើម្បីកំទេចចោល តែចេតិយ៍ និង វិហារតើត្រូវខ្ទេចខ្ទីអស់ នៅតែតួអង្គចេក អង្គចម តែពីរអង្គតែប៉ុណ្ណោះ ‹ អ្នកដែលដាក់មិននោះត្រូវឈឺស្លាប់អស់មួយចំនួនទៀតហើយពួកវាបានដឹកយកទៅដាក់នៅវត្តដំណាក់ ហើយបំរុងយកទៅទុកនៅប្រទេសចិន ពេលរៀបចំលើកដាក់ឡាន CMC តែឡានមិនឆេះលើកមិនរួចទៀត ពេលលើកដាក់រួច បែរជាឡានមិនឆេះវិញអស់ចិត្តអស់ចង់ ទាហានខ្មែរក្រហមក៏លើកព្រះពុទ្ធអង្គមកដីវិញមួយអង្គដួល មួយអង្គទៀតឈរ វាយកមិនមកដាក់ ទៀតតែពេលនោះមីនមិនផ្ទុះទើបវានាំគ្នាយកព្រះអង្គទៅទំលាក់ស្រះ

ខាងត្បូងព្រះវិហារ ( វត្តដំណាក់ ) ចោលទៅ។

- នៅឆ្នាំ ១៩៧៩ - ១៩៨០ គេស្រាវជ្រាវរកព្រះអង្គឃើញ ( ជំនាន់រដ្ឋកម្ពុជា ) បានដង្ហែព្រះអង្គទុកនៅសាលាធម្ម ( វត្ត ដំណាក់សំរាប់ធ្វើសក្ការៈ ) ។

- នៅឆ្នាំ ១៩៨៧ ប្រជាពលរដ្ឋគ្រប់ស្រទាប់ជាន់ថ្នាក់ ចង់បានសន្តិភាព ក៏នាំគ្នាធ្វើពិធីបុណ្យមួយតាមប្រពៃណីយ៍ នៃព្រះពុទ្ធសាសនា ហើយដង្ហែព្រះអង្គមកកាន់កន្លែងដើមវិញ ពេលកសាងព្រះវិហាររួច គឺមានបញ្ហា ដែរ ដំបូងព្រះវិហារដាក់នៅខាងលិចដំណាក់ ខាងកើតស្នងការដ្ឋាននគរបាល ខេត្តសៀមរាប ពេលនោះបាន ពន្យល់សប្តិអ្នកម្ចាស់សាងសង់ គឺមិនអោយដាក់នៅកន្លែងនោះទេ គឺអោយដាក់នៅកន្លែងដើមវិញ ទើបគេ កសាងព្រះវិហារនៅកន្លែងដើមមួយទៀត។

បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

# ប្រវត្តិសង្ខេបនៃព្រះវិហារប្រាំពីរល្វែង

ក្នុងរជ្ជកាលរបស់ព្រះបាទជ័យវរ្ម័នទី ៧ គឺបានកសាងស្នាដៃយ៉ាងច្រើននៅកម្ពុជរដ្ឋយើងនេះ ខ្ញុំសូមលើកយកឧទាហរណ៍ : នៃការកសាងប្រាសាទបាយ័នមួយជាបទពិសោធន៍ :

- កាលបរិច្ឆេទ : ចុងសតវត្សទី ១២ ដើមសតវត្សទី ១៣ ( កំឡុងគស: ១១៨១-១២២០ )
- លទ្ធិសាសនា : ព្រះពុទ្ធសាសនាមហាយាន ( ជ័យពុទ្ធមហានាថ ) ឬ ទេវរាជ គឺជាអ្នកថែរក្សាលោក
- កសាងជាបីជាន់ មានកំពស់ ៤៥.០០ម គិតពីបាតក្រោមដល់កំពូលលើក្នុងផ្ទៃដី ៩.០០ហិចតា ដោយមិនបានគិតពីស្រះព័ទ្ធជុំវិញ ។
- ជាន់និមួយៗមានកំពូលដូចតទៅ :
- ជាន់ទី ១ ( ខាងលើ ) មានកំពូលចំនួន ១៧ កំពូល
- ជាន់ទី ២ មានកំពូលចំនួន ២៩ កំពូល
- ជាន់ទី ៣ ( ជាន់ក្រោម ) មិនមានកំពូលទេ គឺមានតែដំបូលកោង ( Voutre ) តែប៉ុណ្ណោះ
- សរុបកំពូលប្រាសាទបាយ័នមានកំពូល ៤៦ បើរាប់បញ្ចូលក្លោងទ្វារខាងក្រៅ ( គោបុរៈផ្នែកខាងក្រៅ ) ទាំងប្រាំផង មានកំពូល ៥១ មានមុខលោកេស្វរៈ ចំនួន ៤០៤ មុខ ។
- តាមឯកសារបញ្ជាក់ខុសៗគ្នា ដូចខាងក្រោម :-
- ឯកសារខ្លះថាមានកំពូល ៤៩ កំពូល
- ឯកសារខ្លះថាមានកំពូល ៥២ កំពូល
- នឹងឯកសារខ្លះទៀតថា មានកំពូលសរុប ៥៤កំពូល តាមឯកសារប្លង់លំអិតនៃប្រាសាទបាយ័ន គូរដោយលោក JACS Dumacey គឺមានតែ ៥១កំពូលប៉ុណ្ណោះ ដោយមិនបានគិតដល់គោបុរៈទាំង ៥ ខាងក្រៅ ។
- កំពូលទាំងអស់ជានិមិត្តរូបនៃខេត្តទាំងអស់ នៃព្រះរាជាណាចក្រកម្ពុជា នាសម័យកាលនោះ ។
- ប្រាសាទបាយ័ននេះ តាំងនៅចំកណ្ដាលទីក្រុងនគរធំឈ្មោះ " យសោធគិរី " ប្រែថាភ្នំទ្រទ្រង់ដោយបរស្ទ ។
- ក្រុងនគរធំមានផ្ទៃក្រឡាទំហំ ១២គម² ក្នុងមួយជ្រុងប្រវែង ៣គម មានកំពែងព័ទ្ធជុំវិញកំពស់ ៨ម " ហៅថាជ័យគិរី " ប្រែថាជ័យជំនះនៅក្រៅកំពែងមានស្រះទឹកព័ទ្ធជុំវិញ " ហៅថាជ័យសិន្ធុ " ប្រែថា មហាសមុទ្រជ័យជំនះ ។
- ប្រាសាទបាយ័ន បើមើលពីចម្ងាយដូចឃើញរូបព្រហ្មតែមួយគត់ លុះចូលទៅដល់ជិតឃើញរូបព្រហ្ម ដោយឡែកៗពីគ្នា ។

ប្រាសាទបាយ័នទ្រង់ទ្រាយហាក់មានឫទ្ធិអស្ចារ្យ ទ្រង់ទ្រាយល្អឆើតទំខ្ពស់ស្គឹមស្គៃសម្បើម និង ឃើញកំពូលប្រជែងប្រាងខ្ពស់ត្រដែត ( លោកេស្វរៈធំៗ ទឹកមុខញញឹមប្រិមប្រិយ៍ បែរមុខមករកយើង ហាក់បីដូចជារង់ចាំទទួលភ្ញៀវជាតិ និង អន្តរជាតិយ៉ាងរាក់ទាក់ មើលមុខទិសខាងណាក៏ដូចទិសខាងណា ! យើងមុខញញឹមពព្រាយនាំអោយយើងសប្បាយរីករាយ និងភោគស្ងប់ស្ងៀងពីវិវាទេពកោសល្យ នៃស្ថាបត្យកម្មដូនតារបស់យើង ។

- តាមទស្សនៈមួយទៀត ក្នុងចំណោមរូបទាំងអស់នេះ ស្តេចជ័យវរ្ម័នទី ៧ កាន់ព្រះពុទ្ធសាសនា ព្រះអង្គមានចិត្តករុណាធម៌ មេត្តាអាណិតអាសូរច្រើន ។ ហើយសេចក្តីអាណិតអាសូររបស់ស្តេចជ័យវរ្ម័នទី ៧ ផ្សាយទៅទិសទាំង ៤ ហៅថា ព្រហ្មវិហារធម៌ :-

- មេត្តា : សេចក្តីរាប់អាន
- ករុណា : សេចក្តីអាណិត
- ឧបេក្ខា : សេចក្តីស្មោះស្មើ
- មុទិតា : សេចក្តីត្រេកអរចំពោះមុខ

- ទិសទាំង ៤ តំណាងអោយធាតុទាំង ៤ ដែលមាន : ខ្យល់ ភ្លើង ធរណី មនុស្សបើគ្មានធាតុទាំង ៤ នេះទេ គឺមិនអាចរស់នៅលើផែនដីបានឡើយ ។

- ប្រាសាទបាយ័នជានិមិត្តរូប នៃការវិលចុះវិលឡើងរបស់ផែនដី បើយើងមើលពីព្រឹកថ្ងៃរះពីកើត មុខលោកេស្វរៈមុខខាងលិចមានម្លប់ ចំណែកមុខចំហៀងសងខាង ទៅតាមពេលវេលា ទៅតាមខែ និង រដូវរបស់ស្រុកយើង ។

- ពេលថ្ងៃដើរត្រង់ពីលើ ពេលខ្លះដើរឈៀងខាងត្បូង ពេលខ្លះដើរឈៀងខាងជើង ពេលណាថ្ងៃរះជុំត គឺមុខខាងជើងត្រូវពន្លឺថ្ងៃជាង ខាងត្បូងម្លប់បន្តិច ហើយខាងកើតថ្ងៃរះខាងលិច ថ្ងៃលេចជាធម្មតា ។

- ទស្សនៈមួយទៀត ព្រះពីដើមធ្លាប់សោយរាជ្យជាស្តេចចក្រពត្តិ កាន់បាតសុំទានគេ ហើយប្រជារាស្ត្រមិនគោរពព្រះអង្គសំដែងបរិហារកើតជាព្រះពុទ្ធ ១០០០អង្គ អណ្តែតត្រសែតពេញវេហា ។

- ពេលយើងឡើងដល់រោងទងទី ១ ( ខាងលើបង្អស់ ) ហាក់ដូចជាយើងនៅចំកណ្តាលហ្វូងមនុស្សច្រើន ។

- ពេលនោះអាណាចក្រកម្ពុជាមានការច្របូកច្របល់ ដោយសារប្រទេសជិតខាងពន្លានពាន ( សង្គ្រាមសាសនា ) ទើបប្រាសាទបាយ័នកសាងច្រើនស្តេច ដែលចែកចេញជា ៣កាលគឺ :-

- កាលព្រះបាទយសោវរ្ម័ន
- កាលព្រះបាទជ័យវរ្ម័នទី ៧
- កាលចាមលើកទ័ពមកវាយលុកយកក្រុងនគរធំនៅឆ្នាំ ១១៧៧

- ក្រោយមកព្រះបាទជ័យវរ្ម័នទី ៧ បានចាកចេញពីក្រុងនគរធំទៅកសាងរំដោះជាតិវិញ អស់រយៈពេល ៤ឆ្នាំ ហើយបង្រួបបង្រួមជាតិរហូតដល់ឆ្នាំ ១១៨១ និង បណ្តេញចាមអស់ពីក្រុងនគរធំ ទើបរៀបចំក្រុងឡើងវិញ និង រៀបចំកសាងប្រាសាទខ្លះៗបន្ថែមលើសំណង់ចាស់ ដើម្បីកែទម្រង់ប្រាសាទអោយទៅជាប្រាសាទក្នុងរជ្ជកាលរបស់ព្រះអង្គ ។

- យើងដឹងហើយថា ប្រាសាទបាយ័ននេះ កសាងក្រោយប្រាសាទអង្គរវត្ត ( មានការទ្រុឌទ្រោមខ្លាំងជាងប្រាសាទអង្គរវត្ត ) ។

- ក្រោយពេលរំដោះជាតិបានពីចាម មានការបង្រួបបង្រួមជាតិនោះ ប្រជារាស្ត្រខ្មែរមានការនឿយណាយនឹងសង្គ្រាម អ្នកឯកទេសមានបទពិសោធន៍ខ្ពស់ មានការនឿយណាយ ពេលនោះការកសាងប្រាសាទគិតគូរតែខាងបរិមាណ មិនទាន់គិតគូរដល់គុណភាព អាចធានានឹងធម្មជាតិបានទេ ។ យើងឃើញនឹងភ្នែក ហើយសម្ភារៈថ្ម គឺគ្រាន់តែយកថ្មដែលនៅសេសសល់ពីប្រាសាទនានា ( ដែលមានដុំតូចៗ ) យកមកកសាង មិនអាចធានាគុណភាពយូរអង្វែងឡើយ ។

- ពេលគ្មានភ្លៀងរាំងស្ងួត គេតែងតែធ្វើពិធីបន់ស្រន់សុំអោយមានភ្លៀង ពេលធ្វើពិធីរួច ភ្លៀងធ្លាក់ជោគជាំដូចសេចក្តីប្រាថ្នា ទើបប្រជារាស្ត្រជឿជាក់ពពាក់ ។

- រួមសេចក្តីមក យើងអាចសន្និដ្ឋានបានថា : ប្រាសាទបាយ័នកសាងដើម្បី ឧទ្ទិសថ្វាយព្រះពោធិសត្វលោកេស្វរៈមានមុខ ៤ ជាទីសំអាងក្នុងពុទ្ធសាសនាមហាយាន ។

- នៅឆ្នាំ ១៩៣១ លោកហ្សេកទ្រូវ៉ែ ជាអ្នកអភិរក្សទី ៣ ( 3ème Conservateur en france ) បានធ្វើកំណាយក្នុងកំឡុងឆ្នាំ ១៩៣៣ ចំកណ្តាលប្រាសាទធំ ( កណ្តាល ) Tour sanctuair central ) ជម្រៅ ១៤ម ស្មើនឹងកំរិតដីរាបស្មើរបស់ប្រាសាទ បានយកដីចេញទៅក្រៅ ដើម្បីសិក្សាស្រាវជ្រាវរកកេរតំណែផ្សេងៗ តែនៅក្នុងនោះគេរកឃើញព្រះពុទ្ធបដិមាមួយព្រះអង្គ អំពីថ្មភក់ បាក់បែកមានកំពស់ ៣,៦០ម បានយកមកផ្គុំផ្គងឡើងវិញ រួចយកទៅថ្វាយព្រះមហាក្សត្រ ស៊ីសុវត្ថិមុនីវង្ស នៅថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៩៣៥ ។ កាលនោះព្រះអង្គត្រាស់បង្គាប់អោយគេយកទៅតំកល់នៅព្រះវិហារ ៧ល្វែង រហូតដល់សព្វថ្ងៃនេះ ( គឺតាមបណ្តោយផ្លូវទៅក្លោងទ្វារជ័យ ស្ថិតនៅខាងត្បូងផ្លូវក្រោយប្រាសាទសួរព្រ័ត្រ ។

ព្រះពុទ្ធអង្គព្រះវិហារ ៧ល្វែង ការយកទៅតំកល់នៅឆ្ងាយបន្តិចផង មនុស្សម្នាមិនសូវដឹងផង ឯការរៀបចំធ្វើពិធីសក្ការៈបូជាផ្សេងៗតាមទំនៀមទំលាប់ នៃព្រះពុទ្ធសាសនា បច្ចុប្បន្នគឺមនុស្សមានតិចតួចដែរ តែខ្មែរឥឡូវជឿលើជំនឿរូបិយ័ជាង ។ ឯបារមីកាន់ទាន់ តែមនុស្សជឿថាជារបស់សក្តិសិទ្ធិខ្លាំង ឯការធ្វើពិធីទាល់តែបារមីនោះផ្តល់អោយឃើញនូវអ្វីដែលគួរអោយគេជឿដែរ ជាមួយមនុស្សមិនសូវជឿបារមី ក៏មិនមកកាន់ដែរ ។

- ការបង្រួបបង្រួមសាសនា ពីព្រហ្មញ្ញសាសនាមកព្រះពុទ្ធសាសនា គឺកែទម្រង់បន្តិចម្តងៗ ពេមគ្រប់រូបភាព ។ កាលនោះគោរពពោធិសត្វ ដូចជា ពោធិសត្វអាវលោកេស្វរៈ ( AVALOKITEÇVARA Vradiant ) រូបលោកេស្វរៈមានរូបព្រះពុទ្ធ ( ពុទ្ធរូប ) លើក្បួងហៅថា AMITABHAHA ។ ដើម្បីគោរពបូជាទាំងអស់គ្នា តែក្រោយៗមកបានលួចកសាងពុទ្ធបដិមារូបព្រះពុទ្ធដំកល់នៅប្រាសាទបាយ័ន ពិសេសប្រាសាទដែលកសាងដោយព្រះបាទជ័យវរ្ម័នទី ៧ គឺគេច្រើនដំកល់រូបព្រះពុទ្ធអំពីថ្មភក់ ធ្វើអោយលេចធ្លោរហូតដល់អ្នកកាន់ព្រហ្មញ្ញសាសនា មានការចាប់អារម្មណ៍ ក៏ចាប់ផ្តើមរើបម្រាស់ចេញពីពុទ្ធសាសនាវិញ កាលនោះព្រះបាទជ័យវរ្ម័នទី ៧ បានធ្វើអោយប្រជារាស្ត្រជំនឿខ្លាំងលើសាសនា ដើម្បីជាតិមាតុភូមិ មានឥន្ទិតសាមគ្គីភាពល្អ ប្រកបដោយភាពស្មោះត្រង់ ។

ជំនឿរបស់មនុស្សជាអង្គឯកភាពមួយសក្តិសិទ្ធបំផុត ដែលបង្កើតបាននូវសេចក្តីសុខសុភមង្គល ( សម័យមុនគ្រិសករាជ ) ( ព្រោះមនុស្សជឿលើធម្មជាតិ ធាតុអាកាស មេឃដី ទឹកខ្យល់ ពពកភ្លៀងផ្គររន្ទះ គេមានជំនឿថា គេនឹងទទួលបាននូវសេចក្តីសុខ សេរីសួស្តីរបស់គេ ហៅថា លទ្ធិជីវចល ) ជំនឿលើសាសនាយ៉ាងមុតមាំ បើនិយាយពីជីវភាពរបស់ប្រជារាស្ត្រខ្ពស់ ( គេជឿលើខ្លួនគេ ) ព្រះអង្គគិតគូរដល់ប្រជារាស្ត្រធំជាងផលប្រយោជន៍របស់ព្រះអង្គ មានមន្ទីរពេទ្យសំរាប់ព្យាបាល ( មានថ្នាំដង្កូវគ្រប់មុខ គឺយកពីធម្មជាតិសុទ្ធសាធ ) ។ ហើយប្រទេសមានវប្បធម៌ និង អារយធម៌ខ្ពង់ខ្ពស់ណាស់ មានការដាក់ទុកនៅគ្រប់បណ្តាប្រទេស ពិសេសប្រទេសជិតខាង ការនាំចូលតិច សំរាប់តម្រូវការរបស់ប្រជារាស្ត្រ ឯការនាំចេញទៅក្រៅប្រទេស គឺមានច្រើន ) គុណភាពអាចមានកំពូលច្រើន ពីក្រៅប្រទេសសួយសារអាករពីប្រទេសចំណុះ បានមកជារាល់ឆ្នាំ ។ ទើបប្រទេសជាតិទទួលបានស្ថេរភាពនយោបាយ ហើយទទួលបានសុខសន្តិភាព ។ តែក្រោយៗមកទៀត អ្នកកាន់ព្រហ្មញ្ញសាសនា ដឹកនាំទិតរបស់ព្រះបាទជ័យវរ្ម័នទី ៧ ក៏ចាប់ផ្តើមរើបំរាស់ជាបន្តបន្ទាប់ ក៏ទទួលបានជ័យជំនះវិញទៅ ។ អ្វីៗដែលជាស្នាដៃរបស់ស្តេចជ័យវរ្ម័នទី ៧ ត្រូវបានស្តេចជ័យវរ្ម័នទី ៨ កំទេចចោលទាំងអស់ ដូចព្រះពុទ្ធគេវាយកំទេច ឬ យកទៅកប់ចោលតាមអន្លង់ក្បែរៗប្រាសាទ បាយសីអាកាសលើដំបូលប្រាសាទ ដែលមានរូបព្រះពុទ្ធ គឺដាច់ចោលទាំងអស់ កន្លែងខ្លះកែទម្រង់ទៅជាលិង្គរាជ ឧទាហរណ៍ដូចជាព្រះវិហារ ៧ល្វែង កាលពីដើមគេដំកល់នៅកណ្តាលប្រាសាទបាយ័ន ត្រូវបានព្រះបាទជ័យវរ្ម័នទី ៨ វាយបំបែកអោយខ្ទេចខ្ទាំ ហើយជីកអន្លង់កណ្តាលបាតប្រាសាទបាយ័ន យកបំណែកទាំងនោះទៅទំលាក់ចូលក្នុងអន្លង់ ហើយយកដីមកលុបអោយពេញស្មើវិញ ( ព្រះពុទ្ធបដិមារូបព្រះពុទ្ធប្រក់នាគមានកំពស់ ៣.៦០ម ឯព្រះពុទ្ធអង្គ ៣អង្គទៀតតំកល់សំរាប់ជាទីគោរពបូជានៅប្រាសាទបន្ទាយទ័ព ( ស្រុកថ្មពួកខេត្តបន្ទាយមានជ័យ ) ចំនួន ៣អង្គ អំពីថ្មភក់ក៏មានបារមីសក្តិសិទ្ធណាស់ដែរ ប្រជាជនមានជំនឿលើព្រះទាំង ៣នេះ ទោះចោរលួចយកចេញទៅ គឺមិនបានឆ្ងាយ ត្រូវសមត្ថកិច្ចចាប់បានយកមកវិញដែរ ។ បច្ចុប្បន្នមួយអង្គធំ យកមកតំកល់នៅវត្តរលំថ្ងៃ និង វត្តស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ( បច្ចុប្បន្ននេះ ត្រូវបានសម្តេចសង្ឃរាជ្យ ទេព វង្ស ធ្វើការកសាងជាតួអង្គព្រះធំ ( អំពីស៊ីម៉ង់តិ៍ ) យកមកតំកល់នៅមុខប្រាសាទបន្ទាយឆ្មារ មានកំពស់ ២.៦០ម នៅឆ្នាំ ២០០៣ ។

- ជាប្រចាំពេលលើកទ័ពទៅច្បាំង និង ធ្វើពិធីផ្សេងៗ គេតែងបន់ស្រន់តាមទំនៀមទំលាប់ នៃព្រះពុទ្ធសាសនា ឬនៅពេលចេញទៅធ្វើសឹក ឬ ប្រសិទ្ធីផ្សេងៗមុនពេលចេញទៅធ្វើសឹក ពេលត្រឡប់មកវិញ គឺទទួលបានជ័យជំនះ ( ស្លាប់ និង របួសតិចបំផុត ) មនុស្សមានជំនឿពេលចេញ គឺអង្គអាចក្លាហានបំផុត ទើបច្បាំងឈ្នះចាម ទើបគេអោយកសាងក្លោងទ្វារថ្មីមួយទៀត ហៅថា ក្លោងទ្វារជ័យ ចំមុខព្រះលានទៅដល់ក្លោងទ្វារជ័យ ទើបក្លោងទ្វារអង្គរធំមានសរុបចំនួន ៥ ។

រឿងព្រេង-និទានខ្មែរ

# រឿងនាងកែវប្រាំពីរពណ៌ និង វត្តចេតិយ

តាមការតំណាលពីប្រវត្តិវត្តចេតិយ គឺ មានដើមកំណើតពីរឿង នាងកែវប្រាំពីរពណ៌ ។ ខ្ញុំបាទឈ្មោះ **អ៊ុង-ហៀន** ពេលដែលបានស្តាប់ចាស់ៗនិទានរឿង នាងកែវប្រាំពីរពណ៌នេះ ខ្ញុំបាទហាក់ដូចជា-មានអារម្មណ៍ជិតជាប់ទៅលើដំណើរនៃសាច់រឿងនោះណាស់ ជាពិសេសចាប់អារម្មណ៍ទៅលើ បណ្តាគោលដៅទាំងឡាយ លើផ្ទៃភូមិសាស្ត្រដ៏ទូលំទូលាយ ដែលជាប់ទុកជាមត៌កនៃដំណើររឿង ជាសក្ខីភាព មានមកដល់សព្វថ្ងៃនេះ ។ អាស្រ័យហេតុនេះហើយទើបខ្ញុំបាទ ខិតខំប្រមែប្រមូលនូវពាក្យតំណាលដោយផ្ទាល់មាត់ជាច្រើន ខ្លះជាកំណិតកំណាត់ ខ្លះវែងអន្លាយឆ្ងាយលន្លង់លន្លោច ជួនកាលក៏ដូចគ្នា ជួនកាលក៏មានសភាពប្រហាក់ប្រហែលគ្នា យកមកតំរៀបផ្គូផ្គងចងក្រងឱ្យកើតបានជាសាច់រឿងនេះឡើង ។ ចំណែកឯឯកសារជាសាស្ត្រាស្លឹករឹត ឬ ជាសៀវភៅផ្សេងៗនោះ គឺ ខ្ញុំបាទពុំដែលបានឃើញទេ។ ប៉ុន្តែទោះបីជាមានឯកសារជាសាស្ត្រាស្លឹករឹតក្តី ឬ ជាសៀវភៅផ្សេងៗក្តី ក៏ប្រហែលជាមិនអាចស្ថិតស្ថេរគង់វង់បានរហូតមកដល់សព្វថ្ងៃនេះដែរ ពីព្រោះប្រទេសជាតិយើងត្រូវបាន ទទួលរងនូវគ្រោះមហន្តរាយ និង ការបំផ្លិចបំផ្លាញដោយសារភ្លើងសង្គ្រាម ជាច្រើនលើកច្រើនសារ រាប់មិនអស់មកហើយ ។

តាមការតំណាលនៃដំណើររឿងនេះមកថា : ក្នុងយុគសម័យមួយ នៃ សម័យអង្គរ គឺ ក្នុងសម័យដែលកសាងប្រាសាទអំពិតផ្ទ និង ថ្មបាយក្រៀម មានស្តេចមួយអង្គព្រះនាមកងចក្រ សោយរាជ្យសម្បត្តិនៅរាជធានីអង្គរ ទ្រង់មានព្រះរាជបុត្រីមួយព្រះអង្គព្រះនាម នាងកែវប្រាំពីរពណ៌ ។ ហេតុដែលព្រះនាងទ្រង់មានព្រះនាមដូច្នេះ ពីព្រោះជាការសក្តិសមទៅ នឹង ព្រះរូបសម្បត្តិ ដ៏ល្អឥតខ្ចោះ មានសម្រស់លើសលប់ ប្រែប្រួលផ្លាស់ប្តូរបានប្រាំពីរពណ៌ ក្នុងមួយថ្ងៃ ព្រះនាងទ្រង់មានសម្ផស្សល្អជាងគេនៅក្នុងនគរ ។ មានថ្ងៃមួយនោះ ព្រះនាងទ្រង់បានយាងទៅកំសាន្តព្រៃ ទ្រង់ក៏រើសបានពងក្រពើមួយយ៉ាងធំ ខុសប្លែកពីពងក្រពើទាំងពួង ព្រះនាងទ្រង់មានសេចក្តីត្រេកអរយ៉ាងខ្លាំង ហើយព្រះនាងក៏យក ពងក្រពើនោះទៅភ្ញាស់ទុកគ្រាន់នឹងបិញ្ចឹម ។

លុះពងក្រពើនោះញាស់មក ព្រះនាងទ្រង់សព្វព្រះហឫទ័យ និង កូនក្រពើនោះណាស់ ។ ព្រះនាងបានសុំព្រះរាជានុញ្ញាត ពីព្រះវររាជបិតា ដើម្បីធ្វើអាងបិញ្ចឹមក្រពើនោះ នៅក្នុងអាងបារាយណ៍ទឹកថ្លា ត្រង់កន្លែងទីទួលកោះប្រាសាទមេបុណ្យ ។ ដោយព្រះនាងកាន់តែសព្វព្រះហឫទ័យ និង កូនក្រពើនោះ ព្រះនាងក៏បានផ្គត់ផ្គង់ចំណីអាហារ បិញ្ចឹមបីបាច់ថែរក្សាកូនក្រពើ ដោយស្នាព្រះហស្ថអង្គឯងផ្ទាល់ ហើយទ្រង់បានដាក់ឈ្មោះឱ្យក្រពើនោះថា អាថុន ។

ពេលវេលាកន្លងផុតទៅមិនយូរប៉ុន្មាន អាថុនក៏បានរីកចំរើនធំធាត់ជាល់ដាប់ ហួតដល់ទៅធំណាស់ ធំលើសក្រពើផងទាំងពួង ។ អាថុនចេះស្គាល់ និង មានភក្ដីភាពចំពោះព្រះនាងជាម្ចាស់របស់វាណាស់ ។ វាតែងតែបង្ហាញ នូវ ភាពស្មូតបូតចំពោះព្រះនាង ធ្វើឱ្យព្រះនាងកាន់តែស្និទ្ធស្នាលជាមួយវាជានិច្ច រហូតដល់ទ្រង់ហ៊ានយាងជិះលើក្បាលវា ធ្វើជាព្រះទីនាំង កំសាន្តលើផ្ទៃទឹកបាពាយណ៍ទៀតផង ។

លុះអំណឹះតមក អាស្រ័យដោយឥទ្ធិពលព្រះរូបឆោមលោមពណ៌ និង សម្ផស្សដ៏ល្អលើសលប់របស់ព្រះនាង ក៏បានល្បីខ្ចរខ្ចាយខ្ទរខ្ទារទ្វីសុះសាយរហូតដល់នគររាជគ្រឹះ បណ្ដាលឱ្យរាជបុត្រាស្ដេចក្រុងចិន សព្វព្រះហឫទ័យ ចំពោះព្រះនាងជាខ្លាំង ។ បន្ទាប់ពីបានទទួលរាជានុញ្ញាតពីព្រះវររាជបិតា មាតា របស់ព្រះអង្គរួចហើយ នគររាជគ្រឹះ ក៏ បានរៀបចំជាក្បួននាំជំនួនយ៉ាងគគ្រឹកគគ្រេង ចូលមកចងស្ពានមានមេត្រី ស្ដីដណ្ដឹងយកព្រះនាងកែវប្រាំពីរពណ៌ ដើម្បីធ្វើជាព្រះរាជអគ្គមហេសី ។

ចំណែកឯព្រះបាទកងចក្រ ក៏ទ្រង់ព្រះរាជានុញ្ញាតយល់ព្រម ដើម្បីរៀបអភិសេកព្រះរាជបុត្រីនាងកែវប្រាំពីរពណ៌ ថ្វាយទៅព្រះរាជបុត្រាស្ដេចក្រុងចិន ទៅតាមប្រពៃណី ទំនៀមទំលាប់បរមបុរាណខ្មែរយើងនាសម័យកាលនោះ ។

ព្រះនាងកែវប្រាំពីរពណ៌ ក្រោយពីទ្រង់បានដឹងថា ព្រះនាងនឹងត្រូវមានព្រះស្វាមី ហើយនឹងត្រូវឃ្លាតឆ្ងាយពីអ្វីៗនៅក្នុងព្រះរាជនគរ ទៅគង់នៅនគររាជគ្រឹះ ដែលជានគរព្រះស្វាមី ព្រះនាងក៏ទ្រង់ព្រួយព្រះហឫទ័យ នឹកសោកស្ដាយអាលោះអាល័យអាថុន ជាខ្លាំងពន់ពេកណាស់ ។ នៅថ្ងៃមួយនោះ នាព្រឹកព្រាងស្វាងអរុណោទ័យ ព្រះនាងទ្រង់បានទូលសុំព្រះរាជបិតា ដើម្បីយកចំណីអាហារទៅឱ្យអាថុនជាលើកចុងក្រោយ ។ ព្រះបាទកងចក្រ ក៏ បានរាជានុញ្ញាតចំពោះរាជបុត្រី ដូចកាលសព្វដង ។ ព្រះនាងទ្រង់បាននាំភីលៀង និង ស្រីស្នំក្រមការ នាំទាំងចំណីអាហារពេញបរិបូណ៌យកទៅឱ្យអាថុន ។

ពេលដែលបានជួប នឹង សត្វជាទីស្រឡាញ់ពេញហឫទ័យ របស់ព្រះនាងហើយ ទន្ទឹមគ្នា និង ឱ្យចំណីអាហារវាបណ្ដើរ ព្រះនាងក៏ទ្រង់មានព្រះឱស្ឋទៅកាន់វាបណ្ដើរថា :អាថុនអើយ អាថុន នេះគឺជាលើកចុងក្រោយហើយ ដែលយើងបានជួបឯង ។ ចាប់ពីពេលនេះតទៅ យើងនឹងត្រូវឃ្លាតឆ្ងាយពីឯងហើយ ពីព្រោះយើងត្រូវ ព្រះវររាជបិតា ទ្រង់ព្រះរាជានុញ្ញាត ឱ្យមានព្រះស្វាមី ដែលជាព្រះរាជបុត្រានគរស្ដេចក្រុងចិន ។ ពេលរៀបអភិសេកហើយ យើងនឹងយាងទៅជាមួយព្រះស្វាមី នៅឯនគររាជគ្រឹះឯណោះ ។ យើងហាក់ដូចជាមិនដាច់ព្រះទ័យពីឯងសោះ ហាក់បីដូចជានៅអាឡោះអាល័យឯងខ្លាំងណាស់ ។ តែណ្ហើយចុះ ! សូមឯងនៅឱ្យបានសុខ យើងសូមលាសិនហើយ យើងនឹងត្រូវបែកគ្នា មិនដឹងជាថ្ងៃណាបានជួបគ្នាទៀតទេ ។

ចំណែកឯអាថុន ពេលដែលបានស្ដាប់ព្រះបន្ទូលព្រះនាងដូច្នោះ វាក៏កាន់តែរំកិលខ្លួនទៅជិតកៀក និង ព្រះនាង ហាក់បីដូចជាចង់បង្ហាញថា វាសូមទ្រង់យាង ព្រះនាងឡើងគង់លើក្បាលវា ធ្វើជាព្រះរាជទីនាំង ដើម្បីលំហែកំសាន្ត លើផ្ទៃគង្គា នាអាងបាពាយណ៍ទឹកថ្លានោះ ។

តាមព្រះតេជគុណ **លី សុខ** ចៅអធិការវត្តចេតិយមានពុទ្ធដីកាថា : ក្បូនចាប់ក្រពើទាំងពីរផ្នែក មានមនុស្សច្រើនឥតគណនា គ្រាន់តែដីមួយភ្លាប់ដៃម្នាក់គេអាចលុបស្ទឹង ពីទិសខាងជើង ទៅទិសខាងត្បូង នឹងពីទិសខាងត្បូង មកទិសខាងជើងវិញ មកទល់គ្នា និងអន្លង់មួយធំហើយជ្រៅ ស្ថិតនៅជាប់ក្បែរនឹងគោកតាសុស ។

ទីអន្លង់នេះហើយ ដែល **តាដោក** គាត់បានធុំបំហាយក្លិនសាក្រពើ រួចហើយគាត់ ក៏ សន្មតថា ក្រពើ អាថុន ពិតជាកំពុងតែលាក់ខ្លួនពួនអាត្មាក្នុងទីនោះ ។ " អន្លង់ដែល អាថុន លាក់ខ្លួននេះ ក្រោយមក អ្នកស្រុក ហៅថា **អន្លង់សា** " ។ ទន្ទឹម នឹងការរៀបចំពិធីសែនព្រេន បន់ស្រន់លោកអ្នកតាសួស តាម ទំនៀមទំលាប់ ប្រពៃណីបរមបុរាណ តាដោកគាត់ក៏បាន ចាត់ចែងរុករកបោចផ្ដៅ យកមកធ្វើជាខ្សែពួរ ដើម្បីទាក់ចាប់ក្រពើ អាថុននោះ ។ " សូមបញ្ជាក់ថា ទីកន្លែងព្រៃដែលបោចផ្ដៅនោះ គឺជាព្រៃដែលសំបូរទៅដោយផ្ដៅជាងគេ អ្នកស្រុកទម្លាប់ហៅថា ព្រៃផ្ដៅ ។ សព្វថ្ងៃនៅទីនោះ មានវត្តមួយឈ្មោះថា **វត្តរលើក ជលធិមន្ទីរកោះកែវ** ហៅ **វត្តព្រៃផ្ដៅ** ស្ថិតនៅក្នុងឃុំក្របីរៀល ស្រុកពួក ទិសខាងកើតអន្លង់សា " ។

ក្បូនតាមចាប់ក្រពើ ដ៏គគ្រឹកគគ្រេង ក៏បានមកបោមរោមនៅទីអន្លង់ដ៏ជ្រៅនោះ " **អន្លង់សា** " ។ គេបាននាំគ្នាបោះបង្គោលដោយសរសរក្រាក់ធំៗរាប់សិបដើម ដើម្បីទាក់ចាប់ក្រពើដ៏កំណាចនោះ ។ " សូមបញ្ជាក់ថា បង្គោលសរសរក្រាក់ធំៗនោះ ទើបតែដកអស់នៅក្នុងអំឡុងឆ្នាំ ១៩៧៧ ពីព្រោះគេត្រូវធ្វើទំនប់ទ្វារទឹកនៅទីនោះ " ។ មិនយូរប៉ុន្មាន តាដោក ក៏ចាប់ក្រពើអាថុនបាន យកមកវះពោះកាត់ក្បាលដោតឆ្កាងដាក់ថ្វាយលោកអ្នកតាសួស ដែលស្ថិតនៅលើទីទួលគោកក្បែរអន្លង់នោះ ។ " រហូតមកដល់សព្វថ្ងៃក៏នៅតែ ហៅថា គោកតាសួស១ដដែល " ។

បំណែកព្រះនាងកែវប្រាំពីរពណ៌ ពេលដែលវះយកបានពីពោះក្រពើមក ព្រះនាងទ្រង់សន្លប់ស្តូកស្តឹងបាត់ដង្ហើមស្ងួនឡឹង នៅសល់តែជីពចរតែប៉ុណ្ណោះ ។ អស់នាហ្មឺនសព្វមុខមន្ត្រី ក៏មីម្នារៀបចំគ្រែស្នែង សែងព្រះនាងយាងមកកាន់បរមរាជវាំង ក្រែង នឹង អាចព្យាបាលជួយសង្គ្រោះព្រះនាងបាន ។ " សូមបញ្ជាក់ថា ទីដែលរកឃើញនាងកែវប្រាំពីរពណ៌នោះ អំណើះតមកអ្នកស្រុកក៏ហៅថា **កែវពណ៌** សព្វថ្ងៃកើតបានជា ឃុំកែវពណ៌ ក្នុងស្រុកពួក ខេត្តសៀមរាប " ។

ប៉ុន្តែជាអកុសល ផលអាក្រក់ពន់ពេកណាស់ លុះសែងព្រះនាងបានឆ្ងាយបន្តិចពីទីនោះ មច្ចុរាជក៏តាមមកផ្ដាច់សង្ខារ ព្រះរាជបុត្រី របស់ព្រះបាទកងចក្រ ឱ្យដាច់ខ្យល់ផុតដង្ហើម សោយទីវង្គត់លាចាកលោកនេះទៅ ។ " សូមបញ្ជាក់ថា ទីព្រៃដែលព្រះនាងកែវប្រាំពីរពណ៌សោយទីវង្គត់ ផុតរលត់សង្ខារ ហៅថា ព្រៃផុតដង្ហើម ក្រោយមកបានក្លាយជា ព្រៃដង្ហើម ។ សព្វថ្ងៃមានវត្តមួយហៅថា **វត្តព្រៃដង្ហើម** ស្ថិតនៅខាងជើងឆៀងខាងកើតអន្លង់សា ក្នុងឃុំសំរោងយា ស្រុកពួក " ។

បន្ទាប់ពីទ្រង់បានទតយល់អំពីរបៀប របៀបបទរបស់ អាថុន ដែលហាក់បីដូចជាចង់បង្ហាញថា អាថុន ក៏មានស្មាមីភក្តី និង ក្តីអាឡោះអាល័យចំពោះព្រះនាងជាម្ចាស់ណាស់ដែរ ព្រះនាងក៏សព្វព្រះទ័យ ទ្រង់យាងគង់លើក្បាល អាថុន ដូចកាលសព្វដង ។

ក្រោយពីបានរៀបចំ ព្រះរាជដំណើរ ព្រះនាងស្រេចបាច់ហើយ ព្រះរាជទីនាំងក្រពើ ហៅ អាថុន ក៏ថយខ្លួនបង្វិលក្បាលពីទិសខាងកើត នាំព្រះរាជធីតាកែវប្រាំពីរពណ៌ ឆ្ពោះទៅកាន់ទិសខាងត្បូង ក្នុងល្បឿនដ៏គួរឱ្យភ័យខ្លាចខុសពីធម្មតា ។ ព្រះនាងកើតក្តីវិត្កកៈ ភិតភ័យស្លន់ស្លោឥតឧបមា ទ្រង់ក៏ភ្ញាក់ព្រះឱស្ឋទៅកាន់អាថុនថា : នែ៎ ! អាថុន ម្តេចក៏ឯងធ្វើដូច្នេះ យើងភ័យណាស់ ! ប្រយ័ត្នយើងមានគ្រោះថ្នាក់ណា ព្រោះយើងជិតដល់ថ្ងៃរៀបអភិសេកហើយ ។ គ្រាន់តែចប់ព្រះឱស្ឋភ្លាម អាថុនក៏ត្រលៀសលេបព្រះធីតាកែវប្រាំពីរពណ៌ នាព្វដ៏គ្រានោះឯងហោង ។

អាថុនដឹងថា គេនឹងតាមចាប់ខ្លួន វាក៏ខំប្រឹងមុជគេចចេញ ពី អាងបារាយណ៍ទឹកថ្លា តាមដងស្ទឹងដែលចេញពីបារាយណ៍ ទៅទិសខាងត្បូង ឆ្ពោះទៅកាន់បឹងទន្លេសាប ដើម្បីរកទីលាក់ខ្លួនពួនអាត្មា ។

ចំណែកឯភីលៀង ស្រីស្នំក្រមការ ឃើញព្រះរាជធីតាទ្រង់ទទួលនូវមហាគ្រោះភយន្តរាយយ៉ាងដូច្នោះ ក៏កើតមានសេចក្តី ភិតភ័យញ័ររន្ធត់អស់ស្មារតី ស្ទុះស្ទានាំគ្នាម្នីម្នា ទៅទូលដល់ព្រះវររាជបិតារបស់ព្រះនាង ។

ព្រះបាទគងចក្រកើតក្តីរន្ធត់ ក្រេវក្រោធឥតគណនា ក៏ចាត់អាមាត្យ នាហ្មឺនសព្វមុខមន្ត្រីរាជការ ស្រីស្នំក្រមការ អស់ពលសេនា យោធា ឱ្យគោះគង ទូង ភេរីអំពាវនាវជ្រើសរើស រកអ្នកមានថ្វីដៃខ្លាំងពូកែជំនាញខាងចាប់ក្រពើ និង កៀងគរអស់ប្រជានុរាស្ត្រ ដើម្បីតាមរកក្រពើអាថុនឱ្យឃើញ និង ចាប់ឱ្យបាន ។

ដោយសារព្រះរាជបារមី នៃព្រះរាជាជាអម្ចាស់ សេចក្តីអំពាវនាវ ដ៏ ប្រញាប់ប្រញាល់នោះ ក៏បានលេចឡើងនូវអ្នកស្ម័គ្រចិត្ត ជាគ្រូអាលម្តាយម្នាក់ឈ្មោះ **តាដាក** ដែលជាអ្នកមានមន្តអាគមខ្លាំងពូកែ និង ស្ទាត់ជំនាញខាងចាប់ពស់ ចាប់ក្រពើ ។ ចំណែកអស់ប្រជានុរាស្ត្រ ក្រោយពីបានទទួលដំណឹងដ៏មហាទុក្ខសោកនោះហើយ ក៏នាំគ្នាម្នីម្នារូតរះមកចោមរោម មូលមីរដេរដាស់ ជុំជិតទីកើតហេតុនាអាងបារាយណ៍ទឹកថ្លានោះ ។

ការតាមចាប់ក្រពើ ក៏បានបែងចែកជារូបភាពឱ្យទៅជាពីរផ្នែកធំៗ គឺមួយផ្នែកតាមរកចាប់ក្រពើក្នុងអាងបារាយណ៍ និង លុបស្ទឹងដែលចេញពីបារាយណ៍ កាត់តាមភូមិសណ្ឋានចុះទៅក្រោម " **នៅទិសខាងត្បូង** " ។ មួយផ្នែកទៀត លុបស្ទឹងពីព្រៃនាម មាត់បឹងទន្លេសាបឡើងមកខាងលើវិញ " **មកទិសខាងជើង** " ។ រីឯចុងស្ទឹងដែលនៅសេសសល់ មិនបានលុប "**ស្ថិតនៅក្នុងព្រៃនាម**" ចាប់ពីបឹងទន្លេសាប រហូតមកទល់ នឹង ដីដែលគេលុបនោះ អំណើះតមកអ្នកស្រុកហៅថា "**ស្ទឹងកំបុត** " ។ ស្ទឹងកំបុតនេះស្ថិតនៅក្នុងព្រៃនាម មាត់បឹងទន្លេសាប " **ភាគខាងត្បូងឃុំកែវពណ៌ ស្រុកពួក** " ។

ដោយគ្មានបង្អែបង្អង់ ក្បួនសែងសាកសពព្រះនាងក៏កាន់តែជំរុលល្បឿនលឿនទៅមុខ ចេញពីព្រៃផុតដង្ហើម សំដៅទៅកាន់ព្រះបរមរាជវាំង ។ កំពុងតែឆ្លងកាត់វាលធំមួយ ស្រាប់តែពេលនោះ មានខ្យល់កួចបោកបក់យ៉ាងខ្លាំងគួរឱ្យចម្លែកណាស់ បណ្ដាលឱ្យកេសាររបស់ព្រះនាងកែវប្រាំពីរពណ៌ ត្រូវរប៉ើងរសាយពីលើគ្រែស្នែង ទៅតាមអំណាចនៃកម្លាំងព្រះពាយ ដែលកំពុងបោកបក់នោះ ។ អស់នាហ្មឺនសព្វមុខមន្ត្រី មានសេចក្ដីភិតភ័យស្លន់ស្លោ ខិតខំបន់ស្រន់បណ្ដើរ ដង្ហែក្បួនបណ្ដើរ រហូតទាល់តែឆ្លងផុតវាលធំនោះដល់មាត់ព្រៃមួយទើបខ្យល់ធំនោះបានស្ងប់ទៅវិញ ។ ៉ សូមបញ្ជាក់ថាវាលធំ ដែលសែងសាកសពនាងកែវប្រាំពីរពណ៌ឆ្លងកាត់នោះ ហៅថា **វាលរះល្វើយសក់** ។សព្វថ្ងៃគឺជាវាលស្រែ ចាប់ពីវត្តព្រៃដង្ហើមមកទល់និង ភូមិស្វាយ ឃុំខ្នាត ស្រុកពួក ៉ ។

ទន្ទឹម នឹងដល់មាត់ព្រៃ ខ្យល់ក៏ស្ងប់ សែងសាកសពតាមជងព្រៃនោះ ក្លិនអសុភក៏កាន់តែជះចំហាយខ្លាំងឡើងៗ ទើបគេហៅឈ្មោះជងព្រៃនោះថា **ព្រៃស្អុយ** ។ ៉ សូមបញ្ជាក់ថា អ្នកស្រុក អ្នកស្រែដែលបានដើរឆ្លងកាត់ តាមជងព្រៃនោះ តែងតែលាន់មាត់ថា : ធុំស្អុយ ឬ ធុំខ្មោះៗ ដូចៗគ្នា ។ សព្វថ្ងៃក្លាយជាវាលស្រែស្ទើរតែអស់ព្រៃទៅហើយ ។ ព្រៃស្អុយស្ថិតនៅខាងលិចភូមិប្រយុទ្ធ ប្រហែលមួយគីឡូម៉ែត្រ ក្នុងឃុំទីកវិល ស្រុកពួក ៉ ។

ចំណែកឯព្រះបាទកងចក្រ ពេលដែលទ្រង់ជ្រាបនូវដំណឹង ដ៏មហាទុក្ខសោកខ្លោចផ្សាថា ព្រះរាជបុត្រីបានដល់ទីវង្គតទៅហើយនោះ ព្រះអង្គក៏ទ្រង់មានសេចក្ដីវិត្តកៈ សោកសង្រេងអាឡោះអាល័យ រកអ្វីប្រៀបស្មើពុំបានឡើយ ។ ព្រះអង្គក៏ទ្រង់កើតនូវក្ដីសន្ទិះសង្កា ទើបទ្រង់មានព្រះតម្រិះពិគ្រោះយោបល់ និងហោរា ព្រមទាំងអ្នកមុខ អ្នកការ ក្នុងព្រះបរមរាជវាំង ដើម្បីបានជាទីសណ្ដាប់ពិចារណា។ រួចហើយដោយព្រះអង្គទ្រង់យោគយល់ ទៅតាមគន្លងប្រពៃណី ពីបរមបុរាណ តរៀងមកចំពោះមនុស្សផងទាំងឡាយដែលស្លាប់ដូច្នេះ គេហៅថាខ្មោចតៃហោង មិនអាចនាំយកមកចូលផ្ទះ ឬ ចូលបរមរាជវាំងវិញបានទេ ។ ទើបព្រះអង្គចេញព្រះរាជបញ្ជាឱ្យរកទីកន្លែងដីដែលល្អប្រពៃ រៀបចំធ្វើជាចេតិយ ដើម្បីបញ្ចុះសាកសពព្រះនាងឱ្យបានសមរម្យ ។

អស់មុខមន្ត្រី សេនាអាមាត្យ ក៏ម្ដីម្ដាចេញពីបរមរាជវាំង ធ្វើដំណើររួតរះទៅស្ទាក់ស្កាត់ទាន់ក្បួនដង្ហែសាកសពនៅឯទីព្រៃស្អុយនោះ ។ ក្បួនដង្ហែសាកសព ក៏ត្រូវសំរាកផ្អាកដំណើរ ដើម្បីទទួលព្រះរាជសារ រយៈពេលមួយសន្ទុះ ។ បន្ទាប់ពីបានទទួលព្រះរាជសាររួចហើយ ក្បួនដង្ហែសាកសព ក៏បានហែក្បួនឆ្ពោះទៅកាន់ទិសខាងត្បូងវិញ ដើម្បីរកទីដីបញ្ចុះសាកសពព្រះនាង ។ ៉ សូមបញ្ជាក់ថា កន្លែងដែលផ្អាកដំណើរទទួលព្រះរាជសារនោះ គេបានកសាងជាប្រាសាទចេតិយមួយអំពីឥដ្ឋមានសណ្ឋានដូចជាប្រាសាទ វត្តចេតិយដែរ ប៉ុន្តែគ្រាន់តែមានទំហំតូចជាងបន្តិចប៉ុណ្ណោះ ទាំងបរិវេណផ្ទៃដី និង តួប្រាសាទ ។ អ្នកស្រុកទម្លាប់ហៅថា ប្រាសាទព្រៃស្អុយ ។ ប្រាសាទនេះត្រូវបានជនខិលខូចគាស់កកាយ បំផ្លាញរលាយហិនហោច

អស់ហើយ ។ តាមដែលអ្នកធ្វើស្រែនៅក្បែរៗនោះ បានឱ្យដឹងថា ប្រាសាទព្រៃស្អុយនេះ ទើបតែរលាយខូចខ្ទិអស់នៅក្នុងឆ្នាំ ១៩៨៨ ។

លុះក្បួនហែចកដល់ទីកន្លែងមួយ តាមដែលមន្ត្រីខាងភូមិសាស្ត្រ ហោរាសាស្ត្រពិនិត្យគន់គូរមើលទៅ ឃើញថាទីនោះ ជាទីល្អប្រពៃ សមគួរជាទីបញ្ចុះសាកសពព្រះនាងហើយ ទើបគេចាត់ចែងពិធីបុណ្យបញ្ចុះសពព្រះនាងកែវប្រាំពីរពណ៌យ៉ាងអធិកអធមទៅតាមលក្ខណៈប្រពៃណីជាតិខ្មែរយើង ។ ប៉ុន្តែដោយពិនិត្យឃើញថា ទីនោះ ជាទីវាលទំនាបលិចទឹកទន្លេសាប ទើបត្រូវបានចាត់ចែងមនុស្សដ៏ច្រើនសន្ធឹកសន្ធាប់លើកដីនោះឱ្យទៅជា ទីទួលខ្ពស់ផុតពីការលិចទឹក ហាក់បីដូចជាផ្នូរមួយយ៉ាងធំអស្ចារ្យ ។ ជាមួយគ្នានោះគេក៏បានកសាងព្រះចេតិយមួយយ៉ាងធំផុសត្រដែតខ្ពស់លលៃ លើវេហា កណ្តាលព្រៃ មាត់បឹងទន្លេសាប ពីលើដីទួលនោះ ។

ចំណែកឯព្រះបាទកងចក្រ ព្រះអង្គទ្រង់នៅតែមានសេចក្តីសោកស្តាយ អាឡោះអាល័យ និង គិតគូរដល់ព្រះរាជបុត្រី ព្រះអង្គខ្លាំងណាស់ ព្រះអង្គក៏ទ្រង់មានព្រះរាជតិរិះពិចារណាថា គប្បីត្រូវតែរកឆ្មាំចាំថែរក្សា និង សំអិតសំអាតទីព្រះចេតិយនោះ ។ ម្យ៉ាងទៀតត្រូវធ្វើឱ្យបាន ជាទីកុះករ គឺ ការធ្វើបុណ្យទានរបស់អ្នកស្រុក អ្នកភូមិជិតឆ្ងាយ ហើយបានជាលក្ខណៈងាយស្រួល សំរាប់ព្រះអង្គទ្រង់យាងទៅធ្វើបុណ្យទាន ឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ ព្រះរាជបុត្រីផង ។

ក្រោយពីទ្រង់មានព្រះរាជតិរិះដូច្នោះហើយ ព្រះអង្គក៏ទ្រង់បានតែងតាំងតា ជាយសសក្តិដល់តាដោក ឱ្យធ្វើជាឆ្មាំចាំថែរក្សា ការពារ សំអិតសំអាត ទីព្រះចេតិយនោះ ។ រីឯវត្តអារាមក៏ត្រូវបានកសាងឡើងមានព្រះសង្ឃ មានពុទ្ធបរិស័ទ ចេញ ចូល ធ្វើបុណ្យទានហូរហែជារៀងរហូតមកដល់សព្វថ្ងៃនេះ ។ វត្តនេះ ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យឱ្យឈ្មោះថា "**វត្តកោះនាងកែវចុឡាមណីធម្មចេតិយ**" ដែលក្លាយមកជា វត្តចេតិយ ឬ ចៃដីសព្វថ្ងៃ ។ សូមបញ្ជាក់ថា វត្តចេតិយស្ថិតនៅ ខាងត្បូងឆៀងខាងកើត វត្តព្រៃផ្ញើម ។

លុះអំណើះតមក ក្រោយពីលោកតាដោកគាត់បានទទួលអនិច្ចកម្មទៅ គេក៏បានកសាង ជារូបសំណាកលោក តាដោក មួយនៅពីមុខផ្លូវចូលព្រះចេតិយ ចម្ងាយប្រហែល ៧០ ម៉ែត្រ ពីព្រះចេតិយ ជានិមិត្តរូបក្នុងការទទួលខុសត្រូវ លើកិច្ចការការពារ និង ថែរក្សាទីព្រះចេតិយនោះ ។

តាមការតំណាលតៗគ្នាមកថា រូបសំណាក តាដោកនេះ អ្នកស្រុកទំលាប់ហៅថា អ្នកតាដោកមានមហិទ្ធិឫទ្ធិខ្លាំងពូកែណាស់ សូម្បីតែសត្វក៏មិនអាចហើររំលងបានដែរ ឱ្យតែហ៊ានហើររំលងគឺត្រូវតែធ្លាក់ ។ ម្យ៉ាងទៀតចំពោះ គោ ក្របីណា ដែលចូលស៊ីស្មៅក្នុងស្រះ ឬ លើទួលព្រះចេតិយនោះ គឺពិតជាត្រូវអ្នកតាដោកលាក់បាត់ ម្ចាស់ពុំអាចរកឃើញភ្លាមៗទេ ទាល់តែបួន ឬ ប្រាំថ្ងៃ ទើបអាចរកឃើញវិញ។ អាស្រ័យដោយហេតុនេះហើយ បានជាបច្ចុប្បន្ន ពុំឃើញមានរូបសំណាក តាដោកទេ នៅសល់តែកន្លែង -

ដាក់រូបសំណាកបំណ្ណោះ ។ តាមការសន្និដ្ឋាន ប្រហែលជាម្ចាស់គោ ម្ចាស់ក្របីនោះគេខឹង គេស្អប់នឹង អ្នកតាដោក គេក៏មានការគុំគួន នឹង រូបសំណាកនោះ ។ ពេលដែលប្រទេសជាតិយើង ឈានដល់សម័យកាលដ៏ខ្មៅងងឹត " សម័យប៉ុលពត " គេក៏បានឱកាសវាយបំបាក់សែងទំលាក់ទឹកស្រះនោះទៅ។ តាមពត៌មានថា អភិរក្សអង្គរបានដឹករូបសំណាកនោះទាំទុកហើយ ។

ចំពោះទិតាំងវត្តចេតិយ ព្រះតេជគុណ លី សុខ មានព្រះពុទ្ធដីកាថា : កាលដើមឡើយមិនស្ថិតនៅជាប់ជាមួយ ព្រះចេតិយនាងកែវប្រាំពីរពណ៌ ដូចសព្វថ្ងៃនេះទេ ដែលនៅជាប់ និង ព្រះចេតិយត្រង់កន្លែងព្រះវិហារសព្វថ្ងៃនេះ គឺ មានត្រឹមតែចោជមួយប៉ុណ្ណោះ ។ ឯទិតាំងវត្ត គឺ ស្ថិតនៅខាងលិចព្រះចេតិយនោះ ប្រហែល ៦០ ម៉ែត្រ ឆ្លងស្រះធំមួយទើបដល់វត្ត ។ ទីនោះក៏មានដីទួលមានសណ្ឋានជាដីលើក ព្រោះមានស្រះជុំវិញ ដូចទីទួលកោះព្រះចេតិយដែរ ប៉ុន្តែហាក់ដូចជាមានកំពស់ទាបជាង ។ ការប្រែប្រួលបង្វិតទិតាំងវត្ត គឺ បណ្តាលមកពីសម័យកាលមួយ ដែលប្រទេសជាតិជួបប្រទះ នូវគ្រោះកលិយុគ អសន្តិសុខ ឡូកឡូរីករវរអត់ឃ្លាន កើតមានមនុស្សអាក្រក់ ចោរលួច ចោរប្លន់ទាំងយប់ ទាំងថ្ងៃ លែងស្គាល់បុណ្យ ស្គាល់បាបឆ្លៀតពេលព្រះសង្ឃជាប់ចង្ក្រមភាវនា និង ចូលព្រះវិហារនៅឯចោជឯណោះ ចោរក្មួញវាក៏លួចប្រមូលរបស់របរ គរុភ័ណ្ឌ នៅឯវត្តឯណោះអស់រលីងទៅ ។ ដោយមិនអាចទ្រាំទ្រគង់នៅទីនោះបានតទៅទៀត ទីតាំងវត្តក៏ត្រូវបានផ្លាស់ប្តូរនាសម័យកាលនោះឯង "**ប្រហែលជាក្នុងឆ្នាំរាន់ឥស្សរៈ**" ។ ចំណែកឯព្រះវិហារនោះ ការកសាងឡើង គឺ ចំកណ្តាលផ្លូវពីមុខព្រះចេតិយ ត្រង់ចន្លោះព្រះចេតិយ និង អ្នកតា "**តារដោក**" ។

ព្រះតេជគុណ លី សុខ បានមានពុទ្ធដីកាឱ្យដឹងទៀតថា : វត្តចេតិយពីមុនបានរក្សាទុកក្រាំងមួយដែលមានចំណាស់ជាងគេ ។ ក្រាំងនោះមានទំហំ ទទឹងប្រហែលមួយតឹក បណ្តោយប្រហែលមួយតឹកកន្លះ និង កម្រាស់ប្រហែលបីហ៊ុន ធ្វើពីក្រដាសពណ៌ខ្មៅ សរសេរជាអក្សរពណ៌ស ជាភាសាបាលីផង សំស្រ្កឹតផង និងភាសាខ្មែរតិចតួចផង ។ ក្នុងក្រាំងនេះ ក៏ នៅមានគូរជារូបយ័ន្ត និង មានក្បូរក្បាច់ផ្សេងៗទៀតខ្លះផងដែរ ។ ព្រះតេជគុណសន្និដ្ឋានថា ក្រាំងនេះប្រាកដជានិយាយអំពីរឿងរ៉ាវរបស់នាងកែវប្រាំពីរពណ៌ និង ប្រវត្តិចេតិយជាក់ជាមិនខាន ។ ព្រះតេជគុណបានទទួលបន្តថែរក្សាក្រាំងនោះដោយផ្ទាល់ព្រះហស្ថ ។ ប៉ុន្តែគួរឱ្យសោកស្តាយណាស់ ក្នុងសម័យប៉ុលពត ព្រះតេជគុណ និង ព្រះសង្ឃទាំងអស់ គ្រប់អង្គត្រូវបានជន្លៀសចេញពីវត្ត ។ ឯក្រាំងនោះ ព្រះតេជព្រះគុណមានការភ្លេចភ្លាំង មិនបានយកទៅតាមផងទេ ។ ពេលដែលព្រះតេជព្រះគុណនឹកឃើញត្រឡប់មកយកវិញ ក៏ស្រាប់តែបាត់ក្រាំងនោះ ព្រមទាំងគម្ពីរដីកាផ្សេងៗទៀតអស់ទៅ ។

តាមដែលធ្លាប់បានទៅដល់ទីអារាមវត្តចេតិយឃើញថា វត្តចេតិយស្ថិតនៅដាច់ស្រយាល ពីភូមិម្ពុររបស់អ្នកស្រុក ស្ថិតនៅចុងខាងត្បូងនៃភូមិព្រៃ ឃុំសំបួរ ស្រុកសៀមរាប មានចម្ងាយពីទីតាំងឃុំសំបួរប្រហែលជាងពីរគីឡូម៉ែត្រ ។ ទីវត្តនោះ គឺ ជាទីទួលខ្ពស់ជិតប៉ុនកូនភ្នំមួយមានទទឹងប្រហែល ១០០ ម៉ែត្រ

និង បណ្ដោយប្រហែល ១២០ ម៉ែត្រ ហ៊ុំព័ទ្ធទៅដោយស្រះធំជាគូជុំវិញទីទួលនោះ ។ នៅពីលើចំកណ្ដាលទួលមានព្រះវិហារមួយសង់អំពីថ្មប្រក់ក្បឿងដ៏សមរម្យ ។ នៅខាងលិចជាប់ និង ព្រះវិហារ មានព្រះចេតិយជំនាន់បុរាណមួយយ៉ាងធំ កសាងអំពីឥដ្ឋ និង ថ្មបាយក្រៀម ដែលមានទំហំបាតក្រោមប្រហែលប្រាំពីរម៉ែត្រកន្ទះ កម្ពស់ជិតប្រហែល ២០ ម៉ែត្រ ។ នៅជុំវិញព្រះវិហារ និង ព្រះចេតិយ មានព្រៃឫស្សីស្រោង១ ដើមឈើធំ១ ខ្ពស់១ជាមួយបង់ត្រឡឹងត្រឡៃ ។ វត្តចេតិយនៅរដូវវស្សា បើទឹកទន្លេធំ អ្នកភូមិស្រុកជិតឆ្ងាយមិនអាចទៅធ្វើបុណ្យទាន ដោយធ្វើដំណើរតាមផ្លូវគោកបានទេ ពីព្រោះទឹកទន្លេសាបបានឡើងលិចជុំវិញនៅសល់តែទីទួលកោះប៉ុណ្ណោះ ។ ពេលនោះ ទិដ្ឋភាពវត្តទាំងមូល កាន់តែមានសោភ័ណភាពស្រស់បំព្រងថែមទៀតគួរជាទីគាប់ចិត្តគយគន់ ជាទីត្រជាក់មនោរម្យ សមនឹងទៅធ្វើបុណ្យទាន ទៅកំសាន្តលំហែយ៉ាងពន់ពេកណាស់ ។

ការសរសេររៀបរាប់ជាគ្រួស១អំពីរឿងនិទាន រឿងនាងកែវប្រាំពីរពណ៌ និង វត្តចេតិយ ដែលខ្ញុំបាទបានដឹងសន្មតថាចប់ត្រឹមនេះ ។ ប៉ុន្តែក្រែងមានបទត្រង់ណាសង្ស័យថាមិនច្បាស់ មិនពិត អក្ខរាវិរុទ្ធខ្វះចន្លោះខុសឆ្គង សូមលោកមេត្តាអធ្យាស្រ័យ អភ័យទោស សូមកុំឱ្យខ្ញុំបាទមានបាបកម្ម និង ពៀរវេរាតទៅមុខទៀត ពីព្រោះនេះគឺគ្រាន់តែជាការស្ដាប់ឮត១គ្នាតែប៉ុណ្ណោះ ។

សូមថ្លែងអំណរគុណចំពោះព្រះតេជព្រះគុណ ព្រមទាំងលោកតា លោកយាយ ទាំងអស់ដែលបានផ្ដល់ពត៌មាន រឿងនិទានដល់ក្រុមអ្នកស្រាវជ្រាវរបស់ទូលបង្គំខ្ញុំបាទ ។ សូមប្រគេន និង ជូនពរ នូវពុទ្ធពរទាំងប្រាំប្រការគឺ : អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សៀមរាប. ថ្ងៃសុក្រ ទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៥

អ្នករៀបរៀង និង ចងក្រង

**អ៊ុំ ហឿន**

---

៖ រឿងព្រេងនិទាននេះ បានបញ្ចូលទៅក្នុងទស្សនាវដ្ដីអ្នកនិពន្ធខ្មែរ

" ឆ្នាំទី ២ លេខ ៦ ខែ កញ្ញា ឆ្នាំ ១៩៩៦ "

# ប្រវត្តិសង្ខេបរបស់ប្រាសាទអង្គរវត្ត

(អ្នកតាម្ចាស់ស្រុកជាមេធំពយាំងសំខាន់ សំរាប់ការឈរនិស)

**-អត្ថន័យរបស់ពាក្យអង្គរវត្ត:**

ពាក្យអង្គរវត្ត ជាពាក្យផ្សំ ដែលកើតឡើងចេញពីពាក្យ ពីរម៉ាត់ថា:អង្គរ+វត្ត

-អង្គរមានន័យថា:ប្រទេស ឬ នគរ

-វត្ត ជាបូជនីយដ្ឋាននៃព្រះពុទ្ធសាសនា អានកាត់ថាអង្គរវត្ត ។

-មានន័យថា:វត្តនៃនគរដែលមានស្តេចគង់ ខុសពីអាណាខេត្តផ្សេង ក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ព្រះរាជណាចក្រ សម័យបុរាណ ដែលពុំមែនជារាជធានី ។

**ប្រវត្តិសង្ខេប:**

-កាលបរិច្ឆេទ: ពាក់កណ្តាលទី១ នៃសតវត្សទី១២ ( គ.ស ១១១២-១១៥២ ) ។

-រាជស្តេចស្ថាបនិក: សុរិយាវរ្ម័នទី២

-លទ្ធិសាសនា : ព្រះបរមវិស្ណុលោក

-សំណង់រាងបួនជ្រុងទ្រវែង: មានបណ្តោយ ១៥០០ម និង ទទឹង ១២៧៣ម.

ទំហំ ១៩០ហិចតា ៩៥០

-មានកំពស់ ពីបាតក្រោម (ដីរាបចម្ងតា)ដល់កំពូលលើកំពស់ ៦៥ម

-មានអប្សរា: ១៥០០រូប តែសម័យក្រោយស្រាវជ្រាវ អាលីម៉ង់ (អង្គការ GACP មាន១៨)

-មានផ្លូងសក់ ៥០០បែប

-រោងទងទី៣ មានរូបចម្លាក់រឿងភ្ជាប់និងជញ្ជាំងថែវចំនួន ១០០០ម

-ការកសាងក្នុងសម័យវិទ្យាសាស្រ្ត កំពុងមានការអភិវឌ្ឍរីកចម្រើនខ្លាំង មានបទពិសោធន៍ ខ្ពង់ខ្ពស់លើវិស័យសាងសង់ សំណង់ស្ថាបត្យកម្មជាប្រវត្តិសាស្រ្ត ។

-ប្រាសាទអង្គរវត្ត សាងសង់ដើម្បីឧទ្ទិសថ្វាយព្រះវិស្ណុ ពេលចូលទីវង្គត់ទៅ (គេថ្វាយព្រះនាម ថា:(ព្រះបរមវិស្ណុលោក) ។

លក្ខណៈសំគាល់របស់ព្រះវិស្ណុ:

-វិស្ណុ ជាអាទិទេពចម្បងទី២ បន្ទាប់ពីព្រះសិវៈ វិស្ណុជាអាទិទេពរក្សាលោក (CONSERVATERUR DU MONDE) មានមុខតែមួយគត់ ដៃធម្មតាមានពីរ អាចធ្វើឈាន (បែងភាគ) មានដៃបួនឬដៃប្រាំបីបាន ។ ឯដៃប្រាំបីចាប់ផ្តើមមានក្នុង"សតវត្សទី៨" ។

-មុនសម័យអង្គរៈ វិស្ណុពាក់មួករាងរមូរដូចបពង់ (MINE CYLINDRIGUE)

-សំលៀកបំពាក់ពណ៌លឿង

-មានគ្រុឌជាជំនិះ

-សម័យអង្គរៈ គេឆ្លាក់ព្រះវិស្ណុ ពាក់ក្បាំង ឬ មុដ (DIADEIME OU MUKUTA) ។

ដៃ៤ តំណាងអោយទិសទាំង៤ ដៃមានកាន់កេតនភណ្ឌ:-

-កងចក្រ, ខ្យងស័ង្ខ, កាំរន្ទះ, នឹង ដំបងធំ, ដៃ៨ តំណាងអោយទិសទាំង៨ ដៃកាន់កេតនភណ្ឌ បន្ថែមមានៈ-

-ភ្លើង, ថូទឹក, ស្បែកទ្រើក នឹង ដុំមូល

-កំពូលទាំង៥នេះ ជាកន្លែងស្នាក់នៅរបស់អាទិទេពទាំង៣៣អង្គ ក្នុងព្រហ្មញ្ញសាសនា ឯកំពូល ដែលធំស្ថិតនៅចំកណ្តាលហៅថា"កៃលាស" ។ ជាកន្លែងស្នាក់នៅរបស់អាទិទេពចម្បងទី១គឺ"ព្រះសិវៈ"

-តួប្រាង្គប្រាសាទនិមួយៗ និយាយរួមជានិម្មិតរូបនៃបាយសីយ៍ ក្នុងកំពូលនិមួយៗ គេសាងច្រើន ជាន់តម្រួតពីលើគ្នាមានន័យថាៈ ក្នុងរូតមួយគឺតំណាងអោយប្រាសាទមួយដែលជា កន្លែងសំរាប់អាទិទេព ស្នាក់នៅ មានតែមព័ទ្ធជុំវិញ ជាកន្លែងសំរាប់ដើរប្រទក្សិណ ហើយអ្នកប្រាជ្ញជំនាន់នោះបានកសាងដោយ សង្ខេបតែកំពូលមួយ ហើយមានរូត ពី៣រូតទៅ៥រូត ក្នុងវិណ្ណនេះបើនៅខាងលើយើងអាចដើរបានរោាល គឺ គេដើរប្រទក្សិណ នៃប្រាសាទនិមួយៗ ។

-តែនៅចំកណ្តាលប្រាង្គប្រាសាទកណ្តាល(បាកាន)គឺគេបើកទ្វារទាំង៤ទិស នៅចំកណ្តាលគេ ដាក់តាំងរូបព្រះវិស្ណុ សំរាប់ជាទីសក្ការៈបូជា(បរមវិស្ណុលោក) ក្រោយមកព្រះសង្ឃកាន់ព្រះពុទ្ធសាសនា នៅសតវត្សទី១៨ គេបានបិទទ្វារជិត រៀបដោយថ្មភក់ឬ ឥដ្ឋ(ធ្វើជាទ្វារបញ្ឆោត) ហើយ ឆ្លាក់រូប ព្រះពុទ្ធ ទ្រង់ឈរ ជាមុទ្រ ឬ មុទ្រៈ ទៅវិញ ប្រហែលជាព្រះសង្ឃ ដែលគង់នៅទី

នោះ សម្របតាមពុទ្ធសាសនា ទៅ ។ តែរូបព្រះវិស្ណុនៅចំកណ្តាលប្រាង្គប្រាសាទនេះ មិននឹងជាបាត់នៅសម័យកាលណាឡើយ ។

I. ចំពោះជំនឿអរូបីយ៍នៅប្រាសាទអង្គរនេះមានច្រើនដែលប្រជាជនគេសន្មត់ទៅតាមតួអង្គរ និមួយៗ មានដូចតទៅនេះៈ- ចំពោះក្លោងទ្វារទាំងបួននេះគេសន្មត់ឈ្មោះខុសៗគ្នា ដោយកំណត់យក ឈ្មោះមេទ័ពយាមនៅទិសនោះគួបផ្សំរូបចម្លាក់នៅទីនោះផង ។

១-**ក្លោងទ្វារចូលខាងកើត**( អ្នកស្រុកហៅថា( គុកគូ) គេសន្មត់ដាក់ឈ្មោះនេះដោយសន្មត់ដាក់ឈ្មោះមេទ័ពយាមប្រចាំទិសខាងកើត អត់មានរូបអ្វីទេបច្ចុប្បន្ននេះ ប្រហែលសម័យដើមគេ តំកល់រូបអ្វីមួយមិនខានឡើយ ។ កាលពីដើមប្រជាជនរស់នៅខាងកើតនោះ តែងដើរមកធ្វើបុណ្យ ក្នុងវត្តអង្គរ ខាងជើង ខាងត្បូង គេតែងកាច់មែកឈើ ទៅថ្វាយដើម្បីសុំសេចក្តីសុខសប្បាយ ឬ នៅរដូវបុណ្យភ្ជុំបិណ្ឌ ឬ ចេញវស្សាតែងយកចង្កាន់ទៅប្រគេនលោក ពេលដើរដល់ក្លោងទ្វារ គឺគេតែង អុជធូប ទៀន ថ្វាយនំ ចំណី ដែលមានក្នុងស្រាក់ ថ្វាយមុនដែរ ហើយ និយាយថា លោកតាអើយ សុំសេច ក្តីសុខសប្បាយ( បើ មិនបានសែនទេអ្នកទាំងនោះដើរមិនបានឆ្ងាយទេ ច្បាស់ជាឈឺពោះ ចុកពោះ មិនខាន ឡើយ) ។

២-**ក្លោងទ្វារចូលខាងលិចៈ** (ខាងក្រៅ) អ្នកស្រុកសន្មត់ហៅគុកតាមហារាជ ឬ តារាជ ជាមេទ័ពខ្លាំង ពូកែប្រចាំទិសខាងលិច ។ (ទ្វារអមខាងត្បូងអ្នកតាម្ចាស់ស្រុក) ។ ប្រជាជនរស់នៅជិតឆ្ងាយ តែងបន់ ស្រន់ សុំសេចក្តីសុខដែរ ព្រោះលោកតារាជនេះ មានបារមី សប្ដិ៍ កំបាំងបាត់ មានមហិទ្ធិឫទ្ធ ខ្លាំងពូកែ សក្តិសិទ្ធិណាស់ កាលសម័យដើមប្រជាជនតែងមានជំនឿ ជឿជាក់លើលោកតារាជនេះណាស់សុំអ្វីៗគឺ បានដូចសេចក្តីបំណង សត្វហើរកាត់ គឺធ្លាក់ យន្តហោះហោះកាត់ក៏មិនបានដែរ ខ្លះគ្មានកូន សុំកូនបាន តែកូននោះកើតមកពិបាករក្សាណាស់ច្រើន តែស្លាប់ទៅវិញ ។ កាលសម័យសង្គ្រាមឆ្នាំ១៩៧០ ផ្តុំកំលាំង ទ័ព ដើម្បីសំរុកវាយអង្គរពីខ្មែរក្រហម ពេលនោះទ័ពឡើងគ្រប់ទិស កំណត់គ្នានឹងសញ្ញាបាញ់ តែដល់ ពលឡើងទៅទិសខាងកើតដល់មុន ពេលនោះស្រាប់តែផ្ទុះកាំភ្លើង ក៏បាញ់គ្នាយ៉ាងសន្ធឹកសន្ធាប់ ទ័ពខាង លន់ ណុល បាញ់កាំភ្លើងតូច កាំភ្លើងធំ ត្រូវវិសសរជញ្ជាំង តែព្រះរូបលោកតារាជមិនត្រូវឡើយ ។

៣-**គោបុរៈខាងលិច** : ទ្វារអមខាងជើង មានរូបព្រះវិស្ណុដូចគ្នា តែសឹកវិចរិលអស់

មានដៃ៨ អ្នកស្រុក ហៅថា លោកតា តាសិត តាសូស តែអ្នកខ្លះហៅយាយសូស ជាប្រពន្ធលោកតាមហារាជ តាមការពិត ជារូបវិស្ណុដែលមានបារមីសក្តិសិទ្ធិដូចគ្នាមនុស្សមនា តែយកភ្លេងមហោរីទៅលេងថ្វាយក្នុង នោះ គេ រៀបចំបាយសីយ៏តាមថ្នាក់ មានសែនបាយសម្លរ ក្បាលជ្រូក មាន់ និងផ្លែរឈើសឹងគ្រប់មុខ (បើសិនជា ចិនឬសៀម តែងយកនំបារាំងទៅថ្វាយដែរ) ។

-ក្លោងទ្វារគោបុរៈខាងជើង ហៅឈ្មោះថា គុកតាឡឹក មានរូបតំណាងមួយដែរ ។

៤-**<u>គោបុរៈខាងត្បូង</u>** គេសន្មត់ដាក់ឈ្មោះលោកតា ពេជ្រ ដែលជាមេទ័ពខ្លាំងយាមនៅទីនោះ ហៅ គុកតា ពេជ្រ រូបបដិមានេះគឺគេយកអង្ក្រាម ផ្សំជាមួយដីដំបូក ដីឥដ្ឋ ឬអាចម៍គោ កំបោរមកសូន្យ ជារូបអ្នកតា ឬទេវរូប (មិនច្បាស់លាស់ ជារូបអ្វី) ពេលរូបនេះមានមហិទ្ធិឫទ្ធី បារមីខ្លាំងពូកែណាស់ កាលសម័យដើម ប្រជាជនតែងជឿជាក់លើលោកតាពេជ្រនេះមិនសូវមានអ្នកណាដើរឆ្លងកាត់ បើស្រី មានផ្ទៃពោះដើរកាត់ ច្បាស់ជារលូតកូន សត្វក៏មិនហ៊ានហើរពីលើ យន្តហោះ ក៏មិនហ៊ានហោះឆ្លងកាត់ដែរ ។ ដំណឹងនេះបានលេចឮ ដល់បារាំង ទើបវាយថ្មទៅបាំងមុខ ក្រោយមកទៀត គេយកដីមក សន្ទប់ទៅ ។ ក្រោយមកទៀតវាធ្វើយ៉ាងណា មិនអោយ មានបារមីសក្តិសិទ្ធិទៀត ដើម្បីបញ្ឈប់ការជឿ ជាក់ លើអ្នកតាទៀត ។ នៅពេលឡានបារាំងបើកពេលយប់បើកភ្លើងឡានជះពន្លឺដល់គុកតា ពេជ្រ ឡាននោះជ្រុលចង្កូតធ្លាក់ ទក្សិណត្រង់កែងចំបកកំណប់ញ៉ីកញ្ជាប់ដែរ ។

**<u>ព្រះពេនលិចៈ</u>** ព្រះអង្គពេនលិច ទីតាំងនៅខាងរោងទងទី២ ខាងកើត ត្រង់គោបុរៈខាងកើត នៅបន្ទប់មួយផ្នែកខាងជើង ព្រះអង្គនេះពីដើមជារូបព្រះអំពីឈើឬថ្ម មានបារមីខ្លាំងពូកែណាស់ ជារៀង រាល់ថ្ងៃប្រជាជនក្នុងស្រុក ឬក្រៅស្រុក តែងយកស្លាធមិឬដូងមកថ្វាយក្នុងនោះមានផ្លែឈើ នំចំណីតាម របៀបសែនរបស់ខ្មែរយើង ។ ខ្លះគេបន់សុំអោយមានកូន គឺមានកូន ខ្លះសុំសេចក្តីសុខសប្បាយ គឺទទួល បានសេចក្តីសុខសប្បាយ ខ្លះមានការភ័យនឹងអ្វីមួយបន់សុំអោយជួយរួចផុតពីទុក្ខ គឺរួចផុតដូចសេចក្តី ប្រាថ្នា ពេលបានសុខហើយ រកស៊ីមានបាន គេតែងមកកោសក់ ដើម្បីលាបាណន់ ផ្សេងៗ ហើយគេលេង ភ្លេងមហោរីថ្វាយ តាមទំនៀមទំលាប់នៃព្រះពុទ្ធសាសនា ។

-និយាយជារួមមក លោកតានៅគ្រប់ទិសទាំងបួន ជាទ្វារបាលយកឡើងតាមចាស់ៗ និយាយតៗ

គ្នាថា: ពេលយប់ឡើងមិនមានមនុស្សដើរចូលទៅក្នុងអង្គរនៅពេលយប់ឡើយ បើហ៊ានដេកនៅប្រអប់ទ្វារខាងក្រោម លោកតាមហារាជ គាត់អូសប្រវ៉ាក់ កាត់ពីលើហើយ ខ្លះភ័យស្លន់ស្លោរ ក្នុងប្រាសាទអង្គរ ចាស់ៗតែងនិយាយតៗគ្នាថា: នៅពេលយប់គេឮស្នូរដូច ជាអូសប្រវ៉ាក់ដែក នោះធ្វើអោយ ព្រឺក្បាល មិនមែនដែកទេ ។

-ពេលយប់មានលោកតា លោកយាយចាស់ៗ និង ព្រះសង្ឃទៅរៀនធម៌នៅលើប្រាសាទអង្គរ វត្ត មានឮស្នូរព្រះអង្គក្រិង្គ ហោះហើរដូចជាសត្វកន្ធង់ ហើរដូច្នោះដែរ ។

-ជំនឿមួយទៀតរហូតសម្តេចសីហនុ មិនដែលយាងចូលប្រាសាទអង្គរវត្ត តាមក្លោងទ្វារចូល ខាងលិច( ត្រង់ក្លោងទ្វារកណ្តាល ត្រង់ស្ពានហាលនោះ តាមការនិយាយតៗគ្នាថា នៅក្លោងទ្វារធំ កណ្តាលនោះ គេបញ្ចុះអាថាន់ធំណាស់ បើអ្នកចេះមន្តអាគមន៍ ប្រកាន់គ្រូអូមអាមផ្សេងៗ គេមិនសូវ ហ៊ានដើរឆ្លងកាត់ទ្វារនោះទេ ។

-ដូច្នោះហើយ បានជាប្រាសាទអង្គរវត្ត មានបារមីខ្លាំងពូកែណាស់ ពីសម័យដើមដូចនៅគ្រប់ រោងទងព្រះរយព្រះពាន់ ដែលជាកន្លែងគោរពបូជាដ៏ធំមួយផ្នែក នៃព្រះពុទ្ធសាសនា ធ្វើអោយមនុស្ស សម័យ គេតែងឆ្លាក់បដិមារូប អំពីថ្ម សំរិទ្ធ មាស យកទៅដាក់ដំកល់នៅទីនោះផងដែរ គឺមានចន់ចាន របស់មនុស្សម្នាក់ៗដូចជាព្រះអង្គចេក ព្រះអង្គចម ព្រះអង្គជុំ ព្រះអង្គថាន់ និង ព្រះអង្គចែម ធ្វើអំពីសំរិទ្ធ ក៏ចេញពីប្រភពព្រះរយព្រះពាន់ដែរ តាមរឿងព្រេងនិទាន ថា តួអង្គទាំង៥នេះជាបុត្រី របស់ស្តេច ដែលកាន់ព្រះពុទ្ធសាសនាយ៉ាងមុតមាំ បានស្នើសុំព្រះបិតា សាងរូបព្រះ៥អង្គ អំពីសំរិទ្ធ ដើម្បីថ្វាយព្រះ រូបទាំងនេះ គឺមិនប៉ុនៗគ្នាទេ តួអង្គបងធំខ្ពស់ជាងគេ តួអង្គ បន្ទាប់ទាបបន្តិច តួអង្គទី៣ទាបៗ ខុសគ្នា បន្តិចៗ ដល់តួអង្គប្អូនពៅ គឺតូចជាងគេបង្អស់ដែរ ។

-តែដល់សម័យបច្ចុប្បន្ននេះ មុនស្សត្រូវវិទ្យាសាស្ត្រជឿនលឿន គេក៏ឈប់ជឿនូវជំនឿទាំង អស់នោះទៅ ជឿខ្លះៗ តែតិចតួចបំផុត ជំនឿ បើសិនជាជឿបារមី អារុកអារក្ស មានអ្នកសម្លំបង់បត់ អារុកអារក្សអ្នកតាម្ចាស់ទឹក ម្ចាស់ដី ម្ចាស់ព្រៃព្រឹក្សា ខ្លះ មិនជឿបារមីកំបាំងបាត់ ក៏ចេញបាត់ មិននៅ ដែរ ។

**ឧទាហរណ៏:** ដូចមនុស្សពីដើម ពេលដើរកាត់ព្រៃធំស្ងាត់ ច្បាស់ជាមានអាថិកំបាំងអ្វីព្រោះ មនុស្សម្នាក់ៗ ចង់បានសេចក្តីសុខសប្បាយ ខ្លះមិនបានដាក់ធូបទៀនពាមជាមួយ គេតែងកាច់មែកឈើ តំណាងអោយធូប ផ្កា ទៀន ទៅដាក់កន្លែងណាមួយ សុំអោយលោកតាម្ចាស់

ទឹកម្ចាស់ដី ម្ចាស់ព្រៃ ព្រឹក្សា តាមជួយថែរក្សា អ្នកទាំងនោះក៏មកតាំងនៅទីនោះ ជួយថែរក្សាមនុស្សលោក តែដល់អ្នក ក្រោយមកទៀត ដើរដល់ទីនោះឃើញគេ កាច់ថ្វាយ ក៏កាច់ថ្វាយដូចគេតាម១គ្នាទៅ អ្នកណាម្នាក់ឥត បានថ្វាយ អ្នកតាម្ចាស់ទឹក ម្ចាស់ដីនោះ និង ធ្វើអោយឈឺពោះ និងជំងឺផ្សេង១ ។ ជំនឿតពីពាក្យថា ជឿទៅលើអ្វីមួយ ដែលមនុស្សបានគិតថា វាជាការពិតនិងអាចកើតមានឡើង តាមការគោរព តាមការ មើលឃើញ និង តាមការនិយាយត១គ្នា ដែលបង្កអោយមាន ការពិចារណា និង វិនិច្ឆ័យ អោយតំលៃ និង ធ្វើចិត្តគំនិត កំណត់ថា ជាការពិត ឬមួយមិនពិត ជំនឿរូបីយ៍ និង ជំនឿអរូបីយ៍ វាត្រូវដើរទន្ទឹមគ្នា ជានិច្ច ខ្មែរដំបូងប្រកាន់យកសាសនា

-និយាយរូមៈ អ្នកសច្ចំ កំបាំងបាត់ បារមីនេះ គេមើលយើងឃើញ តែមនុស្សមើលទៅវិញមិន ឃើញទេ ពេលមនុស្សធ្វើអ្វី គឺគេកត់ត្រាគ្រប់សកម្មភាពរបស់មនុស្ស បើគេចង់បានអ្វីមួយពីមនុស្ស រូប នោះវត់ចូលព្រលឹងមនុស្សណាម្នាក់ ធ្វើអោយឈឺ ពេលរកគ្រូ មកមើលឬសូត្រ គេបួលហើយបន់ស្រន់ ឬ បញ្ចាន់ បញ្ចូលរូប អាចនិយាយត១គ្នាបាន គេប្រាប់ពីឋានៈ តួនាទី និងបំណងប្រាថ្នា របស់គេ ចង់បានអ្វី ត្រូវរៀបចំសែនព្រេន តាមទៅជាដូច សេចក្តីប្រាថ្នា បញ្ហានេះហើយធ្វើអោយមនុស្ស មានអារម្មណ៍ ជឿ ជាក់ ។

និយាយបញ្ហាមួយទៀតៈ មនុស្សម្នាក់១ កើតមកតែងតែទេវតា ឬបារមីតាមថែរក្សាជាប់ជានិច្ច បើគ្មានអស់លោកទាំងនេះ តាមថែរក្សាទេ ទៅណាមកណា គឺមិនមានគេតាមថែរក្សា ជាប់ជានិច្ចឡើយ អោយតែយើងរលឹកដល់គុណគេ ឬ ប្រព្រឹត្តអំពើល្អ គេនិងតាមថែរក្សាយើង ជាប់ជានិច្ច ។

អ្នកស្រាវជ្រាវ

# ផ្នែករូបថត

ព្រះវិហារអង្គខ្មៅ ឬអង្គតងជុំ
លក្ខណៈភូមិស្សសមុទ្រ
ទិដ្ឋភាពមើលពីមុខ
(រូបថតទី៤៨)





ព្រះវិហារអង្គខ្មៅ ឬអង្គតងជុំ
រូបមើលពីចំហៀង
(រូបថតទី៤៩)

ព្រះវិហារសេអាមេត្រី

ទិដ្ឋភាពមើលចំពីមុខក្នុងលក្ខណៈភុមិស្សសមុទ្រ គង់ភ្អែនព្រះហស្តឆ្វេងដាក់លើភ្លៅជាលក្ខណៈយកព្រះធរណីជាសាក្សីត្រង់នេះព្រះអង្គគង់លើបល្ល័ង្កដាក់បាតដៃឆ្វេងផ្ងារលើភ្លៅ ឯបាតដៃស្តាំសំយ៉ុងចុះទៅដី។

ត្រង់មារលើកទ័ពសេនាមកជិតដល់ព្រះអង្គ ហើយស្រែកថា នែ៎ ព្រះសិទ្ធត្ថចុះចេញពីបល្ល័ង្ករត្នរបស់យើង ព្រះសិទ្ធត្ថមានបន្ទូលថា នែ៎ មហារាជ អ្នកឯងមានអ្វីជាសាក្សី មារឆ្លើយតបថា ព្រះសិទ្ធត្ថ:យើងមានពលរយើងជាសាក្សី ក្រោយមក ព្រះអង្គ:ឆ្លើយថា មហារាជ យើងមានគម្ពីងជាសាក្សី (ពេលនោះឯងនាងគម្ពីងក៏ផុសឡើង) ពីក្រោមបល្ល័ង្កព្រះអង្គ ហើយបួតសក់កើតជាទឹកសមុទ្រល្វេល្វេវមានក្រពើ ឆ្លាម ដ្ករ លេបត្របាក់ស៊ីពលរបស់មារស្លាប់អស់ទៅ។

(រូបថតទី៥០)





ព្រះវិហារសេអាមេត្រី
ទិដ្ឋភាពមើលពិចំហៀង
(រូបថតទី៥១)



ក្លោងទ្វារចូលពីកើតនៃវត្តព្រះព្រហ្មរតន៍ តភ្ជាប់របងព័ទ្ធជុំវិញវត្ត
ទិដ្ឋភាពមើលពីកើតទៅលិច (រូបថតទី៥២)



រូបព្រះចូលនិព្វាន

ស្ថិតនៅក្រោយបល័ង្កព្រះធំ ជាកំណាត់ទូកចង្ហាន់ហុយ នៅសម័យលង្វែក ស្ដេចបានឱ្យគេរើដើមគគីរ ដែលមានឫទ្ធានុភាព មកធ្វើទូកសម្រាប់ប្រើប្រាស់ក្នុងរាជធានីអង្គរ លោក វង្សាអគ្គរាជ តែងប្រើលោកតាព្រហ្ម និងយាយ មាស កេស ឱ្យអុំទូកយកចង្ហាន់ពីក្រុងលង្វែកមកប្រគេនព្រះសង្ឃនៅវត្តអង្គរក្នុងពិធីបុណ្យផ្សេងៗដោយអុំកាត់ទន្លេសាបយ៉ាងរហ័ស ។ ចង្ហាន់រៀបចំទូកចេញដំណើរពីព្រលឹមយកចង្ហាន់មកប្រគេនព្រះសង្ឃទាន់ពេលវេលា ( ឆាន់ថ្ងៃត្រង់) ចង្ហាន់នៅហុយមិនទាន់ត្រជាក់ ។ នៅថ្ងៃមួយ ទូកនោះត្រូវបានជួបគ្រោះថ្នាក់មួយមកយាយីគាត់ ធ្វើឱ្យទូកដាច់ជាពីរកំណាត់ មួយកំណាត់មុខរសាត់លឿនរសៀវមកដល់ត្រើយក្រុងអង្គរ មួយកំណាត់ទៀតខាងកន្សៀងរសាត់តៅក្រុងលង្វែកវិញ ។ ក្រោយពីនោះមក គេបានរក្សាទុកមួយកំណាត់នោះដោយកសាងជារូបព្រះពុទ្ធឈរ ស្រោបទូកធ្វើជាស្នូលតម្កល់ទុកនៅក្នុងព្រះវិហារបរិបូរណ៍ ខេត្តកំពង់ឆ្នាំង ។

ទិដ្ឋភាពមើលពីកើតទៅលិច ( រូបថតទិ៥៣)



រូបព្រះចូលនិញ្វាន

មួយកំណាត់ខាងក្បាល គេកសាងរូបព្រះពុទ្ធចូលនិព្វាន ស្រោបទុកដូចគ្នា

តម្កល់នៅក្នុងព្រះវិហារវត្តព្រះព្រហ្មរតន៍ មកដល់សព្វថ្ងៃនេះ

(រូបថតទី៥៤)

រូបព្រះវិស្ណុឈរមានដៃ៨ តម្កល់នៅគោបុរៈអមខាងត្បូងនៃគោបុរៈខាងលិច។ អ្នកស្រុកហៅថាៈ លោកតា រាជ ជាមេទ័ពដ៏ពូកែស័ក្តិសិទ្ធិមានបារមីខ្លាំងពូកែណាស់ ប្រចាំទិសខាងលិច (រូបថតទី៥៥)





ប្រាសាទអង្គរវត្ត ទិដ្ឋភាពរួម មើលផ្ទាត់ជ្រុងពីលិច ត្បូងទៅទិសខាងកើត (រូបថតទី៥៦)

ព្រះអង្គគោកធ្លក
ពេលលោកតា គាន់ ចាយ
ស្នងការនគរបាលពិសេសការពារ
អង្គរបានប្រគល់ព្រះកេសឱ្យ ហើយ
បានរិភាជួសជុល តម្កល់ទុកនៅ
អភិរក្សអង្គរ សៀមរាប។
(រូបថតទី៥៧)





ព្រះអង្គគោកធ្លក
(រូបថតទី៥៨)



ព្រះអង្គចេក និងព្រះអង្គចម

ទិដ្ឋភាពមើលពីមុខ

ទីតាំងនៅមុខដំណាក់ខេត្តសៀមរាបអង្គរ មានបារមីនិងមហិទ្ធិឫទ្ធិខ្លាំងពូកែណាស់

(រូបថតទី៥៩)

## រូបព្រះអង្គជុំ

មានកូនស្តេចសម័យអង្គរមានជំនឿលើព្រះពុទ្ធសាសនា បានសុំព្រះបិតាធ្វើរូបតំណាង៥អង្គ ព្រោះព្រះអង្គមានបុត្រ៥អង្គដែរ

១. ព្រះអង្គចេក ២. ព្រះអង្គចម ៣. ព្រះអង្គជុំ ៤. ព្រះអង្គច័ន្ទ ៥. ព្រះអង្គចែម



ទិដ្ឋភាពមើលពីមុខ



ទិដ្ឋភាពមើលពីចំហៀង

ព្រះអង្គជុំកាលសម័យមុនឆ្នាំ១៩៧០ លោកតាវត្តអង្គរយកពីអង្គរទៅដាក់នឹងកុដិលោកសម្រាប់ទស្សទាយ និងមើលជម្ងឺឱ្យប្រជាជន ( ព្រះជារូបសរិទ្ធ ) ( រូបថតទី៦០ )



ព្រះវិហារក្រោយអង្គគោកធ្លក
ទិដ្ឋភាពមើលចំពីមុខ ពីកើតទៅលិច
(រូបថតទី៦១)



ព្រះវិហារក្រោយអង្គគោកធ្លក
(រូបថតទី៦២)

ព្រះអង្គប្រក់នាគ
នៅឆ្នាំ១៩៣១ លោក ហ្សកទ្រូវេ
ក្នុងឆ្នាំ១៩៣៣ បានធ្វើកំណាយចំ
កណ្ដាលប្រាសាទ (កណ្ដាល) ជំរៅ
១៤ម៉ែត្រ បានប្រទះឃើញព្រះពុទ្ធ
ប្រក់នាគនេះ។
រូបមើលចំពីមុខ (រូបថតទី៦៣)





ព្រះអង្គប្រក់នាគ
រូបមើលពីចំហៀង
(រូបថតទី៦៤)



រូបព្រះប្រក់នាគ

ព្រះដែលធ្វើកំណាយរកឃើញនៅកណ្តាលប្រាសាទបាយ័ន

ដោយលោក ហ្សក ទ្រូវេ ជាអភិរក្សអង្គរទី៣ នៅឆ្នាំ១៩៣៣

ចំកណ្តាលប្រាសាទធំ (កណ្តាល) ជំរៅ១៤ម៉ែត្រ ស្មើនឹងកំរិតដីរាបស្មើរបស់ប្រាសាទ ហើយបានយក មកចេញតៅក្រៅដើម្បីសិក្សារកគេគនភ័ណ្ឌផ្សេងៗ ជូសជុលរួចយកទៅថ្វាយព្រះមហាក្សត្រស៊ីសុវត្ថិមុនីវង្ស នៅថ្ងៃទី ១៧ ឧសភា ឆ្នាំ១៩៣៥។ កាលនោះ ព្រះអង្គត្រាស់បង្គាប់ឱ្យគេយកទៅតម្កល់នៅព្រះវិហារ៧ល្វែង រហូតដល់សព្វថ្ងៃនេះ (សម័យព្រះបាទជ័យវរ័នទី៧) ។

ទិដ្ឋភាពមើលពីកើតទៅលិច (រូបថតទី៦៥)

ព្រះរូបនេះជារូបទ្វារបាលនៅប្រាសាទព្រះខ័ន
នៅគោបុរៈចូលគ្រប់ទិសទាំង៤





រូបទ្វារបាលនៅប្រាសាទព្រះខ័ន ខេត្តសៀមរាប
កាលសម័យលោក Gróslier ជាអភិរក្សអង្គរ បាក់ងងឹកយកមកតម្កល់នៅខាងកើតមហាសណ្ឋាគារអង្គរ
ប្រជាជនតែងតែគោរពបូជា និងយកដង្វាយទៅថ្វាយជាប្រចាំ តែក្រោយមកចោរបានលួចដាប់កបំរុងលួច
ទើបដឹកយកមកតម្កល់នៅក្នុងអភិរក្សអង្គរវិញ។
(រូបថតទី៦៦ និង៦៧)

រូបព្រះលោកេស្វរៈ
ទិដ្ឋភាពមើលចំហៀង
(រូបថតទី៦៨)





រូបព្រះលោកេស្វរៈ
នៅប្រាសាទព្រះខ័ន ។ ចោរលួចក្បាល បាត់នៅឆ្នាំ
១៩៨៣ ក្រោយមកលួចយកដងខ្លួន តែសមត្ថកិច្ច
ចាប់បាននៅស្រុកនគរធំហើយបានយកទៅតម្កល់
នៅស្រុកអង្គរធំ ពេលនោះមានខ្មែរក្រហមឡោង
ត្រាប់មកមិនដែលធ្លាក់ចូលស្រុក ទើបអ្នកស្រុក
មានជំនឿថា មានបារមីខ្លាំងពូកែណាស់ ។
នៅក្រោយឆ្នាំ១៩៩២ យើងបានស្នើ ស្រុកបើកយក
មកតម្កល់នៅក្នុងអភិរក្សអង្គរ បានចាក់ព្រះកេស
បំពាក់វិញ ។ រូបមើលពីមុខ (រូបថតទី៦៩)

ព្រះឥន្ទទេព
ទិដ្ឋភាពមើលចំពីមុខ
(រូបថតទី៧០)





ព្រះឥន្ទទេព
រូបមើលពីចំហៀង
(រូបថតទី៧១)

ព្រះវិហារអង្គងោក
ទិដ្ឋភាពមើលចំពីមុខ
(រូបថតទី៧២)





ព្រះវិហារអង្គងោក
រូបមើលពីចំហៀង
(រូបថតទី៧៣)

ព្រះពុទ្ធបដិមាទ្រង់ឈរ
ក្នុងលក្ខណៈអភ័យមុទ្រៈ
រូបមើលពីមុខ
(រូបថតទី៧៤)





ព្រះវិហារទេពប្រណម្យ
ក្នុងលក្ខណៈភូមិស្បសមុទ្រៈ
គង់ភ្នែន ព្រះហស្តដាក់លើភ្លៅ
ទិដ្ឋភាពមើលចំពីមុខ
ពីកើតទៅលិច
(រូបថតទី៧៥)

តួអង្គព្រះធំ ធ្វើពីថ្មភក់
ស្ថិតនៅប្រាសាទរលំជ្រៃ
ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ
សម័យព្រះបាទជ័យវរ្ម័នទី៧
ទិដ្ឋភាពមើលពីមុខ
(រូបថតទី៧៨)





តួអង្គព្រះអង្គធំ
ទិដ្ឋភាពមើលពីផ្ទាក់ជ្រុង
ពីចំហៀង (រូបថតទី៧៩)

ព្រះវិហារព្រះបាលិល័យ
រូបមើលចំពីមុខ
(រូបថតទី៧៦)





ព្រះវិហារព្រះអង្គបាលិល័យ
រូបមើលពីចំហៀង
(រូបថតទី៧៧)

រូបពុទ្ធបដិមា
សម័យព្រះបាទជ័យវរ្ម័នទី៧ មានទីតាំង
ស្ថិតនៅវត្តស្វាយចេក ឃុំស្វាយចេក
ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ
រូបនេះមានបារមីណាស់ ប្រជាជនមាន
ជំនឿ ចោរលួចច្រើនដង តែយកទៅមិនបាន
ទិដ្ឋភាពមើលផ្ទាក់ជ្រុង និងមើលពីមុខ
(រូបថតទី ៨០. ៨១. ៨២)









ព្រះវិហារព្រះអង្គសាងទុកនៅតាមដងផ្លូវទៅក្លោងទ្វារជ័យ(ផ្នែកខាងកើត)។ ព្រះពុទ្ធបដិមានេះមានជាច្រើនជំនាន់មកហើយ គេមិនធ្វើអ្វីទាំងអស់តែដល់សម័យយើងនេះបានឆ្លាក់ជារូបរាង (រូបមើលពីកើតទៅលិច) (រូបថតទី៨៣)



ព្រះអង្គសាងទុក
រូបមើលពីចំហៀង
(រូបថតទី៨៤)

រក្សាសិទ្ធិគ្រប់យ៉ាង

# ប្រវត្តិសាស្ត្រសង្ខេបនៃរាជធានីក្នុងតំបន់អង្គរ
# និង សង្គមខ្មែរក្នុងរជ្ជកាលស្តេចជ័យវរ្ម័នទី៧




**មានលក់ដុំ និង លក់រាយ**

សៀវភៅធម៌គ្រប់ប្រភេទ នៅ

បណ្ណាគារវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត

Buddhist Institute Book Shop

**អាស័យដ្ឋាន : អាគារថ្មីជាប់សួនច្បារសម្តេច ហ៊ុន សែន**

**សង្កាត់ទន្លេបាសាក់ ចំការមន រាជធានីភ្នំពេញ**

Address : Adjacent to Hun Sen Park
Tonle Basak, Chamkarman, Phnom Penh

**Mobil : 012 595 427, 012 618 636 / 011 250 277**

**សូមនិមន្ត និង អញ្ជើញដោយមេត្រីភាព**